ស៊េរីប្រវត្តិគម្រោង JICA

# «អប់រំកាយបែបថ្មី» សម្រាប់កុមារដើម្បីអនាគតភ្លឺស្វាង

## ប្រវត្តិនៃអប់រំកាយនៅប្រទេសកម្ពុជា
## មិត្តភាពដែលផ្សារភ្ជាប់ដោយអប់រំកាយ


នីស៊ីយ៉ាម៉ា ណាអូគិ

NISHIYAMA Naoki




© NISHIYAMA Naoki, 2024
ការបកប្រែជាភា សាខ្មែរ
© JICA Ogata Sadako Research Institute for Peace and Development, 2025
បោះពុម្ពលើកដំបូងនៅក្នុងប្រទេសជប៉ុន ក្រោមចំណងជើងថា មីរ៉ាយ អារុ កុដុម៉ុ តាឈិ នី "អាតារ៉ាស៊ីអ៊ី តាយអ៊ីយុ" អុ
ដោយ ក្រុមហ៊ុន Saiki Communications., Ltd.

■ ការផលិតឡើងវិញ ដោយគ្មានការអនុញ្ញាត គ្រប់ផ្នែក ឬផ្នែកណាមួយនៃសៀវភៅនេះ ត្រូវបានហាមឃាត់។
■ ការផ្ទេរ ឬបញ្ជូនទិន្នន័យសៀវភៅអេឡិចត្រូនិកនេះ ជាសាធារណៈ ឬទៅភាគីទីបី ត្រូវបានហាមឃាត់។
■ ព័ត៌មានដែលបានបោះពុម្ពផ្សាយនៅក្នុងទិន្នន័យនេះ (URL លេខទូរសព្ទ ជាដើម។ល។) គឺជាបច្ចុប្បន្នភាព នៅពេលបោះពុម្ពផ្សាយ។ តែ វានឹងអាចមានភាពខុសគ្នា អំពីខ្លឹមសារ និងស្ថានភាពបច្ចុប្បន្ន។
■ ទស្សនៈ និងមតិយោបល់ដែលបានបង្ហាញនៅក្នុងអត្ថបទសៀវភៅនេះ មិនមែនតំណាងឱ្យទិដ្ឋភាព ផ្លូវការ ឬជាមុខតំណែងរបស់អង្គការដែលអ្នកនិពន្ធកំពុងបម្រើការ ឬពាក់ព័ន្ធនោះទេ។

សូមមើលនៅលើគេហទំព័ររបស់យើង សម្រាប់សៀវភៅស៊េរីដទៃជាច្រើនទៀត ជាភាសាអង់គ្លេស។

**វិទ្យាស្ថានស្រាវជ្រាវ ចៃកា អូហ្គាតា សាដាកុ ដើម្បីសន្តិភាព និងការអភិវឌ្ឍន៍**
**JICA Ogata Sadako Research Institute for Peace and Development**
https://www.jica.go.jp/jica-ri/index.html
10-5 Ichigaya Honmura-cho, Shinjuku-ku Tokyo 162-8433, JAPAN
Tel: +81-3-3269-2357
Fax +81-3-3269-2054
ISBN 978-9924-511-24-3

## បុព្វកថា

ប្រទេសកម្ពុជាដែលត្រូវបានគេស្គាល់តាមរយៈតំបន់បេតិកភណ្ឌពិភពលោកមានដូចជាប្រាសាទអង្គរវត្តបានក្លាយជាគោលដៅទេសចរណ៍ឈានមុខគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ យ៉ាងណាមិញ ក្នុងរបប ប៉ុល ពត ដែលអូសបន្លាយពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ សាលារៀនជាច្រើនត្រូវបានបំផ្លាញឬបិទទ្វារ ហើយបញ្ញវន្តរួមទាំងគ្រូបង្រៀនបានបាត់បង់ជីវិត។ចាប់ពីឆ្នាំ១៩៩៣មកដល់បច្ចុប្បន្នJICAបានអនុវត្តគម្រោងសហប្រតិបត្តិការលើវិស័យជាច្រើន សម្រាប់ប្រទេសកម្ពុជារួមមាន កសិកម្ម សុខាភិបាល អប់រំ បរិស្ថាន និងអភិវឌ្ឍជនបទជាដើម។ ក្នុងចំណោមនោះ ជំនួយផ្នែកអប់រំសម្រាប់កុមារដែលជាអ្នកដឹកនាំប្រទេសនាពេលអនាគតគឺជាតម្រូវការបន្ទាន់មួយក្នុងការកសាងប្រទេសឡើងវិញ។ ដោយសារតែសង្គ្រាម ឯកសារទាក់ទងនឹងគោលនយោបាយអប់រំជាដើមមិនមាននៅសេសសល់ទេហើយចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១កិច្ចខិតខំប្រឹងប្រែងដើម្បីកសាងផ្នែកអប់រំឡើងវិញបានដំណើរការ ប៉ុន្តែវាមិនងាយស្រួលនោះឡើយ។

នៅក្នុងការស្តារឡើងវិញនៃផ្នែកអប់រំនៅក្នុងប្រទេសនេះអាទិភាពត្រូវបានផ្តល់ដល់ការសិក្សានៅក្នុងថ្នាក់រៀន ដូចជាភាសាវិទ្យា និងគណិតវិទ្យា ចំណែកមុខវិជ្ជាដូចជាសិល្បៈ តន្ត្រី និងអប់រំកាយ ដែលទាក់ទងនឹងការអភិវឌ្ឍរាងកាយនិងផ្លូវចិត្ត និងការអប់រំផ្លូវអារម្មណ៍របស់កុមារ ត្រូវបានទុកចោលដោយសារតែត្រូវបានគេចាត់ទុកថាជាសកម្មភាពកម្សាន្តច្រើនជាង។ទោះជាយ៉ាងនេះក្តីអប់រំកាយមានគោលបំណងអភិវឌ្ឍរាងកាយនិងផ្លូវចិត្ត ដោយការប្រកួតប្រជែងជាមួយមិត្តភក្តិ ខណៈពេលដែលត្រូវគោរពតាមច្បាប់កំណត់នៃប្រភេទកីឡានីមួយៗ។បទពិសោធន៍នៃការរីករាយក្នុងការធ្វើរឿងដែលមិនអាចធ្វើបានពីមុន និងការអបអរសាទរនិងសរសើរគ្នាទៅវិញទៅមកជាមួយមិត្តភក្តិគឺជាការរៀនសូត្រដ៏សំខាន់សម្រាប់កុមារដើម្បីអភិវឌ្ឍកិច្ចសហការ ជំនាញសង្គម និងអារម្មណ៍គោរពខ្លួនឯង។

លោក នីស៊ីយ៉ាម៉ា ជាបុគ្គលិករបស់អង្គការបេះដូងមាស ដែលជាអង្គការមិនរកប្រាក់ចំណេញ(NPO) ហើយក៏ជាអ្នកនិពន្ធសៀវភៅនេះ បាននិងកំពុងធ្វើការផ្សព្វផ្សាយផ្នែកអប់រំមុខវិជ្ជាអប់រំកាយនៅប្រទេសកម្ពុជា តាមរយៈកម្មវិធីភាពជាដៃគូរបស់JICA។ គ្រូដែលបង្រៀនដល់កុមារជាក់ស្តែងបានចែករំលែកពីសារៈសំខាន់នៃអប់រំកាយជាមួយមន្ត្រីរដ្ឋបាលមូលដ្ឋាន និងគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជាដែលពួកគេមិនមានបទពិសោធន៍ចូលរៀនអំពីអប់រំកាយនេះទេ ហើយក៏ទទួលបានការយល់ដឹងបន្តិចបន្តួចម្តងៗប៉ុណ្ណោះ។នេះជារឿងជោគជ័យដ៏ត្រចះត្រចង់ដែលពួកយើងបានចែករំលែកនូវក្តីប្រាថ្នានៃការ «ចង់ផ្តល់នូវអប់រំកាយបែបថ្មីដល់កុមារកម្ពុជា» ដោយចាប់ផ្តើមពីចំណុចសូន្យទាំងស្រុង និងបានឈានទៅដល់ការដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាដោយធ្វើការសហការជាមួយក្រសួងអប់រំ ហើយអាចនិយាយបានថា នេះពិតជាប្រវត្តិសាស្ត្រនៃ «ការបង្កើតរួមគ្នា»ដែលបានបង្កើតការអប់រំមុខវិជ្ជាអប់រំកាយនៅប្រទេសកម្ពុជាពីដើមទីដំបូងបំផុត។

កិច្ចខិតខំប្រឹងប្រែងដែលបានទទួលផ្លែផ្កាទាំងនេះ សព្វថ្ងៃនេះ នៅតាមសាលារៀនជាច្រើនក្នុងប្រទេសកម្ពុជាកុមារៗដែលនឹងទទួលខុសត្រូវចំពោះអនាគតរបស់ពួកគេនាពេលខាងមុខកំពុងទទួលបាននូវសេចក្តីរីករាយពិតប្រាកដនៃអប់រំកាយ។ ខ្ញុំមានទំនុកចិត្តថានៅទីបំផុតកុមារទាំងនេះនឹងដឹកនាំសង្គមកម្ពុជាទៅកាន់ទីដៅកាន់តែប្រសើរ។

សៀវភៅនេះបង្ហាញអំពីសាច់រឿងរបស់មនុស្សជាតិដែលខិតខំក្នុងការផ្សព្វផ្សាយអំពីការអប់រំកាយឆ្លងប្រទេសរវាងប្រទេសកម្ពុជានិងប្រទេសជប៉ុន។ជុំវិញតួអង្គមនុស្សដែលបានរំលេចឡើងនៅក្នុងសៀវភៅនេះ ត្រូវបានពណ៌នាយ៉ាងលម្អិតតាមការសិក្សាឈ្វេងយល់របស់អ្នកនិពន្ធដែលធ្វើឱ្យសាច់រឿងឆ្លុះបញ្ចាំងអំពីតថភាពពិតជាក់ស្តែង។សៀវភៅនេះត្រូវបានសរសេរឡើងក្នុងគោលបំណងចង់បង្ហាញនូវមេរៀននិងការយល់ដឹងដែលទទួលបានពីសកម្មភាពជាច្រើនឆ្នាំទៅកាន់មនុស្សជាច្រើនជាពិសេសដល់យុវជនដែលនឹងចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិនាពេលអនាគត។ នេះជារឿងរ៉ាវដែលបង្ហាញពីថ្ងៃនៃការតស៊ូដែលមិនបានបន្សល់ទុកក្នុងរបាយការណ៍ផ្លូវការ។ខ្ញុំសង្ឃឹមថាការណែនាំនៅក្នុងសៀវភៅនេះនឹងផ្តល់ឱ្យអ្នកអាននូវឱកាសដើម្បីស្វែងយល់បន្ថែមអំពីពិភពលោកដ៏គួរឱ្យចាប់អារម្មណ៍នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។

ខ្លួនខ្ញុំផ្ទាល់បានស្រាវជ្រាវអំពីការផ្លាស់ប្តូររវាងសារមន្ទីរសន្តិភាពនៅកម្ពុជា និង អូគី ណាវ៉ា («ប្រវត្តិផ្ទាល់មាត់នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍»សារព័ត៌មានសាកលវិទ្យាល័យតូក្យូ) ហើយបានដឹងពីសារៈសំខាន់នៃអន្តរកម្ម «ទំនាក់ទំនងពីបេះដូងទៅបេះដូង» នៅកម្រិតមូលដ្ឋានប្រកបដោយស្ថិរភាព។ខ្ញុំជឿជាក់យ៉ាងមុតមាំថាការផ្លាស់ប្តូរបែបនេះមិនត្រឹមតែត្រូវយកទៅអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែលទ្ធផលគួរតែត្រូវបានកត់ត្រាជាលាយលក្ខណ៍អក្សរ។

សៀវភៅនេះគឺជាភាគទី ៣៨នៃស៊េរី «ប្រវត្តិគម្រោង»របស់វិទ្យាស្ថានស្រាវជ្រាវJICAអូហ្គាតា។ ស៊េរី«ប្រវត្តិគម្រោង»នេះត្រូវបានបោះពុម្ពក្នុងគោលបំណងយល់ដឹងជាថ្មីអំពីសាវតារនិងប្រវត្តិនៃគម្រោងដែលJICAបានសហការដើម្បីកុំឱ្យបាត់បង់ទស្សនៈនៃស្ថានភាពទាំងមូលដោយតាមដានយ៉ាងយកចិត្តទុកដាក់នូវការពិតជាក់លាក់ពីទស្សនៈរបស់អ្នកពាក់ព័ន្ធនៅពេលនោះ។សៀវភៅដែលមានប្រធានបទអំពីកីឡារួមមាន«សន្តិភាពនិងការរួបរួមតាមរយៈកីឡា»ដែលកើតឡើងនៅប្រទេសស៊ូដង់ខាងត្បូងនិង «កិច្ចសហប្រតិបត្តិការអន្តរជាតិដ៏សប្បាយរីករាយប៉ុន្តែមានវីរភាពបន្តិចនៅក្នុងប្រទេសប៉េរូ»ដែលកើតឡើងនៅប្រទេសប៉េរូត្រូវបានគេបោះពុម្ពផ្សាយប៉ុន្តែសៀវភៅនេះគឺជាប្រវត្តិគម្រោងដំបូងគេដែលផ្តោតលើកិច្ចខិតខំប្រឹងប្រែងនៅអាស៊ី។ខ្ញុំសង្ឃឹមថាមានមនុស្សកាន់តែច្រើននឹងមកអានស៊េរីដែលត្រូវបានគេស្គាល់យ៉ាងទូលំទូលាយនេះ។

វិទ្យាស្ថានស្រាវជ្រាវដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍ JICA អូហ្គាតាសាដាកុ ប្រធានវិទ្យាស្ថានស្រាវជ្រាវ មីណិ យ៉ូអ៊ីឈិ

# មាតិកា


បុព្វកថា ២
មាតិកា ៩
អារម្ភកថា ១១
អង្គការបេះដូងមាស និងកាលប្បវត្តិនៃប្រវត្តិអប់រំកាយនៅប្រទេសកម្ពុជា ១៣
ចំណាប់អារម្មណ៍របស់ខ្ញុំអំពីគម្រោងនៅពេលខ្ញុំឡើងកាន់តំណែង ១៧
តើអ្វីទៅជាអប់រំកាយបែបប្រពៃណីនៅប្រទេសកម្ពុជា? ១៨
ការផ្លាស់ប្តូររចនាសម្ព័ន្ធមុនពេលចាប់ផ្តើមជំនួយផ្នែកអប់រំកាយ ២១
ការផ្លាស់ប្តូរដែលនាំមកដោយលោក ព្រុំ ប៊ុណ្ណយី ២២
ការធ្វើឱ្យក្លាយទៅជាមុខវិជ្ជានៅក្នុងកម្មវិធីសិក្សារបស់សាលា ២៤
អត្ថបទទី១៖ អ្វីទៅជាលំហាត់ប្រាណបែបខ្មែរ? ២៥

**ជំពូកទី១**

«អប់រំកាយ»នៅប្រទេសកម្ពុជា ២៧
ផ្នែកទី១៖ អប់រំកាយបែបចាស់ / អប់រំកាយបែបថ្មី ២៩
**គំនិតអំពីអប់រំកាយនៅសាលារៀន** ២៩
ការខិតខំប្រឹងប្រែងដ៏លំបាករបស់អង្គការបេះដូងមាស ៣០
ការស្នើសុំអង្គការបេះដូងមាស ដើម្បីសហការលើថ្នាក់អប់រំកាយបែបថ្មី ៣២
សមភាគី គឺនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ៣២
អត្ថបទទី២៖ បិតានៃអប់រំកាយនៅប្រទេសកម្ពុជា ៣៥
ផ្នែកទី២៖ អ្នកណាបង្រៀនអប់រំកាយនៅសាលារៀន ៣៦
នាយកដ្ឋានពាក់ព័ន្ធនឹងអប់រំកាយក្នុងក្រសួងអប់រំ ៣៦
ការបែងចែក «អប់រំកាយ» និង «កីឡា» មានការវិវត្ត ៣៧
ផ្នែកទី៣៖ តើអប់រំកាយជាការអប់រំ ឬកីឡា? ៣៨
អប់រំកាយជាមុខវិជ្ជានៅក្នុងសាលារៀន ៣៨
ការពិតគឺលំហាត់ប្រាណបែបខ្មែរ ៣៩
ផ្នែកទី៤៖ អ្វីទៅជាថ្នាក់អប់រំកាយបែបថ្មី ៤០
ការចាប់ផ្តើមចំពេលរឿងឆ្ងល់ និងព្រួយបារម្ភ ៤០
នៅមធ្យមសិក្សាបឋមភូមិ លទ្ធផលគឺស្ទើរតែដូចគ្នា ៤១

## ជំពូកទី២


ចាប់ផ្ដើមពីចំណុចសូន្យ ៤៣
ផ្នែកទី១៖ ការបង្កើតកម្មវិធីសិក្សា ៤៥
សំណើពីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ៤៥
ការយកគំរូតាមកម្មវិធីសិក្សារបស់ប្រទេសជប៉ុន ៤៦
គោលគំនិតមើលមិនឃើញនៃបណ្ដុំមុខវិជ្ជារង ៤៨
អ្នកដែលមិនអាចស្រមៃមើល «ប្រអប់ច្រត់សម្រាប់លោត» ៥០
ផ្នែកទី២៖ អ្វីដែលអាចធ្វើបាននៅក្នុងសិក្ខាសាលាក្នុងស្រុក
និងអ្វីដែលអាចធ្វើបានក្នុងទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន ៥១
ការអនុវត្តគម្រោងលើកកម្ពស់ការអប់រំមុខវិជ្ជាអប់រំកាយ ៥១
ដែនកំណត់នៃសិក្ខាសាលា ៥៣
ការ «អនុវត្ត» មិនមែនការ «សរសេរ»ទេ ៥៤
«ទិវាអប់រំកាយ» បានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងខ្លាំង ៥៥
គ្រូជនជាតិជប៉ុនក៏មានគំនិតច្នៃប្រឌិតផងដែរ ៥៧
ផ្នែកទី៣៖ ការលេចឡើងនៃអ្នកដឹកនាំដូចនឹង«សាមូរ៉ៃទាំង៧» ៥៨
ផ្នែកទី៤៖ ដើម្បីឱ្យលទ្ធផលមាននិរន្តរភាព ៦១
តើត្រូវបញ្ចប់ត្រឹមការ «ខ្វះខ្វាយ»? ៦១
គំនិត «RECTI» ៦២
ប្រព័ន្ធត្រូវបានបង្កើតឡើង ប៉ុន្តែប្រឈមនឹងបញ្ហាថវិកា ៦៣


## ជំពូកទី ៣


ការផ្សព្វផ្សាយ «អប់រំកាយបែបថ្មី» ៦៧
ផ្នែកទី១៖ ការលើកទឹកចិត្តចំពោះអប់រំកាយបែបថ្មី ខុសគ្នាពីគ្រូម្នាក់ទៅគ្រូម្នាក់ទៀត ៦៩
ផ្នែកទី២៖ ផលលំបាកក្នុងការពិនិត្យតាមដាន ៧០
ការបង្កើត «សហគមន៍អប់រំកាយ» ៧០
ការពង្រីកសហគមន៍អប់រំកាយគឺជាផ្លូវកាត់ក្នុងការផ្សព្វផ្សាយ ៧១
អត្ថបទទី៣ ដូវ៉ាអិម៉ុនក្នុងវិស័យអប់រំកាយ ៧២
ផ្នែកទី៣៖ ទាំងកម្មវិធីសិក្សានិងសៀវភៅគ្រូគឺជាឯកសារផ្លូវការ ៧៣


## ជំពូកទី ៤


អំណោយផលចំពោះជំនួយផ្នែកអប់រំមុខវិជ្ជាអប់រំកាយ ៧៧
ផ្នែកទី១៖ ការពង្រីកកិច្ចសហប្រតិបត្តិការពីបឋមសិក្សាដល់មធ្យមសិក្សាបឋមភូមិ ៧៩

ភ្លាមៗនោះ ផ្លូវត្រូវបានបើក ៧៩
គ្មានអ្នកគ្រប់គ្រងគម្រោង ៨០
ភាពខុសគ្នាដែលបានបង្ហាញនៅក្នុងការសិក្សាស្ថានភាពជាក់ស្តែង ៨១
ជាភាពដើមរបស់ប្រទេសកម្ពុជា ៨២
ផ្នែកទី២៖ ក្នុងរយៈពេលដែលមានកំណត់ ៨៤
ការបណ្តុះបណ្តាលនៅប្រទេសថៃនិងប្រទេសសិង្ហបុរី ៨៤
ការធ្វើសិក្ខាសាលាម្តងហើយម្តងទៀត ៨៦
ការជឿជាក់លើអង្គការបេះដូងមាស ៨៦
ផ្នែកទី៣៖ កម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាបឋមភូមិបានបញ្ចប់ ៨៨
ការងារដែលបន្សល់ទុកក្នុងប្រវត្តិសាស្ត្រអប់រំ ៨៨
រួមចំណែកដល់ SDGs ផងដែរ ៨៩
ផ្នែកទី៤៖ អប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិបានចាប់ផ្តើមដំណើរការ ៩១
តើគួរដូចសាលាបឋមសិក្សាដែរឬទេ? ៩១
បន្ថែម ល្បុក្កតោ និងប៉េតង់ ៩២
ហែលទឹកគឺជាមុខវិជ្ជារងជ្រើសរើស ៩៣
ផ្នែកទី៥៖ ការចងក្រងសៀវភៅគ្រូ ៩៤
សៀវភៅគ្រូដែលងាយស្រួលអាន និងងាយស្រួលប្រើប្រាស់ ៩៤
ការធានាបាននូវភាពស៊ីសង្វាក់គ្នាជាមួយនឹងកម្មវិធីសិក្សា ៩៦
ផ្នែកទី៦៖ ការដាក់ឱ្យប្រើប្រាស់នៅមធ្យមសិក្សាបឋមភូមិ ១១ ៩៧
អត្ថបទទី៤៖ តារាងវាយកូនឃ្លីលើតុរបស់លោកគ្រូ រាជ សុប៊ុនធឿង ៩៩

**ជំពូកទី៥**

ឆ្ពោះទៅរកឯករាជ្យភាព ១០៣
ផ្នែកទី១៖ កម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាទុតិយភូមិ ១០៥
ខ្លឹមសារស្ទើរតែដូចគ្នានឹងមធ្យមសិក្សាបឋមភូមិដែរ ១០៥
ផែនការកំណែប្រែព្រួញមួយបាញ់បានសត្វពីរ ១០៦
ធ្វើការលើការកែសម្រួលបន្ទាប់ពីការអនុម័ត ១០៨
ជំហានឆ្ពោះទៅរកឯករាជ្យភាពកំពុងដំណើរការ ១១១
ផ្នែកទី២៖ គម្រោង «អប់រំកាយសម្រាប់ទាំងអស់គ្នា» ១១២
ចង់រៀនប្រកបដោយគុណភាពខ្ពស់ជាប់លាប់ ១១២
ហានិភ័យនៃការផ្អាកដោយសារតែការរីករាលដាលនៃកូវីដ ១១៥
ផ្នែកទី៣៖ សកម្មភាពនៃអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស ១១៧

សាច់រឿងរបស់អ្នកនាង ខូបាយ៉ាស៊ីមីគុ ១១៧
សាច់រឿងរបស់លោក យ៉ាម៉ាហ្សាគិ តេបប៉ី ១១៩
ផ្នែកទី៤៖ គុណសម្បត្តិនិងគុណវិបត្តិនៃវិបត្តិកូវីដ ១២២
ឯករាជ្យភាពលេចឡើងនៅក្នុងនាយកដ្ឋានអប់រំ ១២២
កុមារីកាយនឹងថ្នាក់អប់រំកាយ ១២៣
ខេត្តស្វាយរៀង មានឱកាស ៥០% ១២៥
រាជធានីភ្នំពេញដែលមានភាពពិបាកផ្សព្វផ្សាយ ១២៥
អត្ថបទទី៥៖ អប់រំកាយបានផ្លាស់ប្តូរ ១២៩
អត្ថបទទី៦៖ អ្នកដែលយល់ដឹងច្រើនអំពីគម្រោង ១៣២

**ជំពូកទី៦**

ឆ្ពោះទៅរកការបង្កើតសាកលវិទ្យាល័យអប់រំកាយ ១៣៥
ផ្នែកទី១៖ ការប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាទៅជាសាកលវិទ្យាល័យរយៈពេល៤ឆ្នាំ ១៣៧
មានតែកម្មវិធីសិក្សាប៉ុណ្ណោះដែលនាំមុខ ១៣៧
ប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាទៅជាសាកលវិទ្យាល័យរយៈពេល៤ឆ្នាំ ១៣៨
ផ្នែកទី២៖ បន្ទាប់ពីឆ្លងកាត់ការព្យាយាម ១៤០
ផ្តោតលើថ្នាក់អនឡាញ ១៤០
គម្រោងគាំទ្រដោយប្រើ ICT ១៤៤
គ្រូបង្រៀន «អប់រំកាយ» មិនមែនគ្រូបង្រៀនកីឡាទេ ១៤៧
អត្ថបទទី៧៖ អ្នកដឹកនាំគឺជាអ្នកដែលចង់រៀនបំផុត ១៤៩
អត្ថបទទី៨៖ សហការជាមួយសាកលវិទ្យាល័យនៃបណ្តាប្រទេសអាស៊ាន ១៥១

អវសានកថា ១៥៣
ខ្ញុំគិតថា «ការបន្ត» ក៏ជាទម្រង់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ ១៥៥

សេចក្តីបញ្ចប់ ១៥៨

ឯកសារយោង ១៦១

បញ្ជីអក្សរកាត់ ១៦៣

# មាតិកា

# ផែនទីប្រទេសកម្ពុជា និងទីតាំងសាលារៀនដែលបានបង្ហាញនៅក្នុងសៀវភៅនេះ



# អារម្ភកថា

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ ខ្ញុំបានចុះចតនៅរាជធានីភ្នំពេញ នៃ ប្រទេសកម្ពុជា។ ក្នុងនាមជាសមាជិកនៃយុវជនស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេសរបស់ JICA (បច្ចុប្បន្ន អ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស JICA តទៅនេះហៅថា «អ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស») ខ្ញុំត្រូវបានបញ្ជូនទៅប្រទេសប៉ារ៉ាហ្គាយពីឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៧ ហើយខ្ញុំមានអារម្មណ៍ថាផ្លូវក្រួសក្រហមនិងទិដ្ឋភាពដងផ្លូវនៅក្នុងប្រទេសកម្ពុជាស្រដៀងគ្នាទៅនឹងប្រទេសប៉ារ៉ាហ្គាយណាស់។ ការប្រឡូកក្នុងគម្រោងអប់រំកាយនៅក្នុងប្រទេសនេះ សម្រាប់ខ្ញុំដែលបានបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យមួយក្នុងទីក្រុង San Diego សហរដ្ឋអាមេរិក ដែលមានបទពិសោធន៍ធ្វើការតែនៅការិយាល័យអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស និងនៅហ្វូបល ផ្លាហ្សា របស់ JICA គឺដូចជាការផាត់ពណ៌ផ្ទាំងក្រណាត់ទទេម្តងមួយៗ។ ខ្ញុំគ្មានអាជ្ញាប័ណ្ណ ឬប្រវត្តិរូបជាគ្រូអប់រំកាយទេ គឺបានចាប់ផ្តើមពីចំណុចសូន្យតែម្តង។

សៀវភៅនេះកត់ត្រាយ៉ាងលម្អិតតាមដែលអាចធ្វើទៅបាន នូវអ្វីដែលខ្ញុំបានឃើញ មានអារម្មណ៍ និងអ្វីដែលខ្ញុំបានធ្វើដោយសហការជាមួយមិត្តរួមការងារក្នុងអំឡុងពេល ១២ឆ្នាំដែលខ្ញុំបានចូលរួមក្នុងគម្រោងលើកកម្ពស់អប់រំកាយនៅក្នុងប្រទេសកម្ពុជា របៀបដែលខ្ញុំធ្វើផែនការគម្រោង ទំនាក់ទំនងជាមួយមន្ត្រីមកពីក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា(ក្រសួងអប់រំ)មន្ទីរអប់រំនៃខេត្តនីមួយៗ និងគ្រូបង្រៀននៅតាមសាលា ព្រមទាំងការកសាងទំនាក់ទំនងជាមួយ ពួកគេ។

ទោះបីជាខ្លឹមសារនៃសៀវភៅនេះផ្អែកលើទស្សនៈផ្ទាល់ខ្លួនក៏ដោយ ខ្ញុំបានព្យាយាមរៀបរាប់លម្អិតថាតើខ្ញុំបានប្រមូលព័ត៌មានសម្រាប់ការវិនិច្ឆ័យនៅក្នុងកាលៈទេសៈបែបណានិងបានធ្វើការសម្រេចចិត្តបែបណា។ គ្មានអ្វីដែលធ្វើឱ្យខ្ញុំសប្បាយចិត្តជាងនេះទេ ប្រសិនបើខ្ញុំអាចជួយទោះជាតិចតួចក្តីដល់អ្នកដែលគិតចង់ចូលរួមក្នុងគម្រោងសហប្រតិបត្តិការក្នុងវិស័យអប់រំកាយនិងកីឡា ឬអ្នកដែលកំពុងជួបការលំបាកក្នុងស្ថានភាពនេះក្តី។ ម្យ៉ាងវិញទៀត សម្រាប់ខ្ញុំ វាជាឱកាសមួយដើម្បីសញ្ជឹងគិតដល់អ្វីដែលបានកើតឡើងពិតប្រាកដក្នុងរយៈពេល១២ឆ្នាំកន្លងមក ហើយបានអនុញ្ញាតឱ្យខ្ញុំមានការពិភាក្សាស៊ីជម្រៅជាមួយមនុស្សផ្សេងៗ ដែលខ្ញុំមិនអាចធ្វើបាននៅពេលនោះ។

សំខាន់ជាងនេះទៅទៀតអាទិភាពរបស់ខ្ញុំក្នុងការសម្រេចចិត្តនិងការវិនិច្ឆ័យទាំងអស់គឺសួរថា «តើជម្រើសមួយណាដែលល្អនិងមានប្រសិទ្ធភាពបំផុតដើម្បីឱ្យកុមារទូទាំងប្រទេសកម្ពុជាអាចរៀនពីឥរិយាបថចំណេះដឹងជំនាញនិងសហការតាមរយៈអប់រំកាយបែបថ្មីក្នុងបរិយាកាសនិងកាលៈទេសៈផ្សេងគ្នា។ មុខវិជ្ជាអប់រំកាយមានអត្ថន័យទៅបាន លុះត្រាតែគ្រូបង្រៀននៅសាលា

បានបង្រៀនដល់សិស្សម្នាក់ៗ។ នៅក្នុងបរិយាកាសសាលារៀន ថ្នាក់អប់រំកាយត្រូវបានបង្កើតឡើងនៅពេលដែលគ្រូ អប់រំកាយផ្តល់មេរៀនដល់សិស្ស ហើយរបៀបដែលមេរៀនត្រូវបានផ្តល់ទៅដល់សិស្ស នឹងត្រូវផ្លាស់ប្តូរ អាស្រ័យលើវិធីសាស្ត្របង្រៀននោះ។

ដូច្នេះវាទាមទារឱ្យមានសកម្មភាពផ្សេងៗជាច្រើនទៀតដូចជាមានកម្មវិធីសិក្សាមានការបណ្តុះបណ្តាលគ្រូបង្រៀន មានប្រព័ន្ធផ្សព្វផ្សាយ មានការបណ្តុះបណ្តាលមន្ត្រីក្រសួងអប់រំមានមុខងារនៃមុខវិជ្ជាអប់រំកាយក្នុងចំណោមមុខវិជ្ជាទាំងអស់របស់សាលា។ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលរបស់ជប៉ុន យើងកំពុងជួយដល់ប្រទេសកម្ពុជាដែលជាប្រទេសមួយផ្សេងទៀត (តាមពិតយើងកំពុងរៀនសូត្រជាមួយគ្នា) ហើយយើងតែងតែអនុវត្តគម្រោងដោយជឿជាក់លើគោលការណ៍ «ផ្តល់អប់រំកាយប្រកបដោយគុណភាពដល់កុមារ»។

នៅក្នុងជំពូកទី១នៃសៀវភៅនេះពន្យល់ថាតើកាលពីមុនអប់រំកាយប្រភេទណាដែលធ្លាប់បានអនុវត្តនៅក្នុងប្រទេសកម្ពុជា និងគ្រូបង្រៀនយល់ឃើញយ៉ាងណាអំពីអប់រំកាយ។ ជំពូកទី២ ពិពណ៌នាអំពីថាតើអង្គការបេះដូងមាសបានចាប់ផ្តើមគម្រោងដោយមានប្រវត្តិបែបណា និងបានជួបការលំបាកអ្វីខ្លះ។ ជំពូកទី៣ ណែនាំពីភាពលំបាកនៃការផ្សព្វផ្សាយដល់សាលារៀនដោយផ្អែកលើកម្មវិធីសិក្សាសម្រាប់បឋមសិក្សាដែលបានបញ្ចប់ជាលើកដំបូង និងភាពខុសគ្នារវាងកម្រិតរដ្ឋាភិបាល និងថ្នាក់រៀនជាក់ស្តែងជាដើម។ ជំពូកទី៤ ពន្យល់ពីប្រវត្តិនិងខ្លឹមសារនៃគម្រោងនោះដែលបានធ្វើឱ្យការផ្លាស់ប្តូរពីបឋមសិក្សាទៅអនុវិទ្យាល័យអាចធ្វើទៅបាន។ ជំពូកទី៥ ពិនិត្យលើការផ្លាស់ប្តូររបស់ក្រសួងអប់រំនៃប្រទេសកម្ពុជាឆ្ពោះទៅរកឯករាជ្យភាព តាមរយៈគម្រោងជាបន្តបន្ទាប់ និងការប្រែប្រួលនៃទំនាក់ទំនង រវាងអង្គការបេះដូងមាស និងក្រសួងអប់រំ។ ជំពូកទី៦ពន្យល់ពីប្រវត្តិនិងខ្លឹមសារនៃគម្រោងដែលជួយដល់ការបង្កើតសាកលវិទ្យាល័យអប់រំកាយដំបូងគេនៅប្រទេសកម្ពុជា។ ជាចុងក្រោយ អវសានកថា បានសង្ខេបលទ្ធផលនៃគម្រោងរបស់អង្គការបេះដូងមាសដែលបានបន្តរហូតមកដល់បច្ចុប្បន្ន និងបានផ្តល់គំនិតមួយចំនួនអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិតាមរយៈកីឡា។

សូមបញ្ជាក់ថា ទស្សនៈផ្សេងៗដែលបានបង្ហាញនៅក្នុងសៀវភៅនេះ មិនមែនជាទស្សនៈផ្លូវការរបស់ JICA ឬវិទ្យាស្ថានស្រាវជ្រាវ JICA នោះទេ ប៉ុន្តែគ្រាន់តែជាទស្សនៈផ្ទាល់ខ្លួនរបស់អ្នកនិពន្ធប៉ុណ្ណោះ។ លើសពីនេះ ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងជួយអ្នកអានក្នុងការអនុវត្តនិងគិតគូរអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិតាមមធ្យោបាយណាមួយ។

# អង្គការបេះដូងមាស និងកាលប្បវត្តិនៃប្រវត្តិអប់រំកាយនៅប្រទេសកម្ពុជា

១៩៩៦ • ទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្ត (AWHM) លើកទី១ បានចាប់ផ្តើម



១៩៩៨ • អង្គការបេះដូងមាសបានបង្កើតឡើង




២០០១ • ការប្រកួតកីឡាវិស្សមោកាសយុវជនលើកទី១ បានប្រារព្ធឡើង (សៀមរាប)

២០០២ • ការប្រកួតកីឡាវិស្សមោកាសយុវជនលើកទី២ បានប្រារព្ធឡើង (សៀមរាប)

២០០៣ • ពិធីបុណ្យកីឡាបណ្តុះបណ្តាលយុវជននិងគ្រូបង្រៀន(YLTS) លើកទី៣ បានប្រារព្ធឡើង (ភ្នំពេញ)

២០០៤ • ពិធីបុណ្យ YLTS លើកទី ៤ បានប្រារព្ធឡើង (កំពង់ចាម)

២០០៥ • ពិធីបុណ្យ YLTS លើកទី ៥ បានប្រារព្ធឡើង (ស្វាយរៀង)



២០០៦ • គម្រោងជំនួយចងក្រងសៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា (កម្មវិធីភាពជាដៃគូរបស់ JICA) ខែកុម្ភៈ ឆ្នាំ២០០៦ - ខែកក្កដា ឆ្នាំ២០០៨ គោលដៅ៖ ៨ ខេត្ត (ភ្នំពេញ បាត់ដំបង ព្រះសីហនុ កំពង់ចាម កំពង់ឆ្នាំង ស្វាយរៀង ក្រចេះ រតនគិរី)





២០០៧ • កម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សាត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២០០៨

២០០៩ • គម្រោងលើកកម្ពស់ការអប់រំមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា (កម្មវិធីភាពជាដៃគូរបស់ JICA) ខែមិថុនា ឆ្នាំ២០០៩ - ខែមិថុនា ឆ្នាំ២០១២ គោលដៅ៖ ៥ ខេត្ត (បាត់ដំបង សៀមរាប ព្រះសីហនុ ក្រចេះ ស្វាយរៀង)

២០១៣ • គម្រោងផ្សព្វផ្សាយទិវាអប់រំកាយបានចាប់ផ្តើម
• គម្រោងអភិវឌ្ឍធនធានមនុស្ស និងបង្កើតប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៃការអប់រំមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា(កម្មវិធីភាពជាដៃគូរបស់ JICA) ខែមេសា ឆ្នាំ២០១៣ - ខែតុលា ឆ្នាំ២០១៦ គោលដៅ៖ ១៥ ខេត្ត (បាត់ដំបង ក្រចេះ ស្វាយរៀង សៀមរាប ព្រះសីហនុ បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ធំ ព្រះវិហារ កំពត កោះកុង ស្ទឹងត្រែង រតនគិរី ព្រៃវែង តាកែវ)



២០១៤ • សៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា ត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២០១៥ • គម្រោងជំនួយចងក្រងកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិ(កីឡាសម្រាប់ថ្ងៃស្អែក) ខែមករា - ខែមីនា ឆ្នាំ២០១៥, ខែតុលា ឆ្នាំ២០១៥ - ខែធ្នូ ឆ្នាំ២០១៦, គោលដៅ៖ ភ្នំពេញ បាត់ដំបង ស្វាយរៀង



២០១៦ • កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិ ត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២០១៧ • គម្រោងជំនួយចងក្រងនិងផ្សព្វផ្សាយសៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ (កម្មវិធីភាពជាដៃគូរបស់ JICA) ខែមករា ឆ្នាំ២០១៧ - ខែកញ្ញា ឆ្នាំ២០២០ គោលដៅ៖ ៣ រាជធានី-ខេត្ត (ភ្នំពេញ បាត់ដំបង ស្វាយរៀង)

២០១៨ • សៀវភៅគ្រូសម្រាប់មធ្យមសិក្សាបឋមភូមិ ត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

• កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិ ត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២០១៩ • វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា (NIPES) គម្រោង ប្រែក្លាយវគ្គសិក្សាអប់រំកាយ ទៅជាសាកលវិទ្យាល័យរយៈពេល ៤ឆ្នាំ ((គម្រោងជំនួយឥតសំណងសហប្រតិបត្តិការរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន) ខែមករា - ខែធ្នូ ឆ្នាំ២០១៩ ខែមីនា ឆ្នាំ២០២១ - ខែកុម្ភៈ ឆ្នាំ២០២៣)






២០២០

២០២១

• គម្រោង «អប់រំកាយសម្រាប់ទាំងអស់គ្នា» ដែលផ្តល់ការសិក្សាប្រកបដោយគុណភាពខ្ពស់ចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ (កម្មវិធីភាពជាដៃគូរបស់ JICA) ខែកុម្ភៈ ឆ្នាំ២០២១ - ខែមករា ឆ្នាំ២០២៥ រាជធានី/ខេត្តគោលដៅចំនួន៣ (ភ្នំពេញ បាត់ដំបង ស្វាយរៀង)

២០២២

• សៀវភៅគ្រូសម្រាប់មធ្យមសិក្សាទុតិយភូមិត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២០២៣

គម្រោងជំនួយវិទ្យាស្ថានគរុកោសល្យ អប់រំកាយ ៤ឆ្នាំ ប្រកបដោយគុណភាពខ្ពស់ ដោយប្រើ ICT នៃព្រះរាជាណាចក្រកម្ពុជា (គម្រោងជំនួយឥតសំណងសម្រាប់កិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលជប៉ុន) ខែមីនា ឆ្នាំ២០២៣ - ខែមីនា ឆ្នាំ២០២៦





## ចំណាប់អារម្មណ៍របស់ខ្ញុំអំពីគម្រោងនៅពេលខ្ញុំឡើងកាន់តំណែង

កម្ពុជាជាប្រទេសមួយដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មានព្រំប្រទល់ជាប់នឹងប្រទេសថៃ ឡាវ និងវៀតណាម។ មានប្រជាជនចំនួន ១៥,៣ លាននាក់ (ជំរឿនជាតិកម្ពុជាឆ្នាំ២០១៩) ដែលមានភ្នំពេញជារាជធានី ហើយបែងចែកជា ១រាជធានី និង២៤ខេត្ត។ នៅទូទាំងប្រទេសមានសាលាបឋមសិក្សាចំនួន៧២៨២,អនុវិទ្យាល័យចំនួន១២៤៧,វិទ្យាល័យចំនួន៣៤,និងអនុវិទ្យាល័យ និង វិទ្យាល័យរួមគ្នាចំនួន ៥៩០ (ក្រសួងអប់រំ (MoEYS) ឆ្នាំ ២០២០ ទំ. ១)។

នៅពេលដែលខ្ញុំបានមកដល់ប្រទេសកម្ពុជាដំបូងក្នុងឆ្នាំ ២០១២ ខ្ញុំមានឱកាសបានទៅខេត្តក្រចេះ (ខេត្តមួយនៅភាគឦសាននៃប្រទេសកម្ពុជា) ដើម្បីតាមដានថ្នាក់អប់រំកាយនៅសាលាបឋមសិក្សា។ អង្គការក្រៅរដ្ឋាភិបាល បេះដូងមាស ដែលខ្ញុំជាបុគ្គលិក កំពុងអនុវត្ត «គម្រោងលើកកម្ពស់ការអប់រំ មុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា»(ខែមិថុនា ឆ្នាំ២០០៩ ដល់ខែមិថុនា ឆ្នាំ២០១២) ដែលជាដំណាក់កាលទី ២ នៃកម្មវិធីភាពជាដៃគូ និងកំពុងធ្វើការតាមដានសាលាបឋមសិក្សានៅទូទាំងប្រទេសដើម្បីធានាថាសៀវភៅគ្រូមុខវិជ្ជាអប់រំកាយដែលបានចងក្រងជាមួយមន្ត្រីមកពីក្រសួងអប់រំ និងនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត (DPESS) ត្រូវបានបង្រៀននៅក្នុងសាលារៀន។

គោលដៅនៃការពិនិត្យតាមដានរួមមានសាលាបឋមសិក្សាចំនួន២ និងសាលាគរុកោសល្យគ្រូកម្រិតបឋមសិក្សានៅក្នុងខេត្តមួយ។នៅទូទាំងប្រទេសកម្ពុជាមានសាលាបឋមសិក្សាជាង៧០០០សាលាប៉ុន្តែគោលដៅនៅពេលនោះត្រូវបានកំណត់ធ្វើនៅសាលាបឋមសិក្សាចំនួន១០ ពីក្នុងចំណោមខេត្តចំនួន៥ នៅទូទាំងប្រទេស(បាត់ដំបង សៀមរាប ព្រះសីហនុ ក្រចេះ និងស្វាយរៀង) ហើយការបណ្តុះបណ្តាលមន្ត្រីអប់រំកាយគឺជាជំហានដំបូងឆ្ពោះទៅរកគោលនយោបាយអប់រំកាយថ្នាក់ជាតិ។ ទោះបីជាការចងក្រងកម្មវិធីសិក្សា និងសៀវភៅគ្រូដោយសហការជាមួយក្រសួងអប់រំមានសារៈសំខាន់ខ្លាំងយ៉ាងណាក៏ដោយប៉ុន្តែកម្មវិធីសិក្សា និងសៀវភៅគ្រូដែលត្រូវបានចងក្រងឡើងយ៉ាងលំបាកនេះ មានអត្ថន័យតែនៅពេលដែលត្រូវបានគេប្រើប្រាស់នៅក្នុងថ្នាក់អប់រំកាយជាក់ស្តែងប៉ុណ្ណោះ។ សម្រាប់ខ្ញុំនៅពេលនោះការផ្សព្វផ្សាយប្រព័ន្ធអប់រំកាយបែបថ្មីដែលបង្រៀន «ឥរិយាបថ ចំណេះដឹង ជំនាញ និងសហការ» តាមរយៈកីឡាដល់កុមារទូទាំងប្រទេសកម្ពុជា ហាក់ដូចជានៅឆ្ងាយណាស់។

មុនពេលដែលខ្ញុំចាប់ផ្តើមធ្វើការខ្ញុំបានឮថាអង្គការបេះដូងមាសគឺជាអង្គការដ៏អស្ចារ្យដែលមានឥទ្ធិពលលើគោលនយោបាយរបស់ក្រសួងអប់រំផងដែរ។ច្បាស់ណាស់ថាការរៀបចំកម្មវិធីសិក្សា ។ល។ពិតជាមានការលំបាកដើម្បីទទួលបានការអនុម័តពីរដ្ឋមន្ត្រីក្រសួងអប់រំ។ទោះជាយ៉ាងនេះក្តី ខ្ញុំគ្មានជម្រើសអ្វីក្រៅពីផ្លាស់ប្តូរគំនិតរបស់ខ្ញុំទេនៅពេលដែលខ្ញុំឃើញថាជាក់ស្តែងយើងអាចផ្សព្វផ្សាយទៅដល់សាលារៀនប្រហែល ១០ ប៉ុណ្ណោះ។ថ្វីត្បិតតែនេះជាគម្រោងដ៏អស្ចារ្យមួយ ប៉ុន្តែខ្ញុំមានការបារម្ភថា នឹងត្រូវចំណាយពេលយូរទៀត ទម្រាំក្រសួងអប់រំអាចជំរុញឲ្យមានការផ្សព្វផ្សាយដោយ

ខ្លួនឯង និងអនុវត្តកម្មវិធីអប់រំកាយបែបថ្មី នៅគ្រប់រាជធានី-ខេត្ត ក្រោយពេលគម្រោងបានបញ្ចប់ ហើយការគ្រប់គ្រងគម្រោងទាំងអស់នឹងត្រូវផ្ទេរទៅឱ្យក្រសួងអប់រំ។

## តើអ្វីទៅជាអប់រំកាយបែបប្រពៃណីនៅប្រទេសកម្ពុជា?

ជាបឋមហេតុអ្វីបានជាថ្នាក់អប់រំកាយចាំបាច់សម្រាប់សាលារៀននៅកម្ពុជា?នៅប្រទេសជប៉ុន «អប់រំកាយមានគោលបំណងផ្តល់ឱ្យកុមារទាំងអស់នូវសមត្ថភាពរាងកាយ និងចំណេះដឹងចាំបាច់ដើម្បីរស់នៅក្នុងជីវិតដែលមានសុខភាពល្អនិងសុវត្ថិភាពក៏ដូចជាដើម្បីអភិវឌ្ឍភាពស៊ាំជាមួយការធ្វើលំហាត់ប្រាណនិងកីឡាពេញមួយជីវិតរបស់ពួកគេ»(ក្រសួងអប់រំវប្បធម៌កីឡាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា)។ផ្ទុយទៅវិញនៅក្នុងប្រទេសកម្ពុជាជាទម្លាប់គេតែងនិយាយថា«ការរៀនដើម្បីចេះដឹង រៀនដើម្បីចេះធ្វើ រៀនដើម្បីមានសីលធម៌ល្អ និងរៀនដើម្បីចេះរួមរស់ជាមួយគ្នា គឺមានសារៈសំខាន់ណាស់»ហើយការរៀនដើម្បីចំណេះដឹងចរិយាសម្បទាអនាគតរបស់ខ្លួននិងការរួមរស់ជាមួយគ្នាក្នុងសង្គមត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះនៃការអប់រំនៅសាលា។មានន័យថាការសង្កត់ធ្ងន់គឺទៅលើទិដ្ឋភាពនៃការរៀនសូត្រជាក់ស្តែងដូចជាការស្រូបយកចំណេះដឹងហើយតួនាទីនៃអប់រំកាយក្នុងការបណ្តុះបណ្តាលរាងកាយឱ្យមានសុខភាពល្អ គឺមិនច្បាស់លាស់ទេ (រូបថតខាងឆ្វេង)។ ម្យ៉ាងទៀតនៅប្រទេសកម្ពុជាបានចាប់ផ្តើមពីចំណុចដែលការអប់រំតាមសាលាបានដួលរលំដោយសារឥទ្ធិពលនៃរបបប៉ុលពត។ នៅចំពេលមានកង្វះសម្ភារៈបរិក្ខារ និងគ្រូបង្រៀន អប់រំកាយត្រូវបានផ្តល់អាទិភាពទាប ដោយសារបញ្ហាប្រឈមដូចជាធ្វើយ៉ាងណាដើម្បីកែលម្អការអប់រំនៅសាលា។




ចតុស្តម្ភនៃការអប់រំត្រូវបានដំឡើងនៅក្នុងសាលារៀនជាច្រើន

នៅពេលដែលអង្គការបេះដូងមាសកំពុងស្វែងរកគម្រោងអប់រំមុខវិជ្ជាអប់រំកាយនៅក្នុងប្រទេសជប៉ុន វាគឺជាគម្រោងសហ-ប្រតិបត្តិការអន្តរជាតិដែលមានអាទិភាពទាបហើយទាំងJICAទាំងមូលនិធិ ឬក្រសួងការបរទេសក៏មិនមានចំណាប់អារម្មណ៍លើវាដែរ។ទោះជាយ៉ាងណាក៏ដោយមូលហេតុ ដែលយើងសម្រេចថាការអប់រំមុខវិជ្ជាអប់រំកាយអាចធ្វើទៅបានក្នុងប្រទេសកម្ពុជាគឺដោយសារតែ គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាឆ្នាំ ២០០៥-២០០៩ បានកំណត់ច្បាស់ថា មុខវិជ្ជាអប់រំកាយ ត្រូវរៀនរយៈពេល ២ម៉ោងសិក្សា ក្នុងមួយសប្តាហ៍ (MoEYS, ២០០៤)។

ទោះជាយ៉ាងណាក៏ដោយ ចក្ខុវិស័យនៃ Curriculum Framework (តទៅនេះហៅថា ក្របខណ្ឌកម្មវិធីសិក្សា) ដែលបានបង្កើតឡើងក្នុងឆ្នាំ២០១៥ គឺដើម្បីធានាលទ្ធភាពដែលពលរដ្ឋ មានការអភិវឌ្ឍដោយមានតុល្យភាពរវាងវិជ្ជាសម្បទាបំណិនសម្បទាចរិយាសម្បទាកាយសម្បទា និងមនសិការស្នេហាជាតិនិងមនុស្សជាតិ (MoEYS, ២០១៥) ។ ដោយផ្អែកលើចំណុចនេះ សមត្ថភាពសំខាន់ៗចំនួន៩រួមមានអក្ខរសាស្ត្រនិងលេខសាស្ត្រភាសាបរទេសបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍(ICT)ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុមពិចារណានិងការបង្កើតថ្មីអនុវត្ត ចំណេះដឹងនិងជំនាញ អភិវឌ្ឍបុគ្គលគ្រួសារនិងសង្គម សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ ត្រូវ បានកំណត់ដោយការរៀនតាមរយៈ ភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ គណិតវិទ្យា សិក្សាសង្គម វិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) ភាសាបរទេស អប់រំកាយនិងកីឡា អប់រំ សុខភាព អប់រំសិល្បៈ និងបំណិនជីវិតតាមមូលដ្ឋាន។ ក្នុងនោះក៏បានលើកឡើងផងដែរថា ថ្នាក់ អប់រំកាយនឹងធ្វើឡើងរយៈពេល២ម៉ោងក្នុងមួយសប្តាហ៍ហើយអាចនិយាយបានថាតួនាទីនៃអប់រំកាយ នៅក្នុងប្រព័ន្ធគឺច្បាស់លាស់។

លោក ព្រំ ប៊ុណ្ណយី ទីប្រឹក្សាក្រសួងអប់រំ បាននិយាយថា ហេតុផលដែលកំណត់ទុក ថ្នាក់អប់រំកាយរយៈពេល២ម៉ោងគឺ«ដើម្បីជំរុញសកម្មភាពកីឡានៅក្នុងសាលារៀន»។កាលពីដើម ការប្រកួតកីឡាត្រូវបានធ្វើឡើងជាទៀងទាត់នៅថ្នាក់ខេត្តនិងថ្នាក់ជាតិហើយអប់រំកាយនៅសាលាត្រូវ បានធ្វើឡើងដើម្បីត្រៀមចូលរួមក្នុងការប្រកួតទាំងនោះ។អាស្រ័យហេតុនេះអប់រំកាយនៅសាលាមិន ពាក់ព័ន្ធជាមួយកីឡាករណាក្រៅពីអត្តពលិកដែលចូលរួមក្នុងការប្រកួតនោះទេហើយការត្រៀមចូលរួម ការប្រកួតគឺធ្វើឡើងមុនការប្រកួតដូច្នេះនៅក្នុងថ្នាក់អប់រំកាយជាធម្មតាកីឡាដូចជាលំហាត់ប្រាណ បែបខ្មែរ (កាយសម្ព័ន្ធដោយដៃ) ឬបាល់ទាត់ជាដើម ត្រូវបានគេអនុវត្តជាទម្លាប់។ ជាងនេះទៅទៀត អប់រំកាយតាមសាលាត្រូវបានគេយល់ថាជាការរួមបញ្ចូលគ្នានៃថ្នាក់អប់រំកាយនិងកីឡាក្រៅកម្មវិធី សិក្សាហើយនៅក្នុងប្រទេសកម្ពុជានាពេលនោះទាំងមន្ត្រីក្រសួងអប់រំនិងគ្រូបង្រៀនបានយល់ច្រឡំ រវាងអប់រំកាយនិងកីឡា។អាចនិយាយបានថា គោលដៅច្បាស់លាស់មិនត្រូវបានកំណត់តាមរយៈ ថ្នាក់អប់រំកាយនោះទេដោយសារជាក់ស្តែងថ្នាក់អប់រំកាយត្រូវបានបង្រៀនត្រឹមតែ២ម៉ោងប៉ុណ្ណោះ ក្នុងមួយសប្តាហ៍។

នៅក្នុងកាលៈទេសៈបែបនេះតើគ្រូបឋមសិក្សាមានទស្សនៈយ៉ាងណាអំពីសារៈសំខាន់នៃថ្នាក់អប់រំកាយនៅពេលនោះ?

លោកស្រី ញឹម សុខា នាយិការងសាលាបឋមសិក្សាអ៊ិនស៊ីដារ៉េ ខេត្តបាត់ដំបង បានមានប្រសាសន៍អំពីអប់រំកាយមុនពេលដែលប្រព័ន្ធអប់រំកាយបែបថ្មីត្រូវបានអនុវត្ត«យើងគ្រាន់តែប្រគល់បាល់ដល់សិស្សហើយឱ្យពួកគេលេង ជាការស្រេច។ ទន្ទឹមនឹងនោះ អប់រំកាយគឺសម្រាប់សិស្សានុសិស្សគ្រប់ថ្នាក់ទាំងអស់មកជួបជុំគ្នានិងធ្វើលំហាត់ប្រាណជាមួយគ្នា។ វាជាថ្នាក់អប់រំកាយហើយជាជាងបង្រៀនអ្វីមួយ វាត្រូវបានធ្វើឡើងក្នុងគោលបំណងឱ្យសិស្សសប្បាយរីករាយ និងឱ្យពួកគេបញ្ចេញនូវភាពតានតឹងដែលបានប្រមូលផ្តុំពីមុខវិជ្ជាផ្សេងៗ»។

ដូចគ្នានេះផងដែរ លោកគ្រូ ព្រាប វន្ថា នៅសាលាបឋមសិក្សាបាដាក ក្នុងខេត្តបាត់ដំបងមានប្រសាសន៍ថា«មុនពេលដាក់បញ្ចូលអប់រំកាយបែបថ្មី ថ្នាក់រៀនត្រូវបានធ្វើឡើងដោយផ្អែកលើចំណេះ-ដឹងរបស់គ្រូ អំពីលំហាត់ប្រាណបែបខ្មែរ។ អប់រំកាយត្រូវបានបង្រៀននៅថ្ងៃចន្ទ និងថ្ងៃសុក្រ ហើយគោលដៅ គឺមិនមែនបង្រៀនចំណេះដឹង ដូចអប់រំកាយសព្វថ្ងៃនេះទេ បើសិនជាបាល់ទាត់ ថ្នាក់រៀនគ្រាន់តែឱ្យសិស្សលេងបាល់ទាត់ប៉ុណ្ណោះ»។

តាមការលើកឡើងរបស់លោកគ្រូទាំងពីរនេះ មុននឹងដាក់ចេញនូវអប់រំកាយបែបថ្មី អប់រំកាយមិនមានគោលដៅដូចជាចំណេះដឹងនិងជំនាញទេ ប៉ុន្តែផ្តោតលើលំហាត់ប្រាណបែបខ្មែរ ហើយគ្រូអប់រំកាយទៀតសោត ជាគ្រូបឋមសិក្សាដែលមិនមានសញ្ញាបត្រ មិនអាចបង្រៀនថ្នាក់អប់រំកាយបានដូច្នេះ យុវជនដែលចេះលេងកីឡាត្រូវបានគេជួលធ្វើជាគ្រូអប់រំកាយបណ្តោះអាសន្ន ហើយបើគ្រូបណ្តោះអាសន្ននោះលេងបាល់ទាត់ គាត់នឹងបង្រៀនបាល់ទាត់ ហើយបើគាត់លេងបាល់ទះ គាត់នឹងបង្រៀនបាល់ទះតែប៉ុណ្ណោះ។ វិធីសាស្ត្រនេះប្រហែលជាជៀសមិនរួចទេ ដោយសារមិនមានកម្មវិធីសិក្សា និងគ្មានការណែនាំអំពីអ្វីដែលគ្រូគួរបង្រៀន។

ខណៈពេលដែលអប់រំកាយមានតួនាទីជាប្រព័ន្ធយ៉ាងច្បាស់លាស់ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សា ប៉ុន្តែអប់រំកាយជាក់ស្តែងគឺផ្តោតលើលំហាត់ប្រាណបែបខ្មែរ ដូច្នេះលទ្ធភាពនៃការទទួលបានគុណវុឌ្ឍិទាំង៩ដែលបានរៀបរាប់ខាងលើមានកម្រិតទាបបំផុត។

## ការផ្លាស់ប្តូររចនាសម្ព័ន្ធមុនពេលចាប់ផ្តើមជំនួយផ្នែកអប់រំកាយ

មុនពេលចាប់ផ្តើមជំនួយផ្នែកអប់រំកាយអង្គការបេះដូងមាសបានជួយដល់ទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្តដែលបានប្រារព្ធឡើងជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ១៩៩៦មក។ បន្ទាប់ពីបានពិភាក្សាជាមួយលោក អ៊ិក សារ៉េត មន្ត្រីទទួលបន្ទុកនៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប ដែលចូលរួមក្នុងព្រឹត្តិការណ៍នេះ លោកបានស្នើថា គួរតែជួយវិស័យកីឡាទូទៅនៅប្រទេសកម្ពុជាជាជាងជួយតែការរត់ម៉ារ៉ាតុងហេតុដូចនេះការប្រកួតកីឡាវិស្សមកាសយុវជនលើកទី១ក៏ត្រូវបានប្រារព្ធឡើង។

ពិធីបុណ្យ YLTS ត្រូវបានប្រារព្ធឡើងជាលើកដំបូងដើម្បីស្វែងរកលទ្ធភាពនៃការរួមចំណែកដល់សង្គមតាមរយៈកីឡាថ្មីៗហើយបានវិវត្តជាច្រើនឆ្នាំមកហើយ។នៅឆ្នាំទី១យើងបានប្រារព្ធទិវា អប់រំកាយ ប៉ុន្តែតាមលទ្ធផលនៃការពិភាក្សា ចាប់ពីឆ្នាំទី២តទៅព្រឹត្តិការណ៍នេះបានវិវត្តទៅជាទិវាបណ្តុះបណ្តាលគ្រូកីឡារយៈពេល២ថ្ងៃដែលគ្រូបង្រៀនក្នុងប្រទេសអាចទទួលបានបទពិសោធន៍ក្នុងការរៀនសូត្រ។ប្រព័ន្ធមួយត្រូវបានអនុម័តដែលក្នុងនោះអ្នកជំនាញដែលបានអញ្ជើញមកពីប្រទេសជប៉ុនបានបង្រៀនអ្នកដឹកនាំប្រទេសកម្ពុជា (គ្រូបង្រៀន) នៅថ្ងៃដំបូង ហើយនៅថ្ងៃទី២ គ្រូបង្រៀនវ័យក្មេងដែលបានរៀនវិធីសាស្រ្តបង្រៀនក៏បានបង្រៀនកុមារ (សូមមើលតារាងទី១)។ ជាងនេះទៅទៀត ចាប់ពីឆ្នាំទី៣តទៅ ពិធីបុណ្យYLTS ត្រូវបានប្រារព្ធឡើង រួមជាមួយនិងសិក្ខាសាលាអំពីប្រធានបទ ដូចជា មីននិងការការពារជំងឺអេដស៍ តាមគំរូនៃ «កីឡាដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍» ដែលចាប់ផ្តើមក្លាយជានិន្នាការអន្តរជាតិនៅពេលនោះ។ចំពោះកីឡាបាល់ទាត់មានលោក សាសា គិ ណូរីអុ អតីតគ្រូបង្វឹកបាល់ទាត់ជម្រើសជាតិនារីជប៉ុន, អត្តពលកម្មមានលោកស្រី អារីម៉ូរី យូកុ ប្រធានអង្គការបេះដូងមាស(ម្ចាស់មេដាយប្រាក់នៅកីឡាអូឡាំពិកBarcelonaនិងម្ចាស់មេដាយសំរឹទ្ធនៅកីឡាអូឡាំពិក អាត្លង់តា) ព្រមទាំងកីឡាករល្បីៗដូចជាកីឡាបាល់ទាត់ បាល់ទះ និងបាល់បោះ និងសមាជិកល្បីៗខាងកាយសម្ព័ន្ធទូទៅតែស្តកាយសម្បទាជាដើមបានធ្វើដំណើរមកប្រទេសកម្ពុជាហើយបានបង្រៀនដល់គ្រូជនជាតិកម្ពុជា។នៅចុងបញ្ចប់នៃព្រឹត្តិការណ៍លើកទី២លោកព្រំប៊ុណ្ណាយីនិងមន្ត្រីក្រសួងអប់រំផ្សេងទៀតបានស្នើសុំឱ្យកម្មវិធីនេះប្រារព្ធឡើងមិនត្រឹមតែនៅក្នុងខេត្តសៀមរាបប៉ុណ្ណោះទេថែមទាំងនៅទូទាំងប្រទេសផងដែរ។ក្នុងឆ្នាំ២០០៣ដើម្បីរំលឹកខួបលើកទី៥០នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសជប៉ុននិងប្រទេសកម្ពុជាក្រសួងអប់រំនៃប្រទេសកម្ពុជាគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជានិងអង្គការបេះដូងមាសបានរៀបចំគម្រោងរំលឹកដល់កិច្ចសហប្រតិបត្តិការយ៉ាងអធិកអធមរវាងស្ថានទូតជប៉ុនប្រចាំនៅកម្ពុជាJICAនិងក្រុមហ៊ុននានា។ចំនួនអ្នកចូលរួមមានជាង ២,០០០នាក់ហើយឯកឧត្តមឧបនាយករដ្ឋមន្ត្រីសខេងក៏បានចូលរួមក្នុងពិធីនេះដែរ។ជាលទ្ធផលរាជរដ្ឋាភិបាលកម្ពុជាបានចាប់អារម្មណ៍និងជំរុញយ៉ាងខ្លាំងក្នុងការលើកកម្ពស់កីឡានិងអប់រំកាយហើយចលនា គាំទ្រដល់ការអប់រំ មុខវិជ្ជា អប់រំកាយ បានបោះជំហានទៅមុខយ៉ាងខ្លាំង (HG, ២០១០, ទំព័រ១៦)។ យ៉ាងណាមិញ នៅក្នុងព្រឹត្តិការណ៍លើកទី៣ ប្រព័ន្ធស្ម័គ្រចិត្តមួយហៅថា

«HG-CYA-JYA» ត្រូវបានបង្កើតឡើងក្នុងគោលបំណងបណ្តុះបណ្តាលអ្នកដឹកនាំនាពេលអនាគត។ លោក កែវ សុចិត្រា ដែលបានធ្វើការនៅអង្គការបេះដូងមាសអស់រយៈពេល១៨ឆ្នាំមកហើយ ក៏មកពី «HG-CYA-JYA» នេះដែរ។

តារាង១ ទិដ្ឋភាពទូទៅនៃពិធីបុណ្យកីឡាបណ្តុះបណ្តាលយុវជននិងគ្រូ (YLTS) លើកទី៣ ត្រូវបានប្រារព្ធឡើង

| ពេលវេលា | ខែធ្នូ ឆ្នាំ២០០១ | ខែវិច្ឆិកា ឆ្នាំ ២០០២ | ខែធ្នូ ឆ្នាំ ២០០៣ | ខែធ្នូ ឆ្នាំ ២០០៤ | ខែធ្នូ ឆ្នាំ ២០០៥ |
|---|---|---|---|---|---|
| ឈ្មោះ | ការប្រកួតកីឡាវិស្សមោកាសយុវជនលើកទី១ | ការប្រកួតកីឡាវិស្សមោកាសយុវជនលើកទី២ | ពិធីបុណ្យ YLTS លើកទី៣ | ពិធីបុណ្យ YLTS លើកទី៤ | ពិធីបុណ្យ YLTS លើកទី៥ |
| ទីកន្លែង | ខេត្តសៀមរាប | ខេត្តសៀមរាប | ក្រុងភ្នំពេញ | ខេត្ត កំពង់ឆ្នាំង | ខេត្ត ស្វាយរៀង |
| ចំនួនអ្នកចូលរួម | ១៦ សាលា | ១៦ សាលា | ២០ សាលា | ១៦ សាលា | ២៨ សាលា |
| ចំនួនគ្រូបង្រៀន | ០ នាក់ | ៦០ នាក់ | ១៥០ នាក់ | ៨០ នាក់ | ៥៦ នាក់ |
| ចំនួនសិស្ស | ៥០០ នាក់ | ៨៧២ នាក់ | ១៦០០ នាក់ | ៨៥៦ នាក់ | ៨៩០ នាក់ |
| ចំនួនអ្នកស្ម័គ្រចិត្តកម្ពុជា | N / A | N / A | ៥០ នាក់ | ៨០ នាក់ | ១០០ នាក់ |
| ចំនួនអ្នកស្ម័គ្រចិត្តជប៉ុន | ៥០ នាក់ | ៩២ នាក់ | ១០០ នាក់ | ៩០ នាក់ | ៧០ នាក់ |
| ចំនួនអង្គការក្រៅរដ្ឋាភិបាលដែលចូលរួម | សហព័ន្ធអត្តពលកម្មជនពិការ | សហព័ន្ធអត្តពលកម្មជនពិការ | JHP / CPR CHEMS HG CYA-JYA | JHP / KYA CHEMS HG CYA-JYA | JHP / KYA CHEMS / KYA HG CYA-JYA |

## ការផ្លាស់ប្តូរដែលនាំមកដោយលោក ព្រំ ប៊ុណ្ណាយី

អ្នកដែលគិតចង់ផ្លាស់ប្តូរអប់រំកាយបែបប្រពៃណីនៅប្រទេសកម្ពុជាគឺ លោក ព្រំ ប៊ុណ្ណាយី។ លោកព្រំប៊ុណ្ណាយីជាប្រធាននាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតនៃក្រសួងអប់រំនៅពេលដែលអង្គការបេះដូងមាសបានចាប់ផ្តើមផ្តល់ជំនួយផ្នែកអប់រំមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សាក្នុងឆ្នាំ២០០៦។ខណៈពេលដែលអ្នកផ្សេងទៀតនៅក្រសួងអប់រំបានគិតថា«អប់រំកាយ»មានន័យថា «ឱ្យសិស្សធ្វើអ្វីៗដូចជាលំហាត់ប្រាណបែបខ្មែរ ឬបាល់ទាត់ដោយមិនកំណត់វត្ថុបំណង។ល។» លោក ព្រំ ប៊ុណ្ណាយី ជាមនុស្សតែម្នាក់គត់ដែលគិតថា អប់រំកាយបែបនេះគួរតែត្រូវបានផ្លាស់ប្តូរ។

ចាប់ពីពេលនោះមក អង្គការបេះដូងមាស មិនបានបង្រៀនកុមារដោយផ្ទាល់ទេ (អ្នកទទួលផលចុងក្រោយ) ប៉ុន្តែផ្ទុយទៅវិញ ផ្តោតលើគ្រូបង្រៀនដែលនឹងបង្រៀនកុមារដោយសម្លឹងឆ្ពោះទៅរកឯករាជ្យភាពរបស់កម្ពុជា។ លោកស្រី អារីម៉ូរី យូកុ ជានាយិកាតំណាងអង្គការបេះដូងមាស បាននិយាយតាំងពីលោកស្រីបានមកដល់ប្រទេសកម្ពុជាជាលើកដំបូងថា ប្រទេសកម្ពុជាត្រូវការការអប់រំ។ លោក ព្រំ ប៊ុណ្ណយី បានជួបលោកស្រី អារីម៉ូរី ជារៀងរាល់ឆ្នាំនៅក្នុងទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្ត។ ឆ្លៀតឱកាសនោះ គាត់ក៏ស្នើឱ្យអង្គការបេះដូងមាសអនុវត្តគម្រោងបណ្តុះបណ្តាលគ្រូអប់រំកាយ។ លោក យ៉ាម៉ាហ្គូជិ តាគុ ដែលពេលនោះជានាយកនៃអង្គការបេះដូងមាសប្រចាំតំបន់អាស៊ី អាគ្នេយ៍ បាននិយាយថា នៅពេលដែលគាត់បានស្រាវជ្រាវអំពីអប់រំកាយពីមុនមក គាត់បានរកឃើញកម្មវិធីសិក្សាទូទៅមួយ ដែលគ្រាន់តែបញ្ជាក់យ៉ាងសាមញ្ញប្រហែល២ទំព័រថា ត្រូវបង្រៀនការអប់រំលំហាត់ប្រាណ ឬកីឡាបាល់ជាដើម ២ម៉ោងក្នុងមួយសប្តាហ៍។

នៅពេលនោះ អប់រំកាយនៅសាលាត្រូវបានបន្តពីសម័យបារាំងគ្រប់គ្រង ហើយខណៈពេលដែលអប់រំកាយប្រភេទនេះកំពុងត្រូវបានអនុវត្ត នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតបានគិតអំពីអ្វីដែលអាចធ្វើទៅបាន។ នៅពេលនោះ មន្ត្រីក្រសួងអប់រំគិតថា ក្នុងម៉ោងអប់រំកាយ គ្រាន់តែរត់ប្រហែល៦០ម៉ែត្រគឺគ្រប់គ្រាន់ហើយ។ ប៉ុន្តែ លោក ព្រំ ប៊ុណ្ណយី មានគំនិតផ្សេងពីនេះ។គាត់បានគិតថាចាំបាច់ត្រូវបញ្ជាក់អំពីសមត្ថភាពសំខាន់ៗដែលកុមារគួររៀនក្នុងមុខវិជ្ជាអប់រំកាយទើបអាចបង្រៀនបាន។ប៉ុន្តែគ្មាននរណាម្នាក់ផ្សេងទៀតនៅក្នុងក្រសួងអប់រំធ្វើជាដៃគូជាមួយគាត់ទេ។មូលហេតុគឺដោយសារតែកម្រិតអាទិភាពរបស់វាទាប។សូម្បីតែក្នុងចំណោមអប់រំកាយ និងកីឡាក៏ដោយ ការប្រកួតកីឡាត្រូវបានផ្តល់អាទិភាពជាងអប់រំកាយ ហើយនៅក្នុងចំណោមការអប់រំទាំងមូល ការអប់រំវិទ្យាសាស្ត្រ និង គណិតវិទ្យាត្រូវបានផ្តល់អាទិភាពជាងអប់រំកាយ។ ក្នុងស្ថានភាពបែបនេះ លោកនាយក យ៉ាម៉ាហ្គូជិ និងលោកស្រី អារី ម៉ូរី យូកុ បានស្តាប់ និងយល់ពីការលើកឡើងរបស់លោក ព្រំ ប៊ុណ្ណយី ហើយនៅពេលអាហារពេលល្ងាច ពេលដែលពួកគេមកខេត្តសៀមរាបសម្រាប់ទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្តពួកគេបានពិភាក្សាអំពី«ពិធីបុណ្យកីឡាបណ្តុះបណ្តាលយុវជននិងគ្រូបង្រៀន» ដែលបានប្រារព្ធធ្វើមួយឆ្នាំម្តងរហូតមកដល់ពេលនោះថាតើពួកគេអាចបន្តសម្រេចបានលទ្ធផលដោយរបៀបណាថាតើអាចបន្តនិងពង្រីកវាក្នុងរយៈពេលយូរបានដែរឬទេ។កិច្ចប្រជុំនេះហើយដែលជាចំណុចចាប់ផ្តើមនៃជំនួយផ្នែកអប់រំកាយដែលបានបន្តរហូតដល់សព្វថ្ងៃ។

## ការធ្វើឱ្យក្លាយទៅជាមុខវិជ្ជានៅក្នុងកម្មវិធីសិក្សារបស់សាលា

នៅឆ្នាំ២០០៦ អង្គការបេះដូងមាសបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយ JICA និងក្រសួងអប់រំ ដើម្បីចាប់ផ្ដើមកម្មវិធីភាពជាដៃគូ។ ប៉ុន្តែគ្មាននរណាម្នាក់នៅក្នុងក្រសួងអប់រំបានជឿភ្លាមៗថាយើងបានចាប់ផ្ដើមគម្រោងអប់រំមុខវិជ្ជាអប់រំកាយនោះទេ។ទោះជាយ៉ាងណាក៏ដោយ លោក ព្រំ ប៊ុណ្ណាយី និងលោកនាយក យ៉ាម៉ាហ្គូជិ បានកាន់ដៃគ្នាចែករំលែកភាពសប្បាយរីករាយជាមួយគ្នា ហើយពេលខ្លះបានប្រកែកគ្នាខណៈពេលបន្តសកម្មភាពម្តងមួយៗដែលឥឡូវនេះបានផ្តល់នូវលទ្ធផលដ៏ធំ។

ការចាប់ផ្ដើមពី០ទៅ១គឺពិបាកខ្លាំងណាស់។ជាឧទាហរណ៍យើងត្រូវចាប់ផ្ដើមដោយប្រាប់អ្នកដែលគិតថា«ផ្លែប៉ោមមានពណ៌បៃតង»ថា«ផ្លែប៉ោមមានពណ៌ក្រហម»។សម្រាប់អ្នកដែលគិតថាផ្លែប៉ោមមានពណ៌បៃតង ពួកគេទទួលស្គាល់ថាផ្លែប៉ោមមានពណ៌បៃតង ដោយសារតែបទពិសោធន៍ជីវិត និងអ្វីដែលពួកគេបានឃើញ ហើយពួកគេមានគំនិតគិតទុកជាមុនតាំងពីដំបូងថា ផ្លែប៉ោមមិនអាចមានពណ៌ក្រហមបានទេ។ សម្រាប់អ្នកដែលគិតថា អប់រំកាយគឺជាលំហាត់ប្រាណបែបខ្មែរ ឬបាល់ទាត់។ល។ វាគឺជាការលំបាកខ្លាំងណាស់ក្នុងការផ្លាស់ប្តូរការយល់ឃើញរបស់ពួកគេចំពោះអប់រំកាយទោះបីជាយើងប្រាប់ថាអប់រំកាយគឺជាមុខវិជ្ជាមួយនៅក្នុងម៉ោងរបស់សាលា ដែលអាចត្រូវបានបង្រៀនជាប្រព័ន្ធពេញមួយឆ្នាំ និងមានគោលដៅអប់រំផងដែរ។ ខណៈពេលដែលយើងកំពុងព្យាយាមស្វែងរកកន្លែងដែលត្រូវចាប់ផ្ដើមដើម្បីផ្លាស់ប្តូរគោលគំនិតអំពីអប់រំកាយនេះ យើងបានចាប់ផ្ដើមពីការបណ្តុះបណ្តាលលោក ព្រំ ប៊ុណ្ណាយី និងមន្ត្រីទទួលបន្ទុកនៃនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត។ មន្ត្រីដែលទទួលបន្ទុកទាំងនេះមិនដែលបានទទួលការអប់រំមុខវិជ្ជាអប់រំកាយដូចនៅប្រទេសជប៉ុនទេ ហើយការប្រគល់ឱ្យទទួលខុសត្រូវផ្នែកអប់រំមុខវិជ្ជាអប់រំកាយនៅកម្ពុជាច្បាស់ជាមានសកម្មភាពដែលមានភាពមិនច្បាស់លាស់ដូចជាការដើរឆ្លងកាត់ភាពងងឹតអ៊ីចឹង។ហើយការខិតខំប្រឹងប្រែងរបស់លោក យ៉ាម៉ាហ្គូជិ ជានាយកអង្គការបេះដូងមាសនាពេលនោះ ព្រមទាំងនាយករង (នៅពេលនោះ) តាកាហាស៊ី តាខេអ៊ូ និងសាស្ត្រាចារ្យរង(នៅពេលនោះ) អូកាជិ យ៉ូស៊ីណូរិ នៃសាកលវិទ្យាល័យTsukuba ដែលបានធ្វើការរួមគ្នាគឺមិនអាចកាត់ថ្លៃបាន។

## អត្ថបទទី ១៖ អ្វីទៅជាលំហាត់ប្រាណបែបខ្មែរ?

លំហាត់ប្រាណបែបខ្មែរ គឺជាប្រភេទលំហាត់ប្រាណដោយដៃ ដែលបានអនុវត្តជាយូរមកហើយនៅក្នុងថ្នាក់អប់រំកាយក្នុងប្រទេសកម្ពុជា។ជាធម្មតាគ្រូបង្រៀនឬតំណាងសិស្សឈរនៅខាងមុខ ហើយធ្វើចលនាដៃនិងជើងខុសៗគ្នា ម្តងមួយៗ ដោយស្រែកថា «ចលនា១-១» «ចលនា១-២» ហើយសិស្សទាំងអស់ធ្វើចលនាទៅតាមនោះ។

វាជាអប់រំកាយដែលត្រូវបានអនុវត្តតាំងពីមុនអប់រំកាយបែបថ្មីហើយនៅក្នុងសៀវភៅគ្រូសម្រាប់បឋមសិក្សាចលនាចំនួន១៧ត្រូវបានណែនាំនៅក្នុងលំហាត់ប្រាណតាមចង្វាក់ភ្លេង។ការឱ្យតម្លៃប្រពៃណីក៏សំខាន់ផងដែរហើយអ្នកអាចរៀនសកម្មភាពជាក្រុមនៅក្នុងលំហាត់ប្រាណបែបខ្មែរ។ម្យ៉ាងវិញទៀតដោយសារតែវាមិនមានភ្លេងអមដូចលំហាត់ប្រាណតាមវិទ្យុទោះជាខណៈកំពុងធ្វើលំហាត់ប្រាណតាមចង្វាក់ភ្លេងក៏ដោយក៏ពិបាកក្នុងការធ្វើចលនារាងកាយទៅតាមចង្វាក់ដែរ។

អ្នកដែលបានប្រឹក្សាដើម្បីជួយឱ្យលំហាត់ប្រាណបែបខ្មែរនេះទទួលបាននូវ«ឥរិយាបថ ចំណេះដឹង ជំនាញ និងសហការ» នៅក្នុងការអប់រំមុខវិជ្ជាអប់រំកាយបែបថ្មី គឺជាលោក ណាកាម៉ូរ៉ា ហ៊ីដេតាកា ប្រធានក្រុម Social Compass ដែលជាក្រុមអ្នកផលិត ដែលបង្កើតឡើងក្នុងប្រទេសកម្ពុជាដើម្បីដោះស្រាយបញ្ហាសង្គមតាមរយៈសិល្បៈនិងការរចនា។នៅពេលនោះលោកណាកាម៉ូរ៉ាកំពុងបង្កើតតួអង្គគំនូរជីវចលមួយឈ្មោះថា«វត្តី»ដោយផ្អែកលើគំនូរនៃប្រាសាទអង្គរវត្តហើយបានស្នើឱ្យលោកស្រី ស៊ីមីហ្សូ ជីអេមី ដែលត្រូវបានបញ្ជូនទៅខេត្តព្រៃវែង ក្នុងនាមអ្នកស្ម័គ្រចិត្តរបស់ JICA ឱ្យបង្កើតបទភ្លេងសម្រាប់តួអង្គនេះ និងបានបង្កើតវីដេអូមួយដែលមានឈ្មោះថា «លំហាត់ប្រាណបែបខ្មែររបស់វត្តី» និងជាមួយនឹងតួអង្គមួយដែលមានឈ្មោះថា «អ៊ីនឌី» ដោយផ្អែកលើគំនូរវិមានឯករាជ្យ រាជធានីភ្នំពេញ។

វីដេអូនេះផ្សាយរៀងរាល់ព្រឹក វេលាម៉ោង ៦:៥០នាទី នៅលើកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា TVK រយៈពេលប្រមាណ ៤ឆ្នាំ (HG, ២០២១, ទំព័រ៣៨)។ លំហាត់ប្រាណបែបខ្មែរត្រូវបានអនុវត្តជាប្រពៃណី ប៉ុន្តែដោយការចាក់ភ្លេង គេអាចរៀនធ្វើតាមចង្វាក់ភ្លេងបាន។

លំហាត់ប្រាណបែបខ្មែរត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជាជាយូរយារណាស់មកហើយ ប៉ុន្តែជាមួយនឹងការបញ្ចូលនូវអប់រំកាយបែបថ្មី យើងចង់បន្តការខិតខំប្រឹងប្រែង ដើម្បីអភិវឌ្ឍលំហាត់ប្រាណបែបខ្មែរឱ្យកាន់តែរីកចម្រើន និងធ្វើឱ្យវាក្លាយជាលំហាត់ប្រាណដែលកុមារអាចរីករាយបាន។



លំហាត់ប្រាណបែបខ្មែរដែលអនុវត្តនៅសាលាបឋមសិក្សា




លំហាត់ប្រាណបែបខ្មែររបស់វត្តីនិងអ៊ីនឌី ជាមួយនឹងតន្ត្រី និងគំនូរជីវចល

# ជំពូកទី ១

## «អប់រំកាយ»នៅប្រទេសកម្ពុជា

## ផ្នែកទី១៖ អប់រំកាយបែបចាស់ / អប់រំកាយបែបថ្មី
## គំនិតអំពីអប់រំកាយនៅសាលារៀន

នៅប្រទេសកម្ពុជា ក្រោយរបប ប៉ុល ពត ដែលអូសបន្លាយពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានចាប់ផ្តើមសកម្មភាពដើម្បីជួយដល់វិស័យអប់រំ។ ជាទិដ្ឋភាពជាក់ស្តែងមួយនៅសម័យប៉ុលពតដែលការសម្លាប់រង្គាលបានកើតឡើង ខ្ញុំតែងតែនឹកឃើញរឿងដែលខ្ញុំបានឮកាលពីខែតុលាឆ្នាំ២០១៨ ពីឯកឧត្តម អ៊ុក សិទ្ធិជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាន កីឡា។

កាលឯកឧត្តមសិទ្ធិជាតិនៅក្មេងឪពុករបស់លោកដែលកំពុងជួសជុលដំបូលផ្ទះបានមើលពីចម្ងាយពីលើដំបូលឃើញមន្ត្រីយោធាប៉ុលពតមកជិតដល់ភ្លាមនោះឪពុកលោកបានចុះពីលើដំបូលមកស្រែកហៅម្តាយនិងលោកសិទ្ធិជាតិ។ឪពុកលោកបានដឹងថា«ប្រសិនបើគាត់ត្រូវបានយោធាហៅទៅ គាត់នឹងមិនអាចត្រឡប់មកវិញបានទេ (នឹងត្រូវគេសម្លាប់)»។ បន្ទាប់មក គាត់បានប្រាប់កូនប្រុស គឺលោក អ៊ុក សិទ្ធិជាតិ «ពុកមិនអាចត្រឡប់មកវិញបានទេ។ ពុកចង់ឱ្យកូនរស់នៅ និងមើលថែម្តាយ និងបងប្អូន»។ឪពុករបស់លោកត្រូវបានគេនាំទៅបាត់ហើយមួយសន្ទុះក្រោយមកគាត់បានឮស្នូរកាំភ្លើងពីចម្ងាយ។

ឪពុកត្រូវបានគេសម្លាប់គ្រួសារត្រូវបានគេសម្លាប់នៅចំពោះមុខ-អ្នកដែលឆ្លងកាត់ក្នុងសម័យនេះតែងតែមានទុក្ខសោកយ៉ាងជ្រាលជ្រៅនៅក្នុងចិត្តរបស់ពួកគេ។ ក្រោយមក ឯកឧត្តម អ៊ុក សិទ្ធិជាតិ បាននិយាយមកកាន់ខ្ញុំថា៖

«ប្រវត្តិសាស្ត្របែបនេះមិនត្រូវកើតឡើងម្តងទៀតទេ។ ក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែនកម្ពុជាទទួលបានការងើបឡើងវិញយ៉ាងខ្លាំង។នៅក្នុងវិស័យអប់រំកាយ និងកីឡាកម្មវិធីសិក្សានិងសៀវភៅគ្រូត្រូវបានបង្កើតឡើងហើយអប់រំកាយកាន់តែមានប្រជាប្រិយភាព។ ទោះជាការអភិវឌ្ឍមានការយឺតយ៉ាវយ៉ាងណាក៏ដោយ យើងត្រូវតែដើរទៅមុខ។ អង្គការបេះដូងមាសជួយការអប់រំមុខវិជ្ជាអប់រំកាយនៅក្នុងប្រទេសកម្ពុជាក្នុងស្ថានភាពបែបនេះនិងជួយកុមារឱ្យរៀនអំពី «ឥរិយាបថ ចំណេះដឹង ជំនាញ និងសហការ» តាមរយៈអប់រំកាយ។ ខ្ញុំគិតថាវាជារឿងធម្មតាសម្រាប់ខ្ញុំ ក្នុងការ គាំទ្រពួកគេ។»

ឯកឧត្តមសិទ្ធិជាតិដែលនិយាយសង្កត់ខ្លាំងបែបនេះតែងតែជឿជាក់លើគម្រោងរបស់អង្គការបេះដូងមាស ហើយបានបន្តគាំទ្រតាំងពីឆ្នាំ២០១៣មក។

ដោយសារឥទ្ធិពលនៃសម័យ ប៉ុល ពត ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជានៅមានសភាពយឺតយ៉ាវខ្លាំង ហើយ«ក្របខណ្ឌកម្មវិធីសិក្សា»ដែលបង្កើតឡើងក្នុងឆ្នាំ២០១៥ ចែងថា «ចំណេះដឹង ជំនាញ និងឥរិយាបថ» គួរតែត្រូវបានបង្រៀនពេញមួយដំណើរការអប់រំទាំងមូល។ ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាអនុវត្តតាមប្រព័ន្ធ៦-៣-៣ ដូចគ្នាទៅនឹងប្រទេសជប៉ុនដែរ ដោយការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាជាកាតព្វកិច្ច។ក្រោយសម័យ ប៉ុល ពតស្ទើរតែគ្មានបញ្ញវន្តក្នុងប្រទេស ដូច្នេះប្រព័ន្ធអប់រំត្រូវបានបន្តយកពីសម័យបារាំង។

នៅក្នុងកាលៈទេសៈបែបនេះគោលបំណងនៃមុខវិជ្ជានីមួយៗ«ហេតុអ្វីយើងត្រូវការគណិតវិទ្យា?» «ហេតុអ្វីយើងត្រូវការអប់រំកាយ?» ត្រូវបានបាត់បង់។ ដូចដែលបានរៀបរាប់ខាងលើបើទោះបីជាអប់រំកាយត្រូវបានធានា២ម៉ោងក្នុងមួយសប្តាហ៍ក៏ដោយ គឺវាបានធ្លាក់ទៅក្នុងស្ថានភាពដែលមិនមានគោលបំណងជាមូលដ្ឋានថាតើអប់រំកាយមានគោលបំណងអប់រំបែបណានិងគុណភាពអ្វីដែលកុមារចង់ទទួលបានតាមរយៈមុខវិជ្ជាអប់រំកាយនោះទេ។ នៅក្នុងការប៉ុនប៉ងដើម្បីផ្តល់ឱ្យពួកគេនូវភាពជាម្ចាស់ នាយករង តាកាហាស៊ី និងសាស្ត្រាចារ្យ អូកាដិ នៃសាកលវិទ្យាល័យ Tsukuba បានសួរពួកគេថាតើពួកគេចង់ឱ្យប្រទេសកម្ពុជាទៅជាយ៉ាងណាក្នុងរយៈពេល៥ឬ១០ឆ្នាំក្រោយហើយព្យាយាមពិភាក្សាអំពីគោលបំណងនិងអនាគតនៃការអប់រំមុខវិជ្ជាអប់រំកាយប៉ុន្តែអ្វីដែលពិបាកបំផុតនោះគឺពួកគេមិនអាចបញ្ចេញមតិផ្ទាល់ខ្លួនបាន។

## ការខិតខំប្រឹងប្រែងដ៏លំបាករបស់អង្គការបេះដូងមាស

នៅប្រទេសកម្ពុជា ការអប់រំផ្នែកអារម្មណ៍ ដូចជាអប់រំកាយ សិល្បៈ និងតន្ត្រី ត្រូវបានគេយល់ថាមានផ្នែកកម្សាន្ត និងលំហែភាគច្រើន ហើយត្រូវបានផ្តល់អាទិភាពដល់មុខវិជ្ជាសំខាន់ៗ ដូចជាការអប់រំវិទ្យាសាស្ត្រនិងគណិតវិទ្យា និងភាសាខ្មែរ ហើយមិនមានអង្គការណាដែលជួយដល់វិស័យអប់រំកាយទេ។ នៅក្នុងថ្នាក់អប់រំកាយដែលលំហាត់ប្រាណបែបខ្មែរបានក្លាយជារឿងធម្មតាដោយផ្អែកលើប្រព័ន្ធអប់រំក្រោមការគ្រប់គ្រងរបស់បារាំងដែលមាននៅមុនឆ្នាំ១៩៧៥ហើយអ្នកដែលបានព្យាយាមធ្វើកំណែទម្រង់អប់រំកាយដែលមានតែការធ្វើលំហាត់ប្រាណសាមញ្ញៗត្រូវបានអនុវត្តដោយផ្អែកលើប្រព័ន្ធបារាំងមុនឆ្នាំ១៩៧៥ គឺដូចអ្វីដែលលោក ព្រំ ប៊ុណ្ណយី បានរៀបរាប់ខាងលើ។

កន្លងមក ក្នុងវិស័យអប់រំកាយ អ្នកចុះពិនិត្យតាមដានកីឡា(អធិការកិច្ចអប់រំកាយ) មកពីការិយាល័យអប់រំស្រុកនីមួយៗ បានត្រួតពិនិត្យថ្នាក់អប់រំកាយនៅតាមសាលារៀនជារៀងរាល់ខែនិងឆ្នាំ ហើយកីឡាទាំង៥ប្រភេទ ត្រូវបានធ្វើឡើងតាមរបៀបដូចៗគ្នា ចាប់ពីថ្នាក់បឋមសិក្សារហូតដល់វិទ្យាល័យ។ ប្រភេទទាំង៥នោះរួមមាន៖ រត់ចម្ងាយខ្លី (បឋមសិក្សា៖ រត់៦០ម៉ែត្រ មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ៖ រត់១០០ម៉ែត្រ) លោតចម្ងាយ លោតកម្ពស់ ចោលដុំដែក និងឡើងខ្សែពួរ។ ក្រសួងអប់រំបានខិតខំអភិវឌ្ឍវិញ្ញាសានិងកីឡាទាំង៥ប្រភេទនេះ (កីឡាសម្រាប់ទាំងអស់គ្នា ដែលមានការពេញនិយមពី សាធារណជនទូទៅទាំងក្នុងនិងក្រៅសាលា)។ ទោះជាយ៉ាងណាក៏ដោយ វាត្រូវបានគេវាយតម្លៃថាសមត្ថភាពរបស់ស្ថាប័នមិនគ្រប់គ្រាន់ ក្នុងការបង្កើនទំហំរបស់ខ្លួន ដោយផ្អែកលើកំណែទម្រង់អប់រំកាយរបស់សាលា ដូច្នេះនៅឆ្នាំ២០០៣ វាត្រូវបានរៀបចំឡើងវិញ ដោយបំបែកនាយកដ្ឋាន អប់រំកាយ និងកីឡាសិស្ស-និស្សិតចេញពីនាយកដ្ឋានអប់រំកាយ និងកីឡា ហើយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាត្រូវបានបំបែកចេញពីមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា។ លោក ព្រំ ប៊ុណ្ណយី បានបន្តប្រឹក្សាជាមួយអង្គការបេះដូងមាស ហើយអនុស្សរណៈនៃការយោគយល់គ្នាត្រូវបានចុះហត្ថលេខានៅឆ្នាំ២០០៦។

គាត់បានធ្វើការជាមួយអង្គការបេះដូងមាសតាំងពីឆ្នាំ១៩៩៦មកហើយបានពិភាក្សាមិនត្រឹមតែទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្តប៉ុណ្ណោះទេ  ថែមទាំងពិភាក្សាថាតើអប់រំកាយនិងកីឡាអាចអភិវឌ្ឍបានយ៉ាងដូចម្តេច។ទោះបីជាយើងរៀបចំពិធីបុណ្យកីឡាដើម្បីអភិវឌ្ឍសមត្ថភាពរបស់  យុវជន និងគ្រូមួយឆ្នាំម្តង ក្នុងកំឡុងទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្តដើម្បីបង្ហាត់បង្រៀនដល់កុមារយ៉ាងណាក្តី   ក៏ពុំមានការផ្លាស់ប្តូរយូរអង្វែងពេញមួយឆ្នាំឡើយ។មានតែការផ្លាស់ប្តូរគ្រូដែលបង្រៀនថ្នាក់អប់រំកាយនៅសាលារៀនប៉ុណ្ណោះទើបអាចបង្រៀនអប់រំកាយប្រកបដោយប្រសិទ្ធភាពក្នុងថ្នាក់អប់រំកាយប្រចាំថ្ងៃបាន។ក្នុងការស្វែងរកស្ថាប័នសហការសម្រាប់គម្រោងជំនួយអប់រំកាយនៅតាមសាលាយើងបានធ្វើការពិភាក្សាម្តងហើយម្តងទៀតជាមួយស្ថាប័ននានានៅទូទាំងប្រទេសជប៉ុន។ ជាលទ្ធផល ទីបំផុតយើងទទួលបានជោគជ័យក្នុងការទទួលបានកិច្ចសហប្រតិបត្តិការពីJICAដែលទទួលខុសត្រូវចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន និងសាកលវិទ្យាល័យ Tsukuba ដែលទទួលខុសត្រូវលើអប់រំកាយ។

បន្ទាប់ពីការពិភាក្សាជាបន្តបន្ទាប់យើងបានសម្រេចថាចាប់ផ្តើមពីសាលាបឋមសិក្សា។នៅពេលដែលលោក ព្រំ ប៊ុណ្ណយី បានបញ្ជាក់ជាមួយគ្រូបង្រៀននៅតាមសាលា អំពីអ្វីដែលពួកគេកំពុងបង្រៀនគាត់បានរកឃើញថាពួកគេគ្រាន់តែផ្តល់ការបង្ហឹកសាមញ្ញប៉ុណ្ណោះ។ដោយគិតពីស្ថានភាពជាក់ស្តែងបែបនេះការពិភាក្សារវាងអង្គការបេះដូងមាសនិងនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតត្រូវបានពន្លឿនបន្ថែមទៀត។



រូបថតជាមួយមន្ត្រីពាក់ព័ន្ធនៃនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ក្នុងដំណាក់កាលដំបូងនៃគម្រោង

## ការស្នើសុំអង្គការបេះដូងមាស ដើម្បីសហការលើថ្នាក់អប់រំកាយបែបថ្មី

ក្នុងឆ្នាំ២០០២ ខណៈពេលប្រារព្ធព្រឹត្តិការណ៍លើកទី២ នៅខេត្តសៀមរាប លោក ព្រំ ប៊ុណ្ណយី ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត។ ដូច្នេះហើយ លោក ព្រំ ប៊ុណ្ណយី បានស្នើឱ្យអង្គការបេះដូងមាសសហការមិនត្រឹមតែជាមួយខេត្តសៀមរាបប៉ុណ្ណោះទេ ថែមទាំងជាមួយក្រសួងអប់រំទៀតផង។ វាត្រូវបានសម្រេចថាព្រឹត្តិការណ៍នេះនឹងធ្វើឡើងជាលក្ខណៈវិលជុំ ហើយបានពិចារណារៀបចំព្រឹត្តិការណ៍លើកទី៣ នៅពហុកីឡាដ្ឋានជាតិអូឡាំពិកក្នុងរាជធានីភ្នំពេញ ប៉ុន្តែជាក់ស្តែង ពហុកីឡាដ្ឋានជាតិអូឡាំពិក ត្រូវបានគ្រប់គ្រងដោយមន្ត្រីពាក់ព័ន្ធជាមួយរដ្ឋមន្ត្រីក្រសួងអប់រំនិងដោយសារតែការទទួលអនិច្ចកម្ម (ស្លាប់)ភ្លាមៗរបស់រដ្ឋមន្ត្រីក្រសួងអប់រំ ទីបំផុតមិនដឹងច្បាស់ថា តើអាចប្រើប្រាស់បានឬមិនបាននោះទេ។

ច្រកចូលពហុកីឡាដ្ឋានត្រូវបានបិទ ហើយការប្រារព្ធពិធីបុណ្យកីឡាបណ្តុះបណ្តាលយុវជននិងគ្រូបង្រៀនលើកទី៣ ស្ថិតក្នុងការសង្ស័យ។ ដោយសារព្រឹត្តិការណ៍នេះនឹងត្រូវប្រារព្ធឡើងដើម្បីរំលឹកខួបលើកទី៥០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា ដូច្នេះអ្នកជំនាញនិងអ្នកស្ម័គ្រចិត្តកីឡាមកពីប្រទេសជប៉ុនប្រមាណ១០០នាក់ និងកុមារសិស្សានុសិស្ស និង គ្រូបង្រៀនជាង១,៦០០នាក់ មកពីទូទាំងប្រទេសកម្ពុជាបានសម្រេចចិត្តចូលរួម។ យ៉ាងណាក៏ដោយ រហូតមកដល់២សប្តាហ៍ មុនព្រឹត្តិការណ៍នេះ ការអនុញ្ញាតឱ្យប្រើកីឡាដ្ឋានជាតិអូឡាំពិកដែលបានគ្រោងទុក មិនត្រូវបានផ្តល់ឱ្យឡើយ។ ជាចុងក្រោយ ដោយបានការខិតខំប្រឹងប្រែងរបស់ឯកអគ្គរដ្ឋទូតអូហ្គាវ៉ាហ្គូចារ៉ូ(នៅពេលនោះ)ដែលហៀបនឹងត្រលប់ទៅប្រទេសជប៉ុនវិញ ទើបយើងអាចប្រើប្រាស់បាន ហើយទីបំផុតព្រឹត្តិការណ៍នេះត្រូវបានប្រារព្ធឡើង។

## សមភាតីគីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត

បន្ទាប់មកដោយមានការស្នើសុំពី លោក ព្រំ ប៊ុណ្ណយី «ខ្ញុំចង់បណ្តុះបណ្តាលបុគ្គលិករដ្ឋាភិបាលបន្ថែមទៀតដែលពាក់ព័ន្ធនឹងការលើកកម្ពស់អប់រំកាយ និងកីឡា» នាយកយ៉ាម៉ាហ្គូជិបានទៅពិគ្រោះអំពីជំនួយបច្ចេកទេសជាមួយសាកលវិទ្យាល័យTsukuba ដែលធ្វើការស្រាវជ្រាវ និងអភិវឌ្ឍធនធានមនុស្សឈានមុខគេក្នុងប្រទេសជប៉ុនក្នុងវិស័យអប់រំកាយនិងកីឡា។នាយកយ៉ាម៉ាហ្គូជិបានទៅពិគ្រោះជាមួយសាស្ត្រាចារ្យនីស៊ីជីម៉ាតាកាហ៊ីកុ(នាពេលនោះ) នៃសាកលវិទ្យាល័យ Tsukuba ដែលបានពិគ្រោះជាមួយគាត់អំពីសកម្មភាពនៅទីម័រខាងកើត ហើយនៅទីបំផុតសាស្ត្រាចារ្យ តាកាហាស៊ី តាខេអូ ដែលពេលនោះជានាយករងសាកលវិទ្យាល័យTsukubaបានផ្តល់កិច្ចសហប្រតិបត្តិការជាការចូលរួមចំណែកសង្គមរបស់សាកលវិទ្យាល័យ។ ក្រោយមក សាស្ត្រាចារ្យ អូកាដិ យ៉ូស៊ីហ្សូរិ នៃសាកលវិទ្យាល័យTsukubaក៏បានមកសហការជាអ្នកដឹកនាំក្រុមអ្នកជំនាញផ្នែកអប់រំកាយ

របស់ប្រទេសជប៉ុនដែលចូលរួមក្នុងគម្រោងនេះហើយការរៀបចំសម្រាប់ជំនួយត្រូវបានត្រៀមរួចរាល់។

បន្ទាប់មក លោក យ៉ាម៉ាហ្គូជិ បានពិគ្រោះយោបល់ជាមួយការិយាល័យJICA CHUGOKU និង JICA ប្រចាំប្រទេសកម្ពុជា ដើម្បីអនុវត្តគម្រោងនេះជាកម្មវិធីភាពជាដៃគូរបស់JICA។ នៅពេលនោះ លោក ស៊ូជីណូ ហ៊ីរ៉ូស៊ី ដែលទទួលបន្ទុកខាងប្រទេសកម្ពុជានៅនាយកដ្ឋានអាស៊ីទី១ របស់JICA បានមានប្រសាសន៍ថា«គម្រោងនេះហាក់ដូចជាមានឧបសគ្គខ្ពស់។ ប៉ុន្តែ ៣ឆ្នាំក្រោយមក ខ្ញុំបានផ្លាស់ទៅ JICA CHUGOKU និងបានទទួលបន្ទុកគម្រោងរបស់អង្គការបេះដូងមាស ហើយមានអត្ថន័យសំខាន់ណាស់ដែលគម្រោងនេះត្រូវបានធ្វើឡើងស្របគ្នាដោយការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនៃការរៀបចំរដ្ឋបាល កណ្តាលនិងការអភិវឌ្ឍធនធានមនុស្សនៅកម្រិតមូលដ្ឋាន។ »(HG,២០១០)។ដោយពិចារណាលើមតិខាងលើ ខ្ញុំមានអារម្មណ៍ថា ការបង្កើតផែនការគម្រោង ខណៈពេលពិគ្រោះយោបល់ជាមួយ JICA និងធ្វើការសិក្សានៅនឹងកន្លែងក្នុងរយៈពេលមួយឆ្នាំ គឺជាដំណើរការដ៏សំខាន់បំផុត។

ការិយាល័យJICAប្រចាំប្រទេសកម្ពុជា ពីដំបូងមានការប្រុងប្រយ័ត្នចំពោះការអនុវត្តគម្រោងនេះ ព្រោះវាមិនមែនជាអាទិភាពខ្ពស់ក្នុងគោលនយោបាយរបស់ក្រសួងអប់រំ ជាវិស័យកីឡា និងអប់រំកាយ ហើយដោយសារការត្រៀមរៀបចំនៅក្នុងស្រុកមិនគ្រប់គ្រាន់។ ទោះជាយ៉ាងនេះក្តី លោកនាយក យ៉ាម៉ាហ្គូជិ បានប្រឹងប្រែងពន្យល់អំពីសារៈសំខាន់នៃការលើកកម្ពស់អប់រំកាយ នៅក្នុងសាលារៀន ដោយធ្វើការជាមួយលោក ព្រំ ប៊ុណ្ណយី ដើម្បីពន្យល់ពីស្ថានភាពនៅការិយាល័យ JICA ប្រចាំប្រទេសកម្ពុជា ខណៈពេលដែលកំពុងរៀបចំផែនការយ៉ាងប្រុងប្រយ័ត្នជាមួយមន្ត្រីមកពីក្រសួងអប់រំ ហើយជាលទ្ធផល ពួកគេក៏បានយល់។

លោកនាយក យ៉ាម៉ាហ្គូជិ មានប្រសាសន៍ថា គាត់បានទទួលការពន្យល់យ៉ាងយកចិត្តទុកដាក់ ពីការិយាល័យ JICA ប្រចាំប្រទេសកម្ពុជា អំពីរបៀបសរសេរម៉ាទ្រីកស៍រចនាគម្រោង (ប្លង់មេគម្រោង) និងពី JICA CHUGOKU អំពីគ្រោងការណ៍នៃគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសមូលដ្ឋានហើយមានដំណើរការបង្កើតគម្រោងដោយសហការជាមួយ JICA រហូតដល់គម្រោងត្រូវបានអនុម័តនៅទីបំផុតក្នុងឆ្នាំ២០០៥។

ក្នុងការអនុវត្តគម្រោងនេះជាជាងទស្សនៈនៃការបញ្ចូលការអប់រំមុខវិជ្ជាអប់រំកាយដែលថា «អប់រំកាយគឺចាំបាច់នៅក្នុងប្រទេសកម្ពុជា» ទៅក្នុងប្រព័ន្ធអប់រំថ្មីរបស់ប្រទេសកម្ពុជា ខ្ញុំគិតថាអាទិភាពត្រូវបានផ្តល់ទៅឱ្យទស្សនៈនៃការផ្លាស់ប្តូរការអប់រំមុខវិជ្ជាអប់រំកាយទាំងមូលដែលថា« តោះយើងផ្លាស់ប្តូរទៅជាមុខវិជ្ជាដែលកុមារកម្ពុជាទាំងអស់អាចរៀនការអប់រំមុខវិជ្ជាអប់រំកាយនៅក្នុងការអប់រំរបស់សាលាបានច្រើនជាងមុន»នៅពីលើម៉ោងអប់រំកាយដែលមានស្រាប់ហើយធ្វើឡើងរយៈពេល ២ម៉ោង ក្នុងមួយសប្តាហ៍។ នេះមានន័យថា គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជាធម្មតាត្រូវបានអនុវត្តលើមូលដ្ឋានគំរូក្នុងចំនួនកំណត់នៃតំបន់គោលដៅប៉ុន្តែនៅក្នុងគម្រោងនេះ ទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្ត បានវិវត្តទៅជាពិធីបុណ្យកីឡាបណ្តុះ បណ្តាល

យុវជននិងគ្រូបង្រៀន ដោយមានក្រសួងអប់រំ និងនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ដើរតួជាសមភាគីចម្បង ដូច្នេះអាចនិយាយបានថា នេះជាគម្រោងទាក់ទងនឹងគោលនយោបាយអប់រំកាយជាតិដែលផ្តល់អត្ថប្រយោជន៍ដល់កុមារទូទាំងប្រទេសកម្ពុជា។

## អត្ថបទទី ២៖ បិតានៃអប់រំកាយនៅប្រទេសកម្ពុជា

លោក ព្រំ ប៊ុណ្ណយី អាចត្រូវបានគេហៅថាជា «បិតាអប់រំកាយនៅប្រទេសកម្ពុជា»។ លោកជាប្រធាននាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ក្នុងអំឡុងគម្រោងជំនួយផ្នែកអប់រំ មុខវិជ្ជាអប់រំកាយនៅសាលាបឋមសិក្សា ដំបូងក្នុងឆ្នាំ ២០០៦ ហើយមុនពេលគម្រោងនេះចាប់ផ្ដើម លោកបានមកកាន់ការិយាល័យ JICA ប្រចាំប្រទេសកម្ពុជា ដើម្បីពន្យល់ពីមូលហេតុដែលការអភិវឌ្ឍ ផ្នែកអប់រំមុខវិជ្ជាអប់រំកាយនៅកម្ពុជាជាការចាំបាច់។ លោក ព្រំ ប៊ុណ្ណយី បានមានប្រសាសន៍ ដោយមោទនភាពថា លោកចង់ធ្វើឱ្យកំណែទម្រង់ការអប់រំមុខវិជ្ជាអប់រំកាយនៅប្រទេសកម្ពុជាទទួលជោគជ័យដូចការងារក្នុងជីវិតរបស់លោកព្រោះលោកគិតថាវានឹងជាគម្រោងដ៏អស្ចារ្យដែលនឹងបន្សល់ទុកនៅក្នុងប្រទេសកម្ពុជាទោះជាក្រោយពេលលោកទទួលមរណភាពក៏ដោយ។

ជាពិសេស ការបង្កើតគម្រោងដំបូងជាមួយលោកនាយក យ៉ាម៉ាហ្គូជិ ហាក់បីដូចជាចំណាយពេល ច្រើន ហើយគាត់បានពិភាក្សាជាមួយលោកនាយក យ៉ាម៉ាហ្គូជិ ហាក់ដូចជាឈ្លោះប្រកែកគ្នា ប៉ុន្តែគាត់ចងចាំដោយរីករាយអំពីការពិសាស្រា ការផ្សះផ្សាជាមួយគ្នា និងការពិភាក្សាយ៉ាងក្ដៅគគុកអំពី អប់រំកាយ។

ចាប់តាំងពីលទ្ធផលនៃគម្រោងបានចាប់ផ្ដើមបង្ហាញមក ការខិតខំប្រឹងប្រែងបែបនេះត្រូវបានកាត់បន្ថយ ប៉ុន្តែការផ្លាស់ប្ដូរអ្វីមួយដែលមិនផ្លាស់ទីទាល់តែសោះសូម្បីតែបន្តិចនៅពេលដំបូង វាទាមទារនូវការខិតខំប្រឹងប្រែងច្រើន ហើយលោក ព្រំ ប៊ុណ្ណយី និងលោកនាយក យ៉ាម៉ាហ្គូជិ បានចែករំលែកពេលវេលាទាំងនោះ។

នៅឆ្នាំ២០១២ នៅពេលដែលខ្ញុំចូលកាន់តំណែង លោក ព្រំ ប៊ុណ្ណយី បានបញ្ចប់តំណែងជាប្រធាននាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតហើយបានក្លាយជាទីប្រឹក្សាក្រសួងអប់រំនៅ ចំពេលដែលឯកឧត្ដមអ៊ុក សិទ្ធិជាតិ បានក្លាយជាអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡានៅឆ្នាំ២០១៣។ចាប់តាំងពីពេលនោះមកគាត់បានចូលរួមក្នុងពិធីបើកនិងបិទសិក្ខាសាលានិងបង្កើនការលើកទឹកចិត្តដល់អ្នកចូលរួម។លោកព្រំប៊ុណ្ណយីគឺជាបុគ្គលមួយរូបក្នុងចំណោមបុគ្គលមួយចំនួនតូចដែលបានដឹងថាតើគម្រោងជាមួយអង្គការបេះដូងមាសបានចាប់ផ្ដើមនៅពេលណា។ខ្ញុំក៏បានសម្ភាសគាត់ដែរពេលខ្ញុំសរសេរនិក្ខេបបទថ្នាក់អនុបណ្ឌិត។លោកបានប្រាប់ខ្ញុំថាបច្ចុប្បន្នរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការក្រសួងអប់រំក៏កាន់តែយល់ដឹងអំពីអប់រំកាយហើយពេលនេះក្រសួងអប់រំកំពុងជំរុញការដាក់បញ្ចូលនិងបង្រួបបង្រួមអប់រំកាយបែបថ្មីជាគោលនយោបាយតែមួយ ហើយប្រព័ន្ធអនុវត្តក៏មានការវិវត្តទៅតាមនោះដែរ ហើយថាគាត់ពិតជារីករាយណាស់ដែលបានឃើញការវិវត្តនេះ។

ដូចនេះហើយ លោក ព្រំ ប៊ុណ្ណយី បន្តជឿជាក់ថា ប្រទេសកម្ពុជានឹងមានការវិវត្តយ៉ាងខ្លាំង តាមរយៈអប់រំកាយ។ ខ្លួនខ្ញុំផ្ទាល់មានអារម្មណ៍រីករាយយ៉ាងខ្លាំងដែលអាចអនុវត្តគម្រោងជាមួយអ្នកដែលមានការជឿជាក់បែបនេះ។

## ផ្នែកទី២៖ អ្នកណាបង្រៀនអប់រំកាយនៅសាលារៀន
## នាយកដ្ឋានពាក់ព័ន្ធនឹងអប់រំកាយក្នុងក្រសួងអប់រំ

នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត គឺជានាយកដ្ឋានមួយដែលត្រូវបានបង្កើតឡើងនៅក្នុងក្រសួងអប់រំក្នុងឆ្នាំ២០០៣។មុនឆ្នាំ២០០៣នាយកដ្ឋានដែលអនុវត្តការងារដូចគ្នានេះត្រូវបានដាក់នៅក្នុងក្រសួងវប្បធម៌។

បន្ទាប់ពីគម្រោងនេះបានចាប់ផ្តើមនៅឆ្នាំ២០០៦ នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតនៅតែទទួលបន្ទុកលើអប់រំកាយហើយក៏បានគ្រប់គ្រងការប្រកួតកីឡានៅកម្រិតសាលារៀនផងដែរ។ បើនិយាយអំពីការប្រកួតកីឡា វាគឺជាព្រឹត្តិការណ៍ដ៏ស្រស់ស្អាត និងមើលទៅអស្ចារ្យណាស់ខាងផ្នែកទំនាក់ទំនងសាធារណៈ។ ម្យ៉ាងវិញទៀត ថ្នាក់អប់រំកាយគឺជាការប្រមូលផ្តុំនៃសកម្មភាពប្រចាំថ្ងៃ។ថ្នាក់អប់រំកាយមានសារៈសំខាន់សម្រាប់ការអប់រំរបស់កុមារប៉ុន្តែថ្នាក់អប់រំកាយមិនទាក់ទាញមនុស្សច្រើនទេនិងមិនមានភាពទាក់ទាញឡើយ។ជាងនេះទៅទៀតមន្ត្រីទទួលបន្ទុកមានការលើកទឹកចិត្តក្នុងការចូលរួមនិងគាំទ្រដល់ការគ្រប់គ្រងការប្រកួតកីឡាច្រើនជាងបង្រៀនអប់រំកាយដល់កុមារ។ តាមរយៈការបន្តគម្រោងនេះ ថវិកាមួយចំនួនត្រូវបានបង្កើតឡើងសម្រាប់ការលើកកម្ពស់អប់រំកាយ ហើយការងារទាក់ទងនឹងអប់រំកាយដូចជាសិក្ខាសាលា ការចុះពិនិត្យតាមដាន និងការបោះពុម្ពសៀវភៅគ្រូបានកើនឡើងជាលំដាប់។

គិតត្រឹមខែមករាឆ្នាំ២០២៣ ប្រទេសកម្ពុជាមាននាយកដ្ឋានចំនួនពីរទាក់ទងនឹងអប់រំកាយ។ «នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត» មានយុត្តាធិការលើអប់រំកាយនៅកម្រិតសាលា

រូបភាពទី ២ នាយកដ្ឋាននៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ទាក់ទងនឹងគម្រោង (គិតត្រឹមខែមករា ឆ្នាំ២០២១)

រដ្ឋមន្ត្រី — រដ្ឋលេខាធិការ — អនុរដ្ឋលេខាធិការ
- អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ — ៤ នាយកដ្ឋាន
- អគ្គនាយកដ្ឋានកីឡា — ៦ នាយកដ្ឋាន (នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត៖ DPESS វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា៖ NIPES និង៤នាយកដ្ឋានផ្សេងទៀត)
- អគ្គនាយកដ្ឋានយុវជន — ២ នាយកដ្ឋាន
- អគ្គនាយកដ្ឋានឧត្តមសិក្សា — ២ នាយកដ្ឋាន
- អគ្គនាយកដ្ឋានអប់រំ — ៨នាយកដ្ឋាន ១លេខាធិការដ្ឋាន(នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នាយកដ្ឋានចំនួន៦ផ្សេងទៀត និង១លេខាធិការដ្ឋាន)
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ — ៨ នាយកដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង — ១នាយកដ្ឋាន ១លេខាធិការដ្ឋាន
- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ
- មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តនីមួយៗ(POE) — ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ (DOE)

បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យជាក់ស្ដែង រីឯ «វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា (NIPES)» ធ្វើការបណ្ដុះបណ្ដាលគ្រូអប់រំកាយនិងស្រាវជ្រាវលើការអប់រំមុខវិជ្ជាអប់រំកាយ នៅកម្រិតអនុវិទ្យាល័យនិងវិទ្យាល័យ។នាយកដ្ឋានទាំងពីរស្ថិតនៅក្រោមយុត្តាធិការរបស់អគ្គនាយកដ្ឋានកីឡាក្នុងក្រសួងអប់រំហើយមុខវិជ្ជាទាំងអស់ក្រៅពីអប់រំកាយត្រូវបានដាក់នៅក្រោមអគ្គនាយកដ្ឋានអប់រំ (សូមមើលរូបភាពទី២)។ ខណៈមុខវិជ្ជាផ្សេងទៀតទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានអប់រំ មានតែមុខវិជ្ជាអប់រំកាយប៉ុណ្ណោះស្ថិតនៅក្រោមអគ្គនាយកដ្ឋានកីឡា

នៅក្រោមប្រព័ន្ធបែបនេះ បញ្ហាគឺ«ការចែករំលែកព័ត៌មាន»។ អគ្គនាយកដ្ឋានអប់រំមិនបានបញ្ជាក់ជាមួយអគ្គនាយកដ្ឋានកីឡាម្ដងមួយៗពេលសម្រេចចិត្តលើគោលនយោបាយអប់រំទេហើយអគ្គនាយកដ្ឋានកីឡាក៏ពិបាកប្រមូលព័ត៌មានអំពីគោលនយោបាយអប់រំពីអគ្គនាយកដ្ឋានអប់រំផងដែរ។

## ការបែងចែក «អប់រំកាយ» និង «កីឡា» មានការវិវត្ត

នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតបានធ្វើការជាមួយអង្គការបេះដូងមាសជាសមភាគីតាំងពីឆ្នាំ២០០៦ហើយបានទទួលខុសត្រូវក្នុងការបង្កើតកម្មវិធីសិក្សានិងផ្សព្វផ្សាយអប់រំកាយ។ នៅសាលាបឋមសិក្សា ក៏ដូចសាលានៅប្រទេសជប៉ុនដែរ គ្រូបង្រៀនម្នាក់បង្រៀនគ្រប់មុខវិជ្ជា ដូច្នេះ នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតត្រូវទទួលខុសត្រូវក្នុងការផ្ដល់ការណែនាំ។ ក្រៅពីការលើកកម្ពស់អប់រំកាយ ក៏មានការប្រកួតកីឡាជាដើមទាក់ទងនឹងសាលារៀនផងដែរ។

ចាប់ពីឆ្នាំ២០២២មក «នាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា» ថ្មីមួយត្រូវបានបង្កើតឡើងនៅក្នុងអគ្គនាយកដ្ឋានកីឡា ដែលទទួលបន្ទុកគ្រប់គ្រងការប្រកួតកីឡា ហើយនាយកដ្ឋាន អប់រំកាយ និងកីឡាសិស្ស - និស្សិតនឹងពង្រឹងចរិតលក្ខណៈរបស់ខ្លួនជានាយកដ្ឋានដោយទទួលខុសត្រូវចម្បងសម្រាប់ការអភិវឌ្ឍន៍អប់រំកាយ។ តាមរយៈកំណែទម្រង់ស្ថាប័នទាំងនេះ និយមន័យនៃ «អប់រំកាយ» និង «កីឡា» ត្រូវបានបែងចែកនៅពេលដែលគម្រោងរីកចម្រើន ហើយអាចបញ្ជាក់បានថាតួនាទីនៃការអប់រំមុខវិជ្ជាអប់រំកាយជាមុខវិជ្ជានៅក្នុងសាលារៀន (ក្នុងម៉ោងសិក្សា) និងការទទួលខុសត្រូវសម្រាប់ការប្រកួតកីឡាជាដើមនៅក្រៅមុខវិជ្ជានៅក្នុងសាលារៀន (ក្រៅម៉ោងសិក្សា) ត្រូវបានបែងចែកយ៉ាងច្បាស់ជាប្រព័ន្ធ។

នៅតាមសាលាបឋមសិក្សានាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតទទួលបន្ទុកទាំងការលើកកម្ពស់អប់រំកាយនៅតាមសាលារៀននិងការបណ្ដុះបណ្ដាលគ្រូបង្រៀនចំណែកនៅអនុវិទ្យាល័យ និងវិទ្យាល័យ នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតទទួលបន្ទុកជាចម្បងក្នុងការលើកកម្ពស់នៅតាមសាលារៀនដែរចំណែកការបណ្ដុះបណ្ដាលគ្រូអប់រំកាយជាបន្ទុករបស់វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា។វិទ្យាស្ថានជាតិអប់រំកាយនិងកីឡាគឺជាគ្រឹះស្ថានឧត្តមសិក្សាតែមួយគត់របស់ប្រទេសកម្ពុជា សម្រាប់អប់រំគ្រូអប់រំកាយ និងកីឡា។

កាលពីមុន វិទ្យាស្ថានជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូអប់រំកាយសម្រាប់អនុវិទ្យាល័យ និងវិទ្យាល័យ រយៈពេល២ឆ្នាំសិក្សា ហើយគរុសិស្សដែលបានបញ្ចប់ការសិក្សាបានក្លាយជាគ្រូអប់រំកាយ ប៉ុន្តែការពិតពួកគេក៏មានបង្រៀនកីឡាផងដែរ។ ដោយមើលឃើញពីកំណែទម្រង់វិស័យអប់រំដែលគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតអនុវិទ្យាល័យនិងវិទ្យាល័យនៅកម្ពុជានឹងផ្លាស់ប្តូរពីប្រព័ន្ធ២ឆ្នាំសិក្សាទៅប្រព័ន្ធ៤ឆ្នាំសិក្សា ចាប់ពីឆ្នាំ២០១៩តទៅ តាមរយៈគម្រោងជំនួយឥតសំណងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនជាមួយអង្គការបេះដូងមាសកិច្ចសហប្រតិបត្តិការដើម្បីផ្តល់លទ្ធភាពឱ្យវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាផ្តល់នូវកម្មវិធីរយៈពេល៤ឆ្នាំសិក្សាក៏បានចាប់ផ្តើម។ខ្ញុំសូមពន្យល់លម្អិតអំពីគម្រោងនេះនៅពេលក្រោយ។វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា រួមមានការិយាល័យរដ្ឋបាល ការិយាល័យផែនការ ការិយាល័យសមោធានឯកសារកីឡា មជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រអប់រំកាយ និងកីឡា និងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀនអប់រំកាយនិងកីឡាដែលជំរុញការ បណ្តុះបណ្តាលគ្រូអប់រំកាយកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ។

## ផ្នែកទី ៣៖ តើអប់រំកាយជាការអប់រំ ឬកីឡា? អប់រំកាយជាមុខវិជ្ជានៅក្នុងសាលារៀន

យើងអាចនិយាយបានថា នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ចំណុះអគ្គនាយកដ្ឋានកីឡា នៃក្រសួងអប់រំ មានតួនាទីនៅក្នុងក្រសួងអប់រំ ជានាយកដ្ឋានដែលជំរុញសកម្មភាពកីឡាទូទៅនៅតាមសាលារៀន ជាជាងធ្វើការអប់រំកុមារ ដោយចាត់ទុកមុខវិជ្ជា «អប់រំកាយ» ជាមុខវិជ្ជាមួយនៅក្នុងសាលារៀន។ គោលបំណងនៃអប់រំកាយ គឺដើម្បីលើកទឹកចិត្តកុមារឱ្យធ្វើលំហាត់ប្រាណនៅតាមសាលារៀន ជាជាងទទួលបានចំណេះដឹងនិងសមត្ថភាពដូចជាភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ដូចដែលលោក ព្រំ ប៊ុណ្ណយី បានបង្ហាញឈ្មោះរបស់នាយកដ្ឋាន ដូចជា «នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត» និង «វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា» «អប់រំកាយ» និង «កីឡា» ត្រូវបានសរសេររួមគ្នាហើយ និយមន័យនៃអ្វីជាអប់រំកាយ អ្វីជាកីឡានោះ គឺមិនត្រូវបានពិភាក្សាច្រើននោះទេ ប៉ុន្តែនៅក្នុងសង្គម «អប់រំកាយ និងកីឡា» ត្រូវបានសរសេររួមគ្នា ហើយលោក ព្រំ ប៊ុណ្ណយី ក៏បានទទួលស្គាល់ថាមិនមានការបែងចែករវាង អប់រំកាយ និងកីឡានោះទេ។

ផ្ទុយទៅវិញតាមរយៈលទ្ធផលនៃគម្រោងនេះវាត្រូវបានគេទទួលស្គាល់នៅក្នុងប្រទេសកម្ពុជាថា «អប់រំកាយ» = មុខវិជ្ជានៃការអប់រំនៅក្នុងសាលារៀន ដែលរៀនអំពី «ចំណេះដឹងជំនាញនិងឥរិយាបថ»ដូចជាតម្រូវការសម្រាប់ការអភិវឌ្ឍនិងបណ្តុះបណ្តាលរាងកាយនិងផ្លូវចិត្តពេញមួយជីវិត ការសហការជាក្រុម ការគោរពច្បាប់ និងការគោរពដល់អ្នកដទៃ។

ម៉្យាងវិញទៀត«កីឡា»=ព្រឹត្តិការណ៍ប្រកួតប្រជែងកីឡាប្រកួតប្រជែងនិងការប្រកួត

ប្រជែងដើម្បីឈ្នះចាញ់ ឬការកម្សាន្ត ដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយជាទូទៅ ដូចនេះ អត្ថន័យ និងភាពខុសគ្នានៃពាក្យ «អប់រំកាយ» និង «កីឡា» បានលេចឡើងកាន់តែច្បាស់។

## ការពិតគឺលំហាត់ប្រាណបែបខ្មែរ

ម៉្យាងវិញទៀតដោយសារអប់រំកាយដែលធ្លាប់អនុវត្តរហូតមកដល់បច្ចុប្បន្នភាគច្រើន គឺលំហាត់ប្រាណបែបខ្មែរ ដែលគ្រាន់តែធ្វើចលនារាងកាយដោយមិនប្រើឧបករណ៍អ្វី ដែលអាច និយាយបានថាការយល់ដឹងអំពីអប់រំកាយមានកម្រិតទាបជាងមុខវិជ្ជាផ្សេងៗ។ទោះបីជាយើងអាច បង្កើតកម្មវិធីសិក្សា និងសៀវភៅគ្រូដោយសហការជាមួយនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតក៏ដោយក៏គ្រូបង្រៀននៅសាលាបឋមសិក្សាប្រមាណ៧,០០០សាលាទូទាំងប្រទេសនឹង មិនអាចផ្លាស់ប្តូរការគិតរបស់ពួកគេអំពីអប់រំកាយក្នុងមួយប៉ប្រិចភ្នែកបានដែរ។គ្រូបង្រៀនបច្ចុប្បន្ន ត្រូវតែសិក្សាអំពីកម្មវិធីសិក្សានិងពិតជាអាចបង្រៀនមុខវិជ្ជាអប់រំកាយបាន។ថ្នាក់អប់រំកាយដែល បានអនុវត្តរហូតមកដល់បច្ចុប្បន្នគឺជាការបង្រៀនអំពីកីឡារួមទាំងការដែលថាវាត្រូវបានធ្វើឡើង នៅក្នុងម៉ោងសិក្សាដើម្បីហ្វឹកហាត់សម្រាប់ការប្រកួតកីឡាជាដើមដូចនេះវាពិបាកក្នុងការផ្លាស់ប្តូរ ការយល់ឃើញរបស់គ្រូអប់រំកាយដែលថា «អប់រំកាយ» = «ពេលវេលាដើម្បីពង្រឹងជំនាញកីឡា» និង «ពេលវេលាសម្រាប់ឱ្យកុមារធ្វើលំហាត់ប្រាណ»។

នៅពេលដែលអប់រំកាយត្រូវបានចាត់ទុកថាជាមុខវិជ្ជាមួយ សិស្សត្រូវបានរំពឹងថានឹង ទទួលបាន «ចំណេះដឹងជំនាញនិងឥរិយាបថ» នៅក្នុងអប់រំកាយដូចដែលមានចែងក្នុងក្របខណ្ឌ កម្មវិធីសិក្សា។នៅក្នុងក្របខណ្ឌកម្មវិធីសិក្សានេះបានពន្យល់ថាអប់រំកាយនិងកីឡាគឺជាមុខវិជ្ជា មួយដែលផ្តល់ការអភិវឌ្ឍផ្លូវចិត្តគំនិតអាកប្បកិរិយាចំណេះដឹងក្នុងការដោះស្រាយជំងឺផ្លូវកាយនិង ផ្លូវចិត្តហើយធ្វើឱ្យសិស្សមានការជឿជាក់លើខ្លួនឯងតាមរយៈសកម្មភាពរាងកាយព្រមទាំងជួយ ជំរុញដល់ការសិក្សាមុខវិជ្ជាផ្សេងៗទៀត (MoEYS, ២០១៥, ទំ. ៧)។ តាមន័យនេះ យើងអាច និយាយបានថាគម្រោងជាមួយអង្គការបេះដូងមាសដែលផ្តល់គុណតម្លៃអប់រំដល់អប់រំកាយគឺជា គម្រោងដ៏មាន ប្រសិទ្ធភាព ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ។

ប៉ុន្តែទោះបីជាអប់រំកាយត្រូវបានទទួលស្គាល់ជាគោលគំនិតថាជាមុខវិជ្ជាមួយនៅក្នុង ការអប់រំនៅក្នុងសាលារៀនក៏ដោយ ប្រសិនបើអប់រំកាយដែលបង្រៀននៅក្នុងសាលារៀន ជាក់ស្តែង ត្រូវបានកំណត់ដោយខ្លឹមសារសាមញ្ញដូចជា លំហាត់ប្រាណបែបខ្មែរ និងបាល់ទាត់ នោះគោលនយោបាយអប់រំនឹងបាត់បង់អត្ថន័យរបស់វា។ គោលបំណងនៃកិច្ចសហការរវាង ក្រសួងអប់រំ និងអង្គការបេះដូងមាស គឺដើម្បីបង្កើតភាពស៊ីសង្វាក់គ្នារវាងគោលនយោបាយនេះ និងការអនុវត្តនៅក្នុងសាលារៀនជាក់ស្តែង។

## ផ្នែកទី ៤៖ អ្វីទៅជាថ្នាក់អប់រំកាយបែបថ្មី
## ការចាប់ផ្តើមចំពេលងឿងឆ្ងល់ និងព្រួយបារម្ភ

អង្គការបេះដូងមាសបានចាប់ផ្តើមបង្កើតកម្មវិធីសិក្សានិងសៀវភៅគ្រូក្នុងឆ្នាំ២០០៦ ដោយសហការជាមួយក្រសួងអប់រំ។នៅពេលនោះខ្ញុំឆ្ងល់ថាតើគ្រូបង្រៀនដែលត្រូវបង្រៀនថ្នាក់អប់រំកាយនៅក្នុងសាលាដែលខុសពីអ្វីពីពេលកន្លងមកមានអារម្មណ៍យ៉ាងណាចំពោះវិធីសាស្ត្រអប់រំកាយបែបថ្មីនេះ?

ថ្វីត្បិតតែគ្រូបង្រៀននៅសាលាបឋមសិក្សាបច្ចុប្បន្នស្គាល់ពីការអប់រំលំហាត់ប្រាណក៏ដោយក៏ពួកគេមិនដែលចូលរៀនថ្នាក់អប់រំកាយហើយក៏មិនដែលបានរៀនពីវិធីសាស្ត្របង្រៀននៅសាលាគរុកោសល្យដែរ។ ភ្លាមៗនោះ គ្រូបង្រៀនត្រូវបានបង្ខំឱ្យធ្វើការសម្រេចចិត្តដ៏លំបាកមួយ  នៅពេលដែលពួកគេត្រូវបានប្រឈមមុខនឹងការបង្រៀនលំហាត់ផ្សេងៗដល់សិស្សដែលកំពុងរត់លេងក្នុងទីធ្លាសាលារៀន ដើម្បីស្វែងរកប្រសិទ្ធភាពអប់រំ។

នៅពេលដែលអប់រំកាយបែបថ្មីត្រូវបានដាក់បញ្ចូលជាលើកដំបូងគ្រូបង្រៀននៅតាមសាលាបឋមសិក្សាមានការងឿងឆ្ងល់ចំពោះចំនួនកើនឡើងនៃអ្វីដែលពួកគេត្រូវរៀននិងអ្វីដែលត្រូវធ្វើ។គ្រូបង្រៀនខ្លះមានការព្រួយបារម្ភដោយសារតែពួកគេត្រូវបានបង្ខំឱ្យមានការដាក់បញ្ចូលអប់រំកាយបែបថ្មីទាំងមិនដឹងមូលហេតុ ថាហេតុអ្វីបានជាត្រូវដាក់បញ្ចូលភ្លាមៗបែបនេះ។

លោកគ្រូ សាយ មិត្តសារ៉ាយ នៅសាលាបឋមសិក្សាត្រពាំងរុន ក្នុងខេត្តស្វាយរៀងមានប្រសាសន៍ថា «មុនពេលអប់រំកាយបែបថ្មីត្រូវបានដាក់បញ្ចូល ខ្ញុំមិនយល់ពីគោលបំណងនៃអប់រំកាយទេ។ ខ្ញុំបានគិតថា ថ្នាក់អប់រំកាយគឺគ្រាន់តែឲ្យកុមារធ្វើចលនារាងកាយប៉ុណ្ណោះ។ ការបញ្ចូលអប់រំកាយបែបថ្មីនៅសាលាមិនពិបាកដូចដែលខ្ញុំបានគិតនោះទេ។មូលហេតុចម្បងនោះគឺថាគណៈគ្រប់គ្រងសាលាបានជួយជម្រុញនិងលើកទឹកចិត្តខ្ញុំ។ទោះជាយ៉ាងនេះក្តីគ្រូខ្លះទៀតមិនមានការលើកទឹកចិត្តទេហើយពួកគេមិនចង់រៀនអ្វីថ្មីទេ» គាត់ពន្យល់ថាការបញ្ចូលអប់រំកាយបែបថ្មីគឺពិបាកប្រសិនបើគណៈគ្រប់គ្រងសាលាមិនមានឆន្ទៈក្នុងការលើកកម្ពស់អប់រំកាយឬប្រសិនបើមានគ្រូបង្រៀននៅជុំវិញនោះមិនសូវមានចំណាប់។

ម៉្យាងវិញទៀត លោកគ្រូ ចន ចេក ដែលជាបណ្ណារក្ស និងជាប្រធានផ្នែកអប់រំកាយនិងកីឡាក្នុងខេត្តដូចគ្នានេះបានមានប្រសាសន៍ថា «អប់រំកាយកាលពីមុនមិនមានវត្ថុបំណងច្បាស់លាស់ទេហើយសាលារៀនមានថ្នាក់អប់រំកាយរយៈពេល២ម៉ោងក្នុងមួយសប្តាហ៍នៅថ្ងៃចន្ទនិងថ្ងៃសុក្រ។  ការបញ្ចូលអប់រំកាយបែបថ្មីដោយមានការចូលរួមពីគ្រូបង្រៀនវ័យចំណាស់ៗគឺពិបាកណាស់។ពួកគាត់ពិបាកក្នុងការធ្វើចលនារាងកាយដោយសារវ័យរបស់ពួកគាត់»។ទោះបីជាវត្ថុបំណងអប់រំកាយមានភាពច្បាស់លាស់ហើយគ្រូបង្រៀនអាចយល់បាននៅពេលបានស្តាប់ការពន្យល់ក៏ដោយ វានៅតែពិបាកក្នុងការសហការជាមួយគ្រូដទៃដែលមិនបានទទួលការពន្យល់

ឬ ក៏ជាមួយគ្រូចាស់ៗដែលមិនពូកែក្នុងការធ្វើចលនារាងកាយ។

អ្នកគ្រូ អួន សុថារី នាយិការងសាលាបឋមសិក្សាព្រះសីហនុក្នុងខេត្តដូចគ្នានេះ បានចូលរួមសិក្ខាសាលាផ្សេងៗក្នុងនាមជាគ្រូបង្រៀននៅឆ្នាំ២០១១ហើយក្រោយមកក៏បានក្លាយជានាយិការង។ អ្នកគ្រូ អួន សុថារី មានប្រសាសន៍ថា «ក្នុងអប់រំកាយបែបចាស់ គឺគ្រាន់តែឱ្យសិស្សធ្វើចលនាដៃនិងជើងប៉ុណ្ណោះ មិនមានការកំណត់វត្ថុបំណងថាត្រូវសម្រេចបានអ្វីមួយនោះទេបន្ទាប់ពីការរៀននៅក្នុងថ្នាក់៤០នាទី។ អប់រំកាយបែបថ្មីមានការកំណត់វត្ថុបំណងសម្រាប់មេរៀននីមួយៗ ដោយមានគោលដៅច្បាស់លាស់ក្នុងការសម្រេចបាននូវវត្ថុបំណងចំនួន៤គឺ ឥរិយាបថ ចំណេះដឹង ជំនាញ និងសហការ។ កុមារអាចបញ្ចេញយោបល់គ្នាទៅវិញទៅមកក្នុងពេលរៀន ហើយពួកគេម្នាក់ៗមានតួនាទីផ្សេងគ្នាក្នុងការជួយដល់ថ្នាក់រៀនដែលខុសគ្នាខ្លាំងពីអប់រំកាយបែបចាស់»។ ខ្ញុំមានអារម្មណ៍ថាអប់រំកាយបែបថ្មីនេះអាចជំរុញភាពវិជ្ជមាន និងការសហការរបស់កុមារ។

ខ្ញុំបានសម្ភាសគ្រូៗបន្ទាប់ពីបានចូលរួមក្នុងសិក្ខាសាលា និងការតាមដានអំពីការដាក់បញ្ចូលអប់រំកាយបែបថ្មីហើយគ្រូម្នាក់ៗគិតផ្ទាល់ខ្លួនថាការដាក់បញ្ចូលរអប់រំកាយបែបថ្មីមិនពិបាកនោះទេ។ ប៉ុន្តែ ពួកគាត់ហាក់ដូចជាមានអារម្មណ៍ថាពិបាកក្នុងការបញ្ចូលអប់រំកាយបែបថ្មី ដោយសហការជាមួយគ្រូ ឬជាមួយគណៈគ្រប់គ្រងសាលាដទៃផ្សេងទៀត។

## នៅអនុវិទ្យាល័យ លទ្ធផលគឺស្ទើរតែដូចគ្នា

នៅពេលដែលគម្រោងអនុវិទ្យាល័យបានចាប់ផ្តើមនៅឆ្នាំ២០១៥ការស្ទង់មតិមួយត្រូវបានធ្វើឡើងនៅក្នុងខេត្តប៉ៃលិន និងខេត្តកំពង់ចាម។ ទាក់ទងនឹងកម្រិតអប់រំរបស់គ្រូអប់រំកាយជាងពាក់កណ្តាលនៃចំនួនគ្រូបង្រៀន៣២នាក់ដែលបានចូលរួមការស្ទង់មតិនោះ ពួកគាត់មានត្រឹមសញ្ញាបត្រមធ្យមសិក្សាបឋមភូមិឬមធ្យមសិក្សាទុតិយភូមិប៉ុណ្ណោះហើយមានតែនិស្សិតបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាប៉ុណ្ណោះដែលមានចំណេះដឹងនិងជំនាញផ្នែកអប់រំកាយ។ យោងតាមប្រព័ន្ធអប់រំ ថ្នាក់អប់រំកាយត្រូវបង្រៀន ២ម៉ោងក្នុងមួយសប្តាហ៍ ប៉ុន្តែក្នុងចំណោមគ្រូទាំង៣២នាក់មាន៩នាក់បានឆ្លើយថាគាត់បង្រៀនថ្នាក់អប់រំកាយតែ១ម៉ោងប៉ុណ្ណោះក្នុងមួយសប្តាហ៍ ហើយគ្រូចំនួន២៥នាក់ផ្សេងទៀត ឆ្លើយថាខ្លឹមសារមេរៀនមាន តម្រង់ជួរ ដើរ និងលំហាត់ប្រាណបែបខ្មែរ។

នៅពេលយើងពន្យល់ពីអប់រំកាយបែបថ្មីគ្រូអប់រំកាយចំនួន២៧នាក់ក្នុងចំណោម៣២នាក់បានបង្ហាញពីចំណាប់អារម្មណ៍ដោយបញ្ជាក់ថាគុណតម្លៃនៃអប់រំកាយបែបថ្មីអាចយល់បានប្រសិនបើមានការពន្យល់។ បន្ទាប់មកទោះបីជាលទ្ធភាពនៃការបញ្ចូលអប់រំកាយបែបថ្មីកើនឡើងក្រោយពីយើងបានពន្យល់នៅក្នុងសិក្ខាសាលា និងបានយល់ដោយគ្រូក៏ដោយ ក៏កត្តាខាងក្រៅដូចជា៖ ការយល់ដឹងពីគណៈគ្រប់គ្រងសាលានិងការសហការជាមួយគ្រូផ្សេងទៀតបង្ហាញថាការលើកកម្ពស់អប់រំកាយបែបថ្មីនៅតែមិនអាចខ្វះបានដែរ។

ដូចនេះហើយ ថ្វីត្បិតតែមានការចាប់អារម្មណ៍លើអប់រំកាយបែបថ្មី និងអាចយល់ពីគុណសម្បត្តិនៃអប់រំកាយបែបថ្មីបើប្រៀបធៀបនឹងអប់រំកាយចាស់ក៏ដោយក៏វាពិបាកក្នុងការបញ្ចូលអប់រំកាយបែបថ្មី ព្រោះគ្មានឱកាសនេះ (សិក្ខាសាលា។ល។) ហើយនេះគឺជាស្ថានភាពនៅក្នុងសាលារៀនភាគច្រើន។ទោះបីជានៅក្នុងគម្រោងនិងក្រសួងអប់រំបានបង្កើតឱកាសបែបនេះដោយថវិកាផ្ទាល់ខ្លួនក៏ដោយ ក៏វាជាសកម្មភាពដែលត្រូវការពេលវេលា ធនធានមនុស្ស និងថវិកា ដើម្បីផ្សព្វផ្សាយនិងតាមដានវិធីសាស្ត្រនៃការបង្រៀនថ្នាក់អប់រំកាយបែបថ្មីទៅដល់សាលាបឋមសិក្សាប្រមាណ៧,០០០ អនុវិទ្យាល័យប្រមាណ១,៧០០ និងវិទ្យាល័យប្រមាណ៦០០ នៅទូទាំងប្រទេសហើយគម្រោងនេះទាមទារនូវការអនុវត្តសកម្មភាពទាំងនេះប្រកបដោយប្រសិទ្ធភាពនិងជាប្រព័ន្ធ។

# ជំពូកទី ២

## ចាប់ផ្ដើមពីចំណុចសូន្យ

## ផ្នែកទី ១៖ ការបង្កើតកម្មវិធីសិក្សា
## សំណើពីនាយកដ្ឋានអប់រំកាយ និងកីឡា សិស្ស-និស្សិត

នៅពេលបង្កើតកម្មវិធីសិក្សាសម្រាប់សាលាបឋមសិក្សា រឿងដំបូងដែលយើងត្រូវពិចារណាគឺ«តើមុខវិជ្ជាអប់រំកាយមានមុខងារបែបណានៅក្នុងច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា?»។ជាការពិតណាស់យើងត្រូវគិតជាមុនអំពីកុមារដែលនឹងរៀនមុខវិជ្ជានេះជាក់ស្តែងប៉ុន្តែប្រសិនបើច្បាប់និងបទប្បញ្ញត្តិមិនធានាការអនុវត្តថ្នាក់អប់រំកាយ និងសិទ្ធិកីឡាដល់ប្រជាពលរដ្ឋទេនោះ យើងត្រូវចាប់ផ្តើមដោយការកែសម្រួលច្បាប់។

នៅកំពូលនៃច្បាប់គឺជារដ្ឋធម្មនុញ្ញ។ មាត្រា ៦៥ នៃជំពូកទី ៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា «អប់រំ វប្បធម៌ និងសង្គមកិច្ច» ចែងថា «រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំ កាយនិងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប» (ព្រះរាជាណាចក្រកម្ពុជា, ១៩៩៩)។លើសពីនេះ ក្របខណ្ឌកម្មវិធីសិក្សាដែលបានបង្កើតឡើងក្នុងឆ្នាំ២០១៥ (MoEYS, ២០១៥, ទំ. ១១) ធានាបាននូវថ្នាក់អប់រំកាយ ២ម៉ោងក្នុងមួយសប្តាហ៍។ អ្វីដែលខុសពីប្រទេសជប៉ុនគឺ ថ្នាក់អប់រំសុខភាពត្រូវបានកំណត់ ១ម៉ោងក្នុងមួយសប្តាហ៍ មិនហៅថាមុខវិជ្ជាអប់រំកាយនិងសុខភាពទេ ប៉ុន្តែជាមុខវិជ្ជាឯករាជ្យមួយ ដែលហៅថាអប់រំកាយ។

តារាងទី ៣៖ របាយមុខវិជ្ជានិងម៉ោងសិក្សា (ថ្នាក់ទី១ដល់ថ្នាក់ទី៦នៃសាលាបឋមសិក្សា)

| ល.រ. | មុខវិជ្ជា | ថ្នាក់ | | | | | |
|---|---|---|---|---|---|---|---|
| | | ថ្នាក់ទី ១ | ថ្នាក់ទី ២ | ថ្នាក់ទី ៣ | ថ្នាក់ទី ៤ | ថ្នាក់ទី ៥ | ថ្នាក់ទី ៦ |
| ១. | ភាសាខ្មែរ | ១១ | ១១ | ១១ | ៩ | ៩ | ៩ |
| ២. | គណិតវិទ្យា | ៧ | ៧ | ៧ | ៦ | ៦ | ៦ |
| ៣. | វិទ្យាសាស្ត្រ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| ៤. | កុំព្យូទ័រ | ០ | ០ | ០ | ១ | ១ | ១ |
| ៥. | សិក្សាសង្គម | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| ៦. | អប់រំសិល្បៈ | ១ | ១ | ១ | ១ | ១ | ១ |
| ៧. | អប់រំកាយនិងកីឡា | ២ | ២ | ២ | ២ | ២ | ២ |
| ៨. | អប់រំសុខភាព | ១ | ១ | ១ | ១ | ១ | ១ |
| ៩. | ភាសាបរទេស | ២ | ២ | ២ | ២ | ២ | ២ |
| ១០. | បំណិនជីវិតតាមមូលដ្ឋាន | ០ | ០ | ០ | ២ | ២ | ២ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |

សម្គាល់៖៦ថ្ងៃក្នុងមួយសប្តាហ៍៥ម៉ោងសិក្សាក្នុងមួយថ្ងៃនិង១ម៉ោងសិក្សាមានរយៈពេល៤០នាទី

មុនឆ្នាំ ២០១៥ ថ្នាក់អប់រំកាយក៏មាន ២ម៉ោងក្នុងមួយសប្តាហ៍ផងដែរ ហើយក្នុងករណីសាលាបឋមសិក្សា ចាំបាច់ត្រូវពិចារណាក្នុងក្របខណ្ឌកម្មវិធីសិក្សាអំពីរបៀបកែលម្អថ្នាក់រៀនដែលក្នុង១ម៉ោងសិក្សាមាន៤០នាទី និង ៣៨ សប្តាហ៍ក្នុងមួយឆ្នាំ (បច្ចុប្បន្ន ៣៥ សប្តាហ៍)។ ដោយសារថ្នាក់អប់រំកាយពីដើមមកភាគច្រើនជាលំហាត់ប្រាណបែបខ្មែរ ដូចនេះគម្រោងគឺត្រូវចាប់ផ្តើមពីសូន្យ។

នៅពេលដែលកម្មវិធីសិក្សាដំបូងត្រូវបានអនុម័តនៅឆ្នាំ២០០៧ សាស្ត្រាចារ្យ អូកាជិ យ៉ូស៊ីណូរិ នៃសាកលវិទ្យាល័យ Tsukuba នៅពេលនោះ ដែលត្រូវបានបញ្ជូនមកប្រទេសកម្ពុជាក្នុងនាមជាអ្នកជំនាញបាននិយាយថាហេតុផលនៃការដាក់បញ្ចូលអត្តពលកម្មកាយសម្ព័ន្ធអប់រំកាយជាមួយចង្វាក់ភ្លេង បាល់ទាត់ បាល់បោះ បាល់ទះ និងតេស្តកាយសម្បទា ប្រភេទទាំងនោះគឺជាសំណើរបស់នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត។ លោកផ្ទាល់បានងឿងឆ្ងល់ថា តើចាំបាច់ត្រូវមានល្បែងបាល់ ២ គឺបាល់ទាត់និងបាល់បោះឬទេ ឬមួយថាតើវាប្រសើរជាងក្នុងការផ្តោតលើកីឡា១ប្រភេទហើយឱ្យថ្នាក់មានរយៈពេលយូរជាងនេះ។នាយក យ៉ាម៉ាហ្គុជិដែលជាអ្នកគ្រប់គ្រងគម្រោងបានចងក្រងខ្លឹមសារទាំងនេះ ដែលនាំឱ្យមានមុខវិជ្ជារងចំនួន ៦ ប្រភេទ នាពេលបច្ចុប្បន្នបូកនឹងតេស្តកាយសម្បទាផងដែរ។

## ការយកគំរូតាមកម្មវិធីសិក្សារបស់ប្រទេសជប៉ុន

ក្នុងអំឡុងពេលដំណើរការជ្រើសរើសប្រភេទមុខវិជ្ជារងនេះការពិភាក្សាបានកើតឡើងនៅក្នុងនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត រួមទាំងការពិភាក្សាលើការបញ្ចូលមុខវិជ្ជារងហែលទឹក និងអប់រំសុខភាពដោយផ្អែកលើការចង់បានរបស់រដ្ឋលេខាធិការ។ ជាពិសេសទោះបីជាអប់រំសុខភាពត្រូវបានសរសេររួមគ្នាជា «អប់រំកាយនិងសុខភាព» នៅក្នុងកម្មវិធីសិក្សាក៏ដោយ ប៉ុន្តែដោយសារតែ មុខវិជ្ជាអប់រំសុខភាពធ្លាប់ត្រូវបានគ្រប់គ្រងរួមគ្នាជាមួយការអប់រំគិលានុបដ្ឋាយិកា (គិលានដ្ឋាន) ដោយនាយកដ្ឋានសុខភាពសិក្សា នៃអគ្គនាយកដ្ឋានអប់រំ ទើបសកម្មភាពលើកកម្ពស់ជាក់ស្តែងមិនអាចធ្វើទៅបានទេ។ លើសពីនេះទៀត នៅពេលចងក្រងកម្មវិធីសិក្សាសម្រាប់សាលាបឋមសិក្សាយើងបានពិចារណាថាតើអប់រំកាយប្រភេទណាដែលយើងគួរតម្រង់ឆ្ពោះទៅ បន្ទាប់ពីពន្យល់ពីស្ថានភាពអប់រំកាយនៅក្នុងប្រទេសនីមួយៗ។ គំរូអប់រំកីឡា គំរូអប់រំលំហាត់ប្រាណ គំរូអប់រំសុខភាព និងគំរូអប់រំសីលធម៌ត្រូវបានបង្ហាញនៅក្នុងសិក្ខាសាលាដំបូង ហើយបន្ទាប់ពីបានបញ្ជាក់ជាមួយអ្នកចូលរួមទាំងអស់«គំរូអប់រំសីលធម៌»ដែលស្រដៀងនឹងការអប់រំមុខវិជ្ជាអប់រំកាយរបស់ប្រទេសជប៉ុន ត្រូវបាន អនុម័តដោយសំឡេងភាគច្រើន។ ដូច្នេះម៉ូដែលជប៉ុនបាននៅសល់ជាមួយនឹងម៉ូដែលថៃនិងសិង្ហបុរី។ដោយសារអប់រំកាយនៅក្នុងប្រទេសជប៉ុនមានភាពលំអៀងឆ្ពោះទៅរកការបណ្តុះបណ្តាលជំនាញកីឡាមួយចំនួន ជាជាងការអប់រំសីលធម៌ដែលពង្រីកផ្នែកអារម្មណ៍ ដូច្នេះកម្មវិធីសិក្សាមានរួមបញ្ចូលធាតុផ្សំនៃការលេង ដើម្បី

កុំឱ្យមានភាពលំអៀងទៅរកកីឡាប្រកួតប្រជែង។ ទោះជាយ៉ាងណាក៏ដោយ នៅពេលអនុវត្ត ជាក់ស្តែង ការផ្តោតទៅលើកីឡា(ការកែលម្អជំនាញកីឡា)នៅតែជាបញ្ហា។

ទីបំផុត កម្មវិធីសិក្សាអប់រំកាយដំបូងរបស់ប្រទេសកម្ពុជាសម្រាប់សាលាបឋមសិក្សា ត្រូវបានបែងចែកទៅជាថ្នាក់ទាប និងថ្នាក់ខ្ពស់ ហើយត្រូវបានបង្កើតឡើងក្នុងគោលដៅសម្រេចបាននូវវត្ថុបំណងដូចខាងក្រោមៈ

**[ថ្នាក់ទាប]**

១. បណ្តុះឥរិយាបថប្រកបដោយសេចក្តីស្រឡាញ់ចំពោះកីឡា និងគុណតម្លៃដែលគោរពកីឡា ស្របតាមដំណាក់កាលវិវត្តន៍និងសមត្ថភាពផ្ទាល់ខ្លួននិងទទួលបានឥរិយាបថក្នុងការដឹកនាំជីវិតប្រចាំថ្ងៃប្រកបដោយសុខុមាលភាព និងសុវត្ថិភាព។ (ឥរិយាបថ)

២.ទទួលបានចំណេះដឹងជាមូលដ្ឋាននិងវិធីសាស្ត្ររៀនដែលចាំបាច់ដើម្បីលេងមើលនិងរីករាយនឹងកីឡាជាមួយមនុស្សជាច្រើនទៀត ទៅតាមដំណាក់កាលវិវត្តន៍ និងសមត្ថភាពផ្ទាល់ខ្លួន។ (ចំណេះដឹង)

៣. ទទួលបានជំនាញជាមូលដ្ឋាន ជំនាញយុទ្ធសាស្ត្រ និងកាយសម្បទាចាំបាច់ ដើម្បីរីករាយនឹងកីឡា ទៅតាមដំណាក់កាលវិវត្តន៍ និងសមត្ថភាពផ្ទាល់ខ្លួន។ (ជំនាញ)

៤. ទទួលបានជំនាញសង្គមដែលចាំបាច់ដើម្បីរីករាយនឹងកីឡាជាមួយមនុស្សផ្សេងៗគ្នាទៅតាមដំណាក់កាលវិវត្តន៍ និងសមត្ថភាពផ្ទាល់ខ្លួន។ (សហការ)

៥. ទទួលបានចំណេះដឹង វិធីសាស្ត្រ និងទម្លាប់នៃការរស់នៅចាំបាច់ ដើម្បីដឹកនាំជីវិតប្រចាំថ្ងៃប្រកបដោយសុខុមាលភាព និងសុវត្ថិភាព។ (ទម្លាប់)

**[ថ្នាក់ខ្ពស់]**

១.បណ្តុះឥរិយាបថប្រកបដោយសេចក្តីស្រឡាញ់ចំពោះកីឡា ស្របតាមដំណាក់កាលវិវត្តន៍ និងសមត្ថភាពផ្ទាល់ខ្លួននិងទទួលបានឥរិយាបថក្នុងការដឹកនាំជីវិតប្រចាំថ្ងៃប្រកបដោយសុខុមាលភាព និងសុវត្ថិភាព។ (ឥរិយាបថ)

២.ស្វែងយល់អំពីចំណេះដឹងជាមូលដ្ឋានដែលចាំបាច់ក្នុងការលេងនិងមើលកីឡានិងរីករាយជាមួយកីឡាជាមួយមនុស្សជាច្រើន ក៏ដូចជាវិធីសាស្ត្រក្នុងការរៀនសូត្រ ដូចជាវិធីកែលម្អការហ្វឹកហាត់ជាដើម។ ម្យ៉ាងទៀត ជួយសម្រួលដល់ការអភិវឌ្ឍសមត្ថភាពបញ្ញា និងសម្រួលដល់ការរៀនមុខវិជ្ជាផ្សេងៗ។ (ចំណេះដឹង)

៣. ទទួលបានជំនាញជាមូលដ្ឋាន ជំនាញយុទ្ធសាស្ត្រ និងកាយសម្បទាដែលចាំបាច់ក្នុងការលេងកីឡានីមួយៗស្របតាមដំណាក់កាលវិវត្តន៍និងសមត្ថភាពផ្ទាល់ខ្លួន និងអាចបង្ហាញជំនាញទាំងនេះនៅក្នុងការប្រកួតដែលគិតគូរពីដំណាក់កាលវិវត្តន៍ទាំងនោះ។ (ជំនាញ)

៤. អាចអនុវត្តតាមច្បាប់ដែលបានកំណត់ទៅតាមដំណាក់កាលវិវត្តន៍ និងលទ្ធភាពរបស់ពួកគេ

អាចបំពេញតួនាទីរបស់ខ្លួនប្រកបដោយទំនួលខុសត្រូវ និងអភិវឌ្ឍសមត្ថភាពក្នុងការលេងកីឡាជាមួយមិត្តភក្តិដទៃទៀត។
(សហការ)
៥. អាចឆ្លើយតបបានសមស្របទៅនឹងការផ្លាស់ប្តូរក្នុងការអភិវឌ្ឍផ្លូវចិត្ត និងរាងកាយ ព្រមទាំងទទួលបានចំណេះដឹងវិធីសាស្ត្រនិងទម្លាប់នៃការរស់នៅដែលចាំបាច់ដើម្បីដឹកនាំជីវិតក្នុងសង្គមប្រកបដោយសុខុមាលភាព និងសុវត្ថិភាព។ (ទម្លាប់)

ការកំណត់វត្ថុបំណងខាងលើគឺជាចំណុចចាប់ផ្តើមនៃការអប់រំមុខវិជ្ជាអប់រំកាយនៅប្រទេសកម្ពុជា។យ៉ាងណាមិញនៅពេលនោះវាត្រូវបានបង្កើតឡើងជាកម្មវិធីសិក្សាសម្រាប់អប់រំសុខភាពនិងអប់រំកាយដែលរួមបញ្ចូលវត្ថុបំណងសម្រាប់អប់រំសុខភាពផងដែរ។ដោយយល់ឃើញថា«ចំណេះដឹងជំនាញនិងឥរិយាបថ»ត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៥ជាគុណវុឌ្ឍិដែលគួរទទួលបានក្នុងគ្រប់មុខវិជ្ជាដោយក្រសួងអប់រំដូចនេះអាចនិយាយបានថាកម្មវិធីសិក្សាសម្រាប់អប់រំកាយ ដែលបានកំណត់ «ឥរិយាបថ ចំណេះដឹង ជំនាញ សហការ និងទម្លាប់» ក៏ត្រូវបានបង្កើតឡើងក្នុង ទិសដៅដូចគ្នាដែរ។

## គោលគំនិតមើលមិនឃើញនៃបណ្តុំមុខវិជ្ជារង

ដើម្បីបង្រៀនឥរិយាបថ ចំណេះដឹង ជំនាញ សហការ និងទម្លាប់ តើជាក់ស្តែងត្រូវបង្រៀនអ្វីនៅក្នុងថ្នាក់អប់រំកាយ?កម្មវិធីសិក្សាសម្រាប់អប់រំកាយនៅសាលាបឋមសិក្សាក្នុងប្រទេសកម្ពុជាដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧បានកំណត់តារាងបណ្តុំមុខវិជ្ជារងដូចបង្ហាញក្នុងរូបភាពទី៤។នៅក្នុងថ្នាក់ទាបផ្តោតលើលំហាត់ប្រាណជាមូលដ្ឋាននិងការលេងបាល់ដើម្បីរៀនពីមូលដ្ឋាននៃកីឡាដូចជា អប់រំកាយជាមួយចង្វាក់ភ្លេង កាយសម្ព័ន្ធ អត្តពលកម្ម បាល់ទាត់ បាល់បោះ និងបាល់ទះដែលត្រូវសិក្សានៅថ្នាក់ខ្ពស់។នៅថ្នាក់ទី៤-៦ហែលទឹកត្រូវបានបញ្ចូលប៉ុន្តែការបញ្ចូលហែលទឹកគឺមិនអាចទៅរួចទេ ក្នុងស្ថានភាពដែលសាលារៀនមិនមានអាងហែលទឹក។ ដូចដែលបានរៀបរាប់ខាងលើ បណ្តុំមុខវិជ្ជារងនៃអប់រំសុខភាពក៏ត្រូវបានដាក់បញ្ចូល ប៉ុន្តែដោយសារតែមុខវិជ្ជាអប់រំសុខភាពត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានសុខភាពសិក្សានៅក្នុងអគ្គនាយកដ្ឋានអប់រំជាក់ស្តែងកម្មវិធីសិក្សានេះមិនត្រូវបានគេប្រើប្រាស់នៅក្នុងសាលារៀនសម្រាប់មុខវិជ្ជាអប់រំសុខភាពនោះទេ។

តារាងទី ៣៖ តារាងបណ្តុំមុខវិជ្ជារងកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា

<table>
<tr><th>សិស្ស</th><th>១</th><th>២</th><th>៣</th><th>៤</th><th>៥</th><th>៦</th></tr>
<tr><td rowspan="7">មុខវិជ្ជា<br>អប់រំកាយ<br>និងកីឡា</td><td colspan="3" rowspan="3">លំហាត់មូលដ្ឋាន</td><td colspan="3">អប់រំកាយជាមួយចង្វាក់ភ្លេង</td></tr>
<tr><td colspan="3">កាយសម្ព័ន្ធ</td></tr>
<tr><td colspan="3">អត្តពលកម្ម</td></tr>
<tr><td colspan="3"></td><td colspan="3">ហែលទឹក</td></tr>
<tr><td colspan="3" rowspan="3">ការលេងបាល់</td><td rowspan="3">ល្បែងបាល់</td><td colspan="2">បាល់ទាត់</td></tr>
<tr><td colspan="2">បាល់បោះ</td></tr>
<tr><td colspan="2">បាល់ទះ</td></tr>
<tr><td rowspan="6">អប់រំសុខភាព</td><td colspan="4">ជីវិតប្រចាំថ្ងៃដែលមានសុខភាពល្អ</td><td colspan="2"></td></tr>
<tr><td colspan="4"></td><td colspan="2">ការលូតលាស់រាងកាយ</td></tr>
<tr><td colspan="6">ការបង្ការរបួស</td></tr>
<tr><td></td><td colspan="2"></td><td colspan="3">ជំងឺ / ការបង្ការ</td></tr>
<tr><td colspan="4"></td><td colspan="2">វិធានការប្រឆាំងគ្រឿងញៀន</td></tr>
<tr><td colspan="3"></td><td colspan="3">សុខភាពផ្លូវចិត្តនិងផ្លូវកាយ</td></tr>
<tr><td>ផ្សេងទៀត</td><td colspan="6">តេស្តកាយសម្បទា</td></tr>
</table>

ប្រភព៖ ដកស្រង់ចេញពីកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា (MoEYS,២០០៧)

ម្យ៉ាងទៀត នៅក្នុងតារាងបណ្តុំមុខវិជ្ជារងថ្នាក់ទាបរួមមាន៖ លំហាត់មូលដ្ឋាន និងការលេងបាល់ ហើយថ្នាក់ខ្ពស់រួមមាន៖ អប់រំកាយជាមួយចង្វាក់ភ្លេង កាយសម្ព័ន្ធ អត្តពលកម្ម ហែលទឹក បាល់ទាត់ បាល់បោះ និងបាល់ទះ។ ទោះជាយ៉ាងនេះក្តី មន្ត្រីទទួលបន្ទុកជាក់ស្តែងនៃនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតគិតថាប្រភេទទាំង៦ (អប់រំកាយជាមួយចង្វាក់ភ្លេង កាយសម្ព័ន្ធ អត្តពលកម្ម បាល់ទាត់ បាល់បោះ និងបាល់ទះ) បូករួមទាំងតេស្តកាយសម្បទាគួរតែបន្តពីថ្នាក់ទី១ ដល់ថ្នាក់ទី៦។ សៀវភៅគ្រូនីមួយៗមានសរសេរអំពីប្រភេទទាំង៦ ត្រូវបូករួមទាំងតេស្តកាយសម្បទា។ លំហាត់នៃការលេងបាល់នៅក្នុងថ្នាក់ទាបក៏ត្រូវបានចាត់ទុកថាជាលំហាត់មូលដ្ឋានសម្រាប់បាល់ទាត់បាល់បោះនិងបាល់ទះដែលមានលក្ខណៈស្រដៀងទៅនឹងកីឡាដែលមានការប្រកួតប្រជែង ដែលត្រូវរៀននៅថ្នាក់ខ្ពស់។

នេះហាក់បីដូចជាពិបាកយល់អំពីគោលគំនិតមើលមិនឃើញនៃបណ្តុំមុខវិជ្ជារង។ គោលគំនិតនៃការលេងបាល់នៅថ្នាក់ទាបមិនត្រូវបានយល់ទេ ហើយជាឧទាហរណ៍ បាល់ទាត់នៅថ្នាក់ទី៣ត្រូវបានគេយល់ថាជាប្រភេទបាល់ទាត់ទី២។ គោលគំនិតដែលមើលមិនឃើញនេះគឺស្រដៀងគ្នាទៅនឹងការបង្រៀន «ឥរិយាបថ ចំណេះដឹង ជំនាញ សហការ និងទម្លាប់» ដែលការកែលម្អជំនាញរបស់សិស្សគឺអាចមើលឃើញប៉ុន្តែការផ្លាស់ប្តូរឥរិយាបថជាដើមគឺមិនអាចមើលឃើញ ដូច្នេះមន្ត្រីក្រសួងអប់រំមានការលំបាកយ៉ាងខ្លាំងក្នុងការចងក្រងកម្មវិធីសិក្សានេះ។

## អ្នកដែលមិនអាចស្រមៃមើល «ប្រអប់ច្រត់សម្រាប់លោត»

នៅពេលបង្កើតកម្មវិធីសិក្សាសម្រាប់សាលាបឋមសិក្សា បន្ថែមពីលើការពិចារណាលើវត្ថុបំណង និងបណ្តុំមុខវិជ្ជារង យើងក៏មានបញ្ហាផ្នែកភាសាផងដែរ ដូចជារបៀបបកប្រែពាក្យដូចជា «ប្រអប់ច្រត់សម្រាប់លោត» និង «លោតអន្ទាក់» ទៅជាភាសាខ្មែរ ដែលមិនមានលេងនៅក្នុងប្រទេសកម្ពុជារហូតមកដល់ពេលនេះ។ ភាគីជប៉ុនបានស្នើថា ជាការពិតណាស់ គួរតែដាក់បញ្ចូល «ប្រអប់ច្រត់សម្រាប់លោត» ហើយដោយសារមិនមានប្រអប់ច្រត់សម្រាប់លោត ពួកគេបានព្យាយាមប្រើន័យជា «លោតរំលងខ្នងសេះ» នៅសាលារៀន ប៉ុន្តែសម្រាប់ភាគីកម្ពុជា ការបកប្រែត្រង់ៗនៃ «លោតរំលងខ្នងសេះ» គឺគ្មានន័យទាល់តែសោះ។ នៅពេលនោះ លោក កែវ សុចិត្រា ជាបុគ្គលិកអង្គការបេះដូងមាស ដែលមានបញ្ហាក្នុងការបកប្រែភាសាខ្មែរ នៅមុនឆ្នាំ២០០៩ គាត់មិនទាំងយល់ពាក្យថា «អប់រំកាយ» ផង កុំថាឡើយពាក្យកីឡា។

គេតែងនិយាយថា «កីឡា = កីឡា» ហើយ «អប់រំកាយ = អប់រំកាយ» ប៉ុន្តែខ្ញុំត្រូវគិតជាភាសាអង់គ្លេសគឺជាអ្វី? ជាភាសាជប៉ុនគឺជាអ្វី? លោក កែវ សុចិត្រា មានប្រសាសន៍ ដូចខាងក្រោម៖

«មុនឆ្នាំ ២០០៩ សូម្បីតែពាក្យថា «អប់រំកាយ» ក៏ខ្ញុំមិនយល់ដែរ កុំថាឡើយវាក្យសព្ទកីឡា។សូម្បីតែអ្នកនៅក្នុងនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតក៏កម្រមានអ្នកយល់អត្ថន័យនៃ «អប់រំកាយ» ណាស់ ហើយ «ប្រអប់ច្រត់សម្រាប់លោត» ជាភាសាជប៉ុនគឺ «លោត + ប្រអប់» គឺខ្ញុំមិនអាចស្រមៃចេញទេ។ខ្ញុំបាននិយាយជាមួយលោកម៉ាន់សិថាដែលជាគ្រូឧទ្ទេសថ្នាក់ជាតិមួយរូប ហើយគាត់បានប្រាប់ខ្ញុំថា ប្រសិនបើអ្នកផ្សំពាក្យខ្មែរថា «ប្រអប់» ដែលមានន័យថា ប្រអប់ និង «ឧបសគ្គ»ដែលមានន័យថាឧបសគ្គនោះអ្នកនឹងយល់ថាអ្វីជាប្រអប់ច្រត់សម្រាប់លោតហើយក៏បានដាក់ឈ្មោះវាតាមវិធីនេះ។នៅពេលដាក់ឈ្មោះ យើងបានពិនិត្យឈ្មោះជាមួយ VCDs ដែលនាំចូលពីប្រទេស ជប៉ុនជាដើមហើយមានគ្រូបឋមសិក្សានិងសាស្ត្រាចារ្យសាកលវិទ្យាល័យដែលបង្រៀននៅសាលាបឋមសិក្សាជាសាខារបស់សាកលវិទ្យាល័យTsukubaនិងសាកលវិទ្យាល័យតូក្យូហ្គាគឹហ្គេចុះមកមើលយើងហើយបានផ្តល់ឧទាហរណ៍អំពីការបង្រៀនរបស់ពួកគេនៅពេលធ្វើដំណើរជុំវិញប្រទេស។ យើងពិតជាបានសរសេរវានៅក្នុងកិច្ចតែងការបង្រៀននៅពេលនោះដើម្បីឱ្យមនុស្សមកពីនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតពិនិត្យមើលវាហើយយើងបានផ្លាស់ប្តូរយោបល់ និងធ្វើការរួមគ្នាដើម្បីស្វែងយល់អំពីវា»។ដូច្នេះហើយ នៅខែមិថុនា ឆ្នាំ២០០៧ កម្មវិធីសិក្សា មុខវិជ្ជាអប់រំកាយ សម្រាប់បឋមសិក្សា ត្រូវបានអនុម័តដោយក្រសួងអប់រំ។ ឃ្លាថា «កម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយដំបូងនៅប្រទេសកម្ពុជា»គឺត្រឹមត្រូវនិងខុសដូចគ្នា។រហូតមកដល់ពេលនេះ មានឯកសារដែលរៀបរាប់ថាតើអប់រំកាយមានលក្ខណៈបែបណា។ ម៉្យាងវិញទៀត លោក ព្រំ ប៊ុណ្ណាយី មានប្រសាសន៍ថា នេះជាកម្មវិធីសិក្សាដំបូងគេ ដែលបញ្ចូលខ្លឹមសារលម្អិតសម្រាប់ថ្នាក់អប់រំកាយ។យ៉ាងហោចណាស់នេះជាកម្មវិធីសិក្សាដំបូងដែលបានបញ្ជាក់យ៉ាងច្បាស់

អំពីវត្ថុបំណងនៃគុណវុឌ្ឍិដែលសិស្សគួរទទួលបាន។ តាមរយៈការអនុវត្តអប់រំកាយជាមួយចង្វាក់ភ្លេង កាយសម្ព័ន្ធ អត្តពលកម្ម បាល់ទាត់ បាល់បោះ បាល់ទះ និងតេស្តកាយសម្បទា ក្នុងអប់រំកាយ កុមារអាចរៀនពី«ឥរិយាបថ ចំណេះដឹង ជំនាញ សហការ និងទម្លាប់»។

បន្ទាប់ពីកម្មវិធីសិក្សាត្រូវបានបង្កើតឡើង យើងត្រូវតែចែកចាយ និងទាក់ទងទៅសាលានីមួយៗ។ ការផ្សព្វផ្សាយពីគុណតម្លៃនៃ «អប់រំកាយបែបថ្មី» ដែលខុសពីមុន ដល់សាលាបឋមសិក្សាប្រមាណ ៧,០០០ សាលា ទូទាំងប្រទេស ឱ្យរៀនពីរបៀបបង្រៀនជាក់ស្តែង និងបញ្ចូលវាទៅក្នុងថ្នាក់អប់រំកាយ នៅតែជាផ្លូវដ៏វែងឆ្ងាយ។

## ផ្នែកទី២៖ អ្វីដែលអាចធ្វើបាននៅក្នុងសិក្ខាសាលាក្នុងស្រុកនិងអ្វីដែលអាចធ្វើបាននៅក្នុងទស្សនកិច្ច សិក្សានៅប្រទេសជប៉ុន

## ការអនុវត្តគម្រោងលើកកម្ពស់ការអប់រំមុខវិជ្ជាអប់រំកាយ

បន្ទាប់ពីកម្មវិធីសិក្សាអប់រំកាយនៅសាលាបឋមសិក្សាត្រូវបានបង្កើតការចងក្រងកិច្ចតែងការបង្រៀនបានបន្ត រហូតដល់ខែកុម្ភៈឆ្នាំ២០០៨ ហើយដំណាក់កាលទី២ «គម្រោងលើកកម្ពស់ការអប់រំមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា» បានចាប់ផ្តើមនៅក្នុងខែមិថុនា ឆ្នាំ២០០៩ ហើយមានការកែសម្រួលជាបន្តបន្ទាប់រហូតដល់ខែមិថុនា ឆ្នាំ២០១២។

គោលដៅនៃគម្រោងលើកកម្ពស់ការអប់រំមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា គឺបង្កើតប្រព័ន្ធមួយដែលជួយឱ្យនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតរបស់ក្រសួងអប់រំអាចផ្សព្វផ្សាយការអប់រំមុខវិជ្ជាអប់រំកាយនៅសាលាបឋមសិក្សានៅប្រទេសកម្ពុជា ដោយឯករាជ្យ។ ប្រទេសកម្ពុជាទាំងមូលត្រូវបានបែងចែកជា ៥ តំបន់ ដោយគិតគូរពីលក្ខណៈនៃតំបន់នីមួយៗ ខេត្តចំនួន ៥ (ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តក្រចេះ និងខេត្តស្វាយរៀង) ត្រូវបានជ្រើសរើសជាខេត្តគោលដៅដោយក្នុងខេត្តនីមួយៗមានសាលាបឋមសិក្សាចំនួន២ និងសាលាគរុកោសល្យគ្រូបឋមសិក្សាចំនួន ១ ត្រូវបានកំណត់ជាសាលាគោលដៅ និងបានអនុវត្តកម្មវិធីផ្សព្វផ្សាយរៀងរាល់ពាក់កណ្តាលឆ្នាំម្តង (សូមមើលរូបភាពទី ៥)។

ជាលម្អិត គម្រោងត្រូវបានធ្វើឡើងវិញរៀងរាល់កន្លះឆ្នាំម្តងនៅក្នុងតំបន់ចំនួន៥ តាមដំណើរការជាសំណុំ រួមមាន (១) ការជ្រើសរើសសាលារៀនគោលដៅ (២) ការតាមដានបឋម (៣) សិក្ខាសាលាអប់រំកាយ (៤) សិក្ខាសាលាដាក់បញ្ចូល (៥) ការតាមដានលើកទី១ (៦) ការតាមដានលើកទី២ (៧) ការតាមដានលើកទី៣ និង (៨) ថ្នាក់បើកជាសាធារណៈ។ រយៈពេលកន្លះឆ្នាំចុងក្រោយត្រូវបានកំណត់ថាជាអំឡុងពេលវាយតម្លៃដោយក្រុមការងារបានចុះពិនិត្យមើល

សាលាបឋមសិក្សាគោលដៅនិងសាលាគរុកោសល្យក្នុងខេត្តចំនួន៥ម្តងទៀតហើយសាលាដែលអាចរក្សាបាននូវកម្រិតគុណភាពជាក់លាក់មួយសម្រាប់ថ្នាក់អប់រំកាយ ត្រូវបានគេកំណត់ថាជា «សាលាគំរូ» និងបានប្រគល់ស្លាកសញ្ញាផងដែរ។ ជាលទ្ធផល នៅចុងបញ្ចប់នៃគម្រោង សាលាគរុកោសល្យចំនួន២ និងសាលាបឋមសិក្សាចំនួន៦ ត្រូវបានទទួលស្គាល់ថាជាសាលាគំរូ។ ម្យ៉ាងទៀត ជាលទ្ធផលនៃគម្រោងនេះ មន្ត្រីចំនួន៦រូប មកពីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតត្រូវបានទទួលស្គាល់ជាគ្រូឧទ្ទេសថ្នាក់ជាតិហើយដោយផ្តោតលើពួកគាត់៦រូបនេះនឹងត្រូវធ្វើការបណ្តុះបណ្តាលគ្រូបឋមសិក្សាតាមរយៈសិក្ខាសាលាជាដើម។

រូបភាពទី ៥ ដ្យាក្រាមរូបភាពនៃគម្រោង (គម្រោងលើកកម្ពស់ការអប់រំមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា)




[ការពន្យល់អក្សរកាត់]

BTB៖ បាត់ដំបង
REP៖ សៀមរាប
SNV៖ ព្រះសីហនុ
KRT៖ ក្រចេះ
SVR៖ ស្វាយរៀង

BMC៖ បន្ទាយមានជ័យ
PRS៖ ពោធិ៍សាត់
KCH៖ កំពង់ឆ្នាំង
PLN៖ ប៉ៃលិន
OMC៖ ឧត្តរមានជ័យ
PVH៖ ព្រះវិហារ

KTM៖ កំពង់ធំ
KKG៖ កោះកុង
KPT៖ កំពត
KEP៖ កែប
KSP៖ កំពង់ស្ពឺ
RNK៖ រតនគិរី
MDK៖ មណ្ឌលគិរី

STR៖ ស្ទឹងត្រែង
KCM៖ កំពង់ចាម
PNH៖ ភ្នំពេញ
KDL៖ កណ្តាល
PVN៖ ព្រៃវែង
TKO៖ តាកែវ

## ដែនកំណត់នៃសិក្ខាសាលា

តើមន្ត្រីក្រសួងអប់រំ មន្ត្រីមន្ទីរ/ការិយាល័យអប់រំខេត្ត/ស្រុក គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនដែលអនុវត្តថ្នាក់អប់រំកាយជាក់ស្តែងបានរៀនអ្វីខ្លះតាមរយៈសិក្ខាសាលានិងការតាមដានគម្រោង និងទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន?

លោកដុកតឺរីវតន៍អនុប្រធាននាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតដែលបានចូលរួមក្នុងគម្រោងនេះតាំងពីដើមដំបូងមកបាននិយាយថា«ខ្ញុំគិតថាយើងត្រូវគិតថាតើអប់រំកាយបែបណាដែលយើងចង់ឱ្យកុមារទទួលបាននាពេលអនាគត» (HG, ២០២១)។

រហូតមកដល់ពេលនោះថ្នាក់អប់រំកាយនៅសាលារៀនភាគច្រើនមានរយៈពេល៤០នាទី ហើយ១០នាទីដំបូងជាលំហាត់ប្រាណបែបខ្មែរ(រូបភាពនៅទំព័រមុន)។នៅក្នុងលំហាត់ប្រាណបែបខ្មែរ សិស្សម្នាក់ចេញមកឈរខាងមុខជួរ ហើយធ្វើការបញ្ជាចលនានីមួយៗមានលេខដូចជាចលនា ១-១និង២-៣ហើយគ្រប់គ្នាធ្វើចលនាទៅតាមនោះ។សម្រាប់គ្រូបង្រៀនក្នុងវិស័យនេះគោលគំនិតនៃ «អប់រំកាយ» គឺស្រដៀងនឹងចំណុចនេះ ដូច្នេះហើយការផ្លាស់ប្តូរវាទៅជាផ្នត់គំនិតដែលសិស្សរៀន«ឥរិយាបថចំណេះដឹងជំនាញសហការនិងទម្លាប់»តាមរយៈបាល់ទាត់បាល់បោះឬអប់រំកាយជាមួយចង្វាក់ភ្លេងជាដើមពិតជាពិបាកណាស់។អប់រំកាយដែលគ្រូឧទ្ទេសថ្នាក់ជាតិខ្លួនឯងបានរៀនគឺបែបហ្នឹង ហើយវាហាក់ដូចជាពិបាកសម្រាប់ពួកគេក្នុងការផ្លាស់ប្តូរវាដោយខ្លួនឯង។



ស្ថានភាពនៃលំហាត់ប្រាណបែបខ្មែរ

ចាប់តាំងពីអ្នកនិពន្ធបានមកប្រទេសកម្ពុជាក្នុងឆ្នាំ២០១២សិក្ខាសាលាត្រូវបានធ្វើឡើងតាមលំនាំណាមួយគឺ ដោយអ្នកជំនាញដែលបានបញ្ជូនពីប្រទេសជប៉ុនមកប្រទេសកម្ពុជាដើម្បីផ្ដល់ការបង្រៀនឬដោយមានអ្នកនិពន្ធឬបុគ្គលិកជនជាតិខ្មែររបស់អង្គការបេះដូងមាសផ្ដល់ជាការបង្រៀន។ អ្នកនិពន្ធខ្លួនខ្ញុំ ផ្ទាល់មិនមានអាជ្ញាប័ណ្ណ ឬជំនាញជាគ្រូអប់រំកាយទេ ដូច្នេះនៅពេលខ្ញុំស្ដាប់ការបង្រៀនរបស់អ្នកជំនាញដំបូងខ្ញុំស្ទើរតែមិនយល់អំពីអ្វីដែលគាត់កំពុងនិយាយនោះទេ។ ទោះបីខ្ញុំមិនអាចយល់ ពីការបង្រៀនជាភាសាជប៉ុនក៏ដោយ ខ្ញុំចង់ដឹងថាតើមន្ត្រីក្រសួងអប់រំអាចយល់បានប៉ុណ្ណាតាមរយៈ អ្នកបកប្រែ។

ដូច្នេះហើយបន្ទាប់ពីសិក្ខាសាលារបស់អ្នកជំនាញខ្ញុំបានរៀបចំសិក្ខាសាលាមួយដែលអ្នកនិពន្ធមានតួនាទីជាគ្រូ ធ្វើការណែនាំឡើងវិញនូវការបង្រៀនរបស់អ្នកជំនាញ ដើម្បីពិនិត្យអំពីស្ថានភាពបែបណាដែលត្រូវនឹងស្ថានភាពជាក់ស្ដែងរបស់ប្រទេសកម្ពុជា ថាតើពួកគាត់បានយល់បែបណានិងប្រើប្រាស់ការងារជាក្រុមជាដើមដើម្បីបញ្ជាក់ពីកម្រិតនៃការយល់ដឹងរបស់មន្ត្រីក្រសួងអប់រំ។ដូចដែលបានរំពឹងទុកមានករណីជាច្រើនដែលលទ្ធផលរំពឹងទុកមិនត្រូវបានដូចអ្វីដែលគិតនោះទេ ក៏ដោយសារកម្រិតយល់ដឹងមានភាពខុសគ្នាខ្លាំង។

## ការ«អនុវត្ត» មិនមែនការ «សរសេរ» ទេ

នៅពេលបង្កើតកម្មវិធីសិក្សាសម្រាប់អនុវិទ្យាល័យ យើងបានធ្វើការជាក្រុមដើម្បីរកឱ្យឃើញនូវអ្វីដែលអាចធ្វើទៅបានដោយផ្អែកលើមតិរបស់អ្នកជំនាញ។ មានការជជែកគ្នាថាតើត្រូវដាក់បញ្ចូលហែលទឹកក្នុងកម្មវិធីសិក្សាឬអត់ ហើយមន្ត្រីក្រសួងអប់រំបានទទូចថាគួរតែបញ្ចូល។ ខ្ញុំយល់ពីបំណងចង់ដាក់បញ្ចូលវា ប៉ុន្តែតាមហេតុផលវាមិនអាចទៅរួចទេប្រសិនបើគ្មានអាងហែលទឹក ហើយបើគ្មានវិធានការនោះទេ ទោះជាបញ្ចូលក្នុងកម្មវិធីសិក្សាក៏ដោយ វានឹងដូចជានំអង្ករដែលគេគ្រាន់តែផាត់ពណ៌នៅក្នុងរូបភាព ប៉ុន្តែមិនអាចញ៉ាំបាន។

គោលបំណងគឺមិនមែនដើម្បី«ពិពណ៌នា»កម្មវិធីសិក្សានោះទេប៉ុន្តែដើម្បីឱ្យខ្លឹមសារដែលបានសរសេរនៅក្នុងកម្មវិធីសិក្សាត្រូវបាន«អនុវត្ត»នៅក្នុងសាលារៀនជាក់ស្ដែងប៉ុន្តែខ្ញុំមានអារម្មណ៍ថាវាពិបាកនឹងមើលឃើញចំណុចនេះណាស់។

ម្យ៉ាងទៀត នៅពេលចងក្រងសៀវភៅគ្រូអប់រំកាយសម្រាប់អនុវិទ្យាល័យ យើងបានធ្វើការជាក្រុមដើម្បីចងក្រងសៀវភៅគ្រូដោយផ្អែកលើកិច្ចតែងការបង្រៀនដែលបានបង្កើតជាក់ស្ដែង។ជាលទ្ធផលយើងអាចបញ្ជាក់បានថាតើមន្ត្រីក្រសួងអប់រំពិតជាយល់ឬមិនយល់តាមរយៈការពិនិត្យមើល កិច្ចតែងការបង្រៀនដែលពួកគេបានបង្កើតជាក់ស្ដែង ដូចជារបៀបជ្រើសរើសវត្ថុបំណងសម្រាប់ មេរៀន១ ថាតើវត្ថុបំណង និងរង្វាយតម្លៃត្រូវគ្នាដែរឬទេ។ ទោះបីជាសិក្ខាសាលាមានអត្ថប្រយោជន៍ក្នុងការអញ្ជើញអ្នកចូលរួមច្រើនក៏ដោយក៏ពិបាកក្នុងការសម្រេចបាននូវការសិក្សាស៊ីជម្រៅ។ចាំបាច់ត្រូវបញ្ជាក់ពីលទ្ធផលក្នុងអំឡុងពេលសិក្ខាសាលាដោយបង្កើតផែនការប្រចាំឆ្នាំ

ផែនការមេរៀន និងកិច្ចតែងការបង្រៀន ដើម្បីឱ្យអ្វីដែលបានរៀនចេញជាសមិទ្ធផល និងបញ្ជូនលទ្ធផលពីខ្លួនយើងផងដែរ។

## «ទិវាអប់រំកាយ» បានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងខ្លាំង

ទោះបីជាសិក្ខាសាលានេះអាចទាក់ទាញអ្នកចូលរួមក្នុងប្រទេសយ៉ាងច្រើនក៏ដោយ វាពិបាកក្នុងការផ្តល់ការរៀនសូត្របានស៊ីជម្រៅ ប៉ុន្តែការអញ្ជើញមនុស្សមួយចំនួនតូចឱ្យចូលរួមក្នុងទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន ដើម្បីទទួលយកបទពិសោធន៍អប់រំកាយនៅប្រទេសជប៉ុនដោយផ្ទាល់ បានមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការផ្លាស់ប្តូរការយល់ឃើញនិងការយល់ដឹងរបស់អ្នកពាក់ព័ន្ធខាងភាគីកម្ពុជា។

ដោយសារតែចំនួនអ្នកចូលរួមដែលអាចធ្វើដំណើរទៅប្រទេសជប៉ុនមានកំណត់នៅពេលនោះមានតែគ្រូឧទ្ទេសថ្នាក់ជាតិមកពីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស- និស្សិតប៉ុណ្ណោះដែលមានសិទ្ធិចូលរួមទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន។ តើអ្វីទៅជាថ្នាក់អប់រំកាយល្អ ខណៈពេលដែលនៅប្រទេសកម្ពុជាមិនអាចឃើញថ្នាក់រៀនល្អដូចប្រទេសជប៉ុនដោយការមើលអប់រំកាយនៅប្រទេសជប៉ុនយើងមានគោលបំណងចង់ឱ្យអ្នកចូលរួមបានរៀនពីរបៀបបង្រៀនគ្រូនិងរបៀបគ្រប់គ្រងពេលវេលារបៀបបង្ហាញសម្ភារៈជំនួយចក្ខុវិញ្ញាណនិងរបៀបប្រើប្រាស់កាតសិក្សាជាដើម។ ជាលទ្ធផល ដោយមើលឃើញនូវអ្វីដែលកំពុងអនុវត្តជាក់ស្តែងនៅក្នុងប្រទេសជប៉ុន ចំនួនករណីដែលយកមកណែនាំក្នុងសាលារៀននៅប្រទេសកម្ពុជាកំពុងកើនឡើងជាលំដាប់។

រឿងមួយដែលមានឥទ្ធិពលពិសេសដល់បុគ្គលិកក្រសួងអប់រំនៃប្រទេសកម្ពុជាអំឡុងពេល ទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន គឺទិវាអប់រំកាយ។ ក្នុងឆ្នាំ២០១១ យើងបានទទួលយកសិក្ខាកាមចំនួន៧នាក់ដោយប្រើជំនួយពីក្រុមប្រឹក្សាអាជ្ញាធរមូលដ្ឋានសម្រាប់ទំនាក់ទំនងអន្តរជាតិ ហើយទិវាអប់រំកាយដែលយើងសង្កេតឃើញនៅពេលនោះបានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងខ្លាំង រហូតដល់នាំឱ្យមានការប្រារព្ធទិវាអប់រំកាយនៅឆ្នាំ២០១៣ ដែលផ្តួចផ្តើមគំនិតដោយនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិត។ប្រហែលកន្លះឆ្នាំមុនទិវាអប់រំកាយលោកគ្រូហារ៉ាយូអ៊ីឈីនៃសាកលវិទ្យាល័យអូកាយ៉ាម៉ា(កាលនោះ)បានចូលរួមជាចម្បងហើយបានចំណាយពេលជាច្រើនក្នុងការពិភាក្សាអំពីគោលបំណងនៃទិវាអប់រំកាយ។ ទីបំផុតវាត្រូវបានសម្រេចថា ១) ការរីករាយនឹងវប្បធម៌អប់រំកាយជាមួយមនុស្សគ្រប់គ្នា ២) កន្លែងសម្រាប់បង្ហាញលទ្ធផលនៃថ្នាក់អប់រំកាយ និង ៣) កន្លែងសម្រាប់សហការជាមួយប្រជាពលរដ្ឋមូលដ្ឋាន ហើយក្រោយមកក៏បានរីករាលដាលដល់ខេត្តបាត់ដំបង និងខេត្តស្វាយរៀង។ ក្នុងឆ្នាំ២០១៥ មន្ត្រីនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតចំនួន៧នាក់បានទទួលការបណ្តុះបណ្តាលនៅខេត្តអូកាយ៉ាម៉ាក្រោមជំនួយលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ក្រុមប្រឹក្សាអាជ្ញាធរមូលដ្ឋានសម្រាប់ទំនាក់ទំនងអន្តរជាតិ (គម្រោងគំរូ) និងបានឈានទៅដល់ការបញ្ចប់សៀវភៅណែនាំសម្រាប់ទិវាអប់រំកាយ។



មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចុះទៅសង្កេតមើលថ្នាក់អប់រំកាយនៅប្រទេសជប៉ុន អំឡុងពេលទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន

ដូចដែលបានរៀបរាប់មកនេះ វាពិបាកក្នុងការបញ្ជាក់ច្បាស់ថាមួយណាល្អជាង រវាង សិក្ខាសាលាក្នុងប្រទេស និងទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន ព្រោះវាមានគុណសម្បត្តិ និង គុណវិបត្តិ រៀងៗខ្លួន។

នៅក្នុងសកម្មភាពបណ្តុះបណ្តាលគ្រូបង្រៀននាពេលបច្ចុប្បន្ននៅក្នុងគម្រោងដើម្បី ប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាទៅជាសាកលវិទ្យាល័យរយៈពេល៤ឆ្នាំសិក្ខាសាលា ត្រូវបានរៀបចំឡើងនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា បន្ទាប់ពីទស្សនកិច្ចសិក្សានៅប្រទេស ជប៉ុន។

លោកគ្រូអ្នកគ្រូដែលបានទៅទស្សនកិច្ចសិក្សានៅប្រទេសជប៉ុនកំពុងចងក្រងខ្លឹមសារនិងរៀបចំ ដើម្បីអាចបើក សិក្ខាសាលាដោយខ្លួនឯងបាន។ការចូលរួមក្នុងទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន គឺមិនមែនជាទីបញ្ចប់នោះទេដោយផ្តល់ឱកាសឱ្យពួកគេបញ្ចេញនូវអ្វីដែលបានរៀនបន្ទាប់ពីបាន ចូលរួម ពួកគេអាចស្រាវជ្រាវបន្ថែមដោយខ្លួនឯង និងពង្រីកវានៅក្នុងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាដែលនាំទៅដល់ការរៀនសូត្ររបស់ខ្លួនឯងនិងចែករំលែកចំណេះដឹងនិងបទពិសោធន៍ ផង។

## គ្រូជនជាតិជប៉ុនក៏មានគំនិតច្នៃប្រឌិតផងដែរ

លោក កែវ សុចិត្រា បុគ្គលិកនៃអង្គការបេះដូងមាស ដែលបានរួមដំណើរទៅចូលរួមទស្សនកិច្ចសិក្សានៅប្រទេសជប៉ុនជាច្រើនលើកបាននិយាយប្រាប់មន្ត្រីក្រសួងអប់រំដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាលើកដំបូងថា « គ្រូបង្រៀនជនជាតិខ្មែរជាធម្មតាគិតពីអប់រំកាយដោយផ្អែកលើគោលគំនិត "អប់រំកាយ = ចេញទៅទីធ្លាសាលា រួចធ្វើលំហាត់ប្រាណបែបខ្មែរ ២ ដងក្នុងមួយសប្តាហ៍នៅថ្ងៃចន្ទនិងថ្ងៃសុក្រ" ដូច្នេះហើយយើងត្រូវពន្យល់ដោយបញ្ជាក់ពីការយល់ឃើញថា វាជាមុខវិជ្ជាមួយ ដូចនឹងភាសាខ្មែរ និងគណិតវិទ្យាដែរ»។

ទោះបីជាបានបង្ហាញសៀវភៅគ្រូដល់ពួកគេក៏ដោយ ក៏អ្នកខ្លះបានត្អូញត្អែរថា « នៅប្រទេសកម្ពុជាមិនមានឧបករណ៍» ហើយ «នៅប្រទេសជប៉ុនអាចធ្វើបានព្រោះពួកគេមានឧបករណ៍» ប៉ុន្តែគ្រូបង្រៀនជនជាតិជប៉ុនក៏បានពន្យល់ដោយប្រើគំនិតច្នៃប្រឌិតដូចជាប្រើប្រាស់ដបប្លាស្ទិក និងកាត់ក្រដាសជាកោណផងដែរ។ នៅប្រទេសកម្ពុជាគ្មានប្រអប់ច្រត់សម្រាប់លោតទេ ដូច្នេះគេប្រើមនុស្សដើម្បីលោតរំលងខ្នងសេះ ឬប្រើធុងសំរាមជំនួសប្រអប់ច្រត់សម្រាប់លោត។ ដោយសារវាមិនពិបាកយល់ដោយគ្រាន់តែនិយាយ គ្រូឧទ្ទេសថ្នាក់ជាតិបានបង្ហាញដោយកាត់ខ្សែពួរជាក់ស្តែង ដើម្បីធ្វើជាខ្សែលោតអន្ទាក់ ឬក៏ធ្វើការសម្តែងជាក់ស្តែង។ គ្រាន់តែបានបង្ហាញមួយដងជាក់ស្តែង គ្រូបង្រៀននៅបឋមសិក្សានៅកន្លែងនោះគឺឆាប់យល់និងឆ្លាតណាស់។ នៅសាលាបឋមសិក្សាមួយក្នុងខេត្តស្ទឹងត្រែង គេបានប្រើក្រមា (ស្រដៀងនឹងកន្សែងខ្មែរ) ភ្ជាប់គ្នាធ្វើជាខ្សែពួរសម្រាប់ប្រើក្នុងថ្នាក់រៀន។

លោក កែវ សុចិត្រា ខ្លួនឯងបានចូលរួមទស្សនកិច្ចសិក្សានៅប្រទេសជប៉ុនដំបូងក្នុងឆ្នាំ២០០៥ កម្មវិធី«កាហ៊្សុមីហ្គាអ៊ូរ៉ាម៉ារ៉ាតុង»ដែលជាគម្រោងរបស់អង្គការបេះដូងមាសក្នុងឆ្នាំ២០០៨ និងបានមកប្រទេសជប៉ុនក្នុងឆ្នាំ២០១១ ប៉ុន្តែគាត់មិនមានឱកាសបានមើលថ្នាក់អប់រំកាយជប៉ុនមួយរយៈក្រោយចូលរួមក្នុងអង្គការបេះដូងមាសទេ។ គាត់បានឃើញថ្នាក់ដែលបង្រៀនដោយអ្នកជំនាញ និងថ្នាក់ដែលបង្រៀនដោយនាយក យ៉ាម៉ាហ្គុជិ ដែលជាអ្នកគ្រប់គ្រងគម្រោងនៅពេលនោះ ប៉ុន្តែគាត់មិនយល់បានច្រើនទេ។ សូម្បីតែគាត់ក៏គិតថា « ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះថ្នាក់អប់រំកាយដែលខ្ញុំបានឃើញនៅក្នុងប្រទេសជប៉ុន។ ពួកគេទាំងអស់ចូលរួមក្នុងថ្នាក់អប់រំកាយ ហើយខ្ញុំចង់បង្ហាញពីអប់រំកាយប្រភេទនេះដល់ប្រទេសកម្ពុជាផងដែរ»។ ជាឧទាហរណ៍ គ្រូបង្រៀនជនជាតិជប៉ុនបានគូររូបទន្លេនៅលើក្រដាស ហើយបិទភ្ជាប់វានៅលើដី ដើម្បីធ្វើឱ្យសិស្សស្រមៃថាពួកគេលោតកាត់ទន្លេ។ ភាពទាក់ទាញដ៏អស្ចារ្យនៃទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន គឺការអាចមើលឃើញឧទាហរណ៍ជាក់ស្តែងដូចនេះយ៉ាងជិតស្និទ្ធ។

## ផ្នែកទី ៧៖ ការលេចឡើងនៃអ្នកដឹកនាំដូចនឹង«សាមូរ៉ៃទាំង៧»

ដើម្បីលើកកម្ពស់ «អប់រំកាយបែបថ្មី» គម្រោងបានដំណើរការដោយការបង្កើតកម្មវិធីសិក្សានិងសៀវភៅគ្រូ។ ក្នុងដំណាក់កាលទី ២ ប្រទេសកម្ពុជាទាំងមូលដែលមាន១រាជធានីនិង២៣ខេត្ត(នៅពេលនោះ) ត្រូវបានបែងចែកជា ៥ តំបន់ ហើយខេត្តមូលដ្ឋានត្រូវបានបង្កើតឡើងនៅតាមតំបន់នីមួយៗ។តាមរយៈការធ្វើសិក្ខាសាលានិងការពិនិត្យតាមដានរយៈពេលវែងនិងស៊ីជម្រៅនៅសាលាគោលដៅក្នុងខេត្តមូលដ្ឋានគុណភាពនៃថ្នាក់អប់រំកាយនៅសាលាគោលដៅក៏មានដំណើរការប្រសើរឡើង។

មន្ត្រីមកពីនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតក៏អាចប្រមូលចំណេះដឹងនិងបទពិសោធន៍ តាមរយៈសិក្ខាសាលានិងការពិនិត្យតាមដានផងដែរ។

លោក ដុក គីរីរតន៍ អនុប្រធាននាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត និងលោក ម៉ាង វិបុល តែងតែសម្របសម្រួលក្រុមការងាររបស់គម្រោង។ នៅពេលដែលគម្រោងនេះបានចាប់ផ្តើមដំបូង ការងារគម្រោងជាមួយអង្គការបេះដូងមាស កាន់តែមានភាពមមាញឹកជាងការងារក្នុងនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ហើយក្រុមនេះត្រូវបានគេដាក់រហ័សនាមថា «ក្រុមបេះដូងមាស»។ លោក ដុក គីរីរតន៍ មានសំឡេងខ្លាំង និងមានឥទ្ធិពលខ្លាំងលើគ្រូបង្រៀននៅតាមសាលានិងបុគ្គលិកនៃមន្ទីរអប់រំរបស់ខេត្តនីមួយៗ។ ចំណែកឯ លោកម៉ាងវិបុលដើមឡើយជាគ្រូបង្រៀនភាសាខ្មែរដូច្នេះហើយលោកមានចិត្តចង់រៀននិងបានប្រមូលទិន្នន័យយ៉ាងសកម្មពីសាលារៀន ធ្វើឲ្យការសិក្សាអប់រំកាយកាន់តែស៊ីជម្រៅ។ សមត្ថភាពក្នុងការធ្វើសកម្មភាពរបស់គាត់ក៏គួរឱ្យកត់សម្គាល់ផងដែរ ដោយសារគាត់ផ្ទាល់បានបង្កើតសៀវភៅគ្រូសម្រាប់សាលាគរុកោសល្យគ្រូបឋមសិក្សា។

គាត់ទាំង២នាក់នេះជាគ្រូឧទ្ទេសថ្នាក់ជាតិដំបូងគេក្នុងចំណោម៦នាក់ដែលបានបណ្តុះបណ្តាលនៅប្រទេសកម្ពុជា រួមទាំងលោក កែវ សុចិត្រា ត្រូវបានគេស្គាល់ថាជា «សាមូរ៉ៃទាំង៧» ក្នុងគម្រោងនេះ។ «សាមូរ៉ៃទាំង៧» គឺជារឿងដែលដឹកនាំដោយ គូរ៉ូសាវ៉ា អាគីរ៉ា និងប្រាប់ពីរឿងរបស់សាមូរ៉ៃ៧នាក់ដែលត្រូវបានជួលដោយកសិករម្នាក់ ប៉ុន្តែនៅក្នុងអប់រំកាយនៅប្រទេសកម្ពុជាសំដៅដល់មន្ត្រីក្រសួងអប់រំចំនួន៦នាក់ដែលបានរៀនពីប្រទេសជប៉ុននិង១នាក់ទៀតជាបុគ្គលិកនៃអង្គការបេះដូងមាស ហើយវាប្រដូចទៅនឹងរឿងសាមូរ៉ៃទាំង៧ ដែលបង្ហាញនិងលើកកម្ពស់ពីគុណតម្លៃនៃអប់រំកាយដល់គ្រូបង្រៀននិងគណៈគ្រប់គ្រងសាលាដែលមិនទាន់ស្គាល់ពីអប់រំកាយបែបថ្មី។

លោក កែវ សុចិត្រា យល់ថា ឈ្មោះ«សាមូរ៉ៃទាំង៧» គឺជាឈ្មោះដ៏មោទនភាពមួយ ព្រោះគ្រប់គ្នាសូម្បីតែប្រជាជនកម្ពុជាក៏ធ្លាប់ស្គាល់ពាក្យ«សាមូរ៉ៃ»ដែរហើយនៅពេលនោះពួកគាត់ទាំង៧នាក់ពេលទៅចូលរួមសិក្ខាសាលា ឬការពិនិត្យតាមដាននៅទីណាក៏ដោយ គឺពួកគាត់ទាំងអស់គ្នា

តែងចូលរួមក្នុងសកម្មភាពដោយមោទនភាព។ទោះបីគ្រូបង្រៀននៅតាមសាលារៀននិងបុគ្គលិកមន្ទីរអប់រំខេត្តមិនបានហៅបែបនោះក៏ដោយ ក៏ពួកគាត់មានមោទនភាពជាមនុស្សអស្ចារ្យទាំង៧ ហើយបានទៅសិក្ខាសាលានិងវគ្គពិនិត្យតាមដានដោយមានបំណងចង់ចែករំលែកអប់រំកាយដល់មនុស្សគ្រប់គ្នា។

នៅសាលាបឋមសិក្សាអន្លង់វិលខេត្តបាត់ដំបងគ្រូឧទ្ទេសថ្នាក់ក្រោមជាតិម្ដងម្កាលបានជំនួសគ្រូឧទ្ទេសថ្នាក់ជាតិប៉ុន្តែពេលនិយាយជាមួយលោកគ្រូអ្នកគ្រូនៅតាមសាលាមានការត្អូញត្អែរថា ពួកគាត់ មិនសូវយល់ខ្លឹមសារទាំងនោះទេ គឺថាគ្រូឧទ្ទេសថ្នាក់ជាតិមានការយល់ដឹងច្រើនអំពីអប់រំកាយបែបថ្មី និងត្រូវបានគេជឿជាក់។

ការប្រាស្រ័យទាក់ទងគ្នារវាងបុគ្គលិកអង្គការបេះដូងមាស និងមន្ត្រីក្រសួងអប់រំ មិនមានភាពរលូនតាំងពីដើមមកនោះទេគឺត្រូវចំណាយពេលយូរក្នុងការកសាងទំនាក់ទំនងនៃការជឿទុកចិត្តតាមរយៈសកម្មភាពរបស់ពួកគេ។ លោក កែវ សុចិត្រា ធ្លាប់មានបញ្ហាក្នុងការទំនាក់ទំនងជាមួយពួកគេកាលពីមុនឆ្នាំ២០០៩។ គាត់និយាយថា «ពួកគេមិនសរសេរកិច្ចតែងការបង្រៀន ហើយពេលខ្លះក៏សរសេរយឺត។ នៅគ្រានោះ លោក ព្រំ ប៊ុណ្ណយី ប្រធាននាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតបានជួយនិយាយថាយើងជាជនជាតិខ្មែរ ប៉ុន្តែយើងទទួលបានការគាំទ្រពីជនជាតិ ជប៉ុន។ គាត់បានលើកទឹកចិត្តគ្រូឧទ្ទេសថ្នាក់ជាតិឱ្យដើរទៅមុខ ទោះបីជាបន្តិចបន្តួចក៏ដោយ»។

នៅឆ្នាំ២០០៩លោកកែវសុចិត្រាក៏អាចយល់ពីអារម្មណ៍និងគំនិតរបស់ពួកគេហើយពួកគេក៏ចាប់ផ្ដើមយល់ពីគំនិតរបស់លោក កែវ សុចិត្រាផងដែរ។ ជាពិសេស លោក ដុក គីរីរតន៍ អនុប្រធាននាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត(ទទួលបន្ទុកសាលាបឋមសិក្សា) និងលោកម៉ាងវិបុល(ទទួលបន្ទុកកម្មវិធីសិក្សា)បានខិតខំយ៉ាងសកម្មក្នុងការបង្កើតសៀវភៅគ្រូដែលជាគោលនយោបាយនៃនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតតាំងពីឆ្នាំ២០០៩មក។

លោក ម៉ាង វិបុល បានក្រឡេកទៅមើលពេលនោះ និងបានបង្ហោះរូបខាងលើនៅលើហ្វេសប៊ុ ក។ ថ្ងៃដែលពួកគេខិតខំប្រឹងប្រែងធ្វើការលើកកម្ពស់អប់រំកាយ ដោយជិះខាងក្រោយរថយន្តដឹកទំនិញជាមួយគ្រូឧទ្ទេសថ្នាក់ជាតិចំនួន៧នាក់ រួមទាំងលោកនាយក យ៉ាម៉ាហ្គូជិ ដែលជាប្រធានគម្រោង នៅតែស្ថិតក្នុងការចងចាំរបស់ពួកគេរហូតដល់សព្វថ្ងៃ។

ក្នុងចំណោមគ្រូឧទ្ទេសជាតិទាំង៧រូបនាពេលនោះ លោក មៀវ សុផល បានទទួលមរណភាពដោយជំងឺនៅឆ្នាំ២០១៧។គាត់ជាមនុស្សរួសរាយជាងអ្នកណាទាំងអស់ហើយតែងតែប្រាស្រ័យទាក់ទងជាមួយគ្រូៗដោយស្នាមញញឹម។គួរឲ្យសង្វេគណាស់ដែលបាត់បង់មន្ត្រីដែលយល់ពីតម្លៃ នៃអប់រំកាយ បែបនេះ យ៉ាងណាមិញ វាច្បាស់ណាស់ថាដោយសារស្ថានភាពបែបនេះ ទើបយើងត្រូវកសាងប្រព័ន្ធដើម្បីបន្តការលើកកម្ពស់អប់រំកាយឱ្យកាន់តែរឹងមាំ ដើម្បីឱ្យអ្នកជំនាន់ក្រោយ បន្តវេន។




ការបង្ហោះហ្វេសប៊ុករបស់លោក ម៉ាង វិបុល រម្លឹកអំពីសមាជិកដំបូងនៃគម្រោងលើកកម្ពស់អប់រំកាយ

ទំនាក់ទំនងរបស់មនុស្សត្រូវបានកសាងឡើងដោយប្រើរយៈពេលយូរហើយបុគ្គលិកជនជាតិខ្មែរនៃអង្គការបេះដូងមាសក៏កំពុងកសាងទំនុកចិត្តជាមួយក្រសួងអប់រំបន្តិចម្តងៗផងដែរ។ តាមទស្សនៈរបស់មន្ត្រីក្រសួងអប់រំ បុគ្គលិកអង្គការបេះដូងមាសមានវ័យក្មេង ហើយពិបាកស្តាប់ទស្សនៈរបស់ពួកគេដោយស្មោះត្រង់ណាស់។

ក្នុងចំណោមបុគ្គលិក ក៏មានអ្នកខ្លះពិបាកបង្កើតទំនាក់ទំនងល្អជាមួយដែរ។ ដើម្បីលើកកម្ពស់អប់រំកាយយើងនឹងអនុវត្តសកម្មភាពដែលបានសរសេរក្នុងផែនការគម្រោងហើយមានគោលបំណងសម្រេចបាននូវគោលដៅនិងលទ្ធផលរបស់គម្រោងប៉ុន្តែដើម្បីសម្រេចបាននូវចំណុចនេះ ខ្ញុំគិតថា ការបង្កើតបរិយាកាសរីកចម្រើនរួមគ្នា ដែលមន្ត្រីអប់រំនីមួយៗ និងបុគ្គលិកនៃអង្គការបេះដូងមាសម្នាក់ៗនឹងកសាងទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកគេ និងប្រឈមនឹងការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងផ្ទាល់ខ្លួនម្តងមួយៗ នឹងនាំឱ្យមានភាពជោគជ័យដល់គម្រោង។

## ផ្នែកទី ៩៖ ដើម្បីឱ្យលទ្ធផលមាននិរន្តរភាព តើត្រូវបញ្ចប់ត្រឹមការ«ខ្ជះខ្ជាយ»?

អង្គការបេះដូងមាសបាននិងកំពុងអនុវត្តគម្រោងជំនួយអប់រំកាយតាំងពីឆ្នាំ២០០៦ ដោយបានធានានូវថវិកាគម្រោងក្នុងអំឡុងពេលនៃគម្រោងហើយអាចចំណាយថ្លៃធ្វើដំណើរនិងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសម្រាប់មន្ត្រីក្រសួងអប់រំ មន្ទីរ/ការិយាល័យអប់រំខេត្ត/ស្រុក គណៈគ្រប់គ្រងសាលានិងគ្រូ។ យ៉ាងណាមិញ អ្វីដែលពិបាកនោះគឺថាតើភាគីដែលបានរៀបរាប់ខាងលើនឹងបន្តធ្វើការដើម្បីលើកកម្ពស់អប់រំកាយដែរឬទេ ក្រោយពេលគម្រោងនេះបញ្ចប់។

អ្នកនិពន្ធបានចំណាយពេល២ឆ្នាំនៅប្រទេសប៉ារ៉ាហ្គាយ អាមេរិកខាងត្បូង ក្នុងនាមជាសមាជិកនៃក្រុមស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេសពីឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៧។ ជាទូទៅវាជាសកម្មភាពស្ម័គ្រចិត្តរយៈពេល ២ឆ្នាំ។ ក្រុមស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេសមិនត្រូវបានផ្សារភ្ជាប់ទៅនឹងគម្រោងសហប្រតិបត្តិការបច្ចេកទេសផ្សេងទៀតរបស់JICAទេហើយ ទោះបីជាអាចស្នើសុំអ្នកជំនួសបន្ទាប់ពីបញ្ចប់សកម្មភាពរយៈពេល២ឆ្នាំក៏ដោយ ក៏មិនមានការសន្យា ឬការធានាជាក់លាក់ណាមួយទាក់ទងនឹងនិរន្តរភាពរបស់ពួកគេបន្ទាប់ពីបញ្ចប់សកម្មភាពអ្នកស្ម័គ្រចិត្តនោះដែរ។ ពេលនោះ អ្នកនិពន្ធមានទំនុកចិត្តលើសកម្មភាពខ្លួនឯង ប៉ុន្តែនិយាយឱ្យត្រង់ទៅ ខ្ញុំក៏មានអារម្មណ៍ថាវាជាការ «ខ្ជះខ្ជាយ»។ ទោះបីថាការទាមទារនូវនិរន្តភាពនៃគម្រោង ដោយយុវជនដែលគ្មានបទពិសោធន៍ការងារក្នុងសង្គម ជាបន្ទុកច្រើនពេកក៏ដោយ ប៉ុន្តែរយៈពេលពីរឆ្នាំដែលបានធ្វើការជាអ្នកស្ម័គ្រចិត្តយ៉ាងមានចំណូលចិត្តក្នុងអំឡុងពេលវ័យជំទង់ដ៏មានតម្លៃ ត្រូវបានបញ្ចប់ត្រឹមតែជា«អ្នកស្ម័គ្រចិត្ត»ប៉ុណ្ណោះ នោះវាជាការ«ខ្ជះខ្ជាយ»ណាស់។

នៅពេលដែលខ្ញុំបានមកប្រទេសកម្ពុជាក្នុងឆ្នាំ២០១២ពេលដែលគម្រោងដំណាក់កាលទី២បានបញ្ចប់នៅក្នុងខែមិថុនាខ្ញុំមានអារម្មណ៍ថាវាជាការ«ខ្ជះខ្ជាយ»ដែលសកម្មភាពនឹងបញ្ចប់ត្រឹមតែគម្រោង៣ឆ្នាំនេះ។ ដូច្នេះហើយ នៅពេលដាក់ពាក្យស្នើសុំគម្រោងបន្ទាប់ យើងបានកំណត់គោលដៅគម្រោងថ្មីនៃ «ការកសាងប្រព័ន្ធផ្សព្វផ្សាយ» ជាមួយនឹងគោលបំណងកសាងប្រព័ន្ធដែលនឹងបន្តបង្កើតលទ្ធផល។ គំនិតនេះបានមកពីគំនិតផ្សព្វផ្សាយដែលហៅថាRECTI របស់នាយក យ៉ាម៉ាហ្គូជិ ដែលជាអ្នកកាន់តំណែងមុនអ្នកនិពន្ធ។

## **គំនិត** «RECTI»

RECTI មកពីពាក្យ Rectification (មានន័យថាការកែប្រែ ការកែតម្រូវ) ហើយក៏ជាអក្សរកាត់នៃ Regional Education Center Transferring Initiative (រូបភាពទី ៦)។ គឺជាប្រព័ន្ធមួយដែលសាលាបឋមសិក្សាចំនួន២ និងសាលាគរុកោសល្យចំនួន១ ក្នុងខេត្តគោលដៅចំនួន៥ ស្ថិតនៅចំណុចកំពូលនៃវិធី cascade (មកពីពាក្យ cascade មានន័យថា ទឹកជ្រោះដែលមានលក្ខណៈដូចជណ្តើរនិងជាវិធីសាស្ត្រដែលផ្សព្វផ្សាយតាមដំណាក់កាលដូចទឹកហូរពីកំពូលទៅបាត) និងផ្សព្វផ្សាយដល់សាលាបឋមសិក្សាផ្សេងទៀត។ នៅក្នុងគម្រោងនេះ សិក្ខាសាលា និងការពិនិត្យតាមដានត្រូវបានធ្វើឡើងយ៉ាងយកចិត្តទុកដាក់នៅសាលាគំរូ ហើយការអភិវឌ្ឍធនធានមនុស្សនៅសាលាគំរូដែលជាចំណុចចាប់ផ្តើមនៃវិធីសាស្ត្រcascadeត្រូវបានសម្រេច។

នៅក្នុងដំណាក់កាលទី ៣ ដោយផ្អែកលើគំនិតរបស់នាយក យ៉ាម៉ាហ្គូជិ អំពី RECTI យើងមានផែនការផ្សព្វផ្សាយទៅកាន់ខេត្តជិតខាង (ខេត្តផ្សព្វផ្សាយ) ដោយផ្តោតលើខេត្តចំនួន ៥ ដែលត្រូវបានផ្សព្វផ្សាយនៅក្នុងដំណាក់កាលទី ២ (ខេត្តគំរូ)។ ដោយសារក្រសួងអប់រំមានគ្រូឧទ្ទេសថ្នាក់ជាតិចំនួន៦រូបនិងគ្រូឧទ្ទេសថ្នាក់ក្រោមជាតិចំនួន៦រូបគោលដៅគឺដើម្បីដំឡើងគ្រូឧទ្ទេសថ្នាក់ក្រោមជាតិទាំង៦រូបទៅជាគ្រូឧទ្ទេសថ្នាក់ជាតិ។ម្យ៉ាងទៀតក្នុងខេត្តគំរូទាំង៥នេះមានគោលដៅបណ្តុះបណ្តាលគ្រូឧទ្ទេសក្នុងតំបន់ចំនួន៦រូបក្នុងមួយខេត្ត សរុប៥ខេត្តមាន៣០នាក់ (ជ្រើសរើសពីសាលាបឋមសិក្សាគំរូនិងសាលាគរុកោសល្យក្នុងដំណាក់កាលទី ២)។

រូបភាពទី ៦៖ ដ្យាក្រាមពន្យល់ពី RECTI

| | |
|---|---|
| **អក្សរកាត់** | • Rectification [Recti-]<br>• (នាម-១) ការកែប្រែ ការកែតម្រូវ (-២) ការកែសម្រួល (-៣) (អគ្គិសនី) ការបំប្លែង |
| **ឈ្មោះ** | • Regional Education Center Transferring Initiative<br>• ការបញ្ជូនព័ត៌មានដែលដឹកនាំដោយមជ្ឈមណ្ឌលអប់រំក្នុងតំបន់ |
| **វិធីសាស្ត្រ** | •វិធីសាស្ត្របញ្ជូនព័ត៌មានតាមរយៈសាលាគំរូ (សាលាគរុកោសល្យ/សាលាបឋមសិក្សា)<br>• ប្រព័ន្ធ Cascade មុនពេលណែនាំប្រព័ន្ធ Cluster |

ប្រភព៖ ដកស្រង់ចេញពីឯកសារបទបង្ហាញរបស់នាយក យ៉ាម៉ាហ្គូជិ (យ៉ាម៉ាហ្គូជិ, ២០១២)

ខ្ញុំគិតថានេះគឺដើម្បីឱ្យគ្រូឧទ្ទេសថ្នាក់តំបន់ដើរតួនាទីកណ្តាល និងធ្វើដំណើរទៅកាន់ខេត្តផ្សព្វផ្សាយជាមួយគ្រូឧទ្ទេសថ្នាក់ជាតិដើម្បីជំរុញការបញ្ចូលអប់រំកាយបែបថ្មី។បេះដូងមាសអនុវត្តគម្រោងនេះ ប៉ុន្តែគ្រាន់តែមានមុខងារគាំទ្រគ្រូឧទ្ទេសថ្នាក់ជាតិនិងគ្រូឧទ្ទេសថ្នាក់តំបន់របស់ក្រសួងអប់រំប៉ុណ្ណោះ និងបានជំរុញឱ្យពួកគេរៀបចំផែនការសិក្ខាសាលានិងការពិនិត្យតាមដានដោយខ្លួនឯង។ ក្រោយគម្រោងបានបញ្ចប់ ដោយស្នើទៅឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំថា នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតនឹងដឹកនាំការផ្សព្វផ្សាយចាប់ពីពេលនេះតទៅយើងបានគ្រោងទុកនូវគម្រោងដំណាក់កាលទី៣ ក្នុងគោលបំណងបញ្ចប់កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការផ្សព្វផ្សាយការអប់រំមុខវិជ្ជាអប់រំកាយនៅសាលាបឋមសិក្សា។ផ្អែកលើលទ្ធផលដែលសម្រេចបានក្នុងគម្រោង យើងនឹងបង្កើតនិងដាក់សំណើទៅក្រសួងអប់រំអំពីយុទ្ធសាស្ត្រអ្វីខ្លះដែលចាំបាច់ដើម្បីជំរុញការផ្សព្វផ្សាយអប់រំកាយនៅទូទាំងប្រទេសកម្ពុជានិងមានគោលដៅដើម្បីឱ្យការផ្សព្វផ្សាយអប់រំកាយបែបថ្មីនឹងបន្តទៅមុខទៀត នៅក្រោយគម្រោងបានបញ្ចប់។

## ប្រព័ន្ធត្រូវបានបង្កើតឡើង ប៉ុន្តែប្រឈមនឹងបញ្ហាថវិកា

គម្រោងនេះគឺជាគម្រោងដំបូងដែលអ្នកនិពន្ធបានបង្កើតបន្ទាប់ពីបានចូលរួមជាមួយអង្គការបេះដូងមាស។ ជាគម្រោងទី៣ របស់អង្គការបេះដូងមាស ហើយទោះបីជាគម្រោងនេះបានបន្តអស់រយៈពេលជិត ១០ឆ្នាំក៏ដោយវាបានផ្តោតជាពិសេសទៅលើនិរន្តរភាព។ ម្យ៉ាងទៀតគម្រោងនេះត្រូវបានរៀបចំឡើងដោយប្រើប្រាស់សមិទ្ធផលទទួលបានរហូតមកដល់ពេលនេះ ដូចជាវាយតម្លៃវឌ្ឍនភាពដែលសម្រេចបានក្នុងដំណាក់កាលមុន ពង្រីកខេត្តគោលដៅពី៥ ទៅ ១៥ ប្រើប្រាស់គ្រូដែលបានទទួលការបណ្តុះបណ្តាលនៅខេត្តទាំង៥ និងដំឡើងគ្រូឧទ្ទេសថ្នាក់ក្រោមជាតិទៅជាគ្រូឧទ្ទេសថ្នាក់ជាតិ(រូបភាពទី ៧)។

រូបភាពទី ៧៖ ដ្យាក្រាមរូបភាពគម្រោង

(គម្រោងអភិវឌ្ឍធនធានមនុស្ស និងបង្កើតប្រព័ន្ធផ្សព្វផ្សាយឯករាជ្យសម្រាប់អប់រំកាយនៅ សាលាបឋមសិក្សា)




[ការពន្យល់អក្សរកាត់]

MoEYS DPESS៖ ក្រសួងអប់រំ, នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត

PTTC៖ សាលាគរុកោសល្យគ្រូបឋមសិក្សា

POE៖ បុគ្គលិកមន្ទីរអប់រំខេត្ត

DOE៖ បុគ្គលិកការិយាល័យអប់រំស្រុក

BTB៖ បាត់ដំបង

REP៖ សៀមរាប

SNV៖ ព្រះសីហនុ

KRT៖ ក្រចេះ

SVR៖ ស្វាយរៀង

នៅចុងបញ្ចប់នៃគម្រោងគ្រូឧទ្ទេសថ្នាក់តំបន់ចំនួន៣០នាក់ត្រូវបានទទួលស្គាល់ដោយជោគជ័យហើយប្រព័ន្ធមួយត្រូវបានបង្កើតឡើងដើម្បីបន្តផ្សព្វផ្សាយអប់រំកាយនៅក្រោយគម្រោងបានបញ្ចប់។យ៉ាងណាមិញបញ្ហាថវិកាក៏បានលេចចេញផងដែរ។ថវិកាសម្រាប់រៀបចំសិក្ខាសាលានិងការពិនិត្យតាមដានដែលបានធ្វើឡើងក្នុងអំឡុងពេលគម្រោងក៏ដូចជាថ្លៃធ្វើដំណើរនិងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសម្រាប់អ្នកពាក់ព័ន្ធក្នុងគម្រោង នឹងមិនអាចបន្តបានទេ លុះត្រាតែភាគីកម្ពុជាធានាបាននូវថវិកានៅថ្នាក់ជាតិ ខេត្ត ស្រុក និងសាលារៀន។ បន្ទាប់ពីបញ្ចប់ដំណាក់កាលទី៣ នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតអាចបោះពុម្ពសៀវភៅគ្រូនិងរៀបចំសិក្ខាសាលាដោយប្រើថវិកាខ្លួនបាន។

ទោះជាយ៉ាងណាក៏ដោយទាក់ទងនឹងការផ្សព្វផ្សាយដល់២៤ខេត្ត១រាជធានីនៅទូទាំងប្រទេសកម្ពុជា ដែលមានគ្រូឧទ្ទេសថ្នាក់ជាតិចំនួនតែ១២នាក់ប៉ុណ្ណោះហើយត្រូវគ្របដណ្តប់ដល់គ្រប់ខេត្តនោះគឺពិតជាលំបាកខ្លាំងណាស់។ទោះបីជាល្បឿនអាចមានភាពយឺតយ៉ាវក៏ដោយប៉ុន្តែនៅចុងបញ្ចប់នៃគម្រោងក្នុងឆ្នាំ២០១៦វាត្រូវបានសម្រេចថានាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតនឹងអាចទទួលខុសត្រូវលើការផ្សព្វផ្សាយអប់រំកាយសម្រាប់សាលាបឋមសិក្សាបានហើយយើងក៏បន្តការផ្សព្វផ្សាយអប់រំកាយសម្រាប់អនុវិទ្យាល័យ ដែលបានចាប់ផ្តើមនៅឆ្នាំ ២០១៥។

ចំពោះតួនាទីនិងការលើកទឹកចិត្តរបស់មន្ត្រីមន្ទីរ/ការិយាល័យអប់រំខេត្ត/ស្រុកទោះបីពេលនេះអាចរៀបចំសិក្ខាសាលាជាដើមក៏ដោយក៏ពួកគេនៅតែមិនទាន់មានលទ្ធភាពក្នុងការធ្វើការពិនិត្យតាមដានថ្នាក់អប់រំកាយ ឬផ្តល់ដំបូន្មាននិងអនុសាសន៍ដល់សាលារៀនឡើយ។

# ជំពូកទី ៣

## ការផ្សព្វផ្សាយ «អប់រំកាយបែបថ្មី»

## ផ្នែកទី១៖ការលើកទឹកចិត្តចំពោះអប់រំកាយបែបថ្មីខុសគ្នាពីគ្រូបង្រៀនម្នាក់ទៅគ្រូបង្រៀនម្នាក់ទៀត

គ្រូដែលបានអនុវត្តលំហាត់ប្រាណបែបខ្មែររហូតមកដល់ពេលនេះ ត្រូវបានបង្ខំឲ្យអនុវត្ត«អប់រំកាយបែបថ្មី» នៅពេលគម្រោងចាប់ផ្តើម។ នៅពេលក្លាយជាគ្រូបង្រៀន ពួកគេមិនបានដឹងអំពីកម្មវិធីនេះនៅសាលាគរុកោសល្យទេ ដូចនេះពួកគេត្រូវតែរៀនតាំងពីដំបូង។ នេះអាចជាការល្អសម្រាប់គ្រូបង្រៀនវ័យក្មេងដែលទើបតែចាប់ផ្តើមអាជីពបង្រៀនប៉ុន្តែគ្រូបង្រៀនមួយចំនួនបានគិតថា ភ្លាមៗនោះពួកគេត្រូវតែបង្រៀនតេស្តកាយសម្បទាបន្ថែមលើមុខវិជ្ជារង ទាំង៦ បើទោះបីជាប្រាក់ខែរបស់ពួកគេមិនបានឡើងក៏ដោយ។ សម្រាប់គ្រូបង្រៀនទាំងនេះ ការបញ្ចូលអប់រំកាយបែបថ្មីហាក់ដូចជាមិនអាចទ្រាំទ្របាន។

គេអាចគិតថា មានអ្នកចូលរួម ២ ប្រភេទធំៗក្នុងអំឡុងពេលសិក្ខាសាលា។ ក្រុមមួយបានចូលរួមដើម្បីរៀនអំពីវិធីសាស្ត្រនៃការបង្រៀនអប់រំកាយបែបថ្មី។ ក្រុមមួយទៀត ជាអ្នកដែលបានចូលរួមក្នុងសិក្ខាសាលានេះ ក្នុងគោលបំណងដើម្បីទទួលបានប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ។ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៅក្នុងការយល់ដឹងអំពីបញ្ហារវាងគ្រូដែលមានទឹកចិត្តរៀនពីវិធីនៃការបង្រៀនអប់រំកាយបែបថ្មី និងគ្រូដែលមិនមានទឹកចិត្តរៀន។

លោកស្រី ញឹម សុខា នាយិការងសាលាបឋមសិក្សាអ៊ិនស៊ីដារ៉េ ក្នុងខេត្តបាត់ដំបង គិតថាគោលបំណងនៃអប់រំកាយបែបថ្មីនេះមិនត្រឹមតែធ្វើឱ្យសិស្សានុសិស្សមានភាពសប្បាយរីករាយប៉ុណ្ណោះទេប៉ុន្តែថែមទាំងធ្វើឱ្យសិស្សទទួលបានកម្លាំងកាយចំណេះដឹងជំនាញនិងការសហការផងដែរ។គាត់ជឿជាក់ថាគាត់អាចអភិវឌ្ឍសមត្ថភាពគិតរបស់សិស្សហើយលើសពីនេះទៀតអប់រំកាយអាចជួយបណ្តុះសិស្សដែលនឹងបន្តមានចំណាប់អារម្មណ៍ខ្លាំងលើកីឡានាពេលអនាគត។

ម្យ៉ាងទៀត លោក ព្រាប វន្ថា គ្រូបង្រៀននៅសាលាបឋមសិក្សាបាដាក ក្នុងខេត្តដូចគ្នានេះបានគិតថាគោលបំណងនៃអប់រំកាយបែបថ្មីគឺដើម្បីឱ្យសិស្សទាំងអស់ចូលរួមយ៉ាងសកម្មហើយតាមរយៈការបង្រៀនអប់រំកាយបែបថ្មីសិស្សនឹងទទួលបានចំណេះដឹងដែលបានពិពណ៌នានៅក្នុងសៀវភៅគ្រូ។ លោកបានមានប្រសាសន៍ថា «តាមរយៈការចូលរួមក្នុងសិក្ខាសាលា ខ្ញុំអាចទទួលបានចំណេះដឹងថ្មីៗដូចជារបៀបធ្វើផែនការប្រចាំឆ្នាំ និងកិច្ចតែងការបង្រៀន ហើយតាមរយៈការបង្រៀនអប់រំកាយបែបថ្មីសិស្សកាន់តែឆ្លាតជាងមុន»។ជាងនេះទៅទៀតក៏ឃើញមានការចូលរួមយ៉ាងសកម្មរបស់អាណាព្យាបាលសិស្សដូចជាការទិញសម្លៀកបំពាក់ហាត់ប្រាណសម្រាប់សិស្សជាដើម។

ដូចដែលបានរៀបរាប់ខាងលើ លោកគ្រូ អ្នកគ្រូ ដែលបានស្តាប់ការពិភាក្សាក្នុងសិក្ខាសាលាហើយកំពុងអនុវត្តអប់រំកាយបែបថ្មីនៅសាលាពិតជាមានអារម្មណ៍ខុសប្លែកពីអប់រំកាយពីមុនហើយពួកគេអាចដឹងថាកុមារអាចផ្លាស់ប្តូរបានតាមរយៈការបង្រៀន។ គ្រូបង្រៀនដែលអាចមានអារម្មណ៍អំពីភាពខុសគ្នានេះ គឺមានការលើកទឹកចិត្តយ៉ាងខ្លាំងចំពោះអប់រំកាយបែបថ្មី

ហើយនេះត្រូវបានគេគិតថាមានឥទ្ធិពលយ៉ាងខ្លាំងដល់ការផ្សព្វផ្សាយអប់រំកាយ។

## ផ្នែកទី២៖ ការលំបាកក្នុងការពិនិត្យតាមដាន ការបង្កើត «សហគមន៍អប់រំកាយ»

មន្ត្រីមកពីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស- និស្សិតបានចាប់ផ្តើមត្រួតពិនិត្យថ្នាក់រៀន«អប់រំកាយបែបថ្មី» នៅក្នុងគម្រោងដែលគាំទ្រដោយអង្គការបេះដូងមាស។ ដោយសារតួនាទីនៅក្រសួងអប់រំមន្ត្រីទទួលបន្ទុកមានឋានៈខ្ពស់ជាងគ្រូបង្រៀននៅតាមសាលារៀន ហើយជាធម្មតាគ្រូបង្រៀននៅតាមសាលាគឺស្ថិតក្នុងតួនាទី ដែលត្រូវនិយាយដោយគោរពនិងគួរសម។ ទោះជាយ៉ាងនេះក្តី បើនិយាយពីថ្នាក់អប់រំកាយវិញ គ្រូបង្រៀន គឺជាបុគ្គលតែមួយគត់ដែលអាចបង្រៀនអប់រំកាយដល់កុមារហើយមន្ត្រីក្រសួងអប់រំមិនអាចបង្រៀនអប់រំកាយជំនួសគ្រូបានទេ។ ដើម្បីឱ្យគ្រូអាចបង្រៀនកុមារនូវខ្លឹមសារ នៃកម្មវិធីសិក្សាដែលបង្កើតឡើងដោយគ្រូឧទ្ទេសថ្នាក់ជាតិនោះ ដំបូង ចាំបាច់ត្រូវកសាងទំនាក់ទំនងរវាងគ្រូឧទ្ទេសថ្នាក់ជាតិនិងគ្រូបង្រៀន ដើម្បីឲ្យពួកគេអាចនិយាយបានស្មើភាពគ្នា។សាស្ត្រាចារ្យអូកាដិយ៉ូស៊ីណូរិដែលបានចូលរួមក្នុងគម្រោងនេះបានហៅទំនាក់ទំនងល្អបែបនេះថាជា«សហគមន៍អប់រំកាយ»។គំនិតនៃសហគមន៍អប់រំកាយនេះបានរីករាលដាលបន្តិចម្តងៗក្នុងចំណោមមន្ត្រីទទួលបន្ទុកនៃនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត។

ក្នុងឆ្នាំ២០១២ គ្រូឧទ្ទេសថ្នាក់ជាតិមកពីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស- និស្សិតមានចំនួន៦នាក់ ហើយបន្ទាប់ពី៦នាក់ផ្សេងទៀតបានក្លាយជាគ្រូឧទ្ទេសថ្នាក់ក្រោមជាតិ គ្រូឧទ្ទេសថ្នាក់ក្រោមជាតិចំនួន៦នាក់បានក្លាយជាគ្រូឧទ្ទេសថ្នាក់ជាតិនៅឆ្នាំ២០១៦។ក្នុងចំណោមមនុស្សទាំង១២នាក់នេះមានមុខតំណែងខុសគ្នាហើយខ្ញុំគិតថាវាប្រហែលជាពិបាកសម្រាប់មន្ត្រីវ័យក្មេង និងមន្ត្រីជាស្ត្រីក្នុងការបញ្ចេញមតិរបស់ពួកគេ។ បន្ទាប់ពីការពិនិត្យតាមដានបានបញ្ចប់ គ្រូឧទ្ទេសថ្នាក់ជាតិនៃនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតនិងសមាជិកនៃអង្គការបេះដូងមាសបានប្រមូលផ្តុំគ្នាដើម្បីរៀបចំការប្រជុំវាយតម្លៃ។ ពួកគេម្នាក់ៗត្រូវផ្តល់ហេតុផលសម្រាប់ការវាយតម្លៃចំពោះការពិនិត្យតាមដានសាលា ប៉ុន្តែបន្ទាប់ពីអនុប្រធាននាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតបានមានប្រសាសន៍ដើមដំបូងគេរួចមក ខ្ញុំគិតថា គ្រូឧទ្ទេសថ្នាក់ជាតិផ្សេងទៀតប្រហែលជាពិបាកបញ្ចេញយោបល់។

## ការពង្រីកសហគមន៍អប់រំកាយគឺជាផ្លូវកាត់ក្នុងការផ្សព្វផ្សាយ

ដើម្បីតាមដាននិងវាយតម្លៃថ្នាក់អប់រំកាយដោយស្មើភាព និងលើកកម្ពស់គុណភាពថ្នាក់រៀនចាំបាច់ត្រូវវាយតម្លៃថ្នាក់រៀនដោយស្មើភាពដោយផ្ដោតតែលើថ្នាក់អប់រំកាយដោយមិនគិតពីមុខតំណែងឬស្ថាប័នការងារទេ។ក្នុងនាមជាអ្នកខាងក្រៅខ្ញុំបានព្យាយាមបង្កើតឱកាសនិងវិធីនៃការនិយាយដើម្បីឱ្យមនុស្សគ្រប់គ្នាអាចបញ្ចេញមតិដោយស្មើភាព។អ្វីដែលសាស្ត្រាចារ្យអ៊ូកាជិ បានប្រាប់នៅពេលនោះគឺថា គាត់នឹងពង្រីកសហគមន៍អប់រំកាយ។ ដើម្បីពង្រីក «អប់រំកាយ» យើងត្រូវការអ្នកគាំទ្រជាច្រើនបន្ថែមទៀត ហើយចាំបាច់ត្រូវមានការចូលរួមមិនត្រឹមតែពីគ្រូឧទ្ទេសថ្នាក់ជាតិ គ្រូបង្រៀន និងសិស្សានុសិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអ្នកដទៃទៀតផងដែរដូចជាអាណាព្យាបាលនិងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន។ ស្រដៀងគ្នានេះដែរ នៅលើបណ្ដាញសង្គមដូចជាហ្វេសប៊ុកយើងបានប្រមូលផ្ដុំមិត្តភក្តិឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដោយប្រើពាក្យគន្លឹះ «អប់រំកាយ»។

អង្គការយូណេស្កូក៏ដាក់ចេញនូវសហគមន៍សិក្សាវិជ្ជាជីវៈ ហើយវាមានសារៈសំខាន់សម្រាប់អ្នកអប់រំជួបប្រជុំគ្នាជាទៀងទាត់ដើម្បីចែករំលែកបទពិសោធន៍ និងសហការគ្នាដើម្បីកែលម្អវិធីសាស្ត្របង្រៀនរបស់ពួកគេ និងធ្វើឱ្យការសិក្សារបស់សិស្សកាន់តែប្រសើរឡើង (UNESCO)។អប់រំកាយមិនអាចទទួលបានប្រជាប្រិយភាពដោយគ្រូបង្រៀននៅសាលារៀនតែឯងទេ ប្រសិនបើគ្មានការចែករំលែកព័ត៌មានរវាងគ្រូបង្រៀន និងអ្នកគ្រប់គ្រងដូចជាគណៈគ្រប់គ្រងសាលាឬក្រៅពីសាលារៀននោះលំហូរនៃព័ត៌មាននឹងមិនអាចផ្សព្វផ្សាយបានទូលំទូលាយឡើយ ហើយគុណតម្លៃនៃបទពិសោធន៍ក៏មិនត្រូវបានពង្រីកផងដែរ។ នៅពេលដែលពួកគេយល់ពីវិធីបង្រៀនបានប្រសើរឡើងហើយ ពួកគេត្រូវចេះពន្យល់វាតាមទ្រឹស្ដីដល់គ្រូបង្រៀនដទៃទៀត។

ដូច្នេះ គ្រូឧទ្ទេសថ្នាក់ជាតិ មន្ត្រីមន្ទីរ/ការិយាល័យអប់រំខេត្ត/ស្រុក និងគណៈគ្រប់គ្រងសាលានិងលោកគ្រូអ្នកគ្រូចាំបាច់ត្រូវកសាងទំនាក់ទំនងល្អហើយការពង្រីកសហគមន៍អប់រំកាយគឺជាមធ្យោបាយដ៏លឿនបំផុតក្នុងការផ្សព្វផ្សាយអប់រំកាយ។ ដូចដែលគ្រូឧទ្ទេសថ្នាក់ជាតិ និងបុគ្គលិកនៃអង្គការបេះដូងមាសបាននិយាយការយល់ដឹងអំពីអប់រំកាយរបស់គណៈគ្រប់គ្រងសាលាគឺមានសារៈសំខាន់ណាស់ ហើយយើងមិនអាចបង្កើតប្រព័ន្ធផ្សព្វផ្សាយអប់រំកាយបានដោយគ្រាន់តែនិយាយជាមួយគ្រូអំពីអប់រំកាយបែបថ្មីនោះទេ។

1) https://www.unesco.org/sdg4education2030/en/sdg4education2030/knowledge-hub/teachers-teaching-teachers-professional-learning-community-educators

## អត្ថបទទី ៧៖ ដូរ៉ាអិម៉ុនក្នុងវិស័យអប់រំកាយ

សាស្ត្រាចារ្យ អ្ហកាជិ យ៉ូស៊ីណូរិ បានចូលរួមក្នុងគម្រោងគាំទ្រការអប់រំមុខវិជ្ជាអប់រំកាយ នៅប្រទេសកម្ពុជារបស់អង្គការបេះដូងមាសតាំងពីដើមមក។

នៅឆ្នាំ២០១២ ខ្ញុំបានចូលបម្រើការងារ ហើយនៅពេលដែលបានចូលរួមស្ដាប់ការបង្រៀនលើកដំបូងខ្ញុំពិតជាពិបាកយល់នូវអ្វីដែលគាត់និយាយណាស់។នេះអាចមកពីខ្លួនខ្ញុំផ្ទាល់មិនមានសាវតារផ្នែកអប់រំកាយ ប៉ុន្តែពេលខ្លះវាពិបាកក្នុងការប្រើវានៅក្នុងប្រទេសកម្ពុជា ពីព្រោះខ្ញុំត្រូវការចំណេះដឹងអំពីកម្មវិធីសិក្សានិងប្រព័ន្ធអប់រំកាយរបស់ប្រទេសនីមួយៗដើម្បីយល់ពីការពន្យល់អំពីពាក្យនិងគោលគំនិតពិបាកៗ និងយល់អំពីឧទាហរណ៍ក្នុងប្រទេសជប៉ុននិងជុំវិញពិភពលោក។ ដូច្នេះហើយ ខ្ញុំបានរកពេលវេលាក្នុងអំឡុងពេលសិក្ខាសាលា និងបានសួរសំណួរដល់សាស្ត្រាចារ្យ អ្ហកាជិ ដើម្បីឱ្យខ្ញុំអាចយល់បាន។

សាស្ត្រាចារ្យអ្ហកាជិមិនដែលប្រាប់មន្ត្រីក្រសួងអប់រំកម្ពុជាថា«ត្រូវតែធ្វើមួយនេះ»ឬ«ចូរធ្វើបែបនេះ»នោះទេ។ គាត់គិតថា នៅចុងបញ្ចប់ រឿងរបស់ប្រទេសកម្ពុជាគួរតែក្រសួងអប់រំកម្ពុជាជាអ្នកសម្រេចនិងអនុវត្តវា។ការដែលគាត់គោរពគោលជំហររបស់ភាគីម្ខាងទៀតហើយមិនបង្ខំឱ្យប្រើនូវវិធីសាស្ត្ររបស់ប្រទេសជប៉ុន ជាហេតុធ្វើឱ្យគាត់ត្រូវបានប្រជាជនខ្មែរគោរព និងកោតសរសើរ។ ជាងនេះទៅទៀត សាស្ត្រាចារ្យ អ្ហកាជិ ខ្លួនឯងគិតថា វាមិនសមរម្យសម្រាប់គាត់ក្នុងការចូលរួមជាអ្នកជំនាញតែម្នាក់គត់ដែលចូលរួមក្នុងគម្រោងនេះទេ ដោយគិតពីនិរន្តរភាពនៃគម្រោងនេះផងដែរ។ គាត់គិតដល់អ្នកដទៃណាស់ ធ្វើយ៉ាងណាដើម្បីកុំឲ្យមានបន្ទុកតែលើមនុស្សណាម្នាក់ដូចជាគាត់បានណែនាំសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យផ្សេងទៀតឱ្យចូលរួមផងដែរ។

នៅពេលខ្ញុំណែនាំសាស្ត្រាចារ្យ អ្ហកាជិ ដល់បុគ្គលិកអង្គការបេះដូងមាស ខ្ញុំបានពណ៌នាគាត់ថាជា«ដូរ៉ាអិម៉ុន»ក្នុងវិស័យអប់រំកាយ។នេះគឺដោយសារតែលោកបានផ្ដល់ឱ្យយើងនូវព័ត៌មានផ្សេងៗពីហោប៉ៅរបស់គាត់ហើយព័ត៌មាននីមួយៗគឺជាដំបូន្មានដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍអប់រំកាយនៅប្រទេសកម្ពុជា។

អ្នកដែលបានបង្រៀនយើងថាវាជារឿងសំខាន់ក្នុងការបង្កើត«សហគមន៍អប់រំកាយ» ដើម្បីផ្សព្វផ្សាយអប់រំកាយ ក៏ជាសាស្ត្រាចារ្យ អ្ហកាជិ ហើយការបង្រៀនរបស់គាត់បាននាំឱ្យមានសកម្មភាពដែលផ្សារភ្ជាប់គ្រូបង្រៀននៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀងតាមរយៈបណ្ដាញសង្គមផងដែរ។

រូបខ្ញុំដែលបានចូលរៀនកម្មវិធីអនុបណ្ឌិតនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រកីឡានីបប៉ុន(NIPPON) ក្នុងឆ្នាំ២០២០ ក៏បានទទួលការដឹកនាំពីសាស្ត្រាចារ្យ អូកាដិ អស់រយៈពេល២ឆ្នាំហើយមិនត្រឹមតែរបៀបសរសេរនិក្ខេបបទប៉ុណ្ណោះទេប៉ុន្តែថែមទាំងខ្លឹមសារក៏ត្រូវបានគាត់ជួយពិនិត្យមើលទៀតផងដែរ។ ម្យ៉ាងទៀត ដោយការសរសេរជាភាសាអង់គ្លេស ខ្ញុំជឿថានិក្ខេបបទនេះអាចប្រើប្រាស់ជាឯកសារយោងដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡានាពេលអនាគត។

សាស្ត្រាចារ្យ អូកាដិ ត្រូវបានតែងតាំងជាសាស្ត្រាចារ្យកិត្តិយសនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាក្នុងឆ្នាំ២០២០ រួមជាមួយនឹងលោកស្រី អារីម៉ូរី យូកុ នាយិកាតំណាងអង្គការបេះដូងមាស។ វាពិតជាសេចក្តីសោមនស្សរីករាយណាស់សម្រាប់វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដែលមានរូបពួកគាត់បន្តផ្តល់ការណែនាំដល់វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

## ផ្នែកទី ៧៖ ទាំងកម្មវិធីសិក្សានិងសៀវភៅគ្រូគឺជាឯកសារផ្លូវការ

រឿងមួយទៀតដែលត្រូវពិចារណានៅពេលផ្សព្វផ្សាយ«អប់រំកាយបែបថ្មី»គឺមុខងារនៃកម្មវិធីសិក្សានិងសៀវភៅគ្រូ។នៅប្រទេសជប៉ុនកម្មវិធីសិក្សាត្រូវបានប្រកាសដោយក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយមានកាតព្វកិច្ចស្របច្បាប់។ ឯកសារដូចជាសៀវភៅគ្រូនិងសៀវភៅពន្យល់កម្មវិធីសិក្សាលម្អិតត្រូវបានចាត់ទុកថាជាឯកសារយោងដែលបង្កើតឡើងដោយក្រុមហ៊ុនបោះពុម្ពនីមួយៗហើយមិនមានកាតព្វកិច្ចស្របច្បាប់ទេ។ផ្ទុយទៅវិញនៅក្នុងប្រទេសកម្ពុជា ឯកសារទាំងពីរនេះមានការអនុម័តពីរដ្ឋមន្ត្រីក្រសួងអប់រំ និងមានកាតព្វកិច្ចស្របច្បាប់។ ដូច្នេះ តើឯកសារទាំង២នេះខុសគ្នាយ៉ាងណា?

កម្មវិធីសិក្សាពិពណ៌នាអំពី«អ្វីដែលត្រូវរៀនក្នុងមុខវិជ្ជាអប់រំកាយ»នៅកម្រិតនីមួយៗ នៃបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ ទោះបីជាខ្លឹមសារគោលនៃមេរៀនជាក់ស្តែងត្រូវបានផ្តល់ជូនក៏ដោយ ការបង្រៀន«អប់រំកាយបែបថ្មី» ដោយផ្អែកលើកម្មវិធីសិក្សាតែមួយនោះពិតជាលំបាកខ្លាំងណាស់សម្រាប់គ្រូបង្រៀនដែលមិនបានសិក្សាពី«អប់រំកាយបែបថ្មី»ជាពិសេសគ្រូបង្រៀនបច្ចុប្បន្ន ។

សៀវភៅគ្រូ គឺជាសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ដូចដែលបានសរសេរជាភាសាអង់គ្លេសថា«Teachers′Manual»។នៅក្នុងថ្នាក់អប់រំកាយជាក់ស្តែងគ្រូបង្រៀនត្រូវបង្កើតផែនការប្រចាំឆ្នាំ ផែនការមេរៀន និងកិច្ចតែងការបង្រៀន ហើយសៀវភៅគ្រូត្រូវបានកែសម្រួលដើម្បីឱ្យពួកគេបង្កើតឯកសារទាំងនេះ។




ប្រភព៖ កម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា (MoEYS, ២០០៧)



ប្រភព៖ សៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា (MoEYS, ២០១៤)

នៅប្រទេសជប៉ុនគ្រូបង្រៀនមានគំនិតសម្រាប់វិធីសាស្ត្របង្រៀនរបស់ពួកគេសមត្ថភាពក្នុងការ ពិនិត្យតាមដានស្ថានភាពនៃការអភិវឌ្ឍន៍ និងសមិទ្ធផលរបស់សិស្ស និងមានវិធីគិតផ្ទាល់ខ្លួន ដូច្នេះការពន្យល់កម្មវិធីសិក្សាមិនមានខ្លឹមសារលម្អិតច្រើនទេ។ យ៉ាងណាមិញក្នុងករណីប្រទេសកម្ពុជា ប្រសិនបើយើងទុកឱ្យគ្រូបង្រៀនបញ្ចេញគំនិតរបស់ខ្លួនឯង នោះនឹងកើតឡើងនូវស្ថានការណ៍ដែលមិនដឹងថាត្រូវធ្វើអ្វីនោះទេ។ ដូច្នេះ ជាឧទាហរណ៍ ចំនួនម៉ោងនៃបាល់ទាត់ត្រូវបានកំណត់១០ម៉ោងហើយប្រភេទកីឡាត្រូវបានបញ្ជាក់ថាជា«ល្បែងបាល់ទាត់ខ្សែ» សម្រាប់សិស្សថ្នាក់ទី៤។ នៅពេលចុះ ពិនិត្យតាមដាន បុគ្គលិកក្រសួងអប់រំនឹងពិនិត្យជាមួយគ្រូបង្រៀន ប្រសិនបើសិស្សថ្នាក់ទី៤កំពុងរៀនបាល់ទាត់ផ្សេងវិញ (ឧទាហរណ៍ បាល់ទាត់ដែលបង្រៀនក្នុងថ្នាក់ផ្សេងទៀត ដូចជាល្បែងបាល់ចត្រង្គ ឬល្បែងបាល់ទាត់ទី២)។ នៅក្នុងការគិតរបស់ជនជាតិជប៉ុននៅពេលពិចារណាលើការរៀនរបស់សិស្សគេអាចគិតថាមានករណីខ្លះដែលល្បែងបាល់ទាត់ទី២ឬល្បែងបាល់ចត្រង្គអាចដំណើរការប្រកបដោយប្រសិទ្ធភាពបាននៅក្នុងថ្នាក់ទី៤ ដូច្នេះប្រហែលជាមានការងឿងឆ្ងល់ថាការពិនិត្យបែបនេះគឺមិនចាំបាច់ទេ។ យ៉ាងណាមិញនៅពេលគិតតាមទស្សនៈនៃការផ្សព្វផ្សាយ«អប់រំកាយបែបថ្មី» នៅក្នុងប្រទេសកម្ពុជា វាជាការល្អសម្រាប់សាលារៀនដែលមានសិក្ខាសាលា និងការពិនិត្យតាមដានត្រូវបានធ្វើឡើងប៉ុន្តែនៅពេលពិចារណាលើការផ្សព្វផ្សាយដល់សាលារៀន

ផ្សេងទៀត គេអាចមើលឃើញថា វានឹងមានប្រសិទ្ធភាពជាងក្នុងការមានខ្លឹមសារដែលមានភាពថេរសម្រាប់ការបង្រៀន ជាជាងការផ្តល់សេរីភាពដល់គ្រូបង្រៀនច្រើនពេក។

# ជំពូកទី ៤

## អំណោយផលចំពោះជំនួយផ្នែកអប់រំមុខវិជ្ជាអប់រំកាយ

## ផ្នែកទី១៖ ការពង្រីកកិច្ចសហប្រតិបត្តិការពីបឋមសិក្សាដល់អនុវិទ្យាល័យ ភ្លាមៗនោះផ្លូវបានបើក

អង្គការបេះដូងមាសបានចាប់ផ្តើមធ្វើការលើជំនួយផ្នែកអប់រំមុខវិជ្ជាអប់រំកាយសម្រាប់អនុវិទ្យាល័យបន្ទាប់ពីបានធ្វើការលើជំនួយផ្នែកអប់រំមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា។ ផ្លូវទៅកាន់គោលដៅនោះស្រាប់តែបានបើកភ្លាមៗ នៅពេលដែលស្ថានភាពជុំវិញពិភពលោករួមទាំងប្រទេសកម្ពុជា និងប្រទេសជប៉ុនបានផ្លាស់ប្តូរ។

នៅពេលដែលព្រឹត្តិការណ៍កីឡាអូឡាំពិកទីក្រុងតូក្យូឆ្នាំ២០១៤ត្រូវបានគេសម្រេចថានឹងប្រារព្ធឡើងក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រីអាបេស៊ីនហ្សូនៅពេលនោះអគ្គនាយកដ្ឋានកីឡាជប៉ុនបានជំរុញសកម្មភាព«កីឡាសម្រាប់ថ្ងៃស្អែក» ដើម្បី « ផ្តល់តម្លៃនៃអប់រំកាយនិងកីឡារបស់ប្រទេសជប៉ុនដល់មនុស្ស ១០លាននាក់ នៅក្នុងប្រទេសចំនួន១០០ ជុំវិញពិភពលោក» និងបានចាប់ផ្តើមទទួលយកពាក្យសុំសម្រាប់គម្រោងក្នុងទម្រង់ជាគម្រោងការរួមចំណែកអន្តរជាតិទ្វេភាគីជាយុទ្ធសាស្ត្រ។កន្លងមកអង្គការបេះដូងមាសធ្លាប់ត្រូវបានក្រសួងអប់រំស្នើសុំឱ្យជួយឧបត្ថម្ភដល់អប់រំកាយនៅអនុវិទ្យាល័យ។ក៏ប៉ុន្តែដោយសារតែការលំបាកក្នុងការធានាបាននូវថវិកានិងការដែលថាអប់រំកាយនៅសាលាបឋមសិក្សាមិនទាន់មានគ្រឹះរឹងមាំនៅឡើយទើបមានការស្ទាក់ស្ទើរក្នុងការផ្លាស់ប្តូរទៅអនុវិទ្យាល័យ។ប៉ុន្តែភ្លាមៗនោះតាមរយៈការបើកដំណើរការនៃគម្រោងកីឡាសម្រាប់ថ្ងៃស្អែក ផ្លូវនោះក៏ត្រូវបានបើក។

នៅពេលនោះបេះដូងមាសកំពុងធ្វើការលើកម្មវិធីភាពជាដៃគូ«គម្រោងអភិវឌ្ឍធនធានមនុស្ស និងបង្កើតប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៃការអប់រំមុខវិជ្ជាអប់រំកាយសម្រាប់បឋមសិក្សា» (ឆ្នាំ២០១៣-២០១៦) ហើយមិនមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីបែងចែកការងារដល់គម្រោងអនុវិទ្យាល័យទេ។ ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលសកម្មភាពនៅក្នុងសាលាបឋមសិក្សាកំពុងត្រូវបានផ្តោតជាចម្បងសម្រាប់ការផ្សព្វផ្សាយកង្វះកម្មវិធីសិក្សាសម្រាប់អនុវិទ្យាល័យត្រូវបានទទួលស្គាល់ថាជាបញ្ហាជាយូរមកហើយ ហើយក្រសួងអប់រំបានស្នើសុំការគាំទ្រសម្រាប់គម្រោងនេះ។

យើងមិនអាចរំលងឱកាសដែលមានតែម្តងក្នុងមួយជីវិតនេះបានទេ។ ភ្លាមៗនោះយើងបានចាប់ផ្តើមបំពេញពាក្យគម្រោងកីឡាសម្រាប់ថ្ងៃស្អែក។ជាដំបូងដើម្បីបង្កើតកម្មវិធីសិក្សាយើងបានចាប់ផ្តើមដោយការយល់ដឹងអំពីស្ថានភាពជាក់ស្តែងនៃអប់រំកាយនៅអនុវិទ្យាល័យ។យើងក៏បានសម្រេចរួមបញ្ចូលក្នុងពាក្យសុំនូវដំណើរការបញ្ជាក់ពីទិសដៅនៃរបៀបដែលកម្មវិធីសិក្សានឹងត្រូវបានអភិវឌ្ឍ ជាគម្រោងស្រាវជ្រាវ។

នៅឆ្នាំ២០១៤ពាក្យស្នើសុំត្រូវបានអនុម័តដោយជោគជ័យទោះបីជាយើងបានបំពេញពាក្យក្នុង រយៈពេលកំណត់មួយក៏ដោយ។ យើងគិតថា ការដែលអាចបញ្ជាក់យ៉ាងច្បាស់នៅក្នុងពាក្យសុំថា យើងអាចកាត់បន្ថយនីតិវិធីដើម្បីចាប់ផ្តើមគម្រោង និងមានលទ្ធភាពខ្ពស់ក្នុងការ

សម្រេចបាននូវគោលដៅគម្រោង ដោយផ្អែកលើទំនាក់ទំនងដ៏យូរអង្វែងនៃកិច្ចសហប្រតិបត្តិការ និងការជឿទុកចិត្តរវាងបេះដូងមាស និងក្រសួងអប់រំ គឺជាគន្លឹះដែលគម្រោងត្រូវបានអនុម័ត។

## គ្មានអ្នកគ្រប់គ្រងគម្រោង

បញ្ហាដ៏ធំបំផុតក្នុងគម្រោងថ្មីនេះគឺការធានាបាននូវអ្នកគ្រប់គ្រងគម្រោង។ដោយសារខ្ញុំបានធ្វើជាប្រធានការិយាល័យអាស៊ីអាគ្នេយ៍តាំងពីឆ្នាំ២០១២ ហើយជាអ្នកគ្រប់គ្រងគម្រោងសម្រាប់គម្រោង JICA នៅពេលនោះ ខ្ញុំមិនអាចគ្រប់គ្រងគម្រោងទាំងពីរបានទេ ដូច្នេះខ្ញុំត្រូវការស្វែងរកអ្នកគ្រប់គ្រងគម្រោងសម្រាប់គម្រោងនេះជាបន្ទាន់។យើងបានផ្សាយជ្រើសរើសបេក្ខជនជាសាធារណៈដែរប៉ុន្តែយើងរកមិនបានភ្លាមៗនោះទេ។ជាសំណាងល្អលោកតេហ្សិកាកូជីដែលបានចូលនិវត្តន៍ពីសមាគមអ្នកស្ម័គ្រចិត្តអន្តរជាតិShantiក្នុងខែធ្នូ២០១៤ហើយកំពុងរស់នៅក្នុងប្រទេសកម្ពុជានៅពេលនោះ លោកអាចចាប់ផ្តើមធ្វើការបានភ្លាមៗតែម្តង។ ខ្ញុំគិតថាពេលវេលាពិតជាសំខាន់ណាស់។ ដូច្នេះ ចាប់ពីខែមករាដល់ខែមីនា ឆ្នាំ២០១៥ យើងអាចចាប់ផ្តើមគម្រោងស្រាវជ្រាវ ដើម្បីបង្កើតកម្មវិធីសិក្សាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិដោយជោគជ័យ។

ក្នុងខែមករា យើងបានធ្វើការសិក្សាអំពីស្ថានភាពបច្ចុប្បន្ននៃអប់រំកាយនៅក្នុងខេត្តចំនួនពីរគឺ កំពង់ចាម និងប៉ៃលិន ក្នុងខែកុម្ភៈ យើងបានធ្វើទស្សនកិច្ចសិក្សានៅប្រទេសជប៉ុនស្តីពីអប់រំកាយនៅអនុវិទ្យាល័យជប៉ុន ហើយនៅក្នុងខែមីនា យើងបានរៀបចំសិក្ខាសាលាដើម្បីពិនិត្យមើលទិសដៅនៃអប់រំកាយនៅអនុវិទ្យាល័យកម្ពុជា ដោយបានអញ្ជើញលោកគ្រូហារ៉ាយូ អ៊ីឈីនៃសាកលវិទ្យាល័យអូកាយ៉ាម៉ា។

អប់រំកាយនៅអនុវិទ្យាល័យខុសពីសាលាបឋមសិក្សាដោយមានគ្រូជំនាញអប់រំកាយ ដូច្នេះចំណេះដឹងមូលដ្ឋានរបស់គ្រូគឺខ្ពស់ជាងនៅសាលាបឋមសិក្សា។ ម៉្យាងវិញទៀតវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាដែលជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលបណ្តុះបណ្តាលគ្រូអប់រំកាយកម្រិតមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ក្នុងរយៈពេល២ឆ្នាំ បណ្តុះបណ្តាលគ្រូដោយប្រើវិធីបង្រៀនស្រដៀងនឹងការហ្វឹកហ្វឺនកីឡាដោយផ្តោតលើការពង្រឹងជំនាញ។ ខ្លឹមសារខុសឆ្ងាយពីវិធីនៃការបង្រៀនអប់រំកាយបែបថ្មី ដែលបង្រៀនសិស្សានុសិស្សទាំងអស់ក្នុងការអប់រំនៅសាលា ទាំងអ្នកដែលមិនពូកែកីឡា និងអ្នកដែលពូកែកីឡា ដើម្បីឲ្យពួកគេទាំងអស់អាចចូលរួមក្នុងសកម្មភាព។

## ភាពខុសគ្នាដែលបានបង្ហាញនៅក្នុងការសិក្សាស្ថានភាពជាក់ស្តែង

នៅខែមករា ឆ្នាំ២០១៥ ការសិក្សាស្ថានភាពជាក់ស្តែងត្រូវបានបែងចែកជា២ក្រុម និងបានចាប់ផ្តើមក្នុងពេលដំណាលគ្នា។ នាយកដ្ឋានទទួលបន្ទុកបឋមសិក្សា និងអនុវិទ្យាល័យ ក្នុងក្រសួងអប់រំយុវជន និងកីឡា ក៏មានភាពខុសគ្នាដែរ។ បន្ថែមពីលើនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ដែលទទួលបន្ទុកគម្រោងសាលាបឋមសិក្សា ដោយសារវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាទទួលបន្ទុកបណ្តុះបណ្តាលគ្រូបង្រៀនអនុវិទ្យាល័យ ដូចនេះបុគ្គលិកមកពីវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាត្រូវបានបញ្ចូលថ្មីទៅក្នុងសមាជិករបស់គម្រោង។ លោក កែវ សុចិត្រា មានប្រសាសន៍ថាវាពិបាកណាស់នៅពេលចាប់ផ្តើមធ្វើការជាមួយ មន្ត្រីមកពីវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។ សមាជិកនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ដែលដឹងអំពីអប់រំកាយនៅសាលាបឋមសិក្សា និងសមាជិកនៃវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាដែលមិនដឹងអំពីអប់រំកាយនៅសាលាបឋមសិក្សាមានវិធីគិតខុសគ្នា ហើយអ្នកចុងក្រោយនេះដំបូងមានគំនិតថា «អប់រំកាយ» = «ការហ្វឹកហាត់»។

ការសិក្សាស្ថានភាពជាក់ស្តែងនៅក្នុងខេត្តកំពង់ចាម ត្រូវបានធ្វើឡើងដោយនាយកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា លោក តេហ្សូកា ដែលជាប្រធានគម្រោង និងសមាជិកសរុបចំនួន ៨ នាក់មកពីវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា និងនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត។ នៅខេត្តប៉ៃលិន ការសិក្សាត្រូវបានធ្វើឡើងដោយនាយករងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា អ្នកនិពន្ធ និង៩នាក់ផ្សេងទៀត។ នៅខេត្តកំពង់ចាម និងប៉ៃលិន គេសង្កេតឃើញថាគ្រូកំពុងអនុវត្តដោយមិនមានវត្ថុបំណងជាក់លាក់នូវ«លំហាត់ប្រាណបែបខ្មែរ»ដែលអនុវត្តជាទម្លាប់ក្នុងប្រទេសកម្ពុជានិងប្រភេទកីឡាដែលងាយស្រួលបង្រៀនដូចជាបាល់ទាត់បាល់ទះនិងអត្តពលកម្មជាដើម។នៅខេត្តប៉ៃលិនក៏មានអនុវិទ្យាល័យមួយដែលអនុវត្តលំហាត់ប្រាណតាមវិទ្យុរបស់ជប៉ុន។ ម្យ៉ាងទៀត នៅតាមសាលារៀនមួយចំនួន ថ្នាក់អប់រំកាយរយៈពេល២ម៉ោងក្នុងមួយសប្តាហ៍ ត្រូវបានធ្វើឡើងត្រឹមតែ១ម៉ោង ឬ២ម៉ោងជាប់ៗគ្នាក៏មាន។

ការស្ទង់មតិបានបញ្ជាក់ថា គ្រូបង្រៀនស្ទើរតែទាំងអស់ចាប់អារម្មណ៍លើអប់រំកាយបែបថ្មី ហើយការអភិវឌ្ឍធនធានមនុស្សមានសារៈសំខាន់ណាស់។ ដើម្បីដាក់បញ្ចូលអប់រំកាយបែបថ្មី ចាំបាច់ត្រូវផ្លាស់ប្តូរខ្លឹមសារកម្មវិធីសិក្សារបស់វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដែលបណ្តុះបណ្តាលគ្រូប៉ុន្តែបុគ្គលិកនៃវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាមានអារម្មណ៍ច្របូកច្របល់ចំពោះការផ្លាស់ប្តូរភ្លាមៗនូវវិធីដែលពួកគេគិតអំពីការបណ្តុះបណ្តាលគ្រូ។ដូចដែលបានរៀបរាប់មកនេះមានភាពខុសគ្នានៃបទពិសោធន៍ធ្វើការងារលើគម្រោងខុសពីមន្ត្រីនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិត ហើយពួកគេពិបាកទទួលយកអប់រំកាយបែបថ្មីណាស់។

ទោះបីជាមានស្ថានភាពបែបនេះក៏ដោយដើម្បីបញ្ជ្រាបអប់រំកាយបែបថ្មីចាំបាច់ត្រូវបង្កើតភាពស៊ី សង្វាក់គ្នារវាងការបណ្តុះបណ្តាលគ្រូ និងការបណ្តុះបណ្តាលសម្រាប់គ្រូបច្ចុប្បន្ន

និងបង្កើតប្រព័ន្ធ អប់រំកាយមានសុគតភាពគ្នា។ ដូច្នេះហើយ គម្រោងនេះ ត្រូវអនុវត្តដោយគោរព ចំណេះដឹង និងបទពិសោធន៍របស់វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដែលមានការពាក់ព័ន្ធទាំង ការបណ្តុះបណ្តាលគ្រូ និងការបណ្តុះបណ្តាលសម្រាប់គ្រូបច្ចុប្បន្ន។

## ជាភាពដើមរបស់ប្រទេសកម្ពុជា

អ្វីដែលធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលចំពោះខេត្តប៉ៃលិន គឺបណ្តាញធំទូលាយនៃវិទ្យាស្ថានជាតិ អប់រំកាយនិងកីឡា។ ដោយសារវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាគឺជាគ្រឹះស្ថានបណ្តុះបណ្តាល គ្រូអប់រំកាយកម្រិតមធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិតែមួយគត់ដូច្នេះពួកគាត់ស្គាល់ និស្សិតបញ្ចប់ការសិក្សាទាំងអស់ដែលត្រូវបានចាត់តាំងជាគ្រូបង្រៀននៅតាមសាលានានា។ដោយសារ ជាគ្រឹះស្ថានរបស់ក្រសួងអប់រំផងដែរលោកគ្រូអ្នកគ្រូបានគោរព និងជឿជាក់លើពួកគេ។

ទស្សនកិច្ចសិក្សានៅប្រទេសជប៉ុនបានធ្វើឡើងក្នុងខែកុម្ភៈឆ្នាំ២០១៥ហើយអ្នកចូលរួម រួមមានឯកឧត្តមអ៊ុកសិទ្ធិជាតិដែលជាអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំនិងលោក ធម្ម អង្គារ៉ា នាយកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា និងអ្នកផ្សេងទៀត។ ដោយមានការណែនាំ ពីសាស្ត្រាចារ្យ អូកាជិ យ៉ូស៊ីណូរិ នៃសាកលវិទ្យាល័យ Tsukuba (ពេលនោះ) ពួកគេអាចទៅ ទស្សនាអនុវិទ្យាល័យជប៉ុននិងស្តាប់អំពីស្ថានភាពបច្ចុប្បន្ននៃអប់រំកាយនៅអនុវិទ្យាល័យនៅប្រទេស ជប៉ុនពីលោកតាកាហាស៊ី ស៊ូអ៊ីឈីដែលជាអ្នកត្រួតពិនិត្យមុខវិជ្ជាមកពីក្រសួងអប់រំវប្បធម៌កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

លើសពីនេះទៀតពួកគេក៏បានទៅទស្សនាខេត្តអូកាយ៉ាម៉ាទស្សនាសាលាបឋមសិក្សា និងអនុវិទ្យាល័យ ហើយបានទទួលការបង្រៀនដោយលោកគ្រូ ហារ៉ា មកពីសាកលវិទ្យាល័យ អូកាយ៉ាម៉ា។ជាពិសេសសម្រាប់មន្ត្រីមកពីវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាការដែលអាចមើលឃើញ ជាលើកដំបូងពីរបៀបដែលអប់រំកាយត្រូវបានបង្រៀននៅប្រទេសជប៉ុនក្នុងស្ថានភាពជាក់ស្តែងបែប ណានោះ បានធ្វើឱ្យមានបំណងប្រាថ្នាចង់ផ្សព្វផ្សាយអប់រំកាយនៅកម្ពុជា។ បន្ទាប់មក ថាតើត្រូវ បង្កើតកម្មវិធីសិក្សាសម្រាប់អនុវិទ្យាល័យដោយរបៀបណា បានលេចចេញជាបញ្ហាចម្បង។ នៅខែមីនាលោកគ្រូហារ៉ាបានមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជានិងបានបើកសិក្ខាសាលា រយៈពេលបីថ្ងៃដើម្បីពិភាក្សាអំពីទិសដៅបែបណាដែលកម្មវិធីសិក្សាអប់រំកាយសម្រាប់អនុវិទ្យាល័យ គួរតែត្រូវបានបង្កើតឡើង។គោលបំណងមិនត្រឹមតែបង្កើតកម្មវិធីសិក្សាប៉ុណ្ណោះទេប៉ុន្តែសិក្ខាសាលា ត្រូវបានរៀបចំឡើងជាចម្បង ដើម្បីស្រង់មតិពីមន្ត្រីក្រសួងអប់រំ ផ្តោតលើការងារជាក្រុមអំពី រឿងមួយចំនួនដូចជា «តើអ្នកចង់ឱ្យកីឡាមានការអភិវឌ្ឍក្នុងប្រទេសកម្ពុជាក្នុងរយៈពេល ១០ ឬ ២០ឆ្នាំក្រោយដោយរបៀបណា(រូបភាពទី៨)» «តើកុមារអាចរៀនអ្វីខ្លះតាមរយៈអប់រំកាយ ដោយ ផ្អែកលើវត្ថុបំណងនៃកម្មវិធីសិក្សា«ផ្អែកលើខ្លឹមសារនៃសាលាបឋមសិក្សាតើអនុវិទ្យាល័យគួរបញ្ចូល ប្រភេទកីឡាបែបណា»។

ជាលទ្ធផល ពួកគេបានគិតអំពីអនាគតនៃអប់រំកាយនៅកម្ពុជាជាភាសារបស់ពួកគេផ្ទាល់ ដោយយោងលើរចនាសម្ព័ន្ធអប់រំកាយនិងរបៀបនៃការគិតរបស់ប្រទេសជប៉ុន ហើយបានឯកភាពគ្នាថានឹងបង្កើត«កម្មវិធីសិក្សាដើមរបស់ប្រទេសកម្ពុជា»ដោយផ្អែកលើខ្លឹមសារនៃអប់រំកាយសម្រាប់សាលាបឋមសិក្សាកម្ពុជា និងស្ថានភាពកីឡាកម្ពុជានាពេលអនាគត។

គម្រោងស្រាវជ្រាវបានបញ្ចប់ហើយនៅក្នុងរបាយការណ៍គម្រោងស្រាវជ្រាវរយៈពេល៣ខែយើងបានដាក់សំណើទៅក្រសួងអប់រំដើម្បីបង្កើតរចនាសម្ព័ន្ធដែលអាចធ្វើសកម្មភាពជាក់លាក់ដោយបង្កើតគណៈកម្មាធិការកណ្តាលគណៈកម្មាធិការប្រតិបត្តិនិងគណៈកម្មាធិការបច្ចេកទេសសម្រាប់ការបង្កើតកម្មវិធីសិក្សាសម្រាប់អនុវិទ្យាល័យ។ ប្រសិនបើយើងអាចចាប់ផ្តើមគម្រោងបង្កើតកម្មវិធីសិក្សាភ្លាមៗគឺជាការល្អប៉ុន្តែការដាក់ពាក្យនិងការអនុម័តសម្រាប់គម្រោងបន្ទាប់បានចំណាយពេលវេលាយូរហើយពីខែមេសាដល់ខែកញ្ញាយើងមិនទាន់អាចចាប់ផ្តើមគម្រោងបានទេដូច្នេះគម្រោងបង្កើតកម្មវិធីសិក្សាអប់រំកាយសម្រាប់អនុវិទ្យាល័យបានចាប់ផ្តើមនៅដើមខែតុលាឆ្នាំ២០១៥។

រូបភាពទី ៨៖ ឯកសាររបស់លោកគ្រូ ហារ៉ា សម្រាប់ពិចារណាលើកម្មវិធីសិក្សាអប់រំកាយសម្រាប់អនុវិទ្យាល័យ (មួយផ្នែក) (ហារ៉ា, ២០១៥)



## ផ្នែកទី២៖ ក្នុងរយៈពេលដែលមានកំណត់ ការបណ្តុះបណ្តាលនៅប្រទេសថៃនិងសិង្ហបុរី

បន្ទាប់ពីគម្រោងស្រាវជ្រាវត្រូវបានបញ្ចប់ ចាប់ពីខែមេសា ឆ្នាំ២០១៥ យើងបានបន្តពិគ្រោះយោបល់អំពីគម្រោងជំនួយបង្កើតកម្មវិធីសិក្សាជាក់ស្តែង ជាមួយមជ្ឈមណ្ឌលជប៉ុនលើកកម្ពស់កីឡា ដែលទទួលបន្ទុកគម្រោងកីឡាសម្រាប់ថ្ងៃស្អែក។ ប៉ុន្តែ ដោយសារគម្រោងវិភាគទានអន្តរជាតិទ្វេភាគីជាយុទ្ធសាស្ត្រជាកម្មវិធីថ្មីការចាប់ផ្តើមនៃគម្រោងត្រូវបានពន្យារពេលយ៉ាងខ្លាំង។ ទោះបីជាទីបំផុតអាចចាប់ផ្តើមនៅខែតុលាឆ្នាំដដែលក៏ដោយ ប៉ុន្តែកាលកំណត់គឺរហូតដល់ខែធ្នូ ឆ្នាំ២០១៦ ដែលធ្វើឱ្យវាពិបាកក្នុងការបញ្ចប់កម្មវិធីសិក្សាក្នុងរយៈពេលដែលមានកំណត់។

គម្រោងជំនួយបង្កើតកម្មវិធីសិក្សាបានបញ្ចូលការបណ្តុះបណ្តាលនៅប្រទេសថៃនិងសិង្ហបុរី ដើម្បីឱ្យពួកគេបានឃើញមិនត្រឹមតែប្រព័ន្ធអប់រំកាយក្នុងប្រទេសជប៉ុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្ថានភាពជាក់ស្តែងនៃអប់រំកាយនៅក្នុងប្រទេសជិតខាងផងដែរដើម្បីយកមកពិចារណាថាអប់រំកាយនៅកម្ពុជាគួរតែធ្វើបែបណា។ ដោយទទួលបានការណែនាំពីសាស្ត្រាចារ្យ អូកាដិ យើងបានទៅទស្សនាសាកលវិទ្យាល័យស្រ៊ីនណាខារីនវីរ៉ូតវិទ្យាស្ថានអប់រំកាយ ក្រុមប្រឹក្សាអប់រំមូលដ្ឋាន និងអនុវិទ្យាល័យចំនួន៣នៅក្នុងប្រទេសថៃ។

នៅប្រទេសសិង្ហបុរីយើងបានទៅទស្សនាវិទ្យាស្ថានជាតិអប់រំនិងសាកលវិទ្យាបច្ចេកទេសណានយ៉ាង។ នៅទីនេះ ពួកគេបានដឹងថា ការអប់រំបានដាក់បញ្ចូលជាពិសេសនូវការអភិវឌ្ឍ «សមត្ថភាពដែលមិនអាចធ្វើការវាស់កម្រិតបាន (សមត្ថភាពក្នុងការស្រមើស្រមៃ សមត្ថភាពក្នុងការគិត សមត្ថភាពជំនាញទំនាក់ទំនង។ល។) ដែលហៅថាការអប់រំសតវត្សទី ២១ ការអប់រំនៅកម្ពុជាទាំងមូលគឺផ្អែកលើការអប់រំរបស់សិង្ហបុរីហើយពេលខ្លះអប់រំកាយត្រូវបានបង្រៀនក្នុងថ្នាក់អប់រំកាយពិសេសមួយ ដែលជាផ្នែកមួយនៃការអប់រំសតវត្សទី ២១។

ពួកគេក៏បានសិក្សាអំពីតួនាទីនៃអប់រំកាយនិងសុខភាព ការអភិវឌ្ឍធនធានមនុស្សដែលអាចបង្រៀនមិនត្រឹមតែអប់រំកាយប៉ុណ្ណោះទេថែមទាំងមុខវិជ្ជាផ្សេងទៀតនិងការលំបាកក្នុងការបញ្ចូលកម្មវិធីសិក្សានៅក្នុងសាលារៀនជាក់ស្តែងទោះបីជាបានបង្កើតកម្មវិធីសិក្សាក៏ដោយ។ នៅពេលបង្កើតកម្មវិធីសិក្សានៅកម្ពុជា យើងក៏អាចបញ្ជាក់ពីបំណងប្រាថ្នារបស់មន្ត្រីក្រសួងអប់រំក្នុងការបញ្ជូនកម្មវិធីសិក្សាដោយភាពប្រាកដប្រជាទៅសាលារៀនជាក់ស្តែង។

ក្នុងការបង្កើតកម្មវិធីសិក្សា គំនិតនៃ «Quality Physical Education» របស់អង្គការយូណេស្កូ ដែលណែនាំដោយសាស្ត្រាចារ្យ អូកាដិ យ៉ូស៊ីណូរិ បានក្លាយជាសសរស្តម្ភក្នុងការគិតអំពីវត្ថុបំណងនិងខ្លឹមសារ។

ធម្មនុញ្ញអន្តរជាតិ ស្តីពីអប់រំកាយ សកម្មភាពរាងកាយ និងកីឡា ឆ្នាំ២០១៥ ចែងថា «ការអនុវត្តអប់រំកាយសកម្មភាពរាងកាយនិងកីឡាគឺជាសិទ្ធិជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នា

»ហើយថាការបន្ថែមសកម្មភាពរាងកាយធានាសិទ្ធិរបស់មនុស្សក្នុងការធ្វើលំហាត់ប្រាណប្រចាំថ្ងៃក៏ដូចជាអប់រំកាយ និងកីឡា (UNESCO, ២០១៥)។

ម្យ៉ាងទៀត នៅក្នុង «Quality Physical Education - Guidelines for Policy Makers»(UNESCO,២០១៥)បានលើកឡើងថាដើម្បីបង្កើតអប់រំកាយប្រកបដោយគុណភាព «ការគ្រប់គ្រងសុវត្ថិភាព បរិយាបន្ន និងអក្ខរកម្មរូបវន្ត គួរតែត្រូវបានផ្តល់ជូនជាស្នូល ហើយដើម្បីសម្រេចបាននូវចំណុចនេះ យើងត្រូវអភិវឌ្ឍការបណ្តុះបណ្តាលគ្រូ សម្ភារៈបរិក្ខារនិងសម្ភារៈឧបទេស ភាពបត់បែននៃកម្មវិធីសិក្សា ការចូលរួមរបស់សហគមន៍ ការតាមដាននិងការធានាគុណភាពស្របតាមយុទ្ធសាស្ត្រជាតិ» ហើយវាគួរតែត្រូវបានធ្វើតាមរយៈការជួយគាំទ្រនិងទំនាក់ទំនង (UNESCO, ២០១៥)។

រូបភាពទី ៩៖ លក្ខណៈពិសេសនៃអប់រំកាយប្រកបដោយគុណភាពនិងបរិយាបន្ន



## ធ្វើសិក្ខាសាលាម្តងហើយម្តងទៀត

ជាក់ស្តែង « សិក្ខាសាលាស្តីពីការបង្កើតកម្មវិធីសិក្សា» ចំនួន៧ត្រូវបានរៀបចំឡើងដើម្បីបង្កើតសេចក្តីព្រាងអំពីកម្មវិធីសិក្សា ហើយផ្អែកលើសេចក្តីព្រាងដែលបានបង្កើតឡើងក្នុងអំឡុងពេលនោះយើងបានធ្វើឡើងវិញនូវដំណើរការបើក«សិក្ខាសាលាអប់រំកាយ»ចំនួន២ដងនៅក្នុងខេត្តនីមួយៗ ដោយឱ្យគ្រូបង្រៀននៅខេត្តបាត់ដំបង និងខេត្តស្វាយរៀង សាកល្បងថ្នាក់អប់រំកាយ។ អ្វីដែលពិបាកបំផុតនោះគឺថា យើងបានចាត់តាំងអ្នកទទួលខុសត្រូវលើខ្លឹមសារនៃកម្មវិធីសិក្សាទៅតាមប្រភេទនីមួយៗ ហើយឱ្យពួកគេបង្កើតសេចក្តីព្រាងសម្រាប់ប្រភេទនីមួយៗ ដែលធ្វើឱ្យមិនអាចមានសុគតភាពគ្នារវាងប្រភេទទាំងនោះ។

នៅក្នុងសិក្ខាសាលាមួយដែលធ្វើឡើងចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦ ដោយបានអញ្ជើញលោកសាស្ត្រាចារ្យ សាតូ យូតាកា នៃសាកលវិទ្យាល័យថូអ៊ីនយ៉ូកូហាម៉ា កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីកំណត់ស្តង់ដារនៃធាតុនិងរបៀបសរសេរវត្ថុបំណងនៃឥរិយាបថ ចំណេះដឹង ជំនាញ និងការសហការ។ ជាឧទាហរណ៍ វត្ថុបំណងនៃកម្មវិធីសិក្សាឥឡូវនេះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់អំពីអ្វីដែលសិស្សរំពឹងថានឹងត្រូវសម្រេចបាន ដូចជា «អាច...»សម្រាប់ជំនាញ និង «យល់ដឹងពី...» សម្រាប់ចំណេះដឹង។ ការសរសេរពីមុនមានការមិនសុគតភាពគ្នា ប៉ុន្តែតាមរយៈសិក្ខាសាលា ឧទាហរណ៍ ក្បួននៃរបៀបសរសេរត្រូវបានបង្កើតឡើង ហើយពិតជាអស្ចារ្យណាស់ដែលឃើញរបៀបសរសេរឱ្យមានសុគតភាពគ្នា។

សាស្ត្រាចារ្យរងស៊ុបប្រានីខ្វាន់ប៊ុណចាន់នៃសាកលវិទ្យាស្រ៊ីនណាខារីនវីរ៉ូតនៃប្រទេសថៃ ក៏បានមកទស្សនកិច្ចនៅកម្ពុជា ហើយបានបង្រៀន និងអនុវត្តអំពីអក្ខរកម្មរូបវន្តផងដែរ។ គ្រូបង្រៀននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាបានរីកចម្រើន ដោយស្រូបយកចំណេះដឹងថ្មីៗបន្តិចម្តងៗអំពីរបៀបបង្រៀនថ្នាក់អប់រំកាយ។ការអនុម័តកម្មវិធីសិក្សាត្រូវការរយៈពេល២ទៅ៣ខែ សម្រាប់នីតិវិធីអនុម័តនៅក្រសួងអប់រំយុវជន និងកីឡា ដូច្នេះយើងបានដាក់គោលដៅបញ្ចប់សេចក្តីព្រាងចុងក្រោយនៅខែតុលាឆ្នាំ២០១៦ប៉ុន្តែរហូតមកដល់ចុងខែតុលានេះនៅតែមិនទាន់បានបញ្ចប់កម្មវិធីសិក្សាដ៏ស៊ីសង្វាក់គ្នាទាំងស្រុងនៅឡើយ។

## ជឿជាក់លើអង្គការបេះដូងមាស

នៅក្នុងសិក្ខាសាលាចុងក្រោយយើងបានបញ្ជាក់ថាតើត្រូវធានាឱ្យមានភាពស៊ីសង្វាក់គ្នាបែបណា។ អ្នកនិពន្ធបានបន្តនិយាយថា « កម្មវិធីសិក្សានឹងមិនអាចបញ្ចប់បានទេប្រសិនបើដូចពេលនេះ។យើងសូមឱ្យបោះបង់ការបញ្ចប់នៅខែធ្នូហើយពិចារណាថាតើក្រសួងអប់រំនឹងបន្តសរសេរបន្ទាប់ពីឆ្នាំ២០១៧ ឬមួយទុកការងារឱ្យបេះដូងមាសដើម្បីបញ្ជាក់ពីសុគតភាពគ្នា»។

ហេតុផលនៅពីក្រោយសំណើនេះគឺថា ក្រសួងអប់រំប្រហែលជាមិនចង់ពន្យារពេលបង្កើតនូវកម្មវិធីសិក្សានោះទេ។ នេះគឺដោយសារតែវាត្រូវបានបញ្ចូលទៅក្នុងផែនការប្រចាំឆ្នាំរបស់នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ហើយខ្ញុំគិតថា ទោះបីជាយើងពន្យារពេលក៏ដោយ ក៏ក្រសួងអប់រំយុវជន និងកីឡានឹងមិនអាចបញ្ចេញយោបល់ទាក់ទងនឹងយុទ្ធសាស្ត្រកែសម្រួលការសរសេរកម្មវិធីសិក្សាក្នុងទម្រង់មិនស៊ីសង្វាក់គ្នាផងដែរ។ ដូចការរំពឹងទុក មន្ត្រីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាបានប្រាប់យើងថាក្រសួងអប់រំគ្រោងនឹងបញ្ចប់គម្រោងនៅក្នុងឆ្នាំ២០១៦ហើយពួកគេចង់ឱ្យអង្គការបេះដូងមាសជួយដោះស្រាយការងារកែសម្រួលចុងក្រោយ។

ដូច្នេះអ្នកនិពន្ធបានកែសម្រួលសេចក្តីព្រាងដែលរៀបចំដោយមន្ត្រីក្រសួងអប់រំធ្វើការផ្ទៀងផ្ទាត់ចុងក្រោយជាភាសាអង់គ្លេស ហើយបន្ទាប់មក មន្ត្រីគម្រោង លោក កែវ សុចិត្រា បានធ្វើការបកប្រែពេញមួយយប់។ ទីបំផុត នៅពាក់កណ្តាលខែវិច្ឆិកា ការងារអនុម័តបានចាប់ផ្តើមដោយបានសម្របសម្រួលជាមួយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ កម្មវិធីសិក្សាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិកម្ពុជាត្រូវបានទទួលការអនុម័តដោយឯកឧត្តមបណ្ឌិតសភាចារ្យហង់ជួន ណារ៉ុនរដ្ឋមន្ត្រីក្រសួងអប់រំ ហើយនៅថ្ងៃទី២១ ក្នុងខែដដែល «ពិធីអនុម័តកម្មវិធីសិក្សាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិកម្ពុជា» ត្រូវបានប្រារព្ធឡើងក្រោមអធិបតីភាព ឯកឧត្តមរដ្ឋមន្ត្រី ហង់ជួន ណារ៉ុន និង ឯកឧត្តម យ៉ូស៊ិអ៊ីអ៊ិ ហ៊ីរ៉ូយ៉ូគិ អនុរដ្ឋមន្ត្រីក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជប៉ុន ឯកឧត្តម ហូរិណុអ៊ូជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃស្ថានទូតជប៉ុនប្រចាំកម្ពុជា លោកនាយក ខារ៉ាហារា តាគូមិ នៃសម្ព័ន្ធកីឡាសម្រាប់ថ្ងៃស្អែក នៃមជ្ឈមណ្ឌលលើកកម្ពស់កីឡាជប៉ុន លោក អាដាឈិ អ៊ីហ៊្សូ ប្រធានការិយាល័យ JICA ប្រចាំកម្ពុជា សាស្ត្រាចារ្យអូកាដិ យ៉ូស៊ីណូរិផ្នែកអប់រំកាយនៃសាកលវិទ្យា Tsukuba និងលោកស្រីអារីម៉ូរី យូកុ នាយិកាតំណាងអង្គការក្រៅរដ្ឋាភិបាលមិនរកប្រាក់ចំណូល អង្គការបេះដូងមាស និងអ្នកដទៃទៀត។



ពិធីអនុម័តកម្មវិធីសិក្សាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិកម្ពុជា(ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦)

## ផ្នែកទី ៣៖ ការបញ្ចប់សេចក្តីណែនាំកម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាបឋមភូមិ ការងារដែលបន្សល់ទុកក្នុងប្រវត្តិសាស្ត្រអប់រំ

ការបញ្ចប់សេចក្តីណែនាំកម្មវិធីសិក្សានៅកម្ពុជាមិនត្រឹមតែជាការបង្កើតកម្មវិធីសិក្សាប៉ុណ្ណោះទេប៉ុន្តែថែមទាំងមានឥទ្ធិពលលើពិភពលោកទាក់ទងនឹងការគាំទ្រយ៉ាងយកចិត្តទុកដាក់របស់ប្រទេសជប៉ុនក្នុងការបង្កើតកម្មវិធីសិក្សាតាមរយៈគម្រោងកីឡាសម្រាប់ថ្ងៃស្អែក និងការរួមចំណែកក្នុងSDGs។

ឯកឧត្តម ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំបានចូលរួមក្នុងពិធីបិទបញ្ចប់ ធ្វើឡើងនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ ដោយបានថ្លែងសុន្ទរកថាដូចខាងក្រោម៖

ក្នុងឱកាសពិធីអនុម័តកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិដ៏វិសេសវិសាលនេះ តាងនាមក្រសួងអប់រំ លោកគ្រូ អ្នកគ្រូទាំងអស់ សិស្សសាលាបឋមសិក្សាចំនួន ២ លាននាក់ និងសិស្សអនុវិទ្យាល័យចំនួន ៣០ ម៉ឺននាក់ ដែលជាអ្នកទទួលផលពីកម្មវិធីសិក្សាលម្អិតនិងសៀវភៅគ្រូខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមអនុរដ្ឋមន្ត្រីក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃប្រទេសជប៉ុន ឯកឧត្តមឯកអគ្គរាជទូតវិសាមញ្ញ និងកម្លាំងពេញសមត្ថភាពនៃប្រទេសជប៉ុនប្រចាំកម្ពុជា លោកប្រធានការិយាល័យ JICA ប្រចាំកម្ពុជា ប្រធានសម្ព័ន្ធកីឡាសម្រាប់ថ្ងៃស្អែក នៃមជ្ឈមណ្ឌលលើកកម្ពស់កីឡាជប៉ុន និងនាយិកាតំណាងអង្គការមិនរកប្រាក់ចំណេញបេះដូងមាស។

ជាពិសេស បុគ្គលិកនៃក្រសួងអប់រំ និងអង្គការបេះដូងមាស ដែលបានចូលរួមក្នុងគម្រោងនេះ បានបំពេញភារកិច្ចរៀងៗខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសហការគ្នាជំនះការលំបាកក្នុងដំណើរការចងក្រងកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយដែលត្រូវបានអនុម័ត និងអនុវត្តនៅទូទាំងប្រទេសកម្ពុជា ហើយសម្រេចបានកិច្ចការដែលបន្សល់ទុកក្នុងប្រវត្តិសាស្ត្រអប់រំនៅកម្ពុជា។

លើសពីនេះឯកឧត្តមអនុរដ្ឋមន្ត្រីយ៉ូស៊ិអ៊ីអ៊ិក៏បានសង្កត់ធ្ងន់ថាកម្ពុជាគឺជាគំរូជោគជ័យដំបូងគេ ក្នុងគម្រោងគាំទ្រដល់ការបង្កើតកម្មវិធីសិក្សាអប់រំកាយ។ លោកបានមានប្រសាសន៍ថា លោកជឿជាក់ថាគម្រោងនេះបានបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងនៃការជឿទុកចិត្តគ្នារវាងបេះដូងមាសដែលបានធ្វើសកម្មភាពជាយូរមកនៅក្នុងប្រទេសកម្ពុជា និងក្រសួងអប់រំ ហើយខ្លឹមសារនៃសិក្ខាសាលាជាដើមត្រូវបានរៀបចំឡើងដើម្បីធានាថាកម្មវិធីសិក្សាលម្អិតអាចប្រើប្រាស់បានដោយលោកគ្រូ អ្នកគ្រូ នៅតាមសាលារៀន។

## ការរួមចំណែកក្នុង SDGs

នៅសន្និសីទអន្តរជាតិរបស់អង្គការយូណេស្កូលើកទី៦ រដ្ឋមន្ត្រីទទួលបន្ទុកកីឡា និងអប់រំកាយ (MINEPS VI) ដែលធ្វើឡើងនៅទីក្រុងកាហ្សាន ប្រទេសរុស្ស៊ី ឆ្នាំ២០១៧ ឯកឧត្តម ម៉ាហ៊ិរុណុ ហ៊ីរ៉ូខាហ៊្សូ ដែលពេលនោះជារដ្ឋមន្ត្រីក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានមានប្រសាសន៍ថា «គោលដៅទី៤ នៃ SDGs គឺទាក់ទងនឹង «ការផ្តល់ការអប់រំប្រកបដោយបរិយាបន្ន យុត្តិធម៌ និងគុណភាពខ្ពស់» បន្ទាប់មកបានណែនាំឧទាហរណ៍ដូចជា ការគាំទ្រសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាអប់រំកាយនៅកម្ពុជា» (ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, ឆ្នាំ២០១៧ ) ។

គោលបំណងនៃការអប់រំមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិដែលបានកំណត់ក្នុងកម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាបឋមភូមិមានដូចតទៅ៖

ក្របខណ្ឌកម្មវិធីសិក្សាត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ហើយគោលបំណងរួមនៃការអប់រំគឺ
«ចំណេះដឹងជំនាញនិងឥរិយាបថ»ប៉ុន្តែនៅដំណាក់កាលនៃការបញ្ចប់កម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាបឋមភូមិមិនអាចរៀបចំទៅជា៣សមត្ថភាពគុណកោសល្យបានទេដូចនេះ«ឥរិយាបថ ចំណេះដឹង ជំនាញ និងសហការ» ត្រូវបានបង្កើតឡើងជាគោលបំណងសមត្ថភាពដែលបន្តពី

---

2) https://www.mext.go.jp/sports/b_menu/shingi/014_index/shiryo/__icsFiles/afieldfile/2017/09/11/1395318_8.pdf?msclkid=31336443d11611ec8a00d7f7b4c377ea

តារាងទី ១០៖ គោលបំណងកម្មវិធីសិក្សាអប់រំកាយសម្រាប់បឋមសិក្សា

| សមត្ថភាព | មធ្យមសិក្សាបឋមភូមិ |
|---|---|
| ចំណេះដឹង | សិស្សានុសិស្សទទួលបានចំណេះដឹងចាំបាច់ ក្នុងការចូលរួមសកម្មភាពរាងកាយផ្សេងៗរបស់មុខវិជ្ជាអប់រំកាយ និងប្រើប្រាស់គំនិតច្នៃប្រឌិតដើម្បីគិតពិចារណា និងវិភាគបញ្ហា ហើយប្រើប្រាស់ចំណេះដឹងដើម្បីដោះស្រាយបញ្ហាសម្រាប់ចូលរួមក្នុងសកម្មភាពកីឡា និងសកម្មភាពរាងកាយពេញមួយជីវិត។ |
| ជំនាញ | សិស្សានុសិស្សទទួលបានជំនាញដ៏សមស្រប និងរីករាយជាមួយការលេងកីឡានិងសកម្មភាពរាងកាយដោយគិតពិចារណាទៅលើដំណាក់កាលវិវត្តន៍ និងសមត្ថភាពផ្ទាល់ខ្លួន ហើយអាចបញ្ចេញកលល្បិច និងយុទ្ធសាស្ត្រដ៏សមស្របរបស់ពួកគេ។ |
| ឥរិយាបថ | សិស្សានុសិស្សមានគុណតម្លៃ និងឥរិយាបថវិជ្ជមានចំពោះសកម្មភាពកីឡា និងសកម្មភាពរាងកាយ ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពកីឡានិងសកម្មភាពរាងកាយនៅក្នុងមុខវិជ្ជាអប់រំកាយហើយទទួលបានឥរិយាបថក្នុងការរស់នៅប្រកបដោយសុខុមាលភាព សុវត្ថិភាព និងជីវិតប្រចាំថ្ងៃដ៏រីករាយ។ |
| សហការ | សិស្សានុសិស្សមានទំនួលខុសត្រូវតួនាទីភារកិច្ចចែករំលែកគំនិតយោបល់និងរីករាយក្នុងការលេងកីឡានិងសកម្មភាពរាងកាយជាមួយមិត្តភក្តិដោយផ្អែកទៅលើដំណាក់កាលវិវត្តន៍ និងលទ្ធភាពរបស់ពួកគេ។ |

សាលាបឋមសិក្សា។សហការអាចត្រូវបានរួមបញ្ចូលទៅក្នុងផ្នែកបុគ្គល(ឥរិយាបថ)និងផ្នែកសង្គម (សហការ) នៅក្នុងឥរិយាបថ ហើយបន្ទាប់ពីនោះ នៅក្នុងការពន្យល់ទៅកាន់ក្រសួងអប់រំពីភាគីចងក្រងកម្មវិធីសិក្សាបានពន្យល់ថា នេះអាចត្រូវបានចាត់ទុកថាស្របជាមួយនឹងគោលបំណងនៃ «ចំណេះដឹង ជំនាញ និងឥរិយាបថ»។ ដូចនេះហើយ ទោះបីជាកម្មវិធីសិក្សាលម្អិតអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិត្រូវបានបញ្ចប់បន្ទាប់ពីឆ្លងកាត់ភាពលំបាកជាច្រើនក៏ដោយ ការបញ្ចប់មិនមែនជាគោលដៅនោះទេ។ បន្ទាប់ពីបញ្ចប់ អប់រំកាយបែបថ្មីនឹងត្រូវបានបង្រៀននៅតាមសាលានីមួយៗ ហើយសិស្សានុសិស្សនឹងអាចរៀនពី «ឥរិយាបថ ចំណេះដឹង ជំនាញ និងសហការ» ហើយយើងគិតថា គោលដៅគឺដើម្បីឱ្យលំហូរបែបនេះត្រូវបានអនុវត្តដោយឯករាជ្យនិងផ្តោតលើក្រសួងអប់រំ។ ចាប់ពីខែមករាឆ្នាំ២០១៧ តទៅ អង្គការបេះដូងមាសនឹងចាប់ផ្តើមកម្មវិធីភាពជាដៃគូ « គម្រោង ជំនួយចងក្រងនិងផ្សព្វផ្សាយសៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិក្នុងព្រះរាជាណាចក្រកម្ពុជា » ដើម្បីសម្រេចបាននូវគោលដៅបន្តបន្ទាប់របស់ខ្លួន។



កម្មវិធីសិក្សាលម្អិតអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ

ប្រភព៖ កម្មវិធីសិក្សាលម្អិតអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ (MoEYS, ២០១៧)

## ផ្នែកទី ៩៖ ការចាប់ផ្តើមធំណើរការអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ តើគួរដូចសាលាបឋមសិក្សាដែរឬទេ?

នៅប្រទេសកម្ពុជាអប់រំកាយនៅសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិគ្រូបង្រៀនមានតួនាទីខុសគ្នា ដូចនៅប្រទេសជប៉ុនដែរ។ នៅសាលាបឋមសិក្សា គ្រូម្នាក់បង្រៀនគ្រប់មុខវិជ្ជាប៉ុន្តែនៅមធ្យមសិក្សាបឋមភូមិមានគ្រូមុខវិជ្ជាឯកទេស។គ្រូអប់រំកាយត្រូវបានបណ្តុះបណ្តាលតាមរយៈវគ្គ សិក្សារយៈពេល ២ ឆ្នាំនៅ «វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា» តែមួយគត់នៅក្នុងរាជធានីភ្នំពេញ។

ហើយសិស្សក៏មានការផ្លាស់ប្តូររវាងសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិផងដែរ។ នៅពេលក្លាយជាសិស្សអនុវិទ្យាល័យ អារម្មណ៍ខ្លួនឯងចាប់ផ្តើមផុសឡើង ហើយពួកគេចាប់ផ្តើមចេះបញ្ចេញគំនិតផ្ទាល់ខ្លួន។ ចាប់ផ្តើមចេះគិតរឿងអ្វីមួយដោយខ្លួនឯង ហើយធ្វើការសម្រេចចិត្តឬបញ្ចេញមតិ។ ចំណុចនេះមានភាពខុសគ្នាខ្លាំងរវាងសិស្សបឋមសិក្សា និងសិស្សអនុវិទ្យាល័យ។ ជាការពិតណាស់ កម្មវិធីសិក្សានិងសៀវភៅគ្រូក៏ត្រូវបញ្ចូលខ្លឹមសារកម្រិតខ្ពស់ដែលគិតដល់ចំណុចនេះផងដែរ។

ដោយសារតែកម្មវិធីបណ្តុះបណ្តាលគ្រូ ប្រព័ន្ធបង្រៀនរបស់គ្រូ និងលក្ខខណ្ឌនៃការវិវត្តរបស់សិស្សមានភាពខុសប្លែកគ្នា ដូចនេះកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិតម្រូវឱ្យប្រើយុទ្ធសាស្ត្របង្រៀនខុសគ្នាពីសាលាបឋមសិក្សា។នេះនឹងក្លាយជាថ្នាក់អប់រំកាយដែលសិស្សនឹងគិត ហើយដោយសារយើងមានគ្រូដែលមានជំនាញលើមុខវិជ្ជា ខ្លឹមសារនឹងផ្អែកលើ

សម្មទ្ធិផលនៃអប់រំកាយនៅសាលាបឋមសិក្សានិងជាខ្លឹមសារដែលនឹងផ្សារភ្ជាប់ទៅអប់រំកាយនៅសាលាមធ្យមសិក្សាទុតិយភូមិ។ជាងនេះទៅទៀតដោយគិតអំពីការផ្សព្វផ្សាយចាំបាច់ត្រូវបង្កើតកម្មវិធីសិក្សាដែលងាយស្រួលប្រើសូម្បីតែសម្រាប់គ្រូបង្រៀនបច្ចុប្បន្នដែលមិនធ្លាប់បានសិក្សាអប់រំកាយប្រកបដោយវិជ្ជាជីវៈ។

## បន្ថែម ល្បុក្កតោ និងប៉េតង់

កម្មវិធីសិក្សាសម្រាប់អនុវិទ្យាល័យក៏បានកំណត់គោលបំណងដូចគ្នានឹងសាលាបឋមសិក្សាដែរ គឺ«ឥរិយាបថ ចំណេះដឹង ជំនាញ និងសហការ»។ លើសពីនេះទៀតតេស្តកាយសម្បទាត្រូវបានកំណត់ជាមុខវិជ្ជារងបន្ថែមពីមុខវិជ្ជារងទាំង៦ដែលបង្រៀននៅ

តារាងទី ១១៖ តារាងបណ្តុំមុខវិជ្ជារងកម្មវិធីសិក្សាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ

| ប្រភេទ | ប្រភេទមុខវិជ្ជារង | | ថ្នាក់ទី៧ | | ថ្នាក់ទី៨ | | ថ្នាក់ទី៩ | |
|---|---|---|---|---|---|---|---|---|
| | | | មុខវិជ្ជារង | ម៉ោង | មុខវិជ្ជារង | ម៉ោង | មុខវិជ្ជារង | ម៉ោង |
| I. ការមិនប្រកួតប្រជែង/ខ្លួនឯងនិងអ្នកដទៃ | ភាពសមស្របនៃរាងកាយ | | វិស្សមោកាស | ៦ | វិស្សមោកាស | ៦ | វិស្សមោកាស | ៦ |
| | | | តេស្តកាយសម្បទា | | តេស្តកាយសម្បទា | | តេស្តកាយសម្បទា | |
| | អប់រំកាយជាមួយចង្វាក់ភ្លេង | | លំហាត់ប្រាណបែបខ្មែរ | ៨ | រាំតាមចង្វាក់ភ្លេង | ៨ | រាំបែបច្នៃប្រឌិត | ៨ |
| II.ការមិនប្រកួតប្រជែង/វប្បធម៌នឹងប្រពៃណី | កីឡាប្រពៃណី/កីឡាអន្តរជាតិ | | ល្បុក្កតោ | ៨ | ល្បុក្កតោ | ៨ | ល្បុក្កតោ | ៨ |
| | | | ប៉េតង់ | ៦* | ប៉េតង់ | ៦* | ប៉េតង់ | ៦* |
| III. ជំនាញបិទ/ការជម្នះ | អត្តពលកម្ម | | រត់ | ៨ | លោត | ៨ | ចោល | ៨ |
| | កាយសម្ព័ន្ធ | | លំហាត់កម្រាល | ៨ | លំហាត់របារទោល | ៨ | លំហាត់របារលំនឹង | ៨ |
| | ហែលទឹក | | ការណែនាំអំពីទឹក | ២ | ការណែនាំអំពីទឹក | ២ | ការណែនាំអំពីទឹក | ២ |
| | | | ហែលសេរី | ៦* | ហែលសេរី | ៦* | ហែលកង្កែប | ៦* |
| IV. ជំនាញបើក/កលល្បិចការព្រមព្រៀង | ល្បែងបាល់ | ប្រភេទវាយលុក | បាល់ទាត់ | ៨ | បាល់ទាត់ | ៨ | បាល់ទាត់ | ៨ |
| | | | បាល់បោះ | ៨ | បាល់បោះ | ៨ | បាល់បោះ | ៨ |
| | | ប្រភេទសំណាញ់ | បាល់ទះ | ៨ | បាល់ទះ | ៨ | បាល់ទះ | ៨ |
| | | ផ្សេងទៀត | វាយកូនឃ្លីលើតុ | ៦* | វាយកូនឃ្លីលើតុ | ៦* | វាយកូនឃ្លីលើតុ | ៦* |
| ម៉ោងសរុប | | | | ៧០ | | ៧០ | | ៧០ |

* សាលាជ្រើសរើសមុខវិជ្ជារង១ ក្នុងចំណោមមុខវិជ្ជារងទាំង ៣។

ប្រភព៖ ដកស្រង់ចេញពីកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិនៃព្រះរាជាណាចក្រកម្ពុជា (MoEYS, ២០១៦)

សាលាបឋមសិក្សា(អត្តពលកម្ម កាយសម្ព័ន្ធ អប់រំកាយជាមួយចង្វាក់ភ្លេង បាល់ទាត់ បាល់បោះ និងបាល់ទះ)ហើយលើសពីនេះទៀតដើម្បីឱ្យសិស្សទទួលបានបទពិសោធន៍កីឡាជាច្រើនប្រភេទ ក្បាច់គុនបុរាណកម្ពុជាគឺល្បុក្កតោ ប៉េតង់ វាយកូនឃ្លីលើតុ និងហែលទឹក ត្រូវបានបន្ថែម។ តារាងទី១១គឺជាតារាងបណ្ដុំមុខវិជ្ជារងនៃកម្មវិធីសិក្សាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិកម្ពុជា។

ចំពោះល្បុក្កតោ ខ្ញុំបានទទួលទូរសព្ទពីឯកឧត្តម វ៉ាត់ ចំរើន នៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាដែលគ្រោងនឹងចុះបញ្ជីល្បុក្កតោជាបេតិកភណ្ឌវប្បធម៌អរូបីរបស់អង្គការយូណេស្កូនៅពេលនោះ ហើយ បានស្នើឱ្យខ្ញុំបញ្ចូលវាទៅក្នុងកម្មវិធីសិក្សាអប់រំកាយ។ នៅពេលនោះខ្ញុំបានប្រាប់ថា ខ្ញុំមិនអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបានទេ។នៅពេលដែលខ្ញុំបានពិភាក្សាជាមួយមន្ត្រីមកពីនាយកដ្ឋានអប់រំ កាយ និងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាយើងមានការព្រួយបារម្ភថាយើងនឹងមិនអាចបញ្ចូលវាបានទេលុះត្រាតែយើងបានទទួលអនុសាសន៍ពីពួកគេប៉ុន្តែល្បុក្កតោដែលជាកីឡាប្រពៃណីដែលគេស្គាល់យ៉ាងច្បាស់នោះប្រាកដណាស់ត្រូវបានគាំទ្រដោយក្រុមការងារហើយត្រូវបានសម្រេចបញ្ចូលទៅក្នុងកម្មវិធីសិក្សា។ដោយពិចារណាថាល្បុក្កតោក្រោយមកត្រូវបានទទួលស្គាល់ជាបេតិកភណ្ឌវប្បធម៌អរូបីរបស់អង្គការយូណេស្កូក្នុងឆ្នាំ២០២៣ខ្ញុំគិតថាការដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិប្រហែលជាបានចូលរួមចំណែកជួយក្នុងការទទួល ស្គាល់នោះ។

## ហែលទឹកគឺជាមុខវិជ្ជារងជ្រើសរើស

ដោយសារហែលទឹកពិបាកបង្រៀននៅតាមសាលារៀនជាក់ស្ដែង យើងមានការព្រួយបារម្ភក្នុងការបញ្ចូលវាទៅក្នុងកម្មវិធីសិក្សា។ភាគីក្រសួងអប់រំបានបង្ហាញពីបំណងកាត់បន្ថយចំនួនជនរងគ្រោះដោយគ្រោះថ្នាក់ទឹក តាមរយៈការបណ្ដុះបណ្ដាលអ្នកចេះហែលទឹកនៅកម្ពុជាដែលមានគ្រោះថ្នាក់ទឹកច្រើនប៉ុន្តែយើងមានការសង្ស័យថាជាក់ស្ដែងវាពិតជាពិបាកនឹងដាក់បញ្ចូលណាស់។ ទោះជាយ៉ាងណាក៏ដោយ ដោយសារក្រសួងអប់រំមានបំណងប្រាថ្នាយ៉ាងខ្លាំង និងនៅតែជម្នះក្នុងការដាក់បញ្ចូល ដូចនេះវាក៏ត្រូវបានសម្រេចដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ហើយបានពិចារណាថាតើគួរតែអនុវត្តក្នុងទម្រង់បែបណារួចក៏បានដាក់បញ្ចូលជាមុខវិជ្ជារងជ្រើសរើសជាជាងមុខវិជ្ជារងកាតព្វកិច្ច។ នៅក្នុងប្រទេសជប៉ុន ប្រភេទជ្រើសរើសគឺជាជម្រើសក្នុងចំណោមប្រភេទស្រដៀងគ្នាប៉ុន្តែដោយគិតពីលទ្ធភាពនៃការអនុវត្តយើងបានសម្រេចជាទម្រង់ជ្រើសរើសរវាងហែលទឹក និងប៉េតង់។

គ្រូអប់រំកាយនៅអនុវិទ្យាល័យមួយចំនួនមានការព្រួយបារម្ភថានៅសាលាបឋមសិក្សាពួកគេគ្រាន់តែបង្រៀនខ្លឹមសារនៃតេស្តកាយសម្បទាបន្ថែមលើ ៦ មុខវិជ្ជារងប៉ុណ្ណោះ ប៉ុន្តែនៅអនុវិទ្យាល័យ ពួកគេរៀននិងបង្រៀនខ្លឹមសារចំនួន ២០ មុខវិជ្ជារង ក្នុង៧ប្រភេទមុខវិជ្ជារង។

ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀនបច្ចុប្បន្នដែលបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាមានទឹកចិត្តច្រើនជាងគ្រូបឋមសិក្សាទៅទៀត។

លោក ព្រាប វុទ្ធារ៉ា នាយកស្រាវជ្រាវនៃវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាបានមានប្រសាសន៍ថា «ខណៈពេលកំពុងសិក្សាតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលានៅប្រទេសជប៉ុន ខ្ញុំបានស្វែងយល់ថាអ្វីជាអប់រំកាយ និងអ្វីជាកីឡា។ បន្ទាប់មក គ្រូបង្រៀននៅតាមសាលាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបង្កើតកម្មវិធីសិក្សានិងសៀវភៅគ្រូដែលងាយយល់និងងាយស្រួលប្រើរួមទាំងរបៀបបង្កើតផែនការប្រចាំឆ្នាំនិងផែនការមេរៀនផងដែរ»។ទោះបីជាមានមតិខុសគ្នាជាមួយសមាជិកនៃនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតក៏ដោយក៏អ្នកគ្រប់គ្នាបានធ្វើការរួមគ្នាដើម្បីបង្កើតកម្មវិធីសិក្សា ដើម្បីឱ្យកុមារអាចរៀន «ឥរិយាបថ ចំណេះដឹង ជំនាញ និងសហការ» តាមរយៈអប់រំកាយ។

## ផ្នែកទី ៥៖ ការចងក្រងសៀវភៅគ្រូ
## សៀវភៅគ្រូដែលងាយស្រួលអាន និងងាយស្រួលប្រើ

គោលដៅនៃសៀវភៅគ្រូអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិគឺដើម្បីធ្វើឱ្យងាយស្រួលយល់ សូម្បីតែសម្រាប់គ្រូបង្រៀនដែលមិនធ្លាប់បានសិក្សា «អប់រំកាយបែបថ្មី» និងធ្វើឱ្យកាន់តែងាយស្រួលក្នុងការបង្កើតផែនការប្រចាំឆ្នាំផែនការមេរៀននិងកិច្ចតែងការបង្រៀន។ ដោយផ្អែកលើកម្មវិធីសិក្សាដែលត្រូវបានអនុម័តក្នុងខែធ្នូឆ្នាំ២០១៦ យើងបានចាប់ផ្តើមចងក្រងសៀវភៅគ្រូដែលជាផ្នែកមួយនៃគម្រោងសហប្រតិបត្តិការបច្ចេកទេសមូលដ្ឋាន « គម្រោងជំនួយចងក្រងនិងផ្សព្វផ្សាយសៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិក្នុងព្រះរាជាណាចក្រកម្ពុជា»ដែលបានចាប់ផ្តើមនៅឆ្នាំ២០១៧។ផែនការគម្រោងទាំងមូលត្រូវបានរៀបចំឡើងដូចបង្ហាញក្នុងរូបភាពទី១២។ដោយមានគោលដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តនិងផ្សព្វផ្សាយអប់រំកាយនៅមធ្យមសិក្សាបឋមភូមិយើងមានគម្រោងដាក់ឱ្យប្រើប្រាស់អប់រំកាយថ្មីនៅក្នុងខេត្តចំនួនបី(រាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង)ដោយអនុវត្តជា៣ដំណាក់កាល៖ (១) ការអភិវឌ្ឍធនធានមនុស្ស (២) ការចងក្រងសៀវភៅគ្រូសម្រាប់គ្រូអប់រំកាយ និង (៣) ការបង្កើតមូលដ្ឋានគ្រឹះផ្សព្វផ្សាយ។

ចំពោះការអភិវឌ្ឍធនធានមនុស្សជំហានដំបូងយើងមានគោលដៅអភិវឌ្ឍគ្រូបណ្តុះបណ្តាលថ្នាក់ជាតិសម្រាប់មធ្យមសិក្សាបឋមភូមិ តាមគន្លងនៃសាលាបឋមសិក្សាដែលជាធនធានមនុស្សសម្រាប់ក្រសួងអប់រំ។អ្វីដែលខុសពីសាលាបឋមសិក្សានោះគឺមិនត្រឹមតែមានបុគ្គលិក៦នាក់មកពីនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិតប៉ុណ្ណោះទេប៉ុន្តែក៏មាន៦នាក់ទៀតមកពីវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាផងដែរសរុបមានចំនួន១២នាក់។ពួកគេទាំង១២នាក់នោះ។

រូបភាពទី១២៖ ដ្យាក្រាមពន្យល់គម្រោងជំនួយចងក្រងនិងផ្សព្វផ្សាយសៀវភៅគ្រូមុខវិជ្ជា អប់រំកាយសម្រាប់មធ្យម សិក្សាបឋមភូមិក្នុងព្រះរាជាណាចក្រកម្ពុជា។

**ការបង្កើតប្រព័ន្ធមូលដ្ឋានសម្រាប់អនុវត្តនិងផ្សព្វផ្សាយអប់រំកាយថ្មីកម្រិតមធ្យមសិក្សាទុតិយភូមិ**

**(១) ការកសាងប្រព័ន្ធនិងការអភិវឌ្ឍធនធានមនុស្ស**

១. ការលើកកម្ពស់ការយល់ដឹងអំពីអប់រំកាយបែបថ្មីក្នុងចំណោមរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ និងអគ្គនាយកនៃអគ្គនាយកកីឡា (គណៈកម្មាធិការកណ្តាល និងគណៈកម្មាធិការរៀបចំ)
២.ការអភិវឌ្ឍធនធានមនុស្សនៃ NIPES និង DPESS (គណៈកម្មាធិការបច្ចេកទេស)
៣. ការពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកមន្ទីរអប់រំខេត្ត
៤. ការអភិវឌ្ឍធនធានមនុស្សសម្រាប់គណៈគ្រប់គ្រងសាលានិងគ្រូបង្រៀននៅក្នុងខេត្តមូលដ្ឋាននិងសាលារៀនមូលដ្ឋាន

**(២) ការបង្កើតឯកសារអប់រំមុខវិជ្ជាអប់រំកាយ**

១.សិក្ខាសាលាចងក្រងសៀវភៅគ្រូ
២. សិក្ខាសាលាសាកល្បងដើម្បីត្រួតពិនិត្យសៀវភៅគ្រូ
៣.ការបញ្ជាក់ជាមួយអ្នកជំនាញក្នុងការចងក្រងសៀវភៅគ្រូ
៤. ការអនុម័តសៀវភៅគ្រូ
៥. ការចែកចាយសៀវភៅគ្រូទៅខេត្តគំរូ

**(៣) ការបង្កើតមូលដ្ឋានគ្រឹះផ្សព្វផ្សាយ**

១. ការជ្រើសរើសខេត្តមូលដ្ឋាននិងសាលារៀនមូលដ្ឋាន
២. សិក្ខាសាលាណែនាំអំពីអប់រំកាយបែបថ្មីនៅសាលាមូលដ្ឋាន
៣.ការសាកល្បងអនុវត្តអប់រំកាយថ្មីនៅសាលាមូលដ្ឋាន
៤. ការណែនាំអំពីការតាមដាននៅសាលាមូលដ្ឋាន

ប្រភព៖ ដកស្រង់ចេញពីទម្រង់ពាក្យស្នើសុំសម្រាប់គម្រោងជំនួយចងក្រងនិងផ្សព្វផ្សាយសៀវភៅគ្រូមុខវិជ្ជា អប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិក្នុងព្រះរាជាណាចក្រកម្ពុជា (HG, ២០១៥)

រួមជាមួយអង្គការបេះដូងមាស បានគ្រោងធ្វើសិក្ខាសាលា និងបន្តចងក្រងសៀវភៅគ្រូ ហើយជាក់ស្តែងបាននាំយកសេចក្តីព្រាងទៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង។ បន្ទាប់មកយើងនឹងវាយតម្លៃការយល់ដឹងរបស់គ្រូបង្រៀនតាមរយៈការតាមដានថ្នាក់រៀនសាកល្បង ថាគ្រូបង្រៀនកម្រិតអនុវិទ្យាល័យបច្ចុប្បន្នអាចបង្កើតផែនការប្រចាំឆ្នាំ ផែនការមេរៀន និងកិច្ចតែងការបង្រៀនដោយផ្អែកលើសៀវភៅគ្រូដែរឬទេនិងមេរៀនប្រភេទណាដែលនឹងត្រូវអនុវត្តដោយផ្អែកលើកិច្ចតែងការបង្រៀន។

សៀវភៅគ្រូត្រូវបានចងក្រងដោយមន្ត្រីទទួលបន្ទុកមកពីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាដោយបែងចែកទៅតាមមុខវិជ្ជារង។ ដើម្បីចៀសវាងការប្រែប្រួលខ្លឹមសារពីមន្ត្រីមួយទៅមន្ត្រីមួយ យើងបានកំណត់និងសរសេរទៅតាមចំណុចរួមមាន៖ (១) ប្រវត្តិ (២) គោលបំណង (៣) ផែនការមេរៀន (៤) លទ្ធផលសិក្សា

(៥) លក្ខណៈវិនិច្ឆ័យវាយតម្លៃ និង (៦) ខ្លឹមសារនៃកិច្ចតែងការបង្រៀន។ តាមរបៀបនេះ បញ្ហា និង បទពិសោធន៍ដែលទទួលបានក្នុងអំឡុងពេលរៀបចំកម្មវិធីសិក្សាត្រូវបានប្រើប្រាស់ក្នុងការរៀបចំសៀវភៅគ្រូ។

## ធានាបាននូវសុគតភាពគ្នាជាមួយនឹងកម្មវិធីសិក្សា

ទោះបីជាចំណុចត្រូវបានកំណត់រួចហើយក៏ដោយក៏នៅមានភាពខុសគ្នាក្នុងរបៀបនិងប្រវែងនៃការសរសេរ ដូច្នេះយើងបានពិនិត្យខ្លឹមសារ និងធ្វើការកែតម្រូវ។ នៅដំណាក់កាលដែលយើងមានសេចក្ដីព្រាងរួចហើយ យើងបានស្នើលោកគ្រូអ្នកគ្រូឱ្យប្រើប្រាស់វានៅក្នុងរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង ដើម្បីពិនិត្យមើលថាពួកគេអាចសរសេរផែនការមេរៀន និងកិច្ចតែងការបង្រៀនបានដែរឬទេ ហើយប្រសិនបើពិបាកយល់ យើងនឹងធ្វើការកែប្រែបន្ថែមទៀត។

នៅពេលសរសេរកិច្ចតែងការបង្រៀន ឧទាហរណ៍ក្នុងករណីបាល់ទាត់ ខ្លឹមសារនៃកិច្ចតែងការបង្រៀនត្រូវបានគ្រោងទុក៨ម៉ោង ប៉ុន្តែប្រសិនបើគោលបំណងសម្រាប់ម៉ោងទី១គឺឥរិយាបថនិងសហការយើងបានធ្វើឱ្យកាន់តែងាយស្រួលយល់ថាព័ត៌មានគួរទាញយកពីកន្លែងណា។ជាទូទៅដូចជាល្បែងផ្ដុំរូបដែរគ្រូអាចបំពេញកិច្ចតែងការបង្រៀនបានដោយជ្រើសរើសខ្លឹមសារដែលរៀបរាប់ក្នុងសៀវភៅគ្រូ ហើយសរសេរវាចូលក្នុងកិច្ចតែងការបង្រៀន។ បញ្ហាគឺត្រូវយកខ្លឹមសារពីត្រង់ណាមកដាក់ចូល។ក្នុងករណីគ្រូចង់ស្វែងយល់អំពីគោលបំណងនៃថ្នាក់រៀននៅក្នុងម៉ោងសិក្សាណាមួយ ដោយសួរសំណួរដូចជាខ្លឹមសារអ្វីខ្លះពីសៀវភៅគ្រូដែលគួរបញ្ចូលក្នុងកិច្ចតែងការបង្រៀនហើយឱ្យសិស្សឆ្លើយសំណួរដែលជួយឱ្យពួកគេកាន់តែរីកចម្រើនហើយគ្រូអាចបង្កើតកិច្ចតែងការបង្រៀនបានយ៉ាងងាយស្រួល។

លើសពីនេះដោយបន្ថែមការពន្យល់ថាខ្លឹមសារទាំងអស់នៃកិច្ចតែងការបង្រៀនគឺជាគំរូប៉ុណ្ណោះហើយកត់សម្គាល់ថាការកែតម្រូវនឹងមិនមានបញ្ហាទេប្រសិនបើវាផ្ដល់អត្ថប្រយោជន៍ដល់ការសិក្សារបស់សិស្សនាពេលអនាគត ដូចនោះគ្រូបង្រៀនអាចបង្កើនភាពបត់បែនក្នុងការអនុវត្តមេរៀនរបស់ពួកគេ។

បន្ទាប់ពីគ្រូបង្រៀនយល់ម្ដងហើយ ពួកគេអាចបង្កើតកិច្ចតែងការបង្រៀនបានយ៉ាងងាយស្រួល។គ្រូដែលអាចបង្កើតកិច្ចតែងការបង្រៀនបានដោយមានទំនុកចិត្តថាពួកគេបានយល់ហើយនិងបានចាប់ផ្ដើមបង្រៀនដល់គ្រូដែលមិនយល់ក្នុងអំឡុងពេលសិក្ខាសាលា។ថ្នាក់អប់រំកាយក៏ដូចថ្នាក់ផ្សេងទៀតដែរការ«យល់ដឹង»នាំទៅរកទំនុកចិត្ត។ពេលអ្នកយល់អ្នកគិតថានេះពិតជាសប្បាយហើយអ្នកអាចបង្រៀនដល់គ្រូផ្សេងទៀត។ភាពរីករាយនេះហើយនឹងជួយបង្កើនល្បឿនផ្សព្វផ្សាយបន្ថែមទៀត។តាមរបៀបនេះគ្រូឧទ្ទេសថ្នាក់ជាតិនិងគ្រូបង្រៀនបានធ្វើការរួមគ្នាដើម្បីពង្រឹងការយល់ដឹងរបស់ពួកគេអំពីអប់រំកាយបែបថ្មី។



សៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ
ប្រភព៖ សៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ (MoEYS, ២០១៩)

នៅថ្ងៃទី១៦ខែកញ្ញាឆ្នាំ២០១៩សៀវភៅគ្រូអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិត្រូវបានអនុម័តដោយក្រសួងអប់រំ។ខ្លឹមសារត្រូវបានបញ្ចប់ក្នុងលក្ខណៈស្របគ្នាដោយមិនមានសុគតភាពគ្នាដូចជានៅក្នុងសាលាបឋមសិក្សាទេដែលក្នុងនោះកម្មវិធីសិក្សាមានបញ្ចូលបណ្តុំមុខវិជ្ជារងសុខភាពនិងហែលទឹកប៉ុន្តែសៀវភៅគ្រូមិនបានបញ្ចូលបណ្តុំមុខវិជ្ជារងទាំងនេះទេ។ខណៈពេលដែលគោលបំណងនៃការអប់រំកម្ពុជាទាំងមូលត្រូវបានកំណត់ថាជា«ចំណេះដឹងជំនាញនិងឥរិយាបថ» សម្រាប់អនុវិទ្យាល័យ គោលបំណងសមត្ថភាព«សហការ»ត្រូវបានកំណត់បន្តពីបឋមសិក្សា។ ដូចនេះយើងអាចស្ថិតនៅចំណុចចាប់ផ្តើមនៃការដាក់បញ្ចូលអប់រំកាយបែបថ្មីដោយប្រើសៀវភៅគ្រូដែលបានបង្កើតថ្មី។

## ផ្នែកទី៦៖ ការដាក់ឱ្យប្រើប្រាស់នៅអនុវិទ្យាល័យ

នៅពេលដែលគម្រោងដំបូងត្រូវបានគ្រោងទុកនៅក្នុងឆ្នាំ២០១៥ យើងបានគ្រោងផ្សព្វផ្សាយអប់រំកាយនៅអនុវិទ្យាល័យក្នុងខេត្តចំនួន៤ រួមទាំងខេត្តកំពង់ចាមផងដែរ ប៉ុន្តែនៅទីបញ្ចប់ វាត្រូវបានសម្រេចកំណត់គោលដៅរាជធានី/ខេត្តចំនួន៣វិញគឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង។

រាជធានីភ្នំពេញត្រូវបានជ្រើសរើសដោយសារតែមានការស្នើសុំពីរដ្ឋមន្ត្រីក្រសួងអប់រំ រួមទាំងហេតុផលដូចជា អប់រំកាយគួរតែត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់នៅរាជធានីភ្នំពេញ ហើយនៅពេលមានទស្សនកិច្ចមកពីប្រទេសផ្សេងជាដើមពួកគេអាចចុះពិនិត្យសាលាក្នុងរាជធានីភ្នំពេញបាន។នៅខេត្តបាត់ដំបងនិងខេត្តស្វាយរៀងវិញគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសមូលដ្ឋានរបស់JICAបានអនុវត្តនាពេលកន្លងមកនៅកម្រិតបឋមសិក្សាហើយគ្រូឧទ្ទេសថ្នាក់ជាតិត្រូវបានជ្រើសរើសដោយសារតែទំនាក់ទំនងល្អជាមួយមន្ទីរអប់រំខេត្ត។ខេត្តកំពង់ចាមមិនធ្លាប់បានបញ្ចូលគម្រោងកន្លងមកនៅសាលាបឋមសិក្សាទេ ហើយដំបូងឡើយត្រូវបាក្នុងខេត្តគោលដៅ ដើម្បី

ស្វែងយល់ថាវិធីផ្សព្វផ្សាយប្រភេទណាដែលអាចធ្វើទៅបាននៅក្នុងខេត្តដែលគម្រោងបែបនេះមិនធ្លាប់បានដាក់បញ្ចូលនៅសាលាបឋមសិក្សាប៉ុន្តែដោយសារសកម្មភាពមានលក្ខណៈទូលំទូលាយ និងបញ្ហាថវិកា យើងបានសម្រេចចិត្តផ្តោតលើរាជធានី/ខេត្តចំនួន៣ប៉ុណ្ណោះ។ ក្នុងចំណោមរាជធានី/ខេត្តទាំង៣រាជធានីភ្នំពេញមានការលំបាកជាពិសេសក្នុងការដាក់បញ្ចូល។ នៅរាជធានីភ្នំពេញ សាលាចំនួន៣ ត្រូវបានរដ្ឋមន្ត្រីក្រសួងអប់រំ កំណត់ថាជាសាលាគោលដៅ គឺវិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាល័យបឹងត្របែក និងវិទ្យាល័យបឹងកេងកង។ សិក្ខាសាលាត្រូវបានធ្វើឡើង និងបានពន្យល់អំពីផែនការប្រចាំឆ្នាំ ផែនការមេរៀន កិច្ចតែងការបង្រៀន។ល។ ហើយជាក់ស្តែងពួកគេក៏អាចបង្កើតវាបាន។

ខុសពីប្រទេសជប៉ុនគ្រូបង្រៀននៅកម្ពុជាអាចមានការងារក្រៅម៉ោងហើយគ្រូបង្រៀនភាគច្រើននៅភ្នំពេញមានការងារក្រៅម៉ោង។ មានគ្រូបង្រៀនជាច្រើនប្រភេទ រួមទាំងអ្នកធ្វើការជាអ្នកបើកបរតុកតុក(តាក់ស៊ីរ៉ឺម៉កកង់បី) អ្នកលក់សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃនៅផ្ទះ និងអ្នកដែលបង្រៀនកីឡានៅសាលាឯកជន។ នៅក្នុងប្រទេសកម្ពុជា ដែលសាលារៀនមាន២វេន គឺវេនព្រឹក និងវេនរសៀល គ្រូបង្រៀនជាច្រើនបង្រៀនអប់រំកាយនៅសាលានៅពេលព្រឹក ហើយធ្វើការងារក្រៅម៉ោងនៅពេលរសៀល។កាលណាធ្វើការងារក្រៅម៉ោងកាន់តែច្រើន គេនឹងទទួលកម្រៃបានកាន់តែច្រើន ដូច្នេះពួក គាត់ប្រាកដជាខំប្រឹងប្រែងបង្រៀន ឬធ្វើការឯកជន។ ទោះបីជាកុមាររៀនអប់រំកាយបែបថ្មីបានច្រើនដោយចេះពីខ្លឹមសារ ៧ បណ្តុំមុខវិជ្ជារង និង ២០ មុខវិជ្ជារងក៏ដោយ ក៏វាមិននាំឱ្យមានការកើនឡើងនៃប្រាក់ចំណូលរបស់គ្រូដែរ ដូច្នេះគ្រូបង្រៀនក្រៅពីអ្នកដែលស្រលាញ់ការអប់រំ នឹងមិនឃើញអត្ថប្រយោជន៍នៃការប្រឹងប្រែងទៅលើអប់រំកាយបែបថ្មីឡើយ។

ជាងនេះទៅទៀតក្នុងករណីសាលារៀនក្នុងរាជធានីភ្នំពេញសាលារៀននីមួយៗមានគ្រូអប់រំកាយច្រើននាក់ ដូច្នេះការដឹកនាំរបស់គណៈគ្រប់គ្រងសាលា ឬប្រធានដឹកនាំគឺមានសារៈសំខាន់ណាស់។ នៅក្នុងការអប់រំនៅកម្ពុជាទាំងមូល ការអប់រំវិទ្យាសាស្ត្រ គណិតវិទ្យា និងភាសាខ្មែរត្រូវបានចាត់ទុកថាសំខាន់ ដូច្នេះវាពិបាកក្នុងការបញ្ចុះបញ្ចូលថ្នាក់ដឹកនាំឱ្យខិតខំខ្នះខ្នែងក្នុងការដាក់បញ្ចូលអប់រំកាយដូចមុខវិជ្ជាផ្សេងទៀតណាស់។ សិក្ខាសាលាចាប់ផ្តើមនៅម៉ោង ៨:០០ ព្រឹក និងបញ្ចប់នៅម៉ោង ៥:០០ ល្ងាច ដោយមានម៉ោងសម្រាក ហើយជាលក្ខណៈរបស់សាលារៀនទីក្រុងភ្នំពេញ គ្រូបង្រៀនជាច្រើនបានចាកចេញនៅពាក់កណ្តាលម៉ោង។

យ៉ាងណាមិញ ស្ថានភាពនៅខេត្តបាត់ដំបង និងខេត្តស្វាយរៀងគឺខុសគ្នា។ សិក្ខាសាលានិងការតាមដានត្រូវបានធ្វើឡើងនៅសាលាចំនួន១៤ក្នុងខេត្តបាត់ដំបងនិងសាលាចំនួន ១០ក្នុងខេត្តស្វាយរៀង។ក្នុងអំឡុងពេលសិក្ខាសាលារយៈពេល៣ថ្ងៃ អ្នកចូលរួមអាចរៀនយ៉ាងរលូនពីរបៀបសរសេរផែនការប្រចាំឆ្នាំ ផែនការមេរៀន និងកិច្ចតែងការបង្រៀន។ នៅទីនេះខ្ញុំសូមណែនាំសាលាមួយឈ្មោះថាអនុវិទ្យាល័យបាសាក់ដែលជាសាលាដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអប់រំកាយបែបថ្មីប្រកបដោយភាពជោគជ័យ និងប្រសិទ្ធភាព។

## អត្ថបទទី៩៖ តារាងវាយកូនឃ្លីលើតុរបស់លោកគ្រូសុប៊ុនធឿង

នៅអនុវិទ្យាល័យបាសាក់ ខេត្តស្វាយរៀង មានគ្រូអប់រំកាយម្នាក់ឈ្មោះលោកគ្រូ រាជ សុប៊ុនធឿង គាត់បានចូលរួមក្នុងសិក្ខាសាលាអប់រំកាយដែលរៀបចំដោយបេះដូងមាស និង ក្រសួងអប់រំដូចគ្រូដទៃទៀតដែរ។នៅពេលដែលគាត់បានចូលរួមសិក្ខាសាលាលើកទី២គាត់បាន ទទួលការយល់ដឹងកាន់តែច្បាស់អំពីអប់រំកាយកន្លងមក និងអប់រំកាយបែបថ្មី ហើយបានគ្រោង ដាក់បញ្ចូលវាក្នុងសាលារបស់គាត់។គាត់ក៏រាយការណ៍យ៉ាងហ្មត់ចត់នូវខ្លឹមសារនៃសិក្ខាសាលា ដែលគាត់បានចូលរួមទៅកាន់លោកនាយកសាលា គង់ សាបាន។ លោកនាយក គង់ សាបាន ស្រឡាញ់កីឡា ហើយសាមីខ្លួននិយាយថា អប់រំកាយគឺជាមុខវិជ្ជាដែលគាត់ចូលចិត្តខ្លាំង ដូច្នេះ គាត់បានធ្វើការជាមួយគ្រូអប់រំកាយម្នាក់ទៀត ដើម្បីផ្តួចផ្តើមគំនិតក្នុងការបញ្ចូលអប់រំកាយបែប ថ្មី។

លោកគ្រូ រាជ សុប៊ុនធឿង បានអនុវត្តយ៉ាងស្មោះត្រង់នូវអ្វីដែលគាត់បានរៀនពី កម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ និងសិក្ខាសាលា។ តេស្តកាយសម្បទាដែលរួមបញ្ចូលក្នុងភាព សមស្របនៃរាងកាយ ក៏ត្រូវបានកត់ត្រានៅលើសន្លឹកកំណត់ត្រាសិស្សដែរ ហើយលទ្ធផលនៃតេស្ត កាយសម្បទារបស់សិស្សត្រូវបានបង្កើតឡើងក្នុងឆ្នាំទី១។ លើសពីនេះ សាលាគិតថា ចាំបាច់ ត្រូវបញ្ចូលកីឡាវាយកូនឃ្លីលើតុប៉ុន្តែមិនមានសម្ភារៈបង្រៀនទេដូច្នេះហើយទើបពួកគេធ្វើតារាង វាយកូនឃ្លីលើតុ និងរ៉ាកែតដោយប្រើក្តារខៀន ឬតុជាដើមដែលមានស្រាប់នៅសាលា។





តារាងវាយកូនឃ្លីលើតុ និងរ៉ាកែត ដែលបង្កើតដោយ លោកគ្រូ រាជ សុប៊ុនធឿង



ទិដ្ឋភាពថ្នាក់រៀនវាយកូនឃ្លីលើតុ របស់លោកគ្រូ រាជ សុប៊ុនធឿង

នៅពេលដែលអ្នកនិពន្ធចុះតាមដានខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះគំនិតនៃការខិតខំប្រឹងប្រែងប្រកបដោយភាពច្នៃប្រឌិតរបស់លោកគ្រូ រាជ សុប៊ុនធឿង ក្នុងការបង្កើតសម្ភារៈបង្រៀនដោយប្រើប្រាស់សម្ភារៈដែលមានស្រាប់។ លើសពីនេះទៅទៀត គាត់បាននិយាយអំពីវាហាក់ដូចជារឿងធម្មតា។ ថ្វីត្បិតតែសិស្សមិនអាចចូលរួមបានច្រើនក្នុងពេលតែមួយក្នុងថ្នាក់វាយកូនឃ្លីលើតុ ប៉ុន្តែថ្នាក់ដែលបង្រៀនដោយគ្រូដែលមានទឹកចិត្តខ្លាំងបែបនេះគឺពិតជាកំណាប់នៃការសិក្សារបស់សិស្ស។ ពួកគេគោរពលេខរៀង និងរីករាយចំពោះភាពជោគជ័យរបស់មិត្តភក្តិ ហើយនេះជាលើកដំបូងដែលខ្ញុំបានឃើញថ្នាក់រៀនដែលសិស្សមានភាពសប្បាយរីករាយយ៉ាងខ្លាំងបែបនេះ។

ក្នុងនាមជាគ្រូបង្រៀនអប់រំកាយ លោក រាជ សុប៊ុនធឿង មានប្រសាសន៍ថា វាជាបេសកកម្មរបស់លោកក្នុងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអប់រំកាយបែបថ្មីដែលបង្កើតឡើងដោយក្រសួងអប់រំហើយថាលោកចង់សហការជាមួយគ្រូនៅតាមសាលាផ្សេងទៀតប្រសិនបើពួកគេមានបញ្ហាហើយនេះគឺជាគំរូពិតនៃអ្វីដែលគ្រូបង្រៀនគួរធ្វើ។

ក្រោយមក អង្គការបេះដូងមាស បានសាងសង់អគារលេងកីឡាមានដំបូលនៅអនុវិទ្យាល័យបាសាក់ ក្រោមជំនួយរបស់ក្លឹបហ្វូជីសាវ៉ារ៉ូថារី និង ដៃកូអេឡិចត្រូនិចខូអិលធីឌី ដាច់ដោយឡែកពីគម្រោង។





ទិដ្ឋភាពថ្នាក់បាល់ទះប្រារព្ធឡើងក្នុងពិធីប្រគល់អគារលេងកីឡាមានដំបូលដែលបានសាងសង់

# ជំពូកទី៥

## ឆ្ពោះទៅរកឯករាជ្យភាព

## ផ្នែកទី១៖ កម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាទុតិយភូមិ ខ្លឹមសារស្ទើរតែដូចគ្នានឹងមធ្យមសិក្សាបឋមភូមិដែរ

បន្ទាប់ពីបង្កើតកម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាបឋមភូមិ ក្រសួងអប់រំកម្ពុជាបានចាប់ផ្តើមបង្កើតកម្មវិធីសិក្សាលម្អិតអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិដោយខ្លួនឯង។

លោក ម៉ាង វិបុល អនុប្រធាននាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ខណៈបានស្នើសុំកិច្ចសហការពីអង្គការបេះដូងមាសបានប្រាប់ខ្ញុំថាពួកគេបានសម្រេចដំណើរការដោយថវិកាផ្ទាល់ខ្លួន។ ការបណ្តុះបណ្តាលត្រូវបានធ្វើឡើងនៅទីក្រុងតូក្យូក្នុងឆ្នាំ២០១៨ និងនៅអូកាយ៉ាម៉ាក្នុងឆ្នាំ២០១៩ ហើយបុគ្គលិកអង្គការបេះដូងមាស ក៏ត្រូវបានអញ្ជើញផងដែរដោយប្រើប្រាស់ថវិការបស់ក្រសួងអប់រំ។ ដោយសារលោក ម៉ាង វិបុល មានបទពិសោធន៍នៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ កម្មវិធីសិក្សាសម្រាប់វិទ្យាល័យ ត្រូវបានបង្កើតឡើងដោយប្រើសិក្ខាសាលា និងខ្លឹមសារស្រដៀងគ្នា ហើយបានទទួលការអនុម័តម្តងក្នុងខែកក្កដា ឆ្នាំ២០១៨។

អង្គការបេះដូងមាសបានធ្វើការសម្របសម្រួលនិងពិនិត្យនៅពេលដែលមានការស្នើសុំពីភាគីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ដូចជាទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន ប៉ុន្តែទាក់ទងនឹងខ្លឹមសារជាទូទៅយើងសម្រេចគោរពស្វ័យភាពរបស់ពួកគេ។ក្រោយមកនៅពេលដែលខ្ញុំត្រូវបានបង្ហាញនូវកំណែដែលបានបញ្ចប់ ខ្ញុំស្ទើរតែមិនឃើញមានភាពខុសគ្នាពីកម្មវិធីសិក្សាសម្រាប់អនុវិទ្យាល័យទេ។ ក្នុងនោះ គោលបំណងសម្រាប់ឥរិយាបថ និងចំណេះដឹងគឺដូចគ្នាទៅនឹងនៅអនុវិទ្យាល័យដែរ ដោយគ្រាន់តែមានការផ្លាស់ប្តូរមុខវិជ្ជារងមួយចំនួន និងការបន្ថែមបាល់គប់។

ពិតជាអស្ចារ្យណាស់ដែលនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតបានបង្កើតវាដោយខ្លួនឯង ប៉ុន្តែខ្ញុំមានការព្រួយបារម្ភថាខ្លឹមសារនៃអប់រំកាយដែលបាននិងកំពុងរីកចម្រើននៅក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យ គឺស្ទើរតែដូចគ្នានៅក្នុងវិទ្យាល័យ និងអនុវិទ្យាល័យ ដូច្នេះខ្ញុំសម្រេចទៅតវ៉ាផ្ទាល់ជាមួយឯកឧត្តមអ៊ុកសិទ្ធិជាតិទៅអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា។ កិច្ចប្រជុំមួយត្រូវបានធ្វើឡើងភ្លាមៗជាមួយនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

ក្នុងកិច្ចប្រជុំនេះខ្ញុំបានគូសបញ្ជាក់ថាទោះបីជាកម្មវិធីសិក្សាអប់រំកាយត្រូវបានអភិវឌ្ឍសម្រាប់កម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិក៏ដោយក៏កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិគឺស្ទើរតែដូចគ្នាទៅនឹងមធ្យមសិក្សាបឋមភូមិ ហើយមិនមានការវិវត្តសោះ។ដោយសារនៅសាលាបឋមសិក្សាបានឱ្យសិស្សស្គាល់ពីប្រភេទលំហាត់ប្រាណជាច្រើន ហើយសាលាមធ្យមសិក្សាបឋមភូមិក៏ជួយពួកគេឱ្យទទួលបានបទពិសោធន៍កីឡាជាច្រើនផងដែរដូចនេះនៅក្នុងមធ្យមសិក្សាទុតិយភូមិ ខ្ញុំបានស្នើសុំឱ្យពិចារណាលើខ្លឹមសារឡើងវិញ ដែលនឹងជួយសិស្សឱ្យ

កាន់តែមានឯករាជ្យភាព និងចូលរួមក្នុងកីឡាដោយឈរនៅលើគំនិតជាអ្នកផ្តួចផ្តើម។

ទោះបីជាគម្រោងនេះមិនមានចរិកាក៏ដោយ ការចូលរួមរបស់អង្គការបេះដូងមាស ពិតជាមានសារៈសំខាន់ និងគុណតម្លៃណាស់។ ខ្ញុំគិតថានេះនឹងក្លាយជាការចូលរួមចំណែកដ៏សំខាន់មួយក្នុងការពិចារណាថាយើងគួររៀបចំប្រព័ន្ធអប់រំកាយនៅមធ្យមសិក្សាទុតិយភូមិដែលអភិវឌ្ឍពីបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិដោយរបៀបណាកុមារគួរយល់ដឹងពីកីឡាយ៉ាងណា បន្ទាប់ពីរៀនចប់អនុវិទ្យាល័យពួកគេគួរមានទំនាក់ទំនងជាមួយនឹងកីឡាបែបណានៅក្រោយពេលដែលគេក្លាយជាមនុស្សពេញវ័យ។ ដោយសារមានប្រវត្តិបែបនេះ និងដោយមានកិច្ចសហការពីអង្គការបេះដូងមាសកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិត្រូវបានកែសម្រួលនៅឆ្នាំ២០១៩។

## ផែនការកំណែប្រែព្រួញមួយបាញ់បានសត្វពីរ

នៅពេលស្នើសុំការកែសម្រួល អ្នកនិពន្ធមានផែនការមួយក្នុងចិត្ត។ ក្រសួងអប់រំយុវជន និងកីឡាមានសសរស្តម្ភពីរជាគោលនយោបាយកីឡារបស់ខ្លួន។មួយគឺការឈ្នះមេដាយជាច្រើនក្នុងព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ (ស៊ីហ្គេម) និងអាស៊ានប៉ារ៉ាហ្គេម (ASEAN Para Games) ដែលនឹងប្រព្រឹត្តទៅនៅឆ្នាំ២០២៣និងមួយទៀតគឺពលរដ្ឋកម្ពុជាម្នាក់ៗនឹងអាចសុំានឹងកីឡាមួយនៅពេលពួកគេឈានដល់វ័យពេញវ័យ។ នៅអនុវិទ្យាល័យ យើងបង្កើតឱកាសសម្រាប់សិស្សានុសិស្សចូលរួមក្នុងកីឡាផ្សេងៗ ក្រោមការណែនាំរបស់គ្រូ ប៉ុន្តែនៅវិទ្យាល័យ សិស្សអាចរៀបចំផែនការផ្ទាល់ខ្លួនច្នៃប្រឌិតវិធីសាស្ត្រអនុវត្តនិងបញ្ចេញគំនិតរបស់ពួកគេបានកាន់តែច្រើន។ យើងបានគិតថាដោយបញ្ចូលអប់រំកាយកម្រិតខ្ពស់នៅវិទ្យាល័យដែលអាចធ្វើបាន នឹងអាចរួមចំណែកក្នុងគោលដៅទាំងពីរខាងលើ។ បន្ទាប់មក យើងបាននិយាយជាមួយមន្ត្រីក្រសួងអប់រំ ដើម្បីធានាថាខ្លឹមសារទាំងពីរត្រូវបានដាក់បញ្ចូល។ ការធ្វើឱ្យខ្លឹមសារនៃអប់រំកាយ ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ ក៏ត្រូវបានស្វាគមន៍ដោយអគ្គនាយកដ្ឋានកីឡា ដូច្នេះការកែប្រែនេះត្រូវបានអនុម័ត ទោះបីជាវាត្រូវបានអនុម័តម្តងរួចមកហើយក៏ដោយ។




កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិ
ប្រភព៖ កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិ (MoEYS, ២០១៩)

គោលបំណងមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិត្រូវបានបង្កើតឡើងដូចបង្ហាញក្នុងតារាងទី១៣។

នៅក្នុងប្រព័ន្ធអប់រំកម្ពុជា វិទ្យាល័យគឺជាដំណាក់កាលចុងក្រោយមុនពេលក្លាយជាមនុស្សពេញវ័យហើយនៅវិទ្យាល័យគោលបំណងប្រភេទដោះស្រាយបញ្ហាត្រូវបានកំណត់ដែលសិស្សស្វែងរកនិងដោះស្រាយបញ្ហាដោយខ្លួនឯងក្នុងមុខវិជ្ជារងនីមួយៗ។មិនតែប៉ុណ្ណោះជំនាញក៏នឹងអាចបង្ហាញពីសមត្ថភាពកម្រិតខ្ពស់ដូចជា កលល្បិច និងជំនាញកម្រិតខ្ពស់។ ចំពោះឥរិយាបថ វាត្រូវបានសម្រេចរួមបញ្ចូលឥរិយាបថនិងការសហការនៅអនុវិទ្យាល័យ អភិវឌ្ឍឥរិយាបថដែលស្រលាញ់កីឡានាពេលអនាគត និងសហការជាមួយមិត្តភក្តិក្នុងការចូលរួមក្នុងសកម្មភាពកីឡានិងសកម្មភាពរាងកាយ។

ថ្វីត្បិតតែការផ្សព្វផ្សាយអប់រំកាយមិននាំឱ្យឈ្នះមេដាយដោយផ្ទាល់នៅក្នុងការប្រកួតកីឡាស៊ីហ្គេម ឬ អាស៊ានប៉ារ៉ាហ្គេមក៏ដោយ ក៏មានការចាប់អារម្មណ៍យ៉ាងខ្លាំងពីមន្ត្រីរដ្ឋាភិបាល និងមន្ត្រី ក្រសួងអប់រំ។ ពួកគាត់គិតថាការបង្កើនការយល់ដឹងរបស់សិស្សអំពីកីឡាតាមរយៈអប់រំកាយ ក៏នឹងរួមចំណែកជាវិជ្ជមានដល់ការកែលម្អជំនាញកីឡារបស់ពួកគេ។ ដូច្នេះហើយ អ្នកនិពន្ធបានក្រឡេកមើលជំនួយផ្នែកអប់រំកាយនិងគោលនយោបាយកីឡារបស់កម្ពុជាបានបង្កើតដ្យាក្រាមរួមមួយដូចបង្ហាញក្នុងរូបភាពទី១៤ហើយបានពន្យល់ដល់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡាជាដើម។

តារាងទី១៣៖ គោលបំណងកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិ

| សមត្ថភាព | មធ្យមសិក្សាទុតិយភូមិ |
|---|---|
| ចំណេះដឹង | សិស្សទទួលបានចំណេះដឹងកម្រិតខ្ពស់ដើម្បីចូលរួមក្នុងសកម្មភាពកីឡានិងសកម្មភាពរាងកាយពេញមួយជីវិត ប្រើប្រាស់ចំណេះដឹងនិងការស្រមើស្រមៃដើម្បីស្វែងរកបញ្ហា វិភាគសមហេតុផល និងដោះស្រាយបញ្ហានានា។ |
| ជំនាញ | សិស្សទទួលបានជំនាញកម្រិតខ្ពស់ដើម្បីរីករាយនឹងកីឡា និងសកម្មភាពរាងកាយ ដោយគិតគូរពីដំណាក់កាលវិវត្តន៍ និងសមត្ថភាពផ្ទាល់ខ្លួន ហើយអាចបញ្ចេញជំនាញកម្រិតខ្ពស់ វិធីសាស្ត្រកលល្បិច និងយុទ្ធសាស្ត្រសមស្រប។ |
| ឥរិយាបថ | សិស្សរកឃើញ និងបណ្តុះឥរិយាបថវិជ្ជមានខ្ពស់ចំពោះកីឡា និងសកម្មភាពរាងកាយ។ ជាពិសេសបណ្តុះឥរិយាបថវិជ្ជមានចំពោះកីឡាដែលចូលចិត្ត ដើម្បីប្រកួតប្រជែងសមត្ថភាពផ្ទាល់ខ្លួន។ សិស្សដឹងពីសារៈសំខាន់នៃកីឡា ហើយរកឃើញគុណតម្លៃចំពោះកីឡា និងសកម្មភាពរាងកាយ។ សិស្សចូលរួមក្នុងកីឡា និងសកម្មភាពរាងកាយនីមួយៗដោយភាពសហការនិងទទួលខុសត្រូវជាលក្ខណៈបុគ្គល និងជាមួយមិត្តភក្តិ បណ្តុះឥរិយាបថដើម្បីដឹកនាំជីវិតប្រចាំថ្ងៃប្រកបដោយសុខភាព និងចម្រើនរុងរឿង។ |

រូបភាពទី១៤៖ ការរចនាប្រព័ន្ធអប់រំកាយ




## ធ្វើការលើការកែសម្រួលបន្ទាប់ពីការអនុម័ត

ដូចដែលបានបង្ហាញក្នុងរូបភាពទី១៤ «កុមារទូទាំងប្រទេសកម្ពុជា» ត្រូវបានគេចាត់ទុកថាការដែលកុមារទាំងអស់អាចចូលរៀនបានគឺជាបុរេលក្ខខណ្ឌ។សាលាបឋមសិក្សាគឺជាពេលវេលាដើម្បីរៀនចលនាផ្សេងៗ អនុវិទ្យាល័យគឺជាពេលវេលាដើម្បីរីករាយនឹងកីឡាផ្សេងៗ ហើយវិទ្យាល័យគឺជាពេលវេលាដើម្បីរីករាយ និងអភិវឌ្ឍកីឡាដែលខ្លួនចូលចិត្តឬពូកែ។បន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យគោលដៅគឺដើម្បីឱ្យសិស្សានុសិស្សទទួលបានសមត្ថភាពដែលអាចរីករាយនឹងសកម្មភាពរាងកាយ និងកីឡាដើម្បីសុខភាព និងចំណង់ចំណូលចិត្តពេញមួយជីវិត។ ខ្ញុំបានពន្យល់ថា«នេះនឹងជួយឱ្យសម្រេចបាននូវគោលដៅរបស់រដ្ឋាភិបាលក្នុងការឱ្យប្រជាពលរដ្ឋម្នាក់ៗអាចចូលរួមក្នុងកីឡាយ៉ាងហោចណាស់មួយបន្ទាប់ពីឈានដល់ពេញវ័យ»។

ខ្ញុំបានសង្កត់ធ្ងន់ថា អប់រំកាយនៅវិទ្យាល័យ ចាំបាច់ត្រូវអភិវឌ្ឍចេញពីអប់រំកាយនៅអនុវិទ្យាល័យ ហើយការរក្សាកម្មវិធីសិក្សានិងគោលបំណងដូចគ្នាទៅនឹងអនុវិទ្យាល័យ ដោយផ្លាស់ប្តូរតែមុខវិជ្ជារងនោះគឺគ្មានភាពរីកចម្រើននោះទេដូច្នេះយើងបានធ្វើការរួមគ្នាជាមួយក្រសួងអប់រំ ដើម្បីកែសម្រួលកម្មវិធីសិក្សាសម្រាប់វិទ្យាល័យ ដែលត្រូវបានអនុម័តម្តងរួចមកហើយ។ អង្គការបេះដូងមាសមិនអាចអនុវត្តការងារកែសម្រួលនេះជាគម្រោងបានទេដោយសារមិនទទួលបានថវិកាពីគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសមូលដ្ឋាន ឬគម្រោងផ្សេងទៀត ប៉ុន្តែសម្រាប់២ឆ្នាំជាប់គ្នាគឺនៅឆ្នាំ២០១៨ និង ២០១៩ តាមរយៈថវិការបស់នាយកដ្ឋានអប់រំកាយ

និងកីឡាសិស្ស-និស្សិត យើងអាចធ្វើទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន ហើយថវិកាសម្រាប់សិក្ខាសាលាក៏ត្រូវបានបំពេញដោយថវិការបស់នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ដែលជាជំនួយដ៏ធំមួយសម្រាប់ដំណើរការកែសម្រួល។

ដោយសារក្របខណ្ឌកម្មវិធីសិក្សាដែលបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ត្រូវបានទទួលស្គាល់រួចហើយ ហើយ «ចំណេះដឹង ជំនាញ និងឥរិយាបថ» ត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាជាគោលបំណងនៃការអប់រំទូទៅ ដូចនេះ «សហការ» ត្រូវបានរៀបចំនិងដាក់បញ្ចូលទៅក្នុង «ឥរិយាបថ»។ លើសពីនេះ ខ្លឹមសារត្រូវបានរៀបចំឡើងក្នុងគោលបំណងឱ្យសិស្សអាចគិត និងប្រឹងប្រែងដោយខ្លួនឯង ដើម្បីឱ្យពួកគេអាចចូលរួមក្នុងកីឡាដោយស្វ័យភាពបន្ទាប់ពីបញ្ចប់ការសិក្សា។មុខវិជ្ជារងក៏ត្រូវបានបង្កើតឡើងតាមរបៀបមួយដែលគ្រូអប់រំកាយអាចជ្រើសរើសតាមជម្រើសរបស់ពួកគេ យោងទៅតាមតម្រូវការរបស់សិស្សនិងស្ថានភាពសាលារៀន។

នៅអនុវិទ្យាល័យ ជាឧទាហរណ៍ក្នុងអត្តពលកម្ម ត្រូវបានបែងចែកជា រត់ នៅថ្នាក់ទី៧ លោត នៅថ្នាក់ទី៨ និងចោល នៅថ្នាក់ទី៩ រីឯនៅវិទ្យាល័យ ត្រូវបានរចនាឡើងដែលអាចឱ្យសិស្សអាចជ្រើសរើសរត់លោតចោលដោយខ្លួនឯងនៅថ្នាក់ទី១០-១២ឬមួយក្នុងពេលតែមួយក៏អាចអនុវត្ត រត់ លោត ចោល ក្នុងថ្នាក់មួយ។ ដូច្នេះ គ្រូអប់រំកាយត្រូវតែគិតអំពីការបង្កើតឱកាសសម្រាប់អប់រំកាយប៉ុន្តែដោយអនុញ្ញាតឱ្យសិស្សចូលរួមក្នុងលំហាត់នីមួយៗដោយស្ម័គ្រចិត្តសិស្សកាន់តែច្រើនអាចទទួលបានពេលវេលាដើម្បីចូលរួមក្នុងលំហាត់ប្រាណ ហើយសូម្បីតែសម្ភារៈបង្រៀនមានតិចក៏ដោយក៏សិស្សកាន់តែច្រើនអាចចូលរួមក្នុងមុខវិជ្ជារងផ្សេងៗដោយស្វ័យភាព។ តារាងបណ្តុំមុខវិជ្ជារងសម្រាប់វិទ្យាល័យត្រូវបានបង្ហាញក្នុងតារាងទី១៥។

ទោះបីជាចំនួនម៉ោងត្រូវបានកំណត់រវាងបណ្តុំមុខវិជ្ជារងនីមួយៗក៏ដោយ ក៏ពាក្យ «។ល។» ត្រូវបានបន្ថែមរវាងមុខវិជ្ជារងនានា ដើម្បីឱ្យអាចអនុវត្តមុខវិជ្ជារងដែលមិនមាននៅក្នុងតារាងបណ្តុំមុខវិជ្ជារង (រួមទាំងកីឡាថ្មីៗដូចជា គ្រីឃីតបល [cricket ball] និងខហ្វបល [korfball])។ជាលទ្ធផលមុខវិជ្ជារងដែលគ្របដណ្តប់នៅក្នុងអប់រំកាយសាលាមិនត្រូវបានកំណត់ទេ ដោយទុកនូវលទ្ធភាពនៃការបញ្ចូលកីឡាផ្សេងៗ។

ម្យ៉ាងវិញទៀតបញ្ហាប្រឈមគឺការផ្សព្វផ្សាយអប់រំកាយបែបថ្មីនេះ។នៅអនុវិទ្យាល័យ ខ្លឹមសារនៃមុខវិជ្ជារងត្រូវបានកំណត់ ដូច្នេះការរចនាមានលក្ខណៈសង្ខេប និងសាមញ្ញសម្រាប់គ្រូបច្ចុប្បន្នធ្វើការ។ ប្រសិនបើគ្រូដឹងថានៅថ្នាក់ណា ត្រូវបង្រៀនបណ្តុំមុខវិជ្ជារងណា នោះពួកគេអាចស្វែងរកទំព័រដែលសមស្របនៅក្នុងសៀវភៅគ្រូ ហើយស្វែងរកពីទីនោះ។ ម៉្យាងវិញទៀត កម្មវិធីសិក្សាសម្រាប់វិទ្យាល័យតម្រូវឱ្យស្វែងរកទំព័រដែលសមស្របរួចហើយត្រូវគិតដោយខ្លួនឯងបង្កើតកិច្ចតែងការបង្រៀនថាអនុវត្តបែបណា រួចបង្រៀន។ ក្នុងន័យនេះ វាត្រូវបានគេរំពឹងថានឹងចំណាយពេលមួយរយៈដើម្បីធ្វើការផ្សព្វផ្សាយ។

លើសពីនេះ ដើម្បីផ្សព្វផ្សាយឯករាជ្យនៃអប់រំកាយនៅកម្ពុជា នាយកដ្ឋានអប់រំកាយ និងកីឡា សិស្ស-និស្សិតបានធានានូវថវិកា ដែលនាំឱ្យអាចអនុវត្តសកម្មភាពបាន។

តារាងទី១៥ តារាងបណ្តុំមុខវិជ្ជារង៖ មធ្យមសិក្សាទុតិយភូមិ

<table>
<tr><th rowspan="2">ប្រភេទ</th><th rowspan="2" colspan="2">ប្រភេទ មុខវិជ្ជារង</th><th colspan="2">ថ្នាក់ទី១០</th><th colspan="2">ថ្នាក់ទី១១</th><th colspan="2">ថ្នាក់ទី១២</th></tr>
<tr><th>មុខវិជ្ជារង</th><th>ម៉ោង</th><th>មុខវិជ្ជារង</th><th>ម៉ោង</th><th>មុខវិជ្ជារង</th><th>ម៉ោង</th></tr>
<tr><td rowspan="3">I.ការមិនប្រកួតប្រជែង/ខ្លួនឯងនិងអ្នកដទៃ</td><td rowspan="2" colspan="2">ភាពសមស្របនៃរាងកាយ</td><td>វិស្សមោកាស</td><td rowspan="2">៦</td><td>វិស្សមោកាស</td><td>៦</td><td>វិស្សមោកាស</td><td rowspan="2">៦</td></tr>
<tr><td>តេស្តកាយសម្បទា</td><td>តេស្តកាយសម្បទា</td><td></td><td>តេស្តកាយសម្បទា</td></tr>
<tr><td colspan="2">អប់រំកាយជាមួយចង្វាក់ភ្លេង</td><td>រាំ</td><td>១០</td><td>រាំ</td><td>១០</td><td>រាំ</td><td>១០</td></tr>
<tr><td>II.ការមិនប្រកួតប្រជែង/វប្បធម៌និងប្រពៃណី</td><td colspan="2">ភាពសមស្របនៃរាងកាយ</td><td>ល្បុក្កតោ ប៉េតង់ តេក្វាន់ដូការ៉ាតេ។ល។</td><td>១៦*១</td><td>ល្បុក្កតោ ប៉េតង់ តេក្វាន់ដូការ៉ាតេ។ល។</td><td>១៦*១</td><td>ល្បុក្កតោ ប៉េតង់ តេក្វាន់ដូការ៉ាតេ។ល។</td><td>១៦*១</td></tr>
<tr><td rowspan="3">III.ជំនាញបិទ/ជម្នះ</td><td colspan="2">អត្តពលកម្ម</td><td>អត្តពលកម្ម</td><td>១០</td><td>អត្តពលកម្ម</td><td>១០</td><td>អត្តពលកម្ម</td><td>១០</td></tr>
<tr><td colspan="2">កាយសម្ព័ន្ធ</td><td>កាយសម្ព័ន្ធ</td><td>១០</td><td>កាយសម្ព័ន្ធ</td><td>១០</td><td>កាយសម្ព័ន្ធ</td><td>១០</td></tr>
<tr><td colspan="2">ហែលទឹក</td><td>ហែលទឹក</td><td>៨*១</td><td>ហែលទឹក</td><td>៨*១</td><td>ហែលទឹក</td><td>៨*១</td></tr>
<tr><td rowspan="3">IV. ជំនាញបើក/កលល្បិចការព្រមព្រៀង</td><td rowspan="3">ល្បែងបាល់</td><td>ប្រភេទវាយលុក</td><td>បាល់ទាត់ បាល់បោះ បាល់គប់រ៉ាហ្គឺប៊ី។ល។</td><td rowspan="3">១៨*២</td><td>បាល់ទាត់ បាល់បោះ បាល់គប់រ៉ាហ្គឺប៊ី។ល។</td><td rowspan="2">១៨*២</td><td>បាល់ទាត់ បាល់បោះ បាល់គប់រ៉ាហ្គឺប៊ី។ល។</td><td rowspan="3">១៨*២</td></tr>
<tr><td>ប្រភេទសំណាញ់</td><td>បាល់ទះ វាយកូនឃ្លីលើតុ តេននីស ។ល។</td><td>បាល់ទះ វាយកូនឃ្លីលើតុ តេននីស ។ល។</td><td>បាល់ទះ វាយកូនឃ្លីលើតុ តេននីស ។ល។</td></tr>
<tr><td>ផ្សេងទៀត</td><td>បេស្បល(baseball) សុហ្វបល(softball) ។ល។</td><td>បេស្បល(baseball) សុហ្វបល(softball) ។ល។</td><td>៦*</td><td>បេស្បល(baseball) សុហ្វបល(softball) ។ល។</td></tr>
<tr><td>ម៉ោងសរុប</td><td colspan="2"></td><td></td><td>៧០</td><td></td><td>៧០</td><td></td><td>៧០</td></tr>
</table>

*១ សាលាជ្រើសរើសមុខវិជ្ជារងចំនួន២ ក្នុងចំណោមមុខវិជ្ជារងដែលបានតាក់តែងឡើងមក។

*២ សាលាជ្រើសរើសមុខវិជ្ជារងយ៉ាងហោចណាស់ចំនួន២ ពីប្រភេទចំនួន២ នៃប្រភេទវាយលុក ប្រភេទសំណាញ់ និងផ្សេងទៀត។

ដូច្នេះការបណ្តុះបណ្តាលក្នុងសេវាសម្រាប់គ្រូបង្រៀនបច្ចុប្បន្នបានដំណើរការ ប៉ុន្តែវាមានសារៈសំខាន់ផងដែរក្នុងការចូលទៅជិតវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាដែលជាស្ថាប័នមុនសេវាដែលបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ។លើសពីនេះគ្រូបឋមសិក្សាត្រូវបានបណ្តុះបណ្តាលនៅសាលាគរុកោសល្យខេត្តក្នុងខេត្តចំនួន១៨នៅទូទាំងប្រទេស ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការបញ្ចូលអប់រំកាយទៅក្នុងកម្មវិធីសិក្សាដើម្បីឱ្យពួកគេអាចបង្រៀនអប់រំកាយ ហើយនិស្សិតវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា យល់ពីខ្លឹមសារនៃកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ និងបង្រៀនដល់សិស្សរបស់ពួកគេដែលនឹងក្លាយជាគ្រូអប់រំកាយ។

## ជំហានឆ្ពោះទៅរកឯករាជ្យភាពកំពុងដំណើរការ

នៅឆ្នាំ២០១៩ ខ្ញុំទទួលបានការទាក់ទងពីលោក តេហ្សុកា កូជី ដែលកំពុងអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់វិទ្យាស្ថានគរុកោសល្យនៅ JICA ។ គាត់កំពុងបង្កើតកម្មវិធីសិក្សារយៈពេល ៤ ឆ្នាំសម្រាប់ការបណ្តុះបណ្តាលគ្រូបឋមសិក្សា ហើយគាត់ចង់ពិភាក្សាជាមួយអង្គការបេះដូងមាសដែលបានចូលរួមក្នុងផ្នែកអប់រំកាយជាច្រើនឆ្នាំមកហើយ។ នៅពេលនោះលោកសាស្ត្រាចារ្យអូកាដិ យ៉ូស៊ីណូរិ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រកីឡានីបប៉ុន ដែលកំពុងបំពេញទស្សនកិច្ចនៅកម្ពុជាក៏មានវត្តមានហើយយើងបាននិយាយអំពីស្ថានភាពបច្ចុប្បន្ន។ផែនការនៅពេលនោះគឺមានថ្នាក់អប់រំកាយ២ក្រេឌីតនៅឆ្នាំទី៤លើសពីនេះទៀតក៏បានគិតអំពីថ្នាក់លំហាត់ប្រាណរាងកាយរយៈពេល២ ម៉ោងក្នុងមួយសប្តាហ៍ ដែលមិនមែនជាក្រេឌីតទេ។

ប្រសិនបើការធ្វើលំហាត់ប្រាណរាងកាយ១ក្រេឌីតរៀងរាល់ឆ្នាំបន្ថែមពីលើនេះនៅឆ្នាំទី៤រៀនអំពីកម្មវិធីសិក្សាបឋមសិក្សានិងខ្លឹមសារនៃសៀវភៅគ្រូរបៀបសរសេរផែនការប្រចាំឆ្នាំផែនការមេរៀននិងកិច្ចតែងការបង្រៀននោះវាពិបាកក្នុងការបង្រៀនអប់រំកាយនៅសាលាបឋមសិក្សា។ដូច្នេះយើងបានស្នើឱ្យផ្ទេរថ្នាក់អប់រំកាយ២ក្រេឌីតនៅឆ្នាំទី៤ ទៅឆ្នាំទី១វិញ។

នៅឆ្នាំទី១រៀនអំពីកម្មវិធីសិក្សាបឋមសិក្សានិងខ្លឹមសារនៃសៀវភៅគ្រូរបៀបសរសេរផែនការប្រចាំឆ្នាំផែនការមេរៀននិងកិច្ចតែងការបង្រៀន ហើយតាមរយៈការអនុវត្តថ្នាក់អប់រំកាយក្នុងមុខវិជ្ជាលំហាត់ប្រាណរាងកាយ១ក្រេឌីតជារៀងរាល់ឆ្នាំ ដោយប្រើប្រាស់ផែនការប្រចាំឆ្នាំផែនការមេរៀន និងកិច្ចតែងការបង្រៀនដែលពួកគេបង្កើត ខ្ញុំគិតថាសិស្សនឹងអាចទទួលបានបទពិសោធន៍ទាំងការអនុវត្តថ្នាក់អប់រំកាយ។បន្ទាប់មកខ្ញុំបានចូលរួមក្នុងសិក្ខាសាលាជាច្រើនដែលជាផ្នែកមួយនៃគម្រោងវិទ្យាស្ថានគរុកោសល្យហើយឥឡូវនេះនាយកដ្ឋានអប់រំកាយនិងកឡសិស្ស-និស្សិតបានបង្កើតសៀវភៅគ្រូអប់រំកាយសម្រាប់បណ្តុះបណ្តាលគ្រូបឋមសិក្សាដោយខ្លួនឯង។ អង្គការបេះដូងមាស ក្រោយមកបានចូលរួមក្នុងការគាំទ្រដល់វិទ្យាស្ថានជាតិអប់រំកាយនិងកីឡាចាប់ពីឆ្នាំ២០១៩ប៉ុន្តែជំហានឆ្ពោះទៅរកឯករាជ្យកំពុងរីកចម្រើនជាលំដាប់ហើយខណៈដែលយើងនៅតែចង់ធ្វើការជាមួយពួកគេរួមទាំងទំនាក់ទំនងដែលយើងបានកសាងឡើងផងដែរខ្ញុំរីករាយដែលបានឮអំពីការខិតខំប្រឹងប្រែងដោយខ្លួនឯងរបស់ក្រសួងអប់រំ ហើយខ្ញុំមានមោទនភាពយ៉ាងខ្លាំងដែលឃើញឯករាជ្យភាពរបស់ពួកគេកំពុងរីកចម្រើន។

## ផ្នែកទី២៖ គម្រោង អប់រំកាយ សម្រាប់ទាំងអស់គ្នា ចង់រៀនប្រកបដោយគុណភាពខ្ពស់ជាប់លាប់

នៅខែកញ្ញា ឆ្នាំ២០២០ គម្រោងផ្សព្វផ្សាយអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង បានឈានជិតដល់ទីបញ្ចប់ហើយនោះ យើងចាំបាច់ត្រូវស្វែងរកគម្រោងបន្តបន្ទាប់ទៀត។យើងបានអនុវត្តគម្រោងសម្រាប់ សាលាបឋមសិក្សាចំនួន៣ដំណាក់កាលរួចមកហើយប៉ុន្តែការស្នើគម្រោងអប់រំកាយសម្រាប់ មធ្យមសិក្សាបឋមភូមិដែលស្រដៀងគ្នាទៅនឹងគម្រោងដែលបានអនុវត្តសម្រាប់បឋមសិក្សា នឹង មានភាពរីកចម្រើនតិចតួចពេក។លើសពីនេះដោយសារយើងបានជួយបង្កើតកម្មវិធីសិក្សាសម្រាប់ វិទ្យាល័យខ្ញុំមានគិតថាយើងចាំបាច់ត្រូវធ្វើការលើគ្រប់ដំណាក់កាលនៃបឋមសិក្សាអនុវិទ្យាល័យ និងវិទ្យាល័យ។ដូច្នេះហើយ នៅខែធ្នូ ឆ្នាំ២០១៩ យើងបានដាក់ពាក្យស្នើសុំគម្រោង «Physical Education for All» (ហៅកាត់ថា គម្រោង «អប់រំកាយសម្រាប់ទាំងអស់គ្នា») ដែលផ្តល់នូវ ការរៀនសូត្រប្រកបដោយគុណភាពខ្ពស់ជាប់លាប់ពីបឋមសិក្សាដល់វិទ្យាល័យ ជាគម្រោងកិច្ច សហប្រតិបត្តិការបច្ចេកទេសមូលដ្ឋាន។

នៅសាលាបឋមសិក្សា យើងបានផ្សព្វផ្សាយទៅខេត្តចំនួន៥ ក្នុងដំណាក់កាលទី២ និងពង្រីកដល់១៥ខេត្តក្នុងដំណាក់កាលទី៣។ ម៉្យាងវិញទៀត នៅតាមខេត្តនីមួយៗ យើងបាន ផ្សព្វផ្សាយដល់សាលាគរុកោសល្យចំនួន១ និងសាលាបឋមសិក្សាចំនួន២ ទៅ ៣ប៉ុណ្ណោះ ហើយយើងគិតថាវានឹងពិបាកក្នុងការផ្សព្វផ្សាយអប់រំកាយសម្រាប់ទាំងអស់គ្នានៅទូទាំងប្រទេស កម្ពុជា។ ដូច្នេះហើយ នៅក្នុងគម្រោងនេះ យើងបានសម្រេចកាត់បន្ថយចំនួនខេត្តគោលដៅមក ត្រឹម៣ហើយជំនួសមកវិញនូវការផ្សព្វផ្សាយអប់រំកាយបែបថ្មីដល់សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់នៅក្នុងរាជធានី/ខេត្តគោលដៅ។ ពាក្យសុំត្រូវបានអនុម័ត ដោយជោគជ័យ ហើយគម្រោងនេះអាចចាប់ផ្តើមនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១។

ក្នុងគម្រោងនេះ ដូចបង្ហាញក្នុងរូបភាពទី១៧ យើងបានចាត់តាំងមន្ត្រីចំនួន ៤ នាក់ ពី នាយកដ្ឋាន អប់រំកាយ និងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ហើយ មន្ត្រីចំនួន ៦ នាក់មកពីរាជធានី ខេត្តនីមួយៗ ទៅកាន់១រាជធានី និង២ខេត្ត ដើម្បីបង្កើតផែនការ ផ្សព្វផ្សាយ និង បង្កើតផែនការសម្រាប់ដំណើរការសិក្ខាសាលា និងការតាមដាន។ នៅក្នុង គម្រោងមុនៗ មន្ទីរ/ការិយាល័យអប់រំខេត្ត/ស្រុក មិនមានតួនាទីក្នុងសិក្ខាសាលា ឬការតាមដាន ទេ ដូច្នេះហើយ យើងបានសម្រេចផ្តោតលើការឱ្យពួកគេធ្វើជាម្ចាស់ការ ដោយបង្កើតផែនការ ផ្សព្វផ្សាយជាក់លាក់ និងអនុវត្តការតាមដានដោយប្រើសន្លឹកវាយតម្លៃ។

រូបភាពទី១៦៖ ផែនទីនៃសកម្មភាពជំនួយផ្សព្វផ្សាយមុខវិជ្ជាអប់រំកាយ




**សាលាគោលដៅ**
សាលាបឋមសិក្សា៖ ៣៣ សាលា
(២០២១ - ១០៧៤ សាលា)
សាលាគរុកោសល្យ៖
១៣ សាលា
អនុវិទ្យាល័យ៖ ២៦៣ សាលា
វិទ្យាល័យ៖ ៨៨ សាលា
សាកលវិទ្យាល័យ៖ ១ សាលា

ក្នុងចំណោមសាលាគោលដៅ
**សាលាគំរូ**
សាលាបឋមសិក្សា៖
២៩ សាលា
សាលាគរុកោសល្យ៖
១០ សាលា

ចំនួនសិស្សបឋមសិក្សា៖ ៣១,៥៣៥ នាក់
ចំនួនគ្រូបឋមសិក្សា៖ ១,០៥៩ នាក់
ចំនួនសិស្ស PTTC៖ ៣,១៥៨ នាក់
ចំនួនគ្រូ PTTC៖ ២៤ នាក់
ចំនួនសិស្សអនុវិទ្យាល័យ៖ ១៧,៦៥៥ នាក់
ចំនួនគ្រូអនុវិទ្យាល័យ៖ ១,០៤៦ នាក់
ចំនួនគ្រូ NIPES៖ ៦៥ នាក់ *
ចំនួនសិស្ស NIPES៖ ១៧៥* នាក់
* និស្សិតឆ្នាំទី២ ចំនួន ១៥០ នាក់ និស្សិតឆ្នាំទី៣ ចំនួន ២០ នាក់

២០០៩~២០១២ មូលដ្ឋានតំបន់នៃការផ្សព្វផ្សាយអប់រំកាយសម្រាប់បឋមសិក្សាចំនួន ៥ខេត្ត (កម្មវិធីភាពជាដៃគូរបស់JICA)

២០១៣~២០១៦ ការដាក់បញ្ចូលថ្មីនៃការផ្សព្វផ្សាយអប់រំកាយសម្រាប់បឋមសិក្សាចំនួន១០ខេត្ត(កម្មវិធីភាពជាដៃគូរបស់JICA)

២០១៧~២០២០ គោលដៅផ្សព្វផ្សាយអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ ១រាជធានី ២ខេត្ត
២០២១~២០២៥ គោលដៅផ្សព្វផ្សាយ អប់រំកាយសម្រាប់ បឋមសិក្សា/មធ្យមសិក្សាបឋមភូមិ/មធ្យមសិក្សាទុតិយភូមិ ១រាជធានី ២ខេត្ត

២០១៩~ ការប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ទៅជាសាកលវិទ្យាល័យរយៈពេល ៤ ឆ្នាំ

រូបភាពទី ១៧៖ ដ្យាក្រាមរូបភាពនៃគម្រោង
(គម្រោង «អប់រំកាយសម្រាប់ទាំងអស់គ្នា» ដើម្បីសិក្សាប្រកបដោយគុណភាពខ្ពស់ជាប់ លាប់ពីបឋមសិក្សាដល់វិទ្យាល័យ)




[ការពន្យល់អក្សរកាត់]
PNH៖ ភ្នំពេញ
BTB៖ បាត់ដំបង
SVR៖ ស្វាយរៀង
POE៖ មន្ទីរអប់រំខេត្ត
DOE៖ ការិយាល័យអប់រំស្រុក

DPESS៖ នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត
NIPES៖ វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា
MoEYS៖ ក្រសួងអប់រំ យុវជន និងកីឡា
HG៖ អង្គការបេះដូងមាស
TEC៖ វិទ្យាស្ថានគរុកោសល្យ
PTTC៖ សាលាគរុកោសល្យនិងវិក្រឹតការខេត្ត

ប្រភព៖ ដកស្រង់ចេញពីទម្រង់ពាក្យស្នើសុំសម្រាប់«គម្រោង "អប់រំកាយសម្រាប់ទាំងអស់គ្នា" ដើម្បីសិក្សាប្រកបដោយគុណភាពខ្ពស់ជាប់លាប់ពីបឋមសិក្សាដល់វិទ្យាល័យ»

## បានិភ័យនៃការផ្អាកដោយសារតែការរីករាលដាលនៃកូវីដ

គម្រោងនេះបានចាប់ផ្តើមជាមួយនឹងផែនការបែបនេះ ប៉ុន្តែភ្លាមៗបន្ទាប់ពីបានចាប់ផ្តើម វាបានប្រឈមមុខនឹងបញ្ហាដ៏ធំបំផុតនោះគឺការរីករាលដាលនៃជំងឺកូវីដនៅក្នុងប្រទេសកម្ពុជា។ ដោយ ហេតុនេះ សាលារៀនត្រូវបានបង្ខំឱ្យបិទ។ នៅពេលដែលសាលារៀន បិទ ការធ្វើការផ្សព្វផ្សាយអប់រំកាយ គឺមិនអាចទៅរួចទេ។បន្ទាប់ពីការពិភាក្សាម្តងហើយម្តងទៀតជាមួយនាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ជាជាងការផ្អាកគម្រោង យើងបាន សម្រេចផ្លាស់ប្តូរទៅជាសកម្មភាព ដែលប្រើប្រាស់ការប្រជុំតាមអនឡាញ។ល។ ដើម្បីចងក្រងសៀវភៅគ្រូសម្រាប់មធ្យមសិក្សាទុតិយភូមិ ដែលស្ថិតក្នុងដំណើរការចងក្រងនៅឡើយ។

កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិត្រូវបានអនុម័តក្នុងឆ្នាំ២០១៩ ប៉ុន្តែឥឡូវនេះគ្រូបង្រៀនមានសេរីភាពក្នុងការជ្រើសរើសមុខវិជ្ជារងតាមតម្រូវការរបស់សិស្សបានបន្ថែមពីលើខ្លឹមសារសម្រាប់មធ្យមសិក្សាបឋមភូមិ។ ឧទាហរណ៍ នៅក្នុងករណីនៃកាយសម្ព័ន្ធនៅក្នុងមធ្យមសិក្សាបឋមត្រូវបានកំណត់ថាលំហាត់កម្រាលសម្រាប់សិស្សថ្នាក់ទី៧ លំហាត់របារទោលសម្រាប់សិស្សថ្នាក់ទី ៨ និងលំហាត់របារលំនឹងសម្រាប់សិស្សថ្នាក់ទី៩ ប៉ុន្តែនៅវិទ្យាល័យ យើងបានសរសេរត្រឹមតែកាយសម្ព័ន្ធសម្រាប់សិស្សថ្នាក់ទី១០ដល់ទី១២ប៉ុណ្ណោះ។

នៅមធ្យមសិក្សាទុតិយភូមិ សិស្សសម្រេចចិត្ត ដោយខ្លួនឯងថាកាយសម្ព័ន្ធប្រភេទណាដែលពួកគេចង់ធ្វើ និងក៏អាចអនុវត្តមុខវិជ្ជារងជាច្រើនក្នុងពេលតែមួយ។ ពួកគេក៏អាចធ្វើលំហាត់កម្រាល លំហាត់របារទោល និងលំហាត់របារលំនឹងក្នុងពេលតែមួយផងដែរ។ ដោយសារសម្ភារៈបង្រៀននៅក្នុងសាលារៀននៅមានកម្រិតការរៀបចំមុខវិជ្ជារង៣ក្នុងពេលតែមួយមានអត្ថប្រយោជន៍ក្នុងការកាត់បន្ថយចំនួនសិស្សដែលកំពុងរង់ចាំ។ សិស្សរៀបចំផែនការ និងពិចារណាខ្លឹមសារសិក្សាដោយខ្លួនឯងផ្ទាល់ ហើយគ្រូបង្រៀនមានតួនាទីជួយសិស្ស។ ជាការពិតណាស់មានសិស្សមួយចំនួនដែលមិនចេះជម្នះឧបសគ្គរបស់ពួកគេ ដូច្នេះហើយឥឡូវនេះ គ្រូបង្រៀនត្រូវការជំនាញកម្រិតខ្ពស់ក្នុងការណែនាំសិស្សប្រកបដោយភាពបត់បែន ដើម្បីអាចផ្តល់ដំបូន្មានសមរម្យដល់សិស្សបែបនេះ។

ចំពោះមុខវិជ្ជារងវិញ តាមរយៈការសរសេរថា «ផ្សេងទៀត» ជំនួសឱ្យតែអ្វីដែលបានកំណត់ នៅមធ្យមសិក្សាបឋមភូមិ ឧទាហរណ៍ ប្រសិនបើគ្រូពូកែខាងកីឡាណាមួយ ពួកគេក៏អាចបង្រៀន កីឡាផ្សេងទៀតដូចជា ការ៉ាតេ តេក្វាន់ដូ បាល់ឱប និងបេស្បលជាដើម។ នេះអនុញ្ញាតឱ្យមានជម្រើស មុខវិជ្ជារងបានកាន់តែទូលំទូលាយ សម្រាប់អប់រំកាយនៅមធ្យមសិក្សាទុតិយភូមិ។

ក្នុងការបង្កើតសៀវភៅគ្រូនេះ យើងបានទទួលជំនួយពីមនុស្សសរុបចំនួន១៤ នាក់ រួមទាំង អ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស អតីតអ្នកស្ម័គ្រចិត្ត និងគ្រូបង្រៀន នៅសាកលវិទ្យាល័យ

ជាដើមដែលបានត្រឡប់ទៅប្រទេសជប៉ុនជាបណ្ដោះអាសន្នការផ្អាកសកម្មភាពដោយសារវិបត្តិកូវីដ។ ដំបូង យើងបានបើកវគ្គផ្ដល់ព័ត៌មានមួយដើម្បីបញ្ជាក់ថាមុខវិជ្ជារងណាដែលពួកគេចង់ទទួលបន្ទុក។ យើងបានចែករំលែកការទទួលខុសត្រូវរបស់មន្ត្រីមកពីនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា បានកំណត់មុខវិជ្ជារង និង រៀបចំចងក្រងទៅតាមមុខវិជ្ជារងនីមួយៗ។ ដោយសារយើងមិនអាចជួបទល់មុខគ្នា វាពិបាកក្នុងការដំណើរការអ្វីគ្រប់យ៉ាងតាមអនឡាញ។ សិក្ខាសាលាសរុបចំនួន៧ដង ត្រូវបានធ្វើឡើងតាមអនឡាញហើយខ្លឹមសារនៃសិក្ខាសាលានីមួយៗត្រូវបានកែសម្រួលឱ្យមានភាពស៊ីសង្វាក់គ្នារវាងមុខវិជ្ជារង និងត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ (រូបភាពខាងឆ្វេង)។




សៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិ
ប្រភព៖ សៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិ (MoEYS, ២០២១)

## ផ្នែកទី ៧៖ សកម្មភាពនៃអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស
## សាច់រឿងរបស់អ្នកនាង ខូបាយ៉ាស៊ី មីគុ

នៅទីនេះខ្ញុំចង់ណែនាំរឿងរបស់អ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេសដែលបានចូលរួមចងក្រងសៀវភៅគ្រូ។អ្នកនាងខូបាយ៉ាស៊ីមីគុចូលរួមការងារក្នុងនាមជាសមាជិកក្រុមកីឡានៅវិទ្យាល័យនេតយ៉ង់ ក្នុងខេត្តបាត់ដំបង។

ក្នុងរយៈពេល៣ខែនៃការបំពេញភារកិច្ចរបស់ខ្ញុំនៅប្រទេសកម្ពុជា ខ្ញុំបានចាប់ផ្តើមបង្កើតទំនាក់ទំនងនិងការជឿទុកចិត្តជាមួយដៃគូសហការរបស់ខ្ញុំ ហើយបានត្រៀមខ្លួនជាស្រេចថាជាពេល «តស់ ខ្ញុំត្រូវតែធ្វើអ្វីមួយ»។ ដោយសារតែការរីករាលដាលនៃជំងឺកូវីដ ខ្ញុំត្រូវត្រលប់ទៅប្រទេសជប៉ុនវិញ ហើយនៅពេលដែលត្រលប់ទៅវិញខ្ញុំព្រួយបារម្ភនិងមានអារម្មណ៍ធ្លាក់ទឹកចិត្តព្រោះមិនដឹងថាពេលណានឹងអាចត្រលប់ទៅវិញ។ទោះជាយ៉ាងនេះក្តីខ្ញុំបានគិតថាទោះបីជាខ្ញុំត្រលប់ទៅប្រទេសជប៉ុនក៏ដោយដរាបណាខ្ញុំអាចទាក់ទងដៃគូរបស់ខ្ញុំបានខ្ញុំអាចធ្វើអ្វីមួយដែលមានប្រយោជន៍នៅពេលត្រលប់ទៅកម្ពុជាវិញ។

ឧទាហរណ៍ នៅកម្ពុជាអត់មានរបារដែកទេ ដោយសារវាពិបាកក្នុងការបង្ហាញពីការអនុវត្តជាក់ស្តែងខ្ញុំបានទាក់ទងជាមួយគ្រូជាដៃគូរបស់ខ្ញុំអំពីអ្វីៗគ្រប់យ៉ាងតាំងពីអ្វីដែលទាក់ទងនឹងអប់រំកាយរហូតដល់ជីវិតប្រចាំថ្ងៃដូចជាការផ្ញើវីដេអូអំពីការឡើងលើរបារបញ្ច្រាសនៅឧទ្យានក្នុងប្រទេសជប៉ុន។នៅពេលនោះអង្គការបេះដូងមាសបានស្នើឱ្យខ្ញុំចូលរួមក្នុងការចងក្រងសៀវភៅគ្រូសម្រាប់មធ្យមសិក្សាទុតិយភូមិ។ ជាក់ស្តែងខ្ញុំបានចូលរួមនៅពេលក្រោយត្រលប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែភាគច្រើនខ្ញុំទទួលបន្ទុកលំហាត់ហាត់រាងកាយ និងបាល់ទាត់។
ជាអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស ដោយសារខ្ញុំបានឃើញស្ថានភាពនៅនឹងកន្លែងខ្ញុំបានដឹងបរិស្ថានខុសគ្នាទាំងស្រុងពីប្រទេសជប៉ុនដូចនេះខ្ញុំបានគិតអំពីអប់រំកាយប្រភេទណាដែលអាចធ្វើបានក្នុងស្ថានភាពដែលគ្មានបាល់ហើយដីរដិបរដុប។តាមរយៈការចូលរួមក្នុងការចងក្រងសៀវភៅគ្រូដោយបានយល់ដឹងច្រើនអំពីស្ថានភាពនៅនឹងកន្លែង ខ្ញុំអាចផ្តល់យោបល់នៅកន្លែងជាក់ស្តែងបានកាន់តែច្រើន។

ម្យ៉ាងទៀតវាក៏ជារឿងល្អផងដែរដែលអាចសួរដៃគូដោយផ្ទាល់ថាតើផ្នែកណាខ្លះពិបាកនៅពេលសេចក្តីព្រាងសៀវភៅគ្រូត្រូវបានបញ្ចប់។ជាឧទាហរណ៍វាពិតជាមានប្រយោជន៍ណាស់ក្នុងការស្តាប់យោបល់របស់គ្រូអប់រំកាយនិងកីឡាដែលប្រើសៀវភៅគ្រូដោយផ្ទាល់ដូចជាការដែលថាវាងាយស្រួលប្រើប្រសិនបើមានរូបភាពនិងដ្យាក្រាមច្រើនជាងអត្ថបទ។គ្រូបង្រៀននៅសាលាហាក់ដូចជាយល់ថាខ្លឹមសារគឺពិបាកយល់ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា កម្រិតគួរតែនៅកម្រិតនោះដើម្បីឱ្យគ្រូបង្រៀនដែលអាចយល់បានច្រើនគួរសមក្នុងរយៈពេល៥ឬ១០ឆ្នាំខាងមុខក៏នៅតែអាចប្រើប្រាស់វាបាន។ខ្ញុំក៏បានចូលរួមក្នុងកិច្ចប្រជុំទ្វេភាគីជាមួយក្រសួងអប់រំយុវជននិងកីឡាផងដែរ ហើយខ្ញុំពិតជាភ្ញាក់ផ្អើលនិងស្ងើចសរសើរដែលបានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងខ្លាំងមក

លើរូបខ្ញុំ។

លើសពីនេះ ខ្ញុំបានផ្តល់កម្រាលដល់សាលាដែលខ្ញុំត្រូវបានចាត់តាំង ហើយក្នុងអំឡុងពេលតាមដានខ្ញុំបានជួបជាមួយបុគ្គលិកអង្គការបេះដូងមាសនិងបានស្តាប់ឬនិយាយពីស្ថានភាពបច្ចុប្បន្ន។ក្នុងរយៈពេល១ឬ២សប្តាហ៍នៃភារកិច្ចរបស់ខ្ញុំ នៅពេលដែលបានជួបលោក កែវ សុចិត្រា ជាបុគ្គលិកអង្គការបេះដូងមាស វាបានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងខ្លាំងមកលើរូបខ្ញុំនៅពេលគាត់និយាយថាគាត់មានការចាប់អារម្មណ៍ចំពោះអប់រំកាយរបស់ប្រទេសជប៉ុននិងចង់នាំយកអប់រំកាយតាមបែបជប៉ុនដល់កុមារកម្ពុជា។បន្ទាប់ពីរយៈពេលការងារអ្នកស្ម័គ្រចិត្តបានបញ្ចប់វាក៏ជាការចងចាំដ៏រីករាយផងដែរដែលអាចជួបជុំឡើងវិញជាមួយប្រជាជនកម្ពុជាដែលបានមកអូកាយ៉ាម៉ាតាមរយៈទស្សនកិច្ចសិក្សានៅប្រទេសជប៉ុននៅឆ្នាំ២០២២ សម្រាប់ការបណ្តុះបណ្តាលនៅប្រទេសជប៉ុន។



អ្នកនាង ខូបាយ៉ាស៊ី (ទី៥ រាប់ពីខាងឆ្វេងនៅជួរក្រោយ) និងអ្នកនាង ប៊ួយ លីដា ជាដៃគូរបស់គាត់ (ទី៤ រាប់ពីខាងឆ្វេងនៅជួរក្រោយ) ដែលបានជួបជុំគ្នាឡើងវិញបន្ទាប់ពីការងារអ្នកស្ម័គ្រចិត្តរបស់ JICAបានបញ្ចប់ (២០១៩)

កម្មវិធីសិក្សាអប់រំកាយនៅកម្ពុជាត្រូវបានចងក្រងឡើងដោយផ្អែកលើកម្មវិធីនៅក្នុងប្រទេសជប៉ុន។ នៅពេលនៅកន្លែងជាក់ស្តែងនោះ ខ្ញុំមានអារម្មណ៍ថា អ្វីគ្រប់យ៉ាងគឺថ្មីចំពោះពួកគេ ហើយអ្នកគ្រប់គ្នាកំពុងអនុវត្តអប់រំកាយដោយភាពរីករាយយ៉ាងខ្លាំង។

អ្នកនិពន្ធក៏ជាអតីតសមាជិកអ្នកស្ម័គ្រចិត្តកិច្ចសហប្រតិបត្តិការក្រៅប្រទេស។បន្ទាប់ពីការងារស្ម័គ្រចិត្តរយៈពេល២ឆ្នាំត្រូវបានបញ្ចប់ ខ្ញុំពិតជាមានការព្រួយបារម្ភខ្លាំងណាស់ថាតើសកម្មភាពរបស់យើងនឹងបន្តបែបណាហើយនឹងក្លាយទៅជាយ៉ាងណា?

ខ្ញុំមានសេចក្តីសោមនស្សរីករាយណាស់ដែលអាចទទួលបានព័ត៌មានពីអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេសដែលបានចូលរួមក្នុងអប់រំកាយនៅតាមមូលដ្ឋានថាតើសាលារៀនដែលពួកគេធ្វើការនិងគ្រូបង្រៀនដែលជាសហការីគាត់ធ្វើសកម្មភាពអ្វីខ្លះហើយពួកគេកំពុងបន្តអនុវត្តនិងផ្សព្វផ្សាយអប់រំកាយ។

## សាច់រឿងរបស់លោក យ៉ាម៉ាហ្សាគិ តេបប៉ី

លោក យ៉ាម៉ាហ្សាគិ តេបប៉ី ដែលគ្រោងនឹងធ្វើការជាសមាជិកក្រុមអប់រំកាយនៅវិទ្យាល័យបឹងត្របែកក្នុងទីក្រុងភ្នំពេញត្រូវរង់ចាំនៅប្រទេសជប៉ុនមួយរយៈដោយសារការបញ្ជូនរបស់គាត់ត្រូវបានពន្យារពេលដោយសារការរីករាលដាលនៃជំងឺកូវីដ។ក្នុងអំឡុងពេលរង់ចាំគាត់មិនមានមធ្យោបាយទាក់ទងដៃគូរបស់គាត់ទេ ដូច្នេះគាត់បានធ្វើការដុសខាត់លើជំនាញភាសាជាជាងធ្វើសកម្មភាពជាដើម។ នៅពេលដឹងថាគាត់មិនអាចទៅប្រទេសកម្ពុជាបាន គាត់មានអារម្មណ៍ធ្លាក់ទឹកចិត្តខ្លាំងណាស់ ហើយគម្រោងបញ្ជូននៅក្នុងខែមីនាត្រូវបានពន្យារពេលទៅខែឧសភាបន្ទាប់មកក៏ត្រូវបានពន្យារបន្ថែមទៀតគាត់ចាប់ផ្តើមព្រួយបារម្ភកាន់តែខ្លាំងឡើងថាតើគាត់នឹងត្រូវគេបញ្ជូនទៅពិតប្រាកដឬអត់។

រឿងរ៉ាវនៃការចងក្រងសៀវភៅគ្រូ ត្រូវបានលើកឡើងចំពេលដែលសកម្មភាពនៅមូលដ្ឋានបានចាប់ផ្តើមហើយទីបំផុតខ្ញុំអាចត្រូវបានគេបញ្ជូនមកប្រទេសកម្ពុជាវិញ។ខ្ញុំទទួលបន្ទុកលើកីឡាកាយសម្ព័ន្ធប៉ុន្តែដោយសារថ្នាក់អប់រំកាយនៅក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមយឺតជាងនៅប្រទេសជប៉ុន ខ្ញុំរំពឹងថាជំនាញនឹងខ្ពស់បែបនេះទេ។ អាស្រ័យហេតុនេះ ខ្ញុំមានអារម្មណ៍ថាវានឹងពិបាកក្នុងការបញ្ចូលខ្លឹមសារ និងមុខវិជ្ជារងរបស់កម្មវិធីសិក្សារបស់ជប៉ុនទាំងអស់។

ជាឧទាហរណ៍ ចំពោះរបារដែក សៀវភៅគ្រូសម្រាប់មធ្យមសិក្សាទុតិយភូមិនៅជប៉ុនមានសរសេរអំពីបច្ចេកទេសពិបាកខ្លាំង ទន្ទឹមនឹងនោះ សូម្បីតែសិស្សវិទ្យាល័យជប៉ុនក៏ដោយ ក៏យល់ឃើញថាបច្ចេកទេសពិបាកនោះគឺពិបាកដែរដូច្នេះខ្ញុំគិតថាកុំបញ្ចូលបច្ចេកទេសដែលពិបាកខ្លាំងពេកគឺជាការល្អប្រសើរជាង។ជាការពិតនៅពេលដែលខ្ញុំចាប់ផ្តើមសកម្មភាពនៅក្នុងប្រទេសកម្ពុជាថ្នាក់អប់រំកាយមិនទាន់ចាប់ផ្តើមឡើងវិញនៅឡើយដូច្នេះហើយខ្ញុំមិនមានឱកាសច្រើនក្នុងការពិភាក្សាជាមួយគ្រូសាលាអំពីសៀវភៅគ្រូនោះដែរ។

ក្នុងការចងក្រងសៀវភៅគ្រូ ខ្ញុំបានរៀនសូត្រច្រើនមិនត្រឹមតែពីទស្សនៈរបស់គ្រូអប់រំកាយនៅក្នុងប្រទេសជប៉ុនទេប៉ុន្តែក៏មានបទពិសោធន៍របស់អ្នកដែលបានលេងកីឡាអស់រយៈពេលជាយូរមកហើយនៅក្នុងស្រុក ព្រមទាំងអ្នកចូលរួមក្នុងអប់រំកាយ ដែលមានប្រវត្តិផ្សេងៗគ្នាដែលមិនមែនជាគ្រូអប់រំកាយនិងកីឡាផងដែរ។មុនពេលដែលខ្ញុំដាក់ពាក្យចូលធ្វើអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការ ខ្ញុំ ក៏ធ្លាប់ជាគ្រូបង្រៀននៅប្រទេសជប៉ុនអស់រយៈពេល២ឆ្នាំ។

នៅពេលបង្រៀននៅប្រទេសជប៉ុនអស់រយៈពេល២ឆ្នាំ។នៅពេលបង្រៀនថ្នាក់អប់រំកាយនៅតាមមូលដ្ឋាន ខ្ញុំអាចប្រើបទពិសោធន៍ជាគ្រូបង្រៀននៅប្រទេសជប៉ុន ដោយបានបង្ហាញថ្នាក់រៀនគំរូ និងការសម្តែងគំរូដែលប្រើក្នុងថ្នាក់នៅជប៉ុន ជាជាងគ្រាន់តែផ្តល់ការបង្រៀនទូទៅ។

ខ្ញុំពិតជារន្ធត់ចិត្តណាស់ដែលដឹងថាប្រទេសកម្ពុជាមិនមានកម្មវិធីសិក្សាអប់រំកាយត្រឹមត្រូវអស់រយៈពេលជាយូរមកហើយហើយខ្ញុំបានរៀនច្រើនអំពីរបៀបដែលថ្នាក់អប់រំកាយត្រូវបានរៀបចំឡើងដូចនេះនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ខ្ញុំមានការស្ងើចសរសើរដែលថាថ្នាក់រៀនត្រូវបានបង្កើតឡើងដោយមានការចូលរួមពីមនុស្សផ្សេងៗគ្នាជាច្រើន។ម៉្យាងទៀតគ្រូនៅកម្ពុជាមិនមានទម្លាប់មើលឯកសារទេ ដូច្នេះក្នុងការផ្សព្វផ្សាយអប់រំកាយនាពេលអនាគត ខ្ញុំបានស្នើថាប្រសិនបើមានឃ្លីបវីដេអូជាដើម នោះនឹងកាន់តែងាយស្រួលយល់។

នៅពេលដែលខ្ញុំបង្ហាញវីដេអូនៃការអង្គុយឱនទៅមុខនៅលើ YouTube អំឡុងពេលធ្វើតេស្តកាយសម្បទា គ្រូបានចែករំលែកវីដេអូ ហើយព្យាយាមយល់វាឱ្យកាន់តែច្បាស់ ដូច្នេះខ្ញុំយល់ថាវាមានប្រយោជន៍ខ្លាំងណាស់។បន្ថែមលើវីដេអូខ្ញុំមានអារម្មណ៍ថាវានឹងកាន់តែប្រសើរប្រសិនបើមានអត្ថបទដែលពន្យល់ពីចំណុចសំខាន់ៗ ដូចជា «ចំណុចសំខាន់នៅទីនេះ!»។ ក្នុងករណីដូចជាការលោតចំហៀងឆ្វេងស្តាំទោះបីគ្រូអប់រំកាយមិនបានបង្រៀនក៏ដោយក៏ពួកគេនឹងយល់ដោយគ្រាន់តែបង្ហាញវីដេអូ។ គ្រូទទួលបន្ទុកមានភាពសកម្មខ្លាំងណាស់ ដោយបានហ្វឹកហាត់នៅមុនថ្ងៃត្រូវបង្រៀន ឬពន្យល់ដល់គ្រូដទៃទៀតជាដើម។

ក្នុងអំឡុងពេលនៃភារកិច្ចរបស់ខ្ញុំ ខ្ញុំក៏បានផ្លាស់ប្តូរព័ត៌មានជាមួយសមាជិកក្រុមអប់រំកាយមកពីខេត្តផ្សេងទៀតផងដែរ។នៅខេត្តបាត់ដំបង ខ្ញុំមានការភ្ញាក់ផ្អើលដែលបានឃើញថ្នាក់អប់រំកាយធ្វើបានយ៉ាងល្អ។ ទោះបីខ្ញុំត្រូវបានចាត់តាំងនៅទីក្រុងភ្នំពេញ ប៉ុន្តែវាគួរឱ្យស្ងើចសរសើរណាស់ដែលឃើញនៅតាមខេត្តធ្វើបានល្អផងដែរ។ ខ្ញុំមានអារម្មណ៍ថា មិនមែនដោយសារនៅរាជធានីភ្នំពេញ អប់រំកាយមានការជឿនលឿនទេ ប៉ុន្តែកម្រិតនៃការផ្សព្វផ្សាយគឺខុសគ្នាពីសាលាមួយទៅសាលា។

បន្ទាប់ពីធ្វើការស្ម័គ្រចិត្តអស់រយៈពេល១ឆ្នាំ ខ្ញុំមានការព្រួយបារម្ភថា ខ្ញុំមិនយល់អំពីការអប់រំរបស់កម្ពុជាជាងការរំពឹងទុកទៅទៀតទើបខ្ញុំចាប់ផ្តើមគិតអំពីការចូលរៀនថ្នាក់ក្រោយឧត្តមសិក្សា ដើម្បីសិក្សាផ្នែកអប់រំកាយឱ្យបានហ្មត់ចត់។ ខ្ញុំបានត្រលប់មកប្រទេសជប៉ុនវិញ ហើយឥឡូវនេះធ្វើការពេញម៉ោងជាគ្រូបង្រៀន ប៉ុន្តែនៅពេលដែលខ្ញុំណែនាំខ្លួននៅពេលថ្នាក់ចាប់ផ្តើមថាធ្លាប់បានធ្វើការនៅប្រទេសកម្ពុជាខ្ញុំសប្បាយចិត្តដែលឃើញកុមារជប៉ុនចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការស្តាប់អំពីមីននៅកម្ពុជា ថាតើមានការអភិវឌ្ឍប៉ុណ្ណានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។



លោក យ៉ាម៉ាហ្សាគិ អ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស JICA អនុវត្តថ្នាក់គំរូនៅក្នុងសិក្ខាសាលាថ្នាក់ស្រាវជ្រាវមួយ

កុមារកម្ពុជាមានកិច្ចការជាច្រើនដែលពួកគេចង់ធ្វើដូចជាចង់ទៅក្រៅប្រទេសចង់ទៅប្រទេសជប៉ុន ចង់ទៅប្រទេសចិនជាដើម ប៉ុន្តែកុមារជប៉ុនប្រហែលជាមានអារម្មណ៍ថាប្រទេសរបស់ពួកគេមានសុភមង្គលណាស់ហើយពួកគេមិនសូវមើលទៅពិភពលោកក្រៅទេ។ នៅពេលអនាគត ខ្ញុំនឹងសិក្សាបន្ថែមទៀតអំពីអប់រំរាងកាយនៅកម្ពុជានៅឯសាលាក្រោយឧត្តមសិក្សា ហើយព្យាយាមរកមើលថា តើខ្ញុំអាចបញ្ចូលអ្វីដែលខ្ញុំបានរៀននៅកម្ពុជាចូលប្រទេសជប៉ុន។

មានករណីខ្លះដូចជាលោក យ៉ាម៉ាហ្សាគិ ដែលបទពិសោធន៍របស់អ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស JICA នាំទៅរកផ្លូវអាជីពបន្ទាប់ ហើយខ្ញុំគិតថាវាក៏អាចផ្សារភ្ជាប់ទៅនឹងសកម្មភាពនៃបេះដូងមាសផងដែរ។សហគមន៍អប់រំកាយកំពុងពង្រីកតាមរបៀបនេះទាំងក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងប្រទេសកម្ពុជា និងក្នុងចំណោមអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស។

## ផ្នែកទី ៤៖ គុណសម្បត្តិនិងគុណវិបត្តិនៃវិបត្តិកូវីដ ឯករាជ្យភាពលេចឡើងនៅក្នុងនាយកដ្ឋានអប់រំ

វិបត្តិកូវីដក៏បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសកម្មភាពរបស់អង្គការបេះដូងមាសផងដែរ។ កញ្ញា វង្ស វិល័យ ជាបុគ្គលិកទទួលបន្ទុកគម្រោង អប់រំកាយ សម្រាប់ទាំងអស់គ្នា នៅខេត្តស្វាយរៀង បានមានប្រសាសន៍ថា គាត់បានរៀនជំនាញថ្មីៗតាមរយៈថ្នាក់អណឡាញ។ នៅពេលចងក្រងសៀវភៅគ្រូ គាត់ត្រូវបានចាត់តាំងជាពិធីករ អ្នកបកប្រែ និងអ្នកសម្របសម្រួលសម្រាប់សិក្ខាសាលា ហើយដោយសារមិនអាចជួបមុខគ្នាបាន គាត់តែងតែទាក់ទងទៅគ្រូឧទ្ទេសថ្នាក់ជាតិដើម្បីបញ្ជាក់ខ្លឹមសារ។

សិក្ខាសាលាអាចដំណើរការឡើងវិញនៅខែធ្នូ ឆ្នាំ២០២១ នៅពេលដែលប្រារព្ធសិក្ខាសាលាឡើងជាលើកដំបូងនៅក្នុងខេត្តបាត់ដំបងមន្ត្រីក្រសួងអប់រំនិងបុគ្គលិកអង្គការបេះដូងមាសបានឆ្លងកូវីដរួចទៅហើយ។ យើងត្រូវតែមានភាពបត់បែនក្នុងការដោះស្រាយជាមួយនឹងស្ថានភាពដែលមិនបានមើលឃើញទុកជាមុនដែលបានកើតឡើងជាបន្តបន្ទាប់ប៉ុន្តែតាមរយៈការជម្នះរាល់បញ្ហាទាំងនេះម្តងមួយៗ បុគ្គលិករបស់យើងកាន់តែមានភាពជឿជាក់។

សៀវភៅគ្រូសម្រាប់មធ្យមសិក្សាទុតិយភូមិត្រូវបានគ្រោងបង្កើតដោយឯករាជ្យដោយនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត ប៉ុន្តែដោយសារការកែតម្រូវផែនការដោយសារវិបត្តិកូវីដយើងអាចបញ្ចូលវាទៅក្នុងសកម្មភាពគម្រោងនិងធ្វើការពិនិត្យខ្លឹមសារ។ម្យ៉ាងវិញទៀត នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតបានធានានូវថវិកាទាំងមូលសម្រាប់ការបោះពុម្ពដែលបង្ហាញថានិរន្តរភាពត្រូវបានធានាជាបណ្តើរៗ។

សៀវភៅគ្រូសម្រាប់មធ្យមសិក្សាទុតិយភូមិត្រូវបានបញ្ចប់ក្នុងខែតុលា ឆ្នាំ២០២១ ហើយនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំដដែល ក៏បានទទួលការអនុម័តពីរដ្ឋមន្ត្រីក្រសួងអប់រំ។ ម្យ៉ាងទៀត ទន្ទឹមនឹងនេះដែរ វាក៏ត្រូវបានបញ្ជាក់ផងដែរថា សាលារៀននឹងបើកឡើងវិញចាប់ពីខែមករា ឆ្នាំ២០២២។ គម្រោងនេះខុសពីគម្រោងមុនៗ ដោយមានគោលដៅឱ្យមន្ទីរ/ ការិយាល័យអប់រំរាជធានី/ខេត្ត/ ស្រុកដឹកនាំក្នុងការបង្កើតផែនការផ្សព្វផ្សាយ និងផ្តួចផ្តើមគំនិតដើម្បីលើកកម្ពស់ការផ្សព្វផ្សាយ។ក្នុងឆ្នាំទី១២០២១-២០២២មន្ទីរ/ការិយាល័យអប់រំរាជធានី/ខេត្ត/ស្រុក នៃរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង បានបែងចែកខេត្តនីមួយៗជា ៤ ទៅ ៥ ស្រុក ហើយបានធ្វើសិក្ខាសាលា និងការតាមដានដោយផ្អែកលើថវិកាគម្រោង។

មន្ទីរ/ការិយាល័យអប់រំរាជធានី/ខេត្ត/ស្រុក ដែលផ្តោតលើការផ្តល់ទីកន្លែងនៅក្នុងគម្រោងមុនៗ ដើម្បីផ្សព្វផ្សាយ «អប់រំកាយបែបថ្មី» ពួកគេជាអ្នកផ្តួចផ្តើមគំនិតក្នុងដំណើរការផ្សព្វផ្សាយដោយត្រូវពិចារណាយ៉ាងហ្មត់ចត់ពីរបៀបអនុវត្តការតាមដាននិងអ្នកដែលត្រូវអញ្ជើញឱ្យចូលរួមសិក្ខាសាលាជាដើម។ ជាពិសេសសម្រាប់ខេត្តស្វាយរៀងបានធានាថវិកាខេត្តផ្ទាល់

សម្រាប់ឆ្នាំបន្ទាប់២០២២-២៣ ដែលអាចអនុវត្តការតាមដានបាន។គម្រោងនេះនៅសល់រយៈពេល១ឆ្នាំទៀតរហូតដល់ខែមករា ឆ្នាំ២០២៥ហើយយើងមានក្តីសង្ឃឹមខ្ពស់ថាវានឹងបង្កើតគំរូសម្រាប់ផ្សព្វផ្សាយ«អប់រំកាយបែបថ្មី»របស់កម្ពុជា និងរីករាលដាលដល់បណ្តាខេត្តផ្សេងៗទៀត។

## កុមាររីករាយ នឹងថ្នាក់អប់រំកាយ

លោក គង់ ទិត្យកុមារ ប្រធានការិយាល័យអប់រំកាយ និងកីឡានៃមន្ទីរអប់រំខេត្តស្វាយរៀង បានមានប្រសាសន៍ថា រហូតមកដល់ពេលនេះ គម្រោងនេះបានកំណត់គោលដៅតែសាលាប្រហែល៥ប៉ុណ្ណោះ ហើយមន្ទីរអប់រំខេត្តក៏បានពិចារណាលើការផ្សព្វផ្សាយទៅសាលាចំនួន៥ផងដែរ។ សាលារៀនផ្សេងទៀតត្រូវបានទុកចោល ប៉ុន្តែគម្រោង «អប់រំកាយសម្រាប់ទាំងអស់គ្នា» នាពេលបច្ចុប្បន្ននេះ គ្របដណ្តប់សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់នៅក្នុងខេត្តស្វាយរៀង។ដូច្នេះលោកបានពន្យល់ថាមន្ទីរអប់រំខេត្តនឹងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីជួយសម្រេចគោលដៅនោះ។

មន្ទីរអប់រំខេត្តទទួលបានថវិកាចំនួន ២០លានរៀល (៥,០០០ដុល្លារ) សម្រាប់ការតាមដានថ្នាក់អប់រំកាយ និងការតាមដានថ្នាក់កីឡា។ ក្នុងនោះ នៅឆ្នាំ២០២៣ ថវិកា ១៥ លានរៀល (៣,៧៥០ ដុល្លារ) ត្រូវបានប្រើប្រាស់ សម្រាប់ការតាមដានក្នុង១ក្រុង និង៦ស្រុក ក្នុងខេត្តស្វាយរៀង។ មន្ត្រីនាយកដ្ឋានអប់រំខេត្តចំនួន ១២ នាក់បានធ្វើការតាមដាន ហើយទោះបីជាសាលារៀនទាំងអស់មិនទាន់អាចអនុវត្តអប់រំកាយបែបថ្មីក៏ដោយ ក៏ពួកគេបានបង្កើតនិងបញ្ជូនរបាយការណ៍ដោយប្រើសន្លឹកវាយតម្លៃដែលប្រើក្នុងគម្រោង។

លោក គង់ ទិត្យកុមារ បានមានប្រសាសន៍ថា លោកផ្ទាល់មិនដឹងថា តើគោលដៅ ៥០% នៃសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់ក្នុងខេត្តស្វាយរៀង នឹងត្រូវសម្រេចនៅខែមករាឆ្នាំ២០២៥ក្នុងអំឡុងពេលនៃគម្រោងនេះឬយ៉ាងណានោះទេប៉ុន្តែលោកបានសម្តែងនូវបំណងប្រាថ្នាយ៉ាងខ្លាំង ក្នុងការប្រឹងប្រែងធ្វើឱ្យអស់ពីសមត្ថភាព។ លោកបានមានប្រសាសន៍ថា ប្រសិនបើនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត បង្កើនចំនួនសិក្ខាសាលាចំនួន៣ដងក្នុងមួយឆ្នាំជាដើមនឹងជួយបង្កើនឱកាសនៃការសម្រេចគោលដៅបន្ថែមទៀត។ លោកបានមានប្រសាសន៍ថា កុមារដែលចូលរៀនថ្នាក់អប់រំកាយបែបថ្មីកំពុងរីករាយនឹងមេរៀនអប់រំកាយរបស់ពួកគេ ហើយក៏មានកុមារជាច្រើនបានស្នើសុំឱ្យពន្យារពេលថ្នាក់អប់រំកាយ៥នាទី។

នៅតាមសាលារៀនទាំងគ្រូនិងសិស្សបានចាប់ផ្តើមពាក់ឯកសណ្ឋានអប់រំកាយសម្រាប់ថ្នាក់របស់ពួកគេ។គ្រូបង្រៀននៅសាលាបឋមសិក្សាខ្សែតមានវ័យចំណាស់រហូតមកដល់ពេលនេះគាត់មិនធ្លាប់ចូលរួមសិក្ខាសាលាទេហើយក៏មិនមែនជាគ្រូអប់រំកាយដែរប៉ុន្តែគាត់ប្រឹងប្រែងបង្រៀនបាល់ទាត់ឬបាល់ទះរយៈពេល៤០នាទីក្នុងថ្នាក់អប់រំកាយ។គាត់មានគម្រោង

បន្តការតាមដាននៅឆ្នាំក្រោយដើម្បីយល់ពីស្ថានភាពនេះ។គាកស្តាយដែលការផ្សព្វផ្សាយអប់រំកាយកាយមិនរីកចម្រើនដូចការរំពឹងទុកប៉ុន្តែខ្ញុំសប្បាយចិត្តជាខ្លាំងដែលនៅចុងបញ្ចប់គាត់បានបញ្ជាក់យ៉ាងម៉ឺងម៉ាត់ថាគាត់នឹងបន្តខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព។

បន្ទាប់ពីសម្ភាសលោក គង់ ទិត្យកុមារ អ្នកនិពន្ធបានប្រាប់គាត់ថា មិនបាច់សុំទោសទេ។ ខ្ញុំបានប្រាប់ថា វាជាការល្អបំផុត ប្រសិនបើគោលដៅត្រូវបានសម្រេចក្នុងអំឡុងពេលនៃគម្រោងប៉ុន្តែទោះបីជាគោលដៅមិនត្រូវបានសម្រេចក៏ដោយការជំរុញនិងការលើកទឹកចិត្តរបស់គាត់ក្នុងការផ្សព្វផ្សាយអប់រំកាយនឹងបានទៅដល់សាលាបឋមសិក្សាអនុវិទ្យាល័យនិងវិទ្យាល័យក្នុងខេត្តស្វាយរៀង ហើយសាលារៀនកាន់តែច្រើននឹងយល់ពីតម្លៃនៃអប់រំកាយ និងធ្វើការដើម្បីអនុវត្តនិងផ្សព្វផ្សាយអប់រំកាយដោយខ្លួនឯងដោយគ្មានការបង្ខំ។វាជាពេលដែលខ្ញុំមានអារម្មណ៍ជាថ្មីម្តងទៀតថា សហគមន៍អប់រំកាយដែលសាស្ត្រាចារ្យ អូកាដិ យ៉ូស៊ីណូរិ កំពុងនិយាយ គឺសហគមន៍ប្រភេទនេះ។



ការផ្សព្វផ្សាយអប់រំកាយបែបថ្មីដែលកំពុងវិវត្តនៅក្នុងខេត្តស្វាយរៀង

## ខេត្តស្វាយរៀង មានឱកាស ៥០%

កញ្ញា វង្ស វិល័យ បុគ្គលិកអង្គការបេះដូងមាស ដែលបានរៀបរាប់ខាងលើ មានអារម្មណ៍ថា មានឱកាស ៥០% ក្នុងការផ្សព្វផ្សាយអប់រំកាយដល់សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់ក្នុងខេត្តស្វាយរៀង តាមរយៈសិក្ខាសាលា និងការតាមដាន ។ថវិកាត្រូវបានធានាហើយក្នុងអំឡុងពេលនៃការតាមដានថ្មីៗនេះដែលធ្វើឡើងនៅទីក្រុងបាវិត ការិយាល័យអប់រំស្រុកបានសន្យាថានឹងធ្វើការតាមដាន និងដំណើរការផ្សព្វផ្សាយអប់រំកាយដោយខ្លួនឯង។ នៅពេលនិយាយជាមួយមន្ទីរ/ការិយាល័យអប់រំខេត្ត/ស្រុក ខ្ញុំមិនព្យាយាមបង្ខំពួកគាត់ឱ្យលើកកម្ពស់អប់រំកាយទេ ប៉ុន្តែផ្ទុយទៅវិញខ្ញុំនិយាយជាមួយពួកគេដោយបង្កើនការលើកទឹកចិត្តរបស់ពួកគាត់ដែលហាក់ដូចជាជួយពួកគេអភិវឌ្ឍអារម្មណ៍ឯករាជ្យ។

ខណៈពេលដែលកំពុងផ្តោតលើការលើកកម្ពស់កីឡា(រៀបចំការប្រកួតកីឡា។ល។) វាពិបាកក្នុងការផ្លាស់ប្តូរការយល់ដឹងរបស់យើងអំពីកីឡាទៅជាការយល់ដឹងអំពីការលើកកម្ពស់អប់រំកាយណាស់។ ទោះជាយ៉ាងនេះក្តី ខ្ញុំក៏បានកែសម្រួលពាក្យពេចន៍និយាយផងដែរដើម្បីផ្លាស់ទៅរកការលើកកម្ពស់អប់រំកាយខណៈពេលដែលរក្សាការយល់ដឹងអំពីការលើកកម្ពស់កីឡាដោយបានលើកឡើងថាការផ្សព្វផ្សាយអប់រំកាយនឹងជះឥទ្ធិពលដល់ការជ្រើសរើសអត្តពលិកក្នុងការប្រកួតកីឡាជាដើម ហើយនឹងឈានទៅដល់ការរីកសាយភាយកីឡាក្នុងខេត្តស្វាយរៀង។ ខណៈពេលដែលវាពិបាកក្នុងការផ្លាស់ប្តូរការយល់ដឹង ទស្សនកិច្ចសិក្សានៅប្រទេសជប៉ុនដែលរួមបញ្ចូលក្នុងគម្រោងនេះគឺជាការលើកទឹកចិត្តដ៏អស្ចារ្យមួយហើយការដែលថាមានលទ្ធភាពទៅប្រទេសជប៉ុនដោយការខិតខំប្រឹងប្រែងដើម្បីផ្សព្វផ្សាយអប់រំកាយមានន័យថានេះបាននាំឱ្យបង្កើនការលើកទឹកចិត្តដល់មន្ត្រីមន្ទីរអប់រំ/ការិយាល័យអប់រំខេត្ត/ស្រុក នាយកសាលា និងគ្រូបង្រៀន។

វាពិបាកណាស់ក្នុងការលើកកម្ពស់អប់រំកាយទាំងគុណភាពនិងបរិមាណ។នៅពេលនិយាយអំពីគុណភាព សិក្ខាសាលានិងការតាមដានសម្រាប់សាលារៀនមួយចំនួនតូចមានប្រសិទ្ធភាពណាស់ប៉ុន្តែមានក្តីបារម្ភថានេះនឹងមិនបង្កើនចំនួនសាលាដែលត្រូវផ្សព្វផ្សាយនោះទេ។ ខេត្តស្វាយរៀង មានបំណងសម្រេចបានគោលដៅ ៥០%នៃអត្រាផ្សព្វផ្សាយគម្រោងដែលបានកំណត់ដោយអង្គការបេះដូងមាសប៉ុន្តែយើងចង់ឱ្យពួកគាត់ធ្វើការលើគម្រោងនេះជាមួយនឹងគុណភាពនៃថ្នាក់អប់រំកាយនៅក្នុងសាលានីមួយៗ។

## រាជធានីភ្នំពេញដែលពិបាកផ្សព្វផ្សាយ

បើប្រៀបធៀបទៅនឹងស្វាយរៀងរាជធានីភ្នំពេញពិបាកធ្វើការផ្សព្វផ្សាយជាង។កញ្ញា ម៉ម ចាន់ម៉ារី បុគ្គលិករបស់អង្គការបេះដូងមាសដែលទទួលបន្ទុកផ្សព្វផ្សាយនៅរាជធានីភ្នំពេញ បានមានប្រសាសន៍ថាការលំបាកមួយក្នុងការផ្សព្វផ្សាយអប់រំកាយក្នុងរាជធានីភ្នំពេញគឺ គណៈគ្រប់គ្រងសាលាមិនងាយស្តាប់នូវអ្វីដែលការិយាល័យអប់រំរាជធានី/ខណ្ឌនិយាយទេហើយទោះបី

ជាពួកគេនិយាយថា ពួកគាត់នឹងផ្សព្វផ្សាយនៅសាលារៀនក្នុងពេលធ្វើសិក្ខាសាលារួមទាំងការតាមដាន ប៉ុន្តែតាមពិត ពួកគាត់មិនបាន ធ្វើការផ្សព្វផ្សាយទេ។ មូលហេតុគឺថា គណៈគ្រប់គ្រងសាលានៅភ្នំពេញមានឱកាសក្នុងការជួបជាមួយរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការជាដើមដែលមានឋានៈខ្ពស់ជាងមន្ត្រីនៃការិយាល័យអប់រំរាជធានី/ខណ្ឌបានច្រើនជាងម៉្យាងទៀតបើតាមមន្ត្រីការិយាល័យអប់រំរាជធានី/ខណ្ឌមូលហេតុមិនស្តាប់យោបល់ដោយសារមុខតំណែង។ដើម្បីជំរុញការផ្សព្វផ្សាយនេះ មានតែដាក់សំណើទៅរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ គួរតែចុះមកធ្វើការតាមដាន ដើម្បីអាច ប្រាប់ពីស្ថានភាពនៃការផ្សព្វផ្សាយអប់រំកាយដល់រដ្ឋមន្ត្រី។

នៅពេលសួរថាតើអាចផ្សព្វផ្សាយអប់រំកាយបែបថ្មីដល់៥០%នៃសាលាបឋមសិក្សាអនុវិទ្យាល័យនិងវិទ្យាល័យទាំងអស់ក្នុងរាជធានីភ្នំពេញដែរឬទេកញ្ញាម៉មចាន់ម៉ារីឆ្លើយថាវានឹងពិបាកប្រសិនបើដូចពេលនេះ។ អ្នកនាងបាននិយាយថា ជាពិសេសអនុវិទ្យាល័យនិងវិទ្យាល័យមានការពិបាកហើយគ្រូឧទ្ទេសថ្នាក់ជាតិបានពិភាក្សាថាខ្លឹមសារនៃសន្លឹកវាយតម្លៃអប់រំកាយអាចមានភាពតឹងរ៉ឹងពេកហើយវាមិនមានភាពប្រាកដនិយមក្នុងការវាយតម្លៃគ្រូបង្រៀនដែលមិនបានរៀនអប់រំកាយថ្មីក្នុងអំឡុងពេលបណ្តុះបណ្តាលគ្រូដោយផ្អែកលើខ្លឹមសារដែលពិបាកពេកហើយគួរតែពិចារណាធ្វើឱ្យប្រសើរឡើងនូវសន្លឹកវាយតម្លៃ។

នៅពេលគម្រោងដំណើរការទៅមុខវាហាក់ដូចជាមានអារម្មណ៍ថាមានលទ្ធភាពដែលការផ្សព្វផ្សាយនឹងបង្កើនល្បឿនហើយក៏មានឧទាហរណ៍ដ៏ល្អមួយដឹកនាំជាចម្បងដោយនាយករងសាលាបឋមសិក្សាបាក់ទូក ដែលបានចូលរួមទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន បានបើកថ្នាក់សាធារណៈដោយខ្លួនឯង។ បុគ្គលិកនៃបេះដូងមាសក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងថ្នាក់នោះដែរ និងបានផ្តល់យោបល់អំពីរបៀបដែលការផ្សព្វផ្សាយដំណើរការ។យើងរំពឹងយ៉ាងខ្លាំងថាការកើនឡើងនៃគំនិតផ្តួចផ្តើមបែបនេះ នឹងនាំឱ្យមានចលនាផ្សព្វផ្សាយអប់រំកាយដោយខណ្ឌនិងសាលារៀនខ្លួនឯងផ្ទាល់។

នាងនិយាយថា អប់រំកាយបច្ចុប្បន្នត្រូវបានអភិវឌ្ឍជាលំដាប់បើប្រៀបធៀបទៅនឹងនៅពេលដែលនាងជាសិស្ស។អប់រំកាយគឺពិបាកក្នុងការទទួលបានចំណាប់អារម្មណ៍របស់គណៈគ្រប់គ្រងសាលានិងគ្រូជាងមុខវិជ្ជាដទៃទៀត ហើយមិនត្រូវបានបង្រៀនដោយផ្អែកលើកម្មវិធីសិក្សាដូចជាមុខវិជ្ជាផ្សេងទៀតទេ។ លើសពីនេះទៀត ឪពុកម្តាយមិនបានដឹងអំពីអប់រំកាយទេពីព្រោះពួកគេបានស្នើសុំឱ្យសាលាបង្រៀននូវមុខវិជ្ជាសំខាន់ៗសម្រាប់កុមារ។ នៅក្នុងកាលៈទេសៈទាំងនេះ ខ្ញុំមានអារម្មណ៍ថាការខិតខំប្រឹងប្រែងជាបន្តបន្ទាប់នៃបេះដូងមាស បានធ្វើឱ្យកាន់តែស៊ីជម្រៅនូវការយល់ដឹងរបស់មន្ទីរ/ការិយាល័យអប់រំរាជធានី/ខេត្ត/ស្រុកហើយអប់រំកាយបែបថ្មីកំពុងរីករាលដាលបន្តិចម្តងៗ។ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយបន្ថែមទៀតនាពេលអនាគតវាចាំបាច់ត្រូវលើកកម្ពស់ការផ្សព្វផ្សាយជាប្រព័ន្ធ ហើយយើងជឿជាក់ថានាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡានឹងដើរតួយ៉ាងសំខាន់។

ចំណុចរួមទាក់ទងនឹងការផ្សព្វផ្សាយអប់រំកាយនៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និង ខេត្តស្វាយរៀងគឺមានសារៈសំខាន់ណាស់ក្នុងការធ្វើសិក្ខាសាលាពន្យល់អំពីព័ត៌មានអប់រំកាយបែប ថ្មី និងដើម្បីបង្កើតផែនការប្រចាំឆ្នាំ ផែនការមេរៀន និងកិច្ចតែងការបង្រៀន។ ម៉្យាងវិញទៀត វាពិបាកក្នុងការបំពេញសិក្ខាសាលាសម្រាប់គ្រូសាលាទាំងអស់នៅក្នុងគម្រោង ហើយយើង សង្ឃឹមថាទីក្រុងនិងស្រុកនីមួយៗនឹងអាចធានាថវិកាបាន។



ទិដ្ឋភាពនៃថ្នាក់អប់រំកាយនៅអនុវិទ្យាល័យនៅស្វាយរៀងកំពុងលេងប៉េតង់

ចំណុចមួយទៀត គឺថាការយល់ដឹងរបស់គណៈគ្រប់គ្រងសាលាចំពោះអប់រំកាយគឺ មានសារៈសំខាន់ណាស់ក្នុងការផ្សព្វផ្សាយអប់រំកាយ។ មិនថាគ្រូមានឆន្ទៈយ៉ាងដូចម្ដេចទេ ប្រសិនបើគណៈគ្រប់គ្រងសាលាមិនដឹកនាំសាលាធ្វើការផ្សព្វផ្សាយអប់រំកាយទេ គ្រូបង្រៀននឹង បាត់បង់ទឹកចិត្តហើយការផ្សព្វផ្សាយនឹងមិនរីកចម្រើនឡើយ។ក្នុងន័យនេះនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិតបានដឹងខ្លួននៅដើមដំបូង ហើយបន្ទាប់ពីដំណាក់កាលទី ៣ សម្រាប់ សាលាបឋមសិក្សាបានបញ្ចប់នៅឆ្នាំ២០១៦បានផ្ដល់ការបណ្ដុះបណ្ដាលសម្រាប់គណៈគ្រប់គ្រង សាលាដោយប្រើថវិកាផ្ទាល់ខ្លួន។



ទិដ្ឋភាពនៃថ្នាក់អប់រំកាយនៅសាលាបឋមសិក្សានៅស្វាយរៀងកំពុងអនុវត្តលោតរំលងខ្នងសេះ

គម្រោង «អប់រំកាយ សម្រាប់ទាំងអស់គ្នា»ដែលមានរយៈពេលរហូតដល់ខែមករា ឆ្នាំ២០២៥ កំពុងបន្តនៅឡើយ ប៉ុន្តែវាមានសារៈសំខាន់ណាស់ ដែលរាជធានី/ ខេត្ត/ ស្រុកនីមួយៗកំពុងដំណើរការផ្សព្វផ្សាយដោយខ្លួនឯង។ យើងជឿជាក់ថា ការដែលពួកគេបានបង្កើតផែនការផ្សព្វផ្សាយផ្ទាល់ខ្លួនដោយការយល់ដឹងរបស់ពួកគេនិងកំណត់គោលដៅផ្សព្វផ្សាយខ្ពស់ដល់ទៅ ៥០% នៃសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់នៅក្នុងគម្រោង បានធ្វើឱ្យវាច្បាស់នូវអ្វីដែលពួកគេត្រូវធ្វើ។ យើងនឹងបន្តគាំទ្រឱ្យអស់ពីសមត្ថភាពដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជធានីនិងខេត្តទាំង៣ក្នុងការផ្សព្វផ្សាយអប់រំកាយបែបថ្មីខណៈពេលដែលរក្សាបាននូវតុល្យភាពដ៏ល្អរវាងការប្រកួតប្រជែងនិងកិច្ចសហប្រតិបត្តិការនៅក្នុងរាជធានី/ខេត្តនីមួយៗ។

## អត្ថបទទី៥៖ អប់រំកាយបានផ្លាស់ប្តូរ

នៅក្នុងគម្រោង JICA អប់រំកាយ សម្រាប់ទាំងអស់គ្នា តំណាងបេះដូងមាសត្រូវបានចាត់តាំងនៅតាមរាជធានី/ខេត្តនីមួយៗ ក្នុងចំណោមគោលដៅទាំង៣គឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង។ បុគ្គលិកទាំងអស់សុទ្ធតែជាស្ត្រីក្នុងវ័យ២០ឆ្នាំរួមមាន កញ្ញា ម៉ម ចាន់ម៉ារី នៅរាជធានីភ្នំពេញ លោកស្រី គង់ ស៊ីវឡេង នៅខេត្តបាត់ដំបង និង កញ្ញា វង្ស វិល័យ នៅស្វាយរៀង។

ក្មេងជំនាន់ក្រោយមិនដឹងអំពីសម័យប៉ុលពតនោះទេ។ខ្ញុំបានសួរពួកគេថាតើអប់រំកាយរបស់កម្ពុជាបានផ្លាស់ប្តូរយ៉ាងដូចម្តេច។

«នៅពេលខ្ញុំនៅសាលាបឋមសិក្សាខ្ញុំបានធ្វើលំហាត់ប្រាណបែបខ្មែររយៈពេល១ម៉ោងរៀងរាល់សប្តាហ៍។ គណៈគ្រប់គ្រងសាលាបានហៅសិស្សទាំងអស់មកជុំវិញដងទង់ជាតិ ហើយអ្នករាល់គ្នាបានធ្វើចលនាដូចគ្នា។បន្ទាប់ពីបញ្ចប់ខ្ញុំចាំថាពួកយើងត្រូវបានគេប្រាប់ឱ្យចងចាំវាដោយត្រូវធ្វើចលនាដូចគ្នានៅសប្តាហ៍ក្រោយ។ នៅអនុវិទ្យាល័យនិងវិទ្យាល័យ ខ្ញុំត្រូវបានគេសួរថាតើខ្ញុំធ្វើលំហាត់ប្រាណ (លោតបីជង) ឬផាកពិន័យជាការបង់ប្រាក់។ ខ្ញុំបានជ្រើសរើសបង់ប្រាក់ព្រោះខ្ញុំមិនដឹងពីតម្លៃនៃអប់រំកាយនៅពេលនោះ ហើយខ្ញុំមិនមានទំនុកចិត្តទេ។ សិស្សជាច្រើនផ្សេងទៀតក៏បានបង់ប្រាក់ដូចគ្នា (កញ្ញាវង្ស វិល័យ)»។

បន្ទាប់ពីការដាក់បញ្ចូលអប់រំកាយបែបថ្មីសិស្សអាចនិយាយជាមួយមិត្តភក្តិចែករំលែកគំនិតរបស់ពួកគេ ជួយនិងលើកទឹកចិត្តដល់មិត្តភក្តិ នាងនិយាយថា សិស្សបានផ្លាស់ប្តូរច្រើនបើប្រៀបធៀបជាមួយកាលនាងនៅជាសិស្ស។

កញ្ញាម៉ម ចាន់ម៉ារី មានអារម្មណ៍ថា បន្ទាប់ពីដាក់ឱ្យប្រើប្រាស់អប់រំកាយបែបថ្មី កុមារមានចំណង់ខ្លាំង ក្នុងការចូលរួម និងសកម្មជាងមុន។

«នៅក្នុងការងារជាក្រុម សិស្សអាចផ្លាស់ប្តូរយោបល់និងគំនិត និងគាំទ្រដល់មិត្តភក្តិរបស់ពួកគេ។លើសពីនេះទៀតទាំងសិស្សប្រុសនិងសិស្សស្រីអាចបង្ហាញអារម្មណ៍ខ្លួនឯងបាន។ ម្យ៉ាងវិញទៀត សិស្សស្រីនៅតែមានភាពអៀនខ្មាស់ ហើយហេតុផលនេះគឺដោយសារតែពួកគេមិនបានរៀនអប់រំកាយថ្មីតាំងពីថ្នាក់បឋមសិក្សាមកម្លេះ ហើយកុមារទាំងអស់ទន្ទឹងរង់ចាំរៀនអប់រំកាយបែបថ្មី និងរីកចម្រើនតាំងពីថ្នាក់ទី១ (កញ្ញាម៉ម ចាន់ម៉ារី)»។

លោកគ្រូ កែវ សំរេច នៅសាលាបឋមសិក្សាជ័យជំនះ ក្នុងរាជធានីភ្នំពេញ ដែលបានមកសិក្ខាសាលានៅអូកាយ៉ាម៉ា កាលពីខែតុលា ឆ្នាំ២០២៣ បាននិយាយថា ឥរិយាបថរបស់សិស្សរបស់គាត់បានផ្លាស់ប្តូរយ៉ាងខ្លាំងបន្ទាប់ពីបានណែនាំអប់រំកាយបែបថ្មី។គាត់បាននិយាយថាកុមារដែលពីមុនមិនបានគំនាប់គ្នានៅពេលចាប់ផ្តើម ឬបញ្ចប់កាសិក្សាក្នុងថ្នាក់ ឥឡូវនេះបានមករកគ្រូនៅពេលចប់ម៉ោងក្នុងថ្នាក់ដើម្បីនិយាយពាក្យថា«អរគុណ»។ខ្ញុំគិតថារឿងនេះបានបង្ហាញ

ពីរបៀបដែលថ្នាក់អប់រំកាយមិនត្រឹមតែបង្រៀនចំណេះដឹង និងជំនាញកីឡាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្លាស់ប្តូរគំនិតរបស់កុមារកម្ពុជាផងដែរ។ ម្យ៉ាងទៀត ខ្ញុំសប្បាយចិត្តណាស់ដែលឃើញមានគ្រូជាបន្តបន្ទាប់ដែលមានអារម្មណ៍ថានេះគឺជាការជះឥទ្ធិពលដ៏សំខាន់នៃប្រព័ន្ធអប់រំកាយបែបថ្មី។



លោក កែវ សំរេច គ្រូបង្រៀននៅសាលាបឋមសិក្សាជ័យជំនះ រាជធានីភ្នំពេញ

រឿងរ៉ាវនៃអប់រំកាយថ្មីនេះកំពុងលេចចេញជាលំដាប់ក្នុងគម្រោងនៅតាមសាលាបឋមសិក្សាប្រមាណ ១៦៣ ៦៦អនុវិទ្យាល័យ និង៣៩វិទ្យាល័យ ក្នុងរាជធានីភ្នំពេញ សាលាបឋមសិក្សាចំនួន៦៤៩ ១២៣អនុវិទ្យាល័យ និង២៩វិទ្យាល័យ ក្នុងខេត្តបាត់ដំបង និងសាលាបឋមសិក្សាចំនួន២៦២ ៧៤អនុវិទ្យាល័យ និង២០វិទ្យាល័យក្នុងខេត្តស្វាយរៀង។ ទោះបីជាខ្ញុំមិនបានទៅមើលផ្ទាល់ក៏ដោយក៏ខ្ញុំមិនអាចជំនួសការមើលឃើញរបស់បុគ្គលិកវ័យក្មេងដែលបានឃើញវានិងគ្រូបង្រៀននៅសាលាជាក់ស្តែងនិយាយដោយសប្បាយរីករាយនោះទេហើយខ្ញុំមានអារម្មណ៍យ៉ាងមុតមាំអំពីការផ្សព្វផ្សាយអប់រំកាយបែបថ្មីដោយឯករាជ្យក្នុងចំណោមប្រជាជនកម្ពុជា។




កុមារកាន់បដា «អប់រំកាយសម្រាប់ទាំងអស់គ្នា» បន្ទាប់ពីថ្នាក់រៀន

## អត្ថបទទី៦៖ អ្នកដែលយល់ដឹងច្រើនអំពីគម្រោង

ខ្ញុំបានជួបឯកឧត្តមអ៊ុកសិទ្ធិជាតិជាលើកដំបូងក្នុងឆ្នាំ២០១៣។នៅឆ្នាំ២០១២ពេលខ្ញុំមកប្រទេសកម្ពុជាបាន១ឆ្នាំគាត់ត្រូវបានតែងតាំងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា។គាត់ទុកចិត្តខ្ញុំតាំងពីដំបូង ទោះបីខ្ញុំមានបទពិសោធន៍តិចក៏ដោយ។ ជាការពិតណាស់ នេះដោយសារតែទំនាក់ទំនងសហការដ៏យូរជាមួយអង្គការបេះដូងមាស ហើយឯកឧត្តម សិទ្ធិជាតិបានតែងតាំងខ្ញុំ និងសាស្ត្រាចារ្យរង យ៉ាម៉ាហ្គូជិ តាគុ ដែលជាអ្នកកាន់តំណែងមុនខ្ញុំ ជាទីប្រឹក្សារបស់គាត់។ថ្វីត្បិតតែទឹកមុខរបស់គាត់មើលទៅម៉ាំគួរឱ្យខ្លាចបន្តិចប៉ុន្តែនៅពេលនិយាយជាមួយគាត់ ទើបដឹងថាគាត់មានចិត្តល្អ និងមានស្នាមញញឹមដ៏ស្រស់ស្អាត។

មុនពេលវិបត្តិកូវីដ យើងត្រូវបានគាត់អញ្ជើញជារៀងរាល់ឆ្នាំឱ្យចូលរួមក្នុងការប្រជុំប្រចាំឆ្នាំរបស់ក្រសួងអប់រំ (ធ្វើឡើងក្នុងខែមីនាជារៀងរាល់ឆ្នាំ) ហើយយើងមានឱកាសណែនាំគម្រោងអង្គការបេះដូងមាស។ខ្ញុំក៏ត្រូវបានអញ្ជើញជាអ្នកតំណាងមកពីប្រទេសកម្ពុជាទៅចូលរួមកិច្ចប្រជុំជាមួយរដ្ឋមន្ត្រីអប់រំកាយ និងកីឡាអាស៊ាន ដែលធ្វើឡើងនៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ាកាលពីឆ្នាំ២០១៧។ប្រទេសជប៉ុនក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសន្និសីទនេះផងដែរ ដែលជាផ្នែកមួយនៃអាស៊ានបូកជប៉ុន ហើយវាជាកិត្តិយសដ៏អស្ចារ្យដែលត្រូវបានអញ្ជើញជាសមាជិកជប៉ុននៃភាគីកម្ពុជាឱ្យចូលរួមក្នុងសន្និសីទបែបនេះ។

ដូចដែលខ្ញុំបានរៀបរាប់ក្នុងជំពូកទី១ ឯកឧត្តម សិទ្ធិជាតិ បានប្រាប់ខ្ញុំអំពីសម័យប៉ុលពតហើយគាត់ក៏បានមកប្រទេសជប៉ុនសម្រាប់គម្រោងកីឡាសម្រាប់ថ្ងៃស្អែក(ចងក្រងកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិ)។ ខ្ញុំអាចនិយាយដោយប្រាកដថា ឯកឧត្តម អ៊ុក សិទ្ធិជាតិមិនផ្តល់សេចក្តីទុកចិត្តមកលើខ្ញុំនោះទេ ខ្ញុំនឹងមិនអាចបន្តគម្រោងនេះរហូតមកដល់ពេលនេះទេ។ ទោះបីជាលោកកាន់តំណែងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡាក៏ដោយ ក៏លោកបានលះបង់ខ្លួនឯងក្នុងការលើកកម្ពស់អប់រំកាយដោយមិនគិតផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ដោយឆ្លុះបញ្ចាំងពីបទពិសោធន៍ផ្ទាល់ខ្លួនក្នុងសម័យប៉ុលពតគាត់បានគាំទ្រគម្រោងនេះដោយសង្ឃឹមថាកុមារកម្ពុជានឹងចូលចិត្តថ្នាក់អប់រំកាយ។

អង្គការបេះដូងមាសដំណើរការជាមូលដ្ឋានជាមួយនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ប៉ុន្តែអគ្គនាយកដ្ឋានកីឡាសម្របសម្រួលនាយកដ្ឋានទាំងពីរនេះ ដូច្នេះនៅពេលដែលគម្រោងមិនដំណើរការល្អ ខ្ញុំបានពិគ្រោះជាមួយឯកឧត្តម សិទ្ធិជាតិ ហើយរឿងជាច្រើនត្រូវបានដោះស្រាយ។ នៅក្នុងគម្រោងអប់រំកាយ សម្រាប់ទាំងអស់គ្នារបស់ JICA ទាំងនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា មានការពាក់ព័ន្ធ មានពេលខ្លះដែលភាគីទាំងសងខាងមានការស្ទាក់ស្ទើរក្នុងការចូលរួម ដោយសារបញ្ហាដូចជាភាគីណានឹងសរសេរលិខិតដើម្បីរៀបចំសិក្ខាសាលាជាដើម

ហើយភាគីណាជាអ្នកអនុវត្តនីតិវិធីប៉ុន្តែបញ្ហានេះត្រូវបានដោះស្រាយដោយអញ្ជើញភាគីទាំងពីរ និងផ្តល់ការពន្យល់នៅចំពោះមុខឯកឧត្តម សិទ្ធិជាតិ។

ការចូលនិវត្តន៍របស់គាត់ពីអគ្គនាយកកីឡានៅខែសីហា ឆ្នាំ២០២៣ បានបន្សល់ទុកនូវភាពសោះកក្រោះក្នុងចិត្តរបស់ខ្ញុំប៉ុន្តែខ្ញុំនៅតែតែងតែទទួលទានអាហារពេលល្ងាចជាមួយគាត់រាល់ពេលដែលខ្ញុំមកលេងប្រទេសកម្ពុជា។

# ជំពូកទី ៦

## ឆ្ពោះទៅរកការបង្កើតសាកលវិទ្យាល័យអប់រំកាយ

## ផ្នែកទី១៖ ការប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ទៅជាសាកលវិទ្យាល័យរយៈពេល៤ឆ្នាំ មានតែកម្មវិធីសិក្សាប៉ុណ្ណោះដែលនាំមុខ

ចាប់តាំងពីឆ្នាំ២០១៥នៅពេលដែលអង្គការបេះដូងមាសបានចាប់ផ្តើមគាំទ្រអប់រំកាយនៅអនុវិទ្យាល័យ និងវិទ្យាល័យ បេះដូងមាសបានចាប់ផ្តើមសហការជាមួយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដែលបណ្តុះបណ្តាលគ្រូអប់រំកាយមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ។

ក្នុងឆ្នាំ២០១៥ បុគ្គលិកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាចំនួន៦នាក់បានធ្វើការរួមគ្នាជាគណៈកម្មាធិការបង្កើតកម្មវិធីសិក្សា ក្នុងគោលបំណងបង្កើតកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិ។ ក្នុងឆ្នាំ២០១៧ មន្ត្រីចំនួន៦នាក់បានចូលរួមដូចគ្នានៅក្នុងគម្រោងផ្សព្វផ្សាយអប់រំកាយបែបថ្មីសម្រាប់មធ្យមសិក្សាបឋមភូមិ ដែលបានអនុវត្តជាផ្នែកមួយនៃកម្មវិធីភាពជាដៃគូ និងបានចងក្រងសៀវភៅគ្រូ ធ្វើសិក្ខាសាលា និងការតាមដាននៅតាមសាលារៀន។ ប៉ុន្តែខណៈពេលដែលបានចូលរួមក្នុងគម្រោងដាក់បញ្ចូលអប់រំកាយបែបថ្មីដល់សាលារៀនខ្លឹមសារនៃការបង្រៀនអប់រំកាយថ្មីមានភាពយឺតយ៉ាវក្នុងការផ្លាស់ប្តូរនៅក្នុងថ្នាក់បណ្តុះបណ្តាលគ្រូ។មន្ត្រីដែលពាក់ព័ន្ធក្នុងគម្រោងបានយល់ពីរឿងនេះ ប៉ុន្តែការផ្លាស់ប្តូរទម្លាប់គឺពិបាកណាស់។

ទាក់ទងនឹងវិស័យអប់រំទាំងមូល ក្នុងឆ្នាំ២០១៧ ក្រសួងអប់រំបានចាប់ផ្តើមអនុវត្តកំណែទម្រង់អប់រំដើម្បីផ្លាស់ប្តូរវគ្គបណ្តុះបណ្តាលគ្រូពីប្រព័ន្ធពីរឆ្នាំទៅជាប្រព័ន្ធបួនឆ្នាំ។ស្របតាមនិន្នាការនេះ វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា បានសម្រេចតែងតាំងប្រធានគណៈគ្រប់គ្រងថ្មី ចាប់ពីឆ្នាំ២០១៧ តទៅ ហើយប្រកាន់យកគំនិតផ្តួចផ្តើមធ្វើការកែទម្រង់ស្ថាប័ន។ ដំបូងបង្អស់អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យNantesនៃប្រទេសបារាំងត្រូវបានចុះហត្ថលេខា ហើយមន្ត្រីមកពីសាកលវិទ្យាល័យ Nantes បានធ្វើទស្សនកិច្ចនៅកម្ពុជាប្រហែលមួយសប្តាហ៍ និងណែនាំកម្មវិធីសិក្សាដែលបង្កើតឡើងដោយសាកលវិទ្យាល័យដល់ភាគីកម្ពុជា។ ពួកគេបាននិយាយថាប្រសិនបើកម្មវិធីសិក្សានោះត្រូវបានបញ្ចូលពួកគេនឹងអាចចាប់ផ្តើមវគ្គសិក្សាថ្នាក់បរិញ្ញាបត្ររយៈពេលបួនឆ្នាំ។អ្នកនិពន្ធបានចូលរួមក្នុងកិច្ចប្រជុំនោះដែរ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាមានបញ្ហា ដោយសារកម្មវិធីសិក្សាសាកល្បងបានបញ្ចូលខ្លឹមសារដោយផ្អែកលើការយល់ដឹងអំពីកម្មវិធីសិក្សា និងសៀវភៅគ្រូអប់រំកាយសម្រាប់បឋមសិក្សា មធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ។

វាចាំបាច់ក្នុងការបណ្តុះបណ្តាលគ្រូអប់រំកាយដែលអាចបង្រៀនខ្លឹមសារនៃអប់រំកាយបន្ទាប់ពីបានយល់ដឹងអំពីប្រភេទនៃអប់រំកាយបែបណាដែលពួកគេបង្រៀននៅសាលា។គ្រាន់តែអប់រំកាយតែមួយគឺពិបាកទៅហើយ តើអាចបង្កើតវគ្គសិក្សាដែលរួមបញ្ចូលវិទ្យាសាស្ត្រកីឡា និងការគ្រប់គ្រងកីឡាបានទេ?

ជាទូទៅ និស្សិតបញ្ចប់ការសិក្សាទាំងអស់នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ក្លាយ

គ្រូបង្រៀនអប់រំកាយ។ខណៈពេលដែលការបង្កើតកម្មវិធីសិក្សារយៈពេល៤ឆ្នាំគឺជាលទ្ធផលមួយ វាមានការព្រួយបារម្ភថាកម្មវិធីសិក្សានឹងមិនមានសុគតភាពរវាងអ្វីដែលរំពឹងទុករបស់គ្រូបង្រៀន ក្នុងវិស័យនេះ និងអ្វីដែលបានរៀននៅក្នុងវគ្គបណ្ដុះបណ្ដាលគ្រូ។ ខ្ញុំព្រួយបារម្ភថាលទ្ធផលនៃគម្រោងមុនៗនឹងលែងមានផ្លែផ្កាដូច្នេះខ្ញុំបានពិគ្រោះជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំផ្ទាល់។ ចាប់តាំងពីឆ្នាំ២០០៦អង្គការបេះដូងមាសបានបន្តបង្កើតកម្មវិធីសិក្សានិងសៀវភៅគ្រូបន្តរៀបចំសិក្ខាសាលានិងការតាមដានដើម្បីអភិវឌ្ឍការអប់រំមុខវិជ្ជាអប់រំកាយនៅកម្ពុជាហើយទីបំផុតបានផ្សព្វផ្សាយអប់រំកាយបែបថ្មីជាបណ្ដើរៗ ដែលអាចទទួលបាននូវ «ចំណេះដឹង ជំនាញ និងឥរិយាបថ» នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង។ នៅពេលខ្ញុំប្រាប់ថាប្រសិនបើយើងបញ្ចូលកម្មវិធីសិក្សាបណ្ដុះបណ្ដាលគ្រូអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិនិងទុតិយភូមិខុសគ្នាទាំងស្រុង នោះការផ្សព្វផ្សាយអប់រំកាយដែលមានស្រាប់ និងកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិនិងទុតិយភូមិនឹងលែងដំណើរការទៀតហើយ។ គាត់បានណែនាំឲ្យខ្ញុំបន្តពិភាក្សាជាមួយរដ្ឋលេខាធិការក្រសួងអប់រំ និងអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡាដែលយល់ពីលទ្ធផលនៃគម្រោងរហូតមកដល់ពេលនេះ។

## ប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាទៅជាសាកលវិទ្យាល័យក្នុងរយៈពេល៤ឆ្នាំ

ចំពោះរដ្ឋលេខាធិការក្រសួងអប់រំ និងអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា ខ្ញុំបានពន្យល់ថា ដោយសារទំនាក់ទំនងជាមួយសាកលវិទ្យាល័យ Nantes ដែលមានកិច្ចព្រមព្រៀងភាពជាដៃគូរួចហើយមិនអាចត្រូវបានបំពានបានទេ ដូចនេះខ្លឹមសារត្រូវតែផ្អែកលើកម្មវិធីសិក្សាដែលបង្កើតឡើងដោយសាកលវិទ្យាល័យ Nantes ប៉ុន្តែ ជាការចាំបាច់ក្នុងការចាត់វិធានការប្រុងការប្រុងប្រយ័ត្ននៅពេលបង្កើតកម្មវិធីសិក្សាសម្រាប់វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

រូបភាពទី ១៨៖ ដ្យាក្រាមរូបភាពនៃគម្រោង
(គម្រោងប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ទៅជាសាកលវិទ្យាល័យ អប់រំកាយ រយៈពេល៤ឆ្នាំសិក្សា)



ទន្ទឹមនឹងនេះដែរយើងបានបន្តកិច្ចពិភាក្សាជាមួយក្រសួងការបរទេសជប៉ុនហើយជាលទ្ធផលនៃកិច្ចពិភាក្សារយៈពេល២ឆ្នាំ នៅខែមករាឆ្នាំ២០១៩ វាត្រូវបានសម្រេចចាប់ផ្តើម «គម្រោងប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា(NIPES) នៃព្រះរាជាណាចក្រកម្ពុជាទៅជាសាកលវិទ្យាល័យដែលបណ្តុះបណ្តាលអប់រំកាយរយៈពេល៤ឆ្នាំសិក្សា» ដែលជាគម្រោងជំនួយឥតសំណងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។

គម្រោងនេះមានគោលបំណងចាប់ផ្តើមវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាជាសាកលវិទ្យាល័យរយៈពេល៤ឆ្នាំសិក្សាហើយបានកំណត់នូវលទ្ធផលរំពឹងទុកចំនួន៣គឺការកសាងប្រព័ន្ធការអភិវឌ្ឍធនធានមនុស្ស និងការសាងសង់អគារបរិក្ខារ។

ទាក់ទងនឹងការកសាងប្រព័ន្ធយើងបានផ្តោតលើការបង្កើតកម្មវិធីសិក្សានិងបន្តបង្កើតគោលការណ៍ចូលរៀនអំពីរបៀបជ្រើសរើសសិស្ស សៀវភៅណែនាំរដ្ឋបាលដើម្បីពន្យល់មិនត្រឹមតែថ្នាក់រៀននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការគ្រប់គ្រងស្ថាប័នគោលការណ៍វាយតម្លៃដែលកំណត់ស្តង់ដារបញ្ចប់ការសិក្សានិងគន្លងអាជីពដែលបញ្ជាក់ពីអាជីពបន្ទាប់ពីបញ្ចប់ការសិក្សា។ ទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស យើងក៏បានជំរុញការអភិវឌ្ឍគ្រូឧទ្ទេសនិងបុគ្គលិកគ្រប់គ្រងក្នុងពេលដំណាលគ្នាតាមរយៈសិក្ខាសាលានិងទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន។ ទាក់ទងនឹងការសាងសង់អគារបរិក្ខារ អាងហែលទឹកមួយត្រូវបានសាងសង់នៅឆ្នាំទី១បន្ទប់ហាត់ប្រាណត្រូវបានសាងសង់នៅឆ្នាំទី២ហើយអន្តេវាសិកដ្ឋានត្រូវបានជួសជុលនៅឆ្នាំទី៣ ។

កម្មវិធីសិក្សានេះត្រូវបានបង្កើតឡើងដើម្បីឱ្យស្របនឹងកម្មវិធីសិក្សារបស់គម្រោងវិទ្យាស្ថានគរុកោសល្យ ដែលអនុវត្តដោយ JICA ដើម្បីឲ្យស្របទៅនឹងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា ហើយត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំក្នុងខែតុលា ឆ្នាំ២០១៩។ លោកស្រី ប៊ិច គង្គា គ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា បាននិយាយថា តាមរយៈគម្រោងនេះ គាត់បានរៀនបង្កើតប្លង់មេរៀន និងប្រព័ន្ធក្រេឌីត ដោយសម្លឹងឆ្ពោះទៅរកស្តង់ដារជាមួយសាកលវិទ្យាល័យនៅបរទេស (HG, ២០២១)។

លោកស្រីគង្គាក៏បានចូលរួមក្នុងកាផ្សព្វផ្សាយអប់រំកាយតាមរយៈកម្មវិធីភាពជាដៃគូដូច្នេះលោកស្រីបានយល់ថាអប់រំកាយបែបថ្មីអាចឱ្យកុមាររៀននូវ «ចំណេះដឹង ជំនាញ និងឥរិយាបថ»។ ចំពោះថាតើយើងគួរបង្រៀនវាយ៉ាងដូចម្តេចក្នុងដំណាក់កាលបណ្តុះបណ្តាលគ្រូ ថាតើវានឹងត្រូវបង្រៀននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាដែរឬទេ វាពិបាកសម្រាប់គាត់ក្នុងការដោះស្រាយរឿងនេះតែម្នាក់ឯង ដូច្នេះគាត់សប្បាយចិត្តខ្លាំងណាស់ដែលគាត់អាចធ្វើការជាប្រព័ន្ធលើគម្រោងនេះ។

នៅពេលមួយលោកស្រីបានរៀបរាប់ប្រាប់អ្នកនិពន្ធ។«ទោះបីជាអប់រំកាយបែបថ្មីកំពុងរីករាលដាលនៅក្នុងសាលារៀនក៏ដោយក៏គ្រូបង្រៀននៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាមិនបានទទួលយកអ្វីដែលយើងបានរៀននោះទេ។ មិនថាយើងបង្កើនសំឡេងប៉ុណ្ណាក៏ដោយវិទ្យាស្ថាន

ជាតិអប់រំកាយ និងកីឡាមិនអាចផ្លាស់ប្តូរទម្លាប់បច្ចុប្បន្នបានទេ។ ទោះបីគ្រូម្នាក់និយាយឡើងក៏ដោយ វាពិបាកក្នុងការផ្លាស់ប្តូរខ្លឹមសារមេរៀនទាំងមូល»។ ខ្ញុំគិតថាវាគួរអោយសរសើរដែលគម្រោងនេះត្រូវបានចាប់ផ្តើមដើម្បីផ្លាស់ប្តូរស្ថានភាពបែបនេះ ហើយដែលវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាអាចធ្វើការកែទម្រង់ខ្លឹមសារកម្មវិធីសិក្សា រចនាសម្ព័ន្ធអគារបរិក្ខារ និងប្រព័ន្ធគ្រប់គ្រងទាំងមូល។

ដោយវិធីនេះកម្មវិធីសិក្សាត្រូវបានបង្កើតឡើងនៅក្នុងគម្រោងដែលបានចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ២០១៩ ហើយស្ថានភាព គឺពោរពេញទៅដោយការរំពឹងទុកសម្រាប់អ្វីដែលនឹងមកដល់។ ប៉ុន្តែនៅឆ្នាំ២០២០ ការរីករាលដាលនៃជំងឺកូវីដបានបញ្ឈប់ដំណើរការនៃគម្រោងកម្មវិធីរយៈពេល៤ឆ្នាំ។

## ផ្នែកទី២៖ បន្ទាប់ពីឆ្លងកាត់ការព្យាយាម ផ្តោតលើថ្នាក់អនឡាញ

ភ្លាមៗបន្ទាប់ពីកម្មវិធីសិក្សារយៈពេល៤ឆ្នាំត្រូវបានបង្កើតឡើងគម្រោងនេះត្រូវបានរងផលប៉ះពាល់ដោយការរីករាលដាលនៃជំងឺកូវីដជាសកលហើយសកម្មភាពគម្រោងបានជាប់គាំងរយៈពេលមួយឆ្នាំក្នុងឆ្នាំ២០២០។ទីក្រុងត្រូវបានបែងចែកទៅជាតំបន់ក្រហម តំបន់ទឹកក្រូច និងតំបន់លឿងដែលបែងចែកទៅតាមតំបន់ដែលមានចំនួនអ្នកឆ្លងច្រើន។ទីក្រុងទាំងមូលក៏ស្ថិតនៅក្រោមការរឹតបន្តឹងផងដែរ ដូចជាមនុស្សតែ២នាក់ក្នុង១គ្រួសារអាចចេញទៅក្រៅបាន។ ទោះជាយ៉ាងណាក៏ដោយថ្នាក់រៀននៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាក៏គ្មានជម្រើសអ្វីក្រៅពីផ្តោតលើថ្នាក់អនឡាញដែរ។

ទោះជាយ៉ាងណាក៏ដោយនេះមិនមែនមានន័យថាគ្មានអ្វីត្រូវបានធ្វើទេថ្នាក់អនាម័យតាមអនឡាញ និងថ្នាក់សង្គ្រោះបឋមត្រូវបានបង្រៀនដោយអតីតគិលានុបដ្ឋាយិកាជនជាតិអាមេរិក លោកស្រី ដត ម៉ាហ្គត ហើយថ្នាក់អនឡាញបង្រៀនអំពីកីឡាថ្មីត្រូវបានផ្តល់ឱ្យដោយប្រធានសហព័ន្ធកីឡាKorfballអន្តរជាតិព័រទុយហ្គាល់ លោក អាល់វ៉េស ចច ។ លើសពីនេះ យើងបានដាក់ពាក្យស្នើសុំគម្រោងសាងសង់ផ្លូវរត់អត្តពលកម្មសម្រាប់វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដោយប្រើជំនួយឥតសំណងមូលដ្ឋានរបស់ស្ថានទូត។

នៅពេលដែលស្ថានភាពវិបត្តិកូវីដ បានធូរស្រាល យើងអាចចាប់ផ្តើមគម្រោងឆ្នាំទី២នៅខែមីនា ឆ្នាំ២០២១ ហើយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាបានចាប់ផ្តើមថ្នាក់ធម្មតាឡើងវិញជាបណ្តើរៗ។នៅឆ្នាំ២០២២យើងបានបកប្រែសៀវភៅជាភាសាអង់គ្លេសស្តីពីវិធីសាស្ត្របង្រៀនសម្រាប់ថ្នាក់អប់រំកាយ ដែលមានឈ្មោះថា «Instructional Models for Physical Education»

ដោយបញ្ចូលបរិបទកម្ពុជា បានបង្កើតសៀវភៅសិក្សាគោលសម្រាប់ «មុខវិជ្ជាគរុកោសល្យ និងវិធីសាស្ត្របង្រៀនអប់រំកាយ»។ លេសីពនេះទៀត នៅខែតុលា ឆ្នាំ២០២២ យើងអាចចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យរដ្ឋ សេម៉ារាំង របស់ប្រទេសឥណ្ឌូណេស៊ី សាកលវិទ្យាល័យ កាសេតសាត និងសាកលវិទ្យាល័យស្រីនណាខារីនវីរ៉ូត របស់ប្រទេសថៃ។ ទោះបីជាគម្រោងនេះប្រឈមមុខនឹងការលំបាកជាច្រើនក៏ដោយ វាត្រូវបានបញ្ចប់នៅខែកុម្ភៈ ឆ្នាំ២០២៣។ ចំពោះសៀវភៅសិក្សា ទោះបីសៀវភៅសិក្សាសម្រាប់១មុខវិជ្ជាត្រូវបានបង្កើតឡើងក៏ដោយ ដើម្បីចងក្រងសៀវភៅសិក្សាសម្រាប់គ្រប់មុខវិជ្ជានៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា គ្រូបង្រៀនម្នាក់ៗត្រូវគិតពីអ្វីដែលពួកគេនឹងបង្រៀនដោយខ្លួនឯង។ ដើម្បីបញ្ចូលវាទៅក្នុងថ្នាក់រៀនរយៈពេល ១៥ សប្តាហ៍ តើគួរអភិវឌ្ឍបែបណា ហើយតើមាតិកាប្រភេទណាដែលគួរបង្រៀនជារៀងរាល់សប្តាហ៍ចាំបាច់ត្រូវស្រាវជ្រាវនិងបង្កើតសៀវភៅសិក្សាដោយខ្លួនឯង។ យើងគ្រាន់តែអាចបង្ហាញពីរបៀបទទួលបានសិទ្ធិរក្សាសិទ្ធិ និងការងារបកប្រែនៅពេលបង្កើតសៀវភៅសិក្សាសម្រាប់មុខវិជ្ជា១ប៉ុណ្ណោះ ប៉ុន្តែចាប់ពីពេលនេះតទៅ គ្រូបង្រៀនម្នាក់ៗនឹងត្រូវធ្វើការដោយឯករាជ្យដើម្បីបង្កើតសៀវភៅសិក្សាដោយខ្លួនឯង។

នៅឆ្នាំ២០២៣វិទ្យាស្ថានជាតិអប់រំកាយនិងកីឡានឹងរៀបចំសិក្ខាសាលាដើម្បីបង្កើតសៀវភៅសិក្សាដោយប្រើថវិកាផ្ទាល់ខ្លួនជាដើម ហើយអ្វីៗកំពុងដំណើរការទៅមុខបន្តិចម្តងៗ។ លោក ដៀន វិបុល ប្រធានការិយាល័យរដ្ឋបាល បានមានប្រសាសន៍ថា « បច្ចុប្បន្នវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាមានកម្មវិធីសិក្សា។ ប្លង់មេរៀនសម្រាប់បង្រៀនវាក៏មានផងដែរ។ ម៉្យាងវិញទៀត គ្រូបង្រៀនមិនអាចបង្រៀនបានទេ ដោយសារមិនមានសៀវភៅសិក្សាសម្រាប់បង្រៀនខ្លឹមសារនៃប្លង់មេរៀន ហើយគ្រូបង្រៀនដែលមិនចេះភាសាអង់គ្លេស មិនអាចចូលប្រើឯកសារជាភាសាអង់គ្លេសបានធ្វើឱ្យកាន់តែពិបាកក្នុងការបង្រៀន»។គ្រូបង្រៀនដែលបានសិក្សានៅបរទេសដូចជាវៀតណាមនិងថៃចាប់ផ្តើមត្រឡប់មកប្រទេសវិញហើយពួកគេកំពុងនាំមុខក្នុងការបកប្រែឯកសារអង់គ្លេសបន្តិចម្តងៗ។

ទោះបីជាកម្មវិធីសិក្សាបានផ្លាស់ប្តូរទៅជាប្រព័ន្ធរយៈពេល៤ឆ្នាំក៏ដោយក៏វាពិបាកក្នុងការកែលម្អគុណភាពខ្លឹមសារបង្រៀនបានភ្លាមៗដែរ។ ទីមួយគឺបញ្ហាសញ្ញាបត្រគ្រូបង្រៀន។ គ្រូបង្រៀនភាគច្រើននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា នៅតែមានក្របខណ្ឌ ខ នៅឡើយ។ ពេលគឺត្រូវការគ្រូបង្រៀនប្រភេទក្របខណ្ឌ ក ដើម្បីបង្រៀនថ្នាក់បរិញ្ញាបត្រ។ តែមិនមានសញ្ញាបត្រចាំបាច់សម្រាប់បង្រៀននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សា។ ជាងពាក់កណ្តាលនៃគ្រូបង្រៀននៅ វអកត្រូវមានបរិញ្ញាបត្រជាន់ខ្ពស់ ហើយនៅសល់ពីនោះត្រូវមានសញ្ញាបត្របរិញ្ញាបត្រយ៉ាងទាប ប៉ុន្តែវាមិនងាយស្រួលក្នុងការសម្រេចស្តង់ដារទាំងនេះទេ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ នៅឆ្នាំ២០២២ យើងបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យរដ្ឋ សេម៉ារាំង របស់ប្រទេសឥណ្ឌូណេស៊ី សាកលវិទ្យាល័យស្រីនណាខារីនវីរ៉ូត និងសាកលវិទ្យាល័យ កាសេតសាត របស់ប្រទេសថៃ និងអាច

បង្កើតទំនាក់ទំនងដែលអនុញ្ញាតឱ្យគ្រូមកពីវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាទៅសិក្សានៅបរទេស និងទទួលបានសញ្ញាបត្រអនុបណ្ឌិត។ នៅពេលអនាគត វានឹងចាំបាច់ក្នុងការប្រើប្រាស់កិច្ចព្រមព្រៀងភាពជាដៃគូនេះ ដើម្បីផ្តល់លទ្ធភាពឱ្យគ្រូបង្រៀន និងនិស្សិតនៃវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាកាន់តែច្រើនទទួលបានសញ្ញាបត្រអនុបណ្ឌិតនិងបណ្ឌិតនៅសាកលវិទ្យាល័យនៅបរទេស។ ក្រៅពីនេះ ក៏មានបញ្ហាមួយទៀតគឺការជ្រើសរើសគ្រូដែលនឹងមានសិទ្ធិទៅសិក្សានៅបរទេស និងជំនាញភាសាបរទេសរបស់ពួកគេ។ នៅប្រទេសឥណ្ឌូណេស៊ីគឺត្រូវសិក្សាភាសាអង់គ្លេស ហើយនៅប្រទេសថៃគឺត្រូវសិក្សាភាសាថៃ ប៉ុន្តែការរៀនភាសាត្រូវការរយៈពេលជាក់លាក់នៃការសិក្សា។




សៀវភៅសិក្សាគោលសម្រាប់ «មុខវិជ្ជាគរុកោសល្យ និងវិធីសាស្ត្របង្រៀនអប់រំកាយ»



កិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យរដ្ឋ សេម៉ារាំង



កិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ កាសេតសាត

លើសពីនេះយើងបានអនុវត្តការពិនិត្យតាមដាននិងជ្រោមជ្រែងដើម្បីបង្កើនគុណភាពនៃថ្នាក់រៀន។ នៅក្នុងថ្នាក់ដែលខ្ញុំបានឃើញកាលពីថ្ងៃមុន ពួកគេកំពុងបង្រៀនរាំតាមចង្វាក់ភ្លេងនៅក្នុងថ្នាក់អប់រំកាយជាមួយចង្វាក់ភ្លេង ប៉ុន្តែនិស្សិតនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាកំពុងរៀនចងចាំចលនារាំតាមចង្វាក់ភ្លេង គឺមិនមែនជាថ្នាក់រៀនដែលតម្រូវឱ្យគ្រូគិតពីរបៀបបង្រៀនរាំតាមចង្វាក់ភ្លេងបែបណាដល់សិស្សមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិនោះទេ។ សូម្បីតែនៅក្នុងថ្នាក់ «ប្រវត្តិអប់រំកាយ» ពួកគាត់មិនបានបង្រៀនពីប្រវត្តិនៃអប់រំកាយនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែជាការប្រើប្រាស់ ICT នៅក្នុងថ្នាក់អប់រំកាយ។ តាមរបៀបនេះ វាមិនមានភាពស៊ីសង្វាក់គ្នានៅក្នុងមុខវិជ្ជានីមួយៗ ប្លង់មេរៀន និងខ្លឹមសារមេរៀននៅក្នុងកម្មវិធីសិក្សានោះទេ ហើយចាំបាច់ត្រូវត្រួតពិនិត្យ និងតាមដាន៣មុខគឺឈ្មោះមុខវិជ្ជា ខ្លឹមសារនៃប្លង់មេរៀន និងមេរៀន។

ខណៈពេលដែលកម្មវិធីរយៈពេល៤ឆ្នាំត្រូវបានដាក់ឱ្យដំណើរការដើម្បីទទួលស្គាល់ថាជាគ្រឹះស្ថានឧត្តមសិក្សា ទាមទារឱ្យមានអនុក្រឹត្យចេញដោយនាយករដ្ឋមន្ត្រី។ បន្ទាប់ពីទទួលបានអនុក្រឹត្យនេះនឹងឆ្លងកាត់ការពិនិត្យដោយស្ថាប័នបញ្ជាក់ការអប់រំកម្រិតឧត្តមសិក្សាហើយយើងក៏ត្រូវបន្តរៀបចំឯកសារជាដើមសម្រាប់ការពិនិត្យនេះផងដែរ។

## គម្រោងគាំទ្រដោយប្រើ ICT

ខណៈពេលដែលបញ្ហាជាច្រើននៅតែមាននៅឡើយ នៅខែមីនាឆ្នាំ២០២៣គម្រោងជំនួយឥតសំណងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន « គម្រោងគាំទ្រវិទ្យាស្ថានគរុកោសល្យអប់រំកាយរយៈពេល៤ឆ្នាំប្រកបដោយគុណភាពខ្ពស់តាមរយៈ ICT ក្នុងព្រះរាជាណាចក្រកម្ពុជា» ត្រូវបានចាប់ផ្តើម។

អ្នកគ្រប់គ្រងគម្រោង លោក តេហ្សិកា កូជី បានបង្កើតក្របខណ្ឌនៃគម្រោងនេះដោយប្រើប្រាស់ ICT ដើម្បីអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។ ដើម្បីឱ្យវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាក្លាយជាគ្រឹះស្ថានឧត្តមសិក្សាដែលជាសាកលវិទ្យាល័យដែលបណ្តុះបណ្តាលរយៈពេល៤ឆ្នាំនៅកម្ពុជា ជាផ្លូវការនោះ ត្រូវតែបំពេញតាមស្តង់ដារដែលមានចែងក្នុង « ស្តង់ដារជាតិសម្រាប់ការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សា» ដែលបង្កើតឡើងដោយក្រសួងអប់រំ ហើយយើងត្រូវកែលម្អចំណុចទាំងនេះ។ទោះបីជាកុំព្យូទ័រត្រូវបានទិញក្នុងដំណាក់កាលទី១នៃគម្រោងក៏ដោយ យើងមានការព្រួយបារម្ភថាវាមិនត្រូវបានប្រើប្រាស់នៅក្នុងវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា ដូច្នេះយើងចាប់ផ្តើមស្រាវជ្រាវអំពីស្ថានភាពនៃ ICT នៅកម្ពុជា។ រដ្ឋាភិបាលកម្ពុជាមានគោលបំណងចង់ក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមនិងខ្ពស់ហើយគោលនយោបាយរបស់ខ្លួនរួមមានការលើកកម្ពស់ ICT នៅទូទាំងប្រទេស។ នៅក្នុងវិស័យអប់រំ គោលដៅជាលេខជាក់លាក់ត្រូវបានកំណត់សម្រាប់អនុវិទ្យាល័យ និងវិទ្យាល័យជាពិសេស ហើយការបញ្ចូល ICT ត្រូវបានណែនាំយ៉ាងខ្លាំង។ ដូចនេះ ជាពិសេស ការលើកកម្ពស់ ICT មានអាទិភាពខ្ពស់ទាក់ទង

នឹងគោលនយោបាយអប់រំ ដូច្នេះហើយ គម្រោងនេះមានគោលបំណងដើម្បីពង្រឹងសមត្ថភាពរបស់គ្រូបង្រៀន និងបុគ្គលិកនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាឱ្យប្រើប្រាស់ ICT ឱ្យបានពេញលេញ។ ដោយផ្អែកលើក្របខណ្ឌនេះ យើងនឹងពិចារណាថាតើសកម្មភាពប្រភេទណាខ្លះដែលអាចធ្វើទៅបានដើម្បីសម្រេចបាននូវស្តង់ដារចំនួន៩ និងសូចនាករចំនួន៧៣ ដែលកំណត់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សា។រូបភាពទី១៩បង្ហាញពីការអភិវឌ្ឍនៃវិស័យចំនួន៧៖ បណ្ណាល័យ មជ្ឈមណ្ឌលអន្តរជាតិ ការវាយតម្លៃផ្ទៃក្នុង ការបណ្តុះបណ្តាលគ្រូ ការគ្រប់គ្រងនិស្សិត ការគាំទ្រអតីតនិស្សិត និងការគ្រប់គ្រងសុវត្ថិភាព។

អគារថ្មីកម្ពស់៣ជាន់នឹងត្រូវសាងសង់ ដែលមានបណ្ណាល័យ បន្ទប់គ្រូបង្រៀននិងបុគ្គលិក បន្ទប់ពិសោធន៍ បន្ទប់សិក្ខាសាលា ថ្នាក់រៀន សាលតូច បន្ទប់ប្រឹក្សាជាដើម។ យើងមានគោលបំណងលើកកម្ពស់គុណភាពអប់រំបន្ថែមទៀតនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាតាមរយៈការគ្រប់គ្រងសិស្ស គ្រប់គ្រងពិន្ទុ ចែករំលែកឯកសារមេរៀនជាដើម តាមរយៈ ICT។

ចំពោះការបណ្តុះបណ្តាលគ្រូ «ការវាយតម្លៃ» គឺសំខាន់។ ដើម្បីធ្វើការវាយតម្លៃចាំបាច់ត្រូវកំណត់គោលដៅ និងផែនការ។ ដោយបន្តវដ្ត PDCA (Plan, Do, Check, Action) រៀងរាល់ឆមាសនិងឆ្នាំយោងទៅតាមគោលដៅនិងផែនការយើងនឹងអាចរកឃើញអ្វីដែលសម្រេចបានធៀបនឹងគោលដៅ និងបញ្ហាដែលកើតឡើងនៅពេលដែលមិនអាចសម្រេចបាន។

នៅក្នុងគម្រោងនេះយើងកំពុងពិចារណាលើការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យដែលប្រើប្រាស់ ICT ដែលមានលក្ខណៈស្រដៀងនឹងសាកលវិទ្យាល័យនៅប្រទេសជប៉ុន។ តាមរយៈការគ្រប់គ្រងកណ្តាលនៃព័ត៌មានទាំងអស់នៅក្នុងប្រព័ន្ធទិន្នន័យ យើងនឹងអាចចែករំលែកព័ត៌មានដោយអនុញ្ញាតឱ្យគ្រូផ្តល់ឯកសារមេរៀនសិស្សមានការពិភាក្សានៅក្នុងវិបផតថល និងមើលពិន្ទុរបស់ពួកគេជាដើម។

រូបភាពទី ១៩៖ ដ្យាក្រាមរូបភាពនៃគម្រោង
(គម្រោងគាំទ្រវិទ្យាស្ថានគរុកោសល្យអប់រំកាយរយៈពេល៤ឆ្នាំប្រកបដោយគុណភាពខ្ពស់តាមរយៈICTក្នុងព្រះរាជាណាចក្រកម្ពុជា)




ប្រភព៖ ដកស្រង់ចេញពីពាក្យស្នើសុំគម្រោង
«គម្រោងគាំទ្រវិទ្យាស្ថានគរុកោសល្យអប់រំកាយរយៈពេល៤ឆ្នាំប្រកបដោយគុណភាពខ្ពស់តាមរយៈ ICT ក្នុងព្រះរាជាណាចក្រកម្ពុជា»

## គ្រូបង្រៀន «អប់រំកាយ» មិនមែនគ្រូបង្រៀនកីឡាទេ

លោកស្រី ហ៊ូ សិទ្ធិសោភាល័យ អតីតនាយិកា នៃវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា បានមានប្រសាសន៍ថា«ខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការរបស់អង្គការបេះដូងមាសដែលអាចឱ្យយើងចាប់ផ្តើមកម្មវិធីបរិញ្ញាប័ត្ររយៈពេល៤ឆ្នាំនៅក្នុងការគាំទ្រផ្នែកហិរញ្ញវត្ថុក៏ដូចជាការគាំទ្រផ្នែកបច្ចេកទេស និងការខិតខំប្រឹងប្រែងព្យាយាមស្វែងយល់យ៉ាងច្បាស់ពីស្ថានភាពនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា»។

លោកស្រីបានមានប្រសាសន៍ថាខ្លួនលោកស្រីផ្ទាល់បានយល់ដឹងកាន់តែច្បាស់ពីភាពខុសគ្នារវាងការបង្រៀនអប់រំកាយ និងការបង្រៀនកីឡា ហើយបាននិងកំពុងគិតពីរបៀបកែលម្អប្រព័ន្ធបណ្តុះបណ្តាលគ្រូអប់រំកាយហើយលោកស្រីអាចយល់កាន់តែច្បាស់តាមរយៈការចូលរួមសិក្ខាសាលា និងមានឱកាសពិភាក្សាជាមួយសាស្ត្រាចារ្យមកពីប្រទេសជប៉ុន។

ជាមួយគ្នានេះលោកស្រីបានយល់ដឹងថាតើថ្នាក់អប់រំកាយមានសារៈសំខាន់យ៉ាងណាចំពោះកុមារកម្ពុជា។ កាលគាត់នៅជាសិស្ស គាត់មិនបានដឹងពីសារៈសំខាន់នៃការអប់រំកាយសម្រាប់កុមារកម្ពុជាទេ។ ទោះបីជាគាត់ជឿថាមុខវិជ្ជាដែលទាក់ទងនឹងការប្រឡងដូចជាគណិតវិទ្យាឬវិទ្យាសាស្ត្រ និងភាសាអង់គ្លេសដែលទាក់ទងនឹងអាជីពមានសារៈសំខាន់ក៏ដោយគាត់ស្ទើរតែមិនបានគិតអំពីសារៈសំខាន់និងតួនាទីនៃអប់រំកាយសម្រាប់ការលូតលាស់ផ្លូវចិត្តនិងរាងកាយរបស់កុមារឱ្យមានសុខភាពល្អនោះទេ។

ឥឡូវនេះលោកស្រីចង់ស្វែងយល់បន្ថែមអំពីអប់រំកាយ និងកំពុងពិចារណាបន្តការស្រាវជ្រាវ។ការលើកកម្ពស់ការស្រាវជ្រាវអប់រំកាយនៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាមិនត្រឹមតែជាការលើកកម្ពស់គុណភាពនៃថ្នាក់អប់រំកាយប៉ុណ្ណោះទេ ថែមទាំងស្រាវជ្រាវលើវគ្គបណ្តុះបណ្តាលគ្រូ ការស្រាវជ្រាវកម្មវិធីសិក្សានិងស្រាវជ្រាវអំពីអត្រាវីកវាលដាលនៃអប់រំកាយនៅកម្ពុជា ដែលមានសក្តានុពលក្នុងការអភិវឌ្ឍវិស័យជាច្រើន។

វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា បច្ចុប្បន្នមានវគ្គបណ្តុះបណ្តាលគ្រូអប់រំកាយរយៈពេល៤ឆ្នាំ ដែលស្របតាមកម្មវិធីសិក្សារបស់អនុវិទ្យាល័យ និងវិទ្យាល័យ។ ជាលទ្ធផលគ្រូដែលចំណុះវិទ្យាស្ថានអាចយល់ពីអ្វីដែលពួកគេត្រូវបង្រៀនសិស្ស និងអ្វីដែលពួកគេត្រូវការដើម្បីក្លាយជាគ្រូបង្រៀនផ្នែកអប់រំកាយ មិនមែនជាគ្រូកីឡា។ ខ្ញុំមានអារម្មណ៍ថាពួកគេយល់កាន់តែស៊ីជម្រៅ ហើយបានចាប់ផ្តើមច្នៃវិធីសាស្ត្រ និងខ្លឹមសារបង្រៀន។ ពីមុនពួកគេបង្រៀននូវជំនាញដើម្បីឈ្នះការប្រកួត ដូចជាបាល់ទាត់ និងបាល់បោះ ប៉ុន្តែតាមរយៈសិក្ខាសាលា និងការប្រជុំម្តងហើយម្តងទៀត ពួកគេបានចាប់ផ្តើមគិតអំពីការបង្រៀនដើម្បីក្លាយជាគ្រូអប់រំកាយមិនមែនគ្រូកីឡាទេ។

ដំបូងឡើយ ហាក់ដូចជាមានការភាន់ច្រឡំ ប៉ុន្តែគ្រូបង្រៀនមួយចំនួនក៏បានធ្វើការជាមួយបេះដូងមាស លើគម្រោង «អប់រំកាយ សម្រាប់ទាំងអស់គ្នា» ដែលជាគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសមូលដ្ឋាន ហើយគ្រូបង្រៀនផ្សេងទៀត ចាប់ពីឆ្នាំ២០១៩មកដល់សព្វថ្ងៃក៏បានចូលរួមសិក្ខាសាលា និងទទួលបានការបង្រៀនពីអ្នកជំនាញ ពួកគេចាប់ផ្ដើមគិតថាការបង្រៀនមុនរបស់ពួកគេមិនល្អបំផុតទេ។ ពួកគេចាប់ផ្ដើមយល់ពីសារៈសំខាន់នៃការប្រើប្រាស់ទ្រឹស្តីកីឡាផ្សេងៗដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការបង្រៀនអប់រំកាយដល់កុមារ។ ក្នុងរយៈពេល៤ឆ្នាំ ចាប់ពីឆ្នាំ២០១៩ ដល់ ឆ្នាំ២០២៣ ការផ្លាស់ប្តូរបែបនេះ ត្រូវបានគេមើលឃើញ។

## អត្ថបទទី៧៖ អ្នកដឹកនាំគឺជាអ្នកដែលចង់រៀនបំផុត

ខ្ញុំបានធ្វើការជាមួយលោកស្រី ហ៊ូ សិទ្ធិសោភាល័យ នាយិកានៃវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាក្នុងគម្រោងតាំងពីឆ្នាំ២០១៩។ បើខ្ញុំពណ៌នាគាត់ក្នុងពាក្យមួយម៉ាត់ ខ្ញុំនឹងប្រើពាក្យថា«ស្មោះត្រង់»។លោកស្រីមានការព្រួយបារម្ភអំពីការបម្រើការជានាយិកានៃវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដោយសារលោកស្រីមិនមានសាវតារផ្នែកអប់រំកាយ ឬកីឡានោះទេ។ ទោះជាយ៉ាងណាក៏ដោយ បំណងប្រាថ្នារបស់លោកស្រីក្នុងការធ្វើឱ្យវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ក្លាយជាសាកលវិទ្យាល័យដ៏ល្អប្រសើរមួយ ។ ខណៈដែលប្រទេសកម្ពុជានៅតែមានបញ្ហាដូចជាអំពើពុករលួយនិងស៊ីសំណូកជាដើម លោកស្រីមានបំណងប្រាថ្នាក្នុងការចង់លុបបំបាត់បញ្ហាទាំងនេះនិងបង្កើតសាកលវិទ្យាល័យស្អាតស្អំជាខ្លាំង។នៅក្នុងគម្រោងនេះគាត់តែងតែជឿជាក់លើពួកយើង។

អ្វីដែល «ខ្លួនមិនដឹងអ្វីទាល់តែសោះ» វានឹងជួយជម្រុញលើកទឹកចិត្តអ្នកនោះក្នុងការសម្រេចបំណងអ្វីមួយជាក់ជាមិនខាន។ ដោយសារតែអ្វីដែលអ្នកមិនចេះ មិនដឹងនោះហើយ វាជាកត្តាជម្រុញអ្នកត្រូវតែព្យាយាមរុករកស្វែងយល់បន្ថែមដើម្បីយល់ដឹងពីរបស់នោះ។ថ្វីត្បិតតែលោកស្រីបានបញ្ចប់ថ្នាក់អនុបណ្ឌិតភាសាអង់គ្លេសក៏ដោយ ក៏គាត់នៅតែមានឆន្ទៈចង់រៀនផ្នែកអប់រំកាយ ហើយតែងតែនិយាយថាគាត់ចង់ធ្វើការស្រាវជ្រាវ។ ខ្ញុំបានរៀនពីលោកស្រីថា ធ្វើជាអ្នកដឹកនាំ បើអ្នកចង់រៀនបន្ថែមដោយសារតែមិនចេះ គឺប្រសើរជាងចេះតែធ្វើខ្លួនក្រអឺតក្រទម។

នៅពេលទៅប្រទេសឥណ្ឌូណេស៊ីដើម្បីចូលរួមក្នុងសន្និសីទអប់រំកាយ និងកីឡាអាស៊ាន គាត់តែងតែសួរសំណួរមកខ្ញុំ។ គាត់មានសំណួរជាប់រហូតដូចជា តើយើងអាចក្លាយជាសមាជិកនៃសមាគមអប់រំកាយ និងកីឡាអាស៊ានដោយរបៀបណា តើវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាអាចចាប់ផ្តើមការស្រាវជ្រាវបានដោយរបៀបណា តើវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាអាចសម្រេចបានអ្វីខ្លះតាមរយៈការបន្តសកម្មភាពរបស់ខ្លួនក្នុងគម្រោង ហើយតើអ្នកណាខ្លះគួរទៅទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន។ ពេលខ្ញុំត្រូវបានលោកស្រីសួរសំណួរ ខួរក្បាលរបស់ខ្ញុំផ្ទាល់ក៏សកម្មដែរ ព្រោះខ្ញុំត្រូវឆ្លើយតប។ លើសពីនេះ លោកស្រីបានទទួលយកព័ត៌មានជាច្រើន ដូច្នេះខ្ញុំមានអារម្មណ៍ថាខ្ញុំត្រូវបានគាត់ជឿទុកចិត្ត។ យើងបានសន្ទនាគ្នានៅក្នុងតេឡេក្រាមជារៀងរាល់ថ្ងៃ ហើយអាចបញ្ជាក់ពីបញ្ហានីមួយៗជាមួយគ្នា។

នៅពេលអនាគត ទោះបីជាមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយក៏ដោយ ដូចជាការអភិវឌ្ឍប្រព័ន្ធក្រេឌីតសម្រាប់កម្មវិធីបណ្តុះបណ្តាលរយៈពេល២ឆ្នាំដែលបច្ចុប្បន្នកំពុងដំណើរការស្របគ្នាជាមួយនឹងកម្មវិធីបណ្តុះបណ្តាលរយៈពេល ៤ឆ្នាំ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យក្នុងប្រទេសជប៉ុននិងបណ្តាប្រទេសអាស៊ានព្រមទាំងលើកទឹកចិត្តដល់គ្រូបង្រៀននិងនិស្សិតឱ្យទៅសិក្សានៅបរទេសនៅសាកលវិទ្យាល័យដែលទាក់ទងនឹងអប់រំកាយ

ក្នុងបណ្ដាប្រទេសអាស៊ាន ប៉ុន្តែវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា បានចាប់ផ្ដើមអភិវឌ្ឍជាលំដាប់ឆ្ពោះទៅរកការក្លាយជាសាកលវិទ្យាល័យអប់រំកាយជាសកលដែលបើកចំហសម្រាប់ពិភពលោក។

លទ្ធផលនៃការផ្សព្វផ្សាយអប់រំកាយហាក់មានឥទ្ធិពលយ៉ាងទូលំទូលាយដល់អ្នកពាក់ព័ន្ធវិស័យអប់រំនៅកម្ពុជា។ លោកបណ្ឌិត សំ ចាន់ភីរុណ នាយករងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានមានប្រសាសន៍ថា កាលលោកនៅក្មេង លោកមិនបានយល់ថា អ្វីទៅជាអប់រំកាយទេ។ កាលខ្ញុំរៀននៅសាលាបឋមសិក្សា ស្ទើរតែគ្មានថ្នាក់អប់រំកាយ ហើយពេលចូលរៀនអនុវិទ្យាល័យ ថ្នាក់អប់រំកាយក៏ចាប់ផ្ដើម ប៉ុន្តែភាគច្រើនខ្ញុំគ្រាន់តែធ្វើចលនាកាយតាមគ្រូ។ បច្ចុប្បន្ននេះ មនុស្សកាន់តែច្រើនកំពុងយល់ពីសារៈសំខាន់នៃអប់រំកាយ ហើយកុមារក៏កំពុងរីករាយនឹងថ្នាក់អប់រំកាយផងដែរ។

នៅវិទ្យាស្ថានគរុកោសល្យដែលបណ្ដុះបណ្ដាលគ្រូបឋមសិក្សា សិស្សមិនទាន់ដឹងច្បាស់អំពីថ្នាក់អប់រំកាយទេ។ ទោះយ៉ាងណាក៏ដោយ ថ្នាក់អប់រំកាយត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាបឋមសិក្សា។ សម្រាប់សិស្សដែលនឹងទទួលបានសញ្ញាបត្របរិញ្ញាបត្រក្នុងកម្មវិធីបណ្ដុះបណ្ដាលគ្រូរយៈពេល៤ឆ្នាំ យើងត្រូវធ្វើឱ្យប្រាកដថាពួកគាត់អាចរៀនបានពេញលេញនូវថ្នាក់អប់រំកាយ។

ម្យ៉ាងវិញទៀតលោកស្រីក៏ប្រឈមនឹងការលំបាកផងដែរដោយសារតែគាត់មិនមានសាវតារក្នុងផ្នែកអប់រំកាយ និងកីឡា។ ដោយសារបុគ្គលិកភាគច្រើនមកពីវិស័យអប់រំកាយ និងកីឡា បុគ្គលិកខ្លះមិនអាចទទួលយកយោបល់ និងគំនិតរបស់លោកស្រីបានទេ។ ថ្វីត្បិតតែជានាយិកាវិទ្យាស្ថានក៏ដោយ ការមិនទុកចិត្តពីបុគ្គលិក ធ្វើឱ្យលោកស្រីបាត់បង់ទំនុកចិត្ត ប៉ុន្តែគាត់មានជំនឿយ៉ាងមុតមាំថា គាត់នឹងមិនបោះបង់ឡើយ។ លោកស្រីផ្ទាល់ត្រូវបានលោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំណែនាំពេលលោកស្រីឡើងជានាយិកា។ លោកជំទាវ គឹម សេដ្ឋានី ក៏ជាស្ត្រីដូចគ្នាម្នាក់ដែលបានលើកកម្ពស់ឋានៈស្ត្រីនៅកម្ពុជា។ ការមានមនុស្សបែបនេះជាគោលដៅរបស់គាត់ គឺជាការគាំទ្រដ៏ អស្ចារ្យសម្រាប់លោកស្រី។

ទោះបីជាគាត់បានបញ្ចប់ពីតំណែងជានាយិកាវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាក្នុងខែសីហា ឆ្នាំ២០២៣ក៏ដោយ ប៉ុន្តែគាត់នៅតែបន្តគាំទ្រគម្រោងនេះក្នុងនាមជាអគ្គនាយករងនៃអគ្គនាយកដ្ឋានកីឡា។ ម៉្យាងទៀត ចាប់ពីពេលនេះតទៅ គាត់ក៏គិតចង់ធ្វើការស្រាវជ្រាវលើផ្នែកអប់រំកាយទៀតដែរ។

## អត្ថបទទី៩៖ សហការជាមួយសាកលវិទ្យាល័យនៃបណ្ដាប្រទេសអាស៊ាន

ចាប់តាំងពីឆ្នាំ២០១៧ អ្នកនិពន្ធបានចូលរួមជាទៀងទាត់នៅក្នុង «ក្រុមប្រឹក្សាអប់រំកាយ និងកីឡាអាស៊ាន (ACPES)» ដែលប្រារព្ធឡើងជារៀងរាល់ឆ្នាំ។ ខ្ញុំជឿជាក់ថាសន្និសីទនេះនឹងជះឥទ្ធិពលយ៉ាងធំធេងដល់ការអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំកាយ និងកីឡានាពេលអនាគត។

នៅឆ្នាំ២០១៥ ខ្ញុំបានទៅទស្សនកិច្ចការបណ្ដុះបណ្ដាលអប់រំកាយនៅប្រទេសថៃ និងសិង្ហបុរី ដែលជាផ្នែកមួយនៃគម្រោងកីឡាសម្រាប់ថ្ងៃស្អែក។ នៅពេលនោះ សាស្ត្រាចារ្យ អូកាដិ យ៉ូស៊ីណូរិ បានណែនាំខ្ញុំទៅកាន់សាស្ត្រាចារ្យរង ស៊ុបប្រានី ខ្វាន់ប៊ុណចាន់ នៃសាកលវិទ្យាល័យស្រ៊ីនណាខារីនវីរ៉ូត ក្នុងប្រទេសថៃ ដែលនាំឱ្យខ្ញុំចូលរួមក្នុងសន្និសីទនេះចាប់ពីពេលនោះមក។ នៅពេលនោះ សាស្ត្រាចារ្យរង ស៊ុបប្រានី កំពុងបម្រើការជាប្រធាន ACPES ហើយត្រូវបានលើកទឹកចិត្តឱ្យចូលរួមជាមួយACPES។សាស្ត្រាចារ្យមកពីសាកលវិទ្យាល័យនានាក្នុងប្រទេសជាណឺម៉ាកនិងរដ្ឋអូហៃអូក្នុងសហរដ្ឋអាមេរិកត្រូវបានអញ្ជើញធ្វើជាវាគ្មិនដោយផ្ដល់ឱកាសក្នុងការកសាងទំនាក់ទំនងផ្សេងៗ។

ដោយសារវាជាសន្និសីទសិក្សាសម្រាប់អប់រំកាយ និងកីឡា វាជាកន្លែងដែលការស្រាវជ្រាវអំពីអប់រំកាយ និងកីឡាមកពីប្រទេសអាស៊ាននីមួយៗត្រូវបានបង្ហាញ ដើម្បីឱ្យវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា រីកចម្រើនជាស្ថាប័នស្រាវជ្រាវទៅថ្ងៃអនាគត ខ្ញុំចង់ឱ្យបុគ្គលិក និងនិស្សិតនៃវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ធ្វើការស្រាវជ្រាវ និងធ្វើបទបង្ហាញនៅកន្លែងបែបនេះ ហើយខ្ញុំគិតថាវាចាំបាច់សម្រាប់ពួកគេដើម្បីអាចទទួលបានសញ្ញាបត្រអនុបណ្ឌិត ឬបណ្ឌិត។

ACPES មានប្រព័ន្ធសមាជិកភាព ហើយសមាជិកពេញលេញទទួលបានអត្ថប្រយោជន៍ដូចជាតម្លៃចុះឈ្មោះចូលរួមសមាគមទាប។ដើម្បីក្លាយជាសមាជិក ត្រូវតែមានអ្នកចូលរួមចាប់ពី៥នាក់ឡើងទៅឱ្យចូលរួមសន្និសីទក្នុងរយៈពេល២ ឆ្នាំ ហើយបន្ទាប់ពីការចូលរួម បន្ថែមពីលើការអាចបញ្ជូនសិស្សទៅធ្វើបទបង្ហាញជារៀងរាល់ឆ្នាំ ក៏នឹងត្រូវទទួលបន្ទុករៀបចំសន្និសីទដោយខ្លួនឯងតាមវេន។ការធានានូវទីកន្លែងបែបនេះនឹងក្លាយជាឱកាសមួយដើម្បីប្រមូលផ្ដុំអ្នកចូលរួមក្នុងផ្នែកអប់រំកាយ និងកីឡានៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំគិតថាការភ្ជាប់បណ្ដាញនៅក្នុងសន្និសីទនេះក៏នឹងបង្កើតនូវលទ្ធភាពនៃគម្រោងស្រាវជ្រាវរួមគ្នាជាដើមផងដែរ។

នៅខែតុលា ឆ្នាំ២០២៣ សន្និសីទសិក្សាលើកទី៩ ត្រូវបានប្រារព្ធឡើងនៅសាកលវិទ្យាល័យម៉ាហា សារ៉ាខាម ក្នុងប្រទេសថៃ ហើយគ្រូបង្រៀនចំនួន៥នាក់មកពីវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាត្រូវបានអញ្ជើញទៅចូលរួម។ ខ្ញុំសង្ឃឹមថាមិនយូរប៉ុន្មាននៅថ្ងៃខាងមុខ វិទ្យាស្ថានជាតិអប់រំកាយនិងកីឡានឹងបង្កើតមជ្ឈមណ្ឌលអន្តរជាតិដោយពួកគេដើរតួនាទីកណ្ដាលចូលរួមជាសមាជិក ACPES និងសហការជាមួយសាកលវិទ្យាល័យអាស៊ានផ្សេងៗ។

# អវសានកថា

## ខ្ញុំគិតថា «ការបន្ត» ក៏ជាទម្រង់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ

លោកស្រី អារីម៉ូរី យូកុ នាយិកាតំណាងអង្គការបេះដូងមាស ក្រុមទ្បេក មើលទៅ២០ឆ្នាំមុននៅក្នុង «ការអប់រំមុខវិជ្ជាអប់រំកាយនៅកម្ពុជាបានចាប់ផ្តើម» (រោងពុម្ព Fukuro)ហើយនិយាយថា«រាល់ពេលដែលយើងប្រឈមមុខនឹងបញ្ហាខ្ញុំគិតថាការពិភាក្សាឱ្យបានហ្មត់ចត់ ផ្តល់តម្លៃទំនាក់ទំនង និងការបន្តដោយមិនបោះបង់ បានផ្លាស់ប្តូរមនុស្ស និងផ្លាស់ប្តូរខ្លួនឯងផងដែរ» (HG, ២០២១។ ការដែលបេះដូងមាស និងក្រសួងអប់រំអាចចាប់ផ្តើមអប់រំកាយនៅកម្ពុជាចាប់ពីថ្នាក់បឋមសិក្សា ហើយអភិវឌ្ឍរហូតដល់មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិនិងរហូតដល់សាកលវិទ្យាល័យអប់រំកាយកត្តាសំខាន់នោះគឺដោយសារតែការប្រាស្រ័យទាក់ទងគ្នាបានល្អជាមួយអ្នកនៅក្រសួងអប់រំ និងការបន្តអភិវឌ្ឍគម្រោង។

បុគ្គលិកបេះដូងមាស រួមទាំងអ្នកនិពន្ធផង បើទោះជាផ្លូវឆ្ពោះទៅរកការផ្សព្វផ្សាយអប់រំកាយថ្មីនៅឆ្ងាយគ្មានទីបញ្ចប់ក៏យើងមិនបានចុះចាញ់ ហើយបំពេញតួនាទីរបស់យើងអស់ពីសមត្ថភាព និង បានកសាងទំនាក់ទំនងជាមួយក្រសួងអប់រំមន្ទីរការិយាល័យអប់រំរាជធានី/ ខេត្ត / ស្រុក ព្រមទាំងគណៈគ្រប់គ្រងសាលានិងលោកគ្រូអ្នកគ្រូ ហើយបានដើរដោយរៀនសូត្រជាមួយគ្នា។ ជាការពិតណាស់ គោលដៅគឺមិនមែនពេលនេះទេ ប៉ុន្តែនៅមានផ្លូវវែងឆ្ងាយទៀត ដើម្បីឱ្យអប់រំកាយបែបថ្មីមានភាពរីករាលដាលដោយឯករាជ្យ និងនិរន្តភាព ហើយយើងចង់បន្តសហការគ្នាជាមួយក្រសួងអប់រំដោយធ្វើការជាក្រុមដើម្បីផ្សព្វផ្សាយអប់រំកាយដែលមានលក្ខណៈដើមរបស់កម្ពុជា និងសមស្របសម្រាប់កម្ពុជា។

ម៉្យាងទៀត លោកស្រី អារីម៉ូរី ក៏តែងនិយាយដែរថា គោលដៅដែលយើងគួរតែមានគឺគោលដៅដើម្បីឱ្យប្រជាជនកម្ពុជាមានឯករាជ្យភាពទោះបីគ្មានបេះដូងមាសក៏ដោយ។វាជារឿងសំខាន់ដែលការអប់រំមុខវិជ្ជាអប់រំកាយនៅកម្ពុជាបន្តអភិវឌ្ឍហើយកុមារកម្ពុជាបន្តរីករាយនិងបន្តខិតខំរៀនសូត្រនូវ «ចំណេះដឹង ជំនាញ ឥរិយាបថ (និងសហការ)» នៅក្នុងការអប់រំមុខវិជ្ជាអប់រំកាយ។ខ្ញុំសង្ឃឹមថាអប់រំកាយបែបនេះនឹងរីករាលដាលទូទាំងប្រទេសកម្ពុជាដោយប្រជាជនកម្ពុជា។

នៅពេលគម្រោងនេះបានចាប់ផ្តើមនៅឆ្នាំ២០០៦ « ការអប់រំមុខវិជ្ជាអប់រំកាយ» សម្រាប់ប្រទេសកម្ពុជារួមមានលំហាត់ប្រាណបែបខ្មែរជាចម្បង ព្រមទាំងមានការលេងបាល់ទាត់ និងបាល់ទះ។ ក្នុងរយៈពេល១៨ឆ្នាំកន្លងមកនេះ និយមន័យនៃមុខវិជ្ជាសម្រាប់សិក្សា «ចំណេះដឹង ជំនាញ ឥរិយាបថ (និងសហការ)» បានចាក់ឫសនៅទូទាំងប្រទេសកម្ពុជា តាមរយៈភាពសមស្របនៃរាងកាយ អត្តពលកម្ម កាយសម្ព័ន្ធ អប់រំកាយជាមួយចង្វាក់ភ្លេង កីឡាប្រពៃណី/កីឡាអន្តរជាតិ ហែលទឹក និងល្បែងបាល់ និងបានរីកចម្រើនជាលំដាប់។

អ្នកនិពន្ធបានចំណាយពេល២ឆ្នាំនៅប្រទេសប៉ារ៉ាហ្គាយក្នុងនាមជាអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស ហើយបន្ទាប់មកទទួលបានបទពិសោធន៍ការងារនៅលេខាធិការដ្ឋានអ្នកស្ម័គ្រចិត្ត

នៃកិច្ចសហប្រតិបត្តិការក្រៅប្រទេស ហ្គូបល ផ្លាហ្សា ជាដើម ហើយនៅឆ្នាំ២០១២បានផ្លាស់ទៅតួនាទីបច្ចុប្បន្នរបស់ខ្ញុំនៅអង្គការបេះដូងមាសនិងបានអភិវឌ្ឍគម្រោងនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលប្រហែល១២ឆ្នាំ។ ខ្ញុំតែងតែប្រឈមមុខនឹងសំណួរថាតើ « កិច្ចសហប្រតិបត្តិការអន្តរជាតិ» មានន័យយ៉ាងណា។

ដូចដែលបានរៀបរាប់ខាងលើ ខ្ញុំមានអារម្មណ៍ថា វាជាគោលការណ៍មួយសម្រាប់ប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីឱ្យមានភាពឯករាជ្យ។ ម្យ៉ាងវិញទៀត អង្គការបេះដូងមាសក៏មានបុគ្គលិកជាជនជាតិខ្មែរផងដែរហើយសម្រាប់ពួកគេការបន្តគម្រោងក្នុងប្រទេសកម្ពុជាមានន័យថាការរួមចំណែកដល់ប្រទេសខ្លួនឯង។ចំណែកបុគ្គលិកជនជាតិជប៉ុនដែលបានបញ្ជូនមក ក៏ហាក់ដូចជាមានភាពសប្បាយរីករាយជាខ្លាំងដែលបានធ្វើការជាមួយសមភាគីកម្ពុជា និងអ្នកទទួលផល ប៉ុន្តែនៅពេលដែលគម្រោងនេះបានបញ្ចប់ ហើយពួកគេបានចាប់ផ្តើមធ្វើការលើគម្រោងផ្សេងទៀត យើងនឹងមានឱកាសតិចជាងមុនក្នុងការធ្វើការជាមួយពួកគេ។

ខ្ញុំគិតថា«ការបន្ត»គឺជាទម្រង់មួយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។នៅពេលដែលយើងគិតពី «ការអភិវឌ្ឍន៍» យើងតែងស្រមៃដល់ការរីកចម្រើនទៅមុខ ប៉ុន្តែខ្ញុំគិតថាការរក្សាបាននូវអ្វីដែលបានអភិវឌ្ឍក្នុងកម្រិតណាមួយក៏ជាទម្រង់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ។ ជាជាងបន្តធ្វើរឿងដដែលនេះប្រសិនបើយើងអាចកសាងទំនាក់ទំនងជាមួយប្រទេសជាដៃគូនិងបង្កើតអ្វីដែលថ្មី ខ្ញុំគិតថានោះជាទម្រង់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។



មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បុគ្គលិកបេះដូងមាស និងកុមារដែលពោរពេញទៅដោយស្នាមញញឹមតាមរយៈថ្នាក់គំរូអប់រំកាយ

អង្គការយូណេស្កូបានចែងនៅក្នុង«ធម្មនុញ្ញអន្តរជាតិស្តីពីអប់រំកាយសកម្មភាពរាងកាយ និងកីឡា» ថា «អប់រំកាយ សកម្មភាពរាងកាយ និងកីឡា» គឺជាសិទ្ធិដែលមនុស្សគ្រប់រូបមាន ហើយថា«មានសិទ្ធិជាមូលដ្ឋានក្នុងការអនុវត្តអប់រំកាយ / សកម្មភាពរាងកាយ / កីឡាដោយគ្មានការរើសអើងដោយផ្អែកលើជាតិសាសន៍ យេនឌ័រ ទំនោរផ្លូវភេទ ភាសា សាសនា នយោបាយ ឬទស្សនៈផ្សេងទៀត សញ្ជាតិឬឋានៈសង្គម ទ្រព្យសម្បត្តិ ឬមូលដ្ឋានណាមួយផ្សេងទៀត (យូណេស្កូ, ២០១៥) ។

ខ្ញុំជឿថាមនុស្សអាចរៀន និងរីកចម្រើនជាមួយគ្នាតាមរយៈ« អប់រំកាយ/ សកម្មភាពរាងកាយ/កីឡា»ហើយខ្ញុំចង់បន្តធ្វើការដើម្បីផ្តល់តម្លៃនេះដល់មនុស្សឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

## សេចក្ដីបញ្ចប់

បេះដូងមាសបានចំណាយពេល១៨ឆ្នាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអប់រំកាយរបស់ប្រទេសកម្ពុជាចាប់ពីថ្នាក់បឋមសិក្សារហូតដល់សាកលវិទ្យាល័យ។ខ្ញុំមិននិយាយថាអ្វីៗបានទៅតាមផែនការទាំងស្រុងនោះទេប៉ុន្តែផ្ទុយទៅវិញខ្ញុំបានឆ្លៀតរកសំណាងនិងពេលវេលាម្ដងម្កាល ហើយនៅពេលដែលខ្ញុំរកបានឱកាសខ្ញុំមិនខកខាននោះទេ។ដោយផ្អែកលើទស្សនវិជ្ជានៃការផ្ដល់ការអប់រំកាយដល់កុមារទូទាំងប្រទេសកម្ពុជាយើងបង្កើតយុទ្ធសាស្ត្រដោយបត់បែនពីពេលមួយទៅពេលមួយផ្ដល់តម្លៃលើការបង្កើតទំនាក់ទំនងនៃការជឿទុកចិត្តជាមួយក្រសួងអប់រំយុវជននិងកីឡាកម្ពុជា ការបន្តគម្រោងនិងទំនាក់ទំនងជាមួយJICA និងការពិភាក្សាជាប្រចាំជាមួយអ្នកជំនាញ។

ខ្លួនខ្ញុំផ្ទាល់មិនមែនជាអ្នកជំនាញផ្នែកអប់រំកាយទេប៉ុន្តែចាប់តាំងពីខ្ញុំត្រូវបានចាត់តាំងមកប្រទេសកម្ពុជាក្នុងឆ្នាំ២០១២ ខ្ញុំបានរៀនសូត្រអំពីអប់រំកាយរួមគ្នាជាមួយអ្នកជំនាញ មន្ត្រីពាក់ព័ន្ធមកពីក្រសួងអប់រំកម្ពុជានិងគ្រូបង្រៀននៅសាលា។អ្វីដែលខ្ញុំបានដឹងលើសពីអ្វីទាំងអស់នោះ គឺការផ្ដល់អប់រំកាយដែលមានគុណភាពខ្ពស់ដល់កុមារគ្រប់រូបក្នុងប្រទេសកម្ពុជា និងជួយពួកគេឱ្យទទួលបាន «ចំណេះដឹង ជំនាញ និងឥរិយាបថ» ដែលបានដាក់ចេញដោយក្រសួងអប់រំកម្ពុជា។ខ្ញុំបានគិតអំពីអ្វីមួយជាពិសេសថ្មីៗនេះ។នេះគឺថាប្រសិនបើគ្រូចូលចិត្តបង្រៀនអប់រំកាយនោះកុមារក៏នឹងរីករាយដែរ។ សូម្បីតែតាមរយៈសិក្ខាសាលា និងការតាមដាន ជំនួសឱ្យការចង្អុលបង្ហាញចំណុចខ្សោយរបស់គ្រូយើងសរសើរចំណុចល្អរបស់ពួកគេ។ចំពោះវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដែលទទួលខុសត្រូវលើការបណ្ដុះបណ្ដាលគ្រូ ការមានគោលដៅដើម្បីអភិវឌ្ឍគ្រូអប់រំកាយឱ្យចូលចិត្តបង្រៀនអប់រំកាយ ខ្ញុំគិតថាជាវិធីខ្លីបំផុតដើម្បីបង្រៀនកុមារឱ្យស្រឡាញ់លំហាត់ប្រាណ និងកីឡា។ នៅពេលអ្នកចាប់ផ្ដើមចូលចិត្តអ្វីមួយ ពួកគេនឹងរៀនវាដោយខ្លួនឯង ហើយអាស្រ័យលើការយល់ដឹងនិងការជួយគាំទ្រ ពួកគេនឹងប្រសើរឡើងដោយធម្មជាតិ។ ខ្ញុំជឿថាការយល់ដឹង និងការគាំទ្រនេះពិតជាតួនាទីរបស់គ្រូបង្រៀន។ នេះគឺស្រដៀងនឹងដំណើរការនៃការលូតលាស់របស់កុមារ។ កុមារមិនធ្វើអ្វីដែលពួកគេមិនចង់ធ្វើទេ។ ពួកគេខិតខំធ្វើអ្វីដែលពួកគេចង់ធ្វើ។ ខ្ញុំគិតថាការបណ្ដុះបណ្ដាលគ្រូអប់រំកាយក៏ដូចគ្នាដែរ។

ការផ្សព្វផ្សាយអប់រំកាយនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាប្រព័ន្ធបណ្ដុះបណ្ដាលគ្រូអប់រំកាយ ក៏ចាប់ផ្ដើមទទួលបានឯករាជ្យភាព ទោះបីជាបន្តិចម្ដងៗក៏ដោយ។ គ្មានអ្វីសប្បាយចិត្តជាងការឃើញការអនុវត្តសិក្ខាសាលា និងការតាមដាន ដោយធានាបាននូវថវិកាផ្ទាល់ខ្លួនហើយគ្រូបង្រៀនដែលបានទទួលសញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យនៅក្រៅប្រទេសបានគិតដោយខ្លួនឯង និងបញ្ចេញមតិក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់គុណភាព និងផ្សព្វផ្សាយអប់រំកាយកម្ពុជាឱ្យកាន់តែទូលំទូលាយ។

ខ្ញុំត្រូវបានស្នើឱ្យសរសេរប្រវត្តិគម្រោងនេះ ដោយលោក ស៊ីប៊ូយ៉ា ខាហ្សូរ៉ូ ប្រធានផ្នែកនៃ JICA Chugoku។ ខ្ញុំមិនដែលគិតចង់សរសេរសៀវភៅទេ ប៉ុន្តែតាមរយៈការកត់ត្រានូវអ្វីដែល

ខ្ញុំបានធ្វើកន្លងមក និងការបោះពុម្ពផ្សាយជាសៀវភៅពីវិទ្យាស្ថានស្រាវជ្រាវ JICA Ogata មនុស្សជាច្រើននឹងអាចអានបាន។ ខ្លួនខ្ញុំផ្ទាល់មានការព្រួយបារម្ភអំពីការធ្វើការលើគម្រោងចំនួន២ប៉ុន្តែខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលខ្ញុំអាចបញ្ចប់ការសរសេរសៀវភៅនេះដោយមានការគាំទ្រពីមនុស្សជាច្រើន។

ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នានៃJICAក្រសួងការបរទេសមជ្ឈមណ្ឌលលើកកម្ពស់កីឡាជប៉ុន ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា មន្ទីរ/ ការិយាល័យអប់រំរាជធានី/ខេត្ត/ស្រុកនៅទូទាំងប្រទេសកម្ពុជាដែលបានសហការគ្នាលើគម្រោងនេះព្រមទាំងកុមារដែលកំពុងខិតខំសិក្សាផ្នែកអប់រំកាយនៅសាលារៀងៗខ្លួន និងអាណាព្យាបាល។

លើសពីនេះ ខ្ញុំសូមសម្តែងនូវការគោរព និងថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអ្នកជំនាញដូចជា លោក អូកាដិ យ៉ូស៊ីណូរិ ដែលបានដាំដុះដី ដាំគ្រាប់ពូជ ផ្តល់ទឹកនិងជីសម្រាប់ការអប់រំមុខវិជ្ជាអប់រំកាយ លោក យ៉ាម៉ាហ្គូជិ តាគុ នាយកទីមួយនៃការិយាល័យអាស៊ីអាគ្នេយ៍ នៃអង្គការបេះដូងមាសបុគ្គលិកអាស៊ីអាគ្នេយ៍នៃការិយាល័យកណ្តាលរហូតមកដល់បច្ចុប្បន្នក៏ដូចជាសមាជិកនិង អ្នកគាំទ្រអង្គការបេះដូងមាសទាំងអស់។

ម្យ៉ាងទៀតក្នុងការសរសេរអត្ថបទសៀវភៅនេះខ្ញុំក៏សូមថ្លែងអំណរគុណដល់បុគ្គលិកនៃក្រុមហ៊ុន Saeki Communications សម្រាប់កិច្ចសហប្រតិបត្តិការជាច្រើន បុគ្គលិកនៅវិទ្យាស្ថានស្រាវជ្រាវ JICA អូហ្គាតា និង លោក យុស៊ីមូរ៉ា ហ៊ីការី សម្រាប់ជំនួយក្នុងការកែសម្រួលសៀវភៅនេះរួមទាំងអ្នកទាំងអស់គ្នាដែលបានជួយក្នុងដំណើរការកែសម្រួល។បន្ថែមពីនេះទាក់ទងនឹងខ្លួនខ្ញុំផ្ទាល់ខ្ញុំសូមថ្លែងអំណរគុណចំពោះភរិយារបស់ខ្ញុំដែលធ្វើការនៅប្រទេសកម្ពុជាបានកន្លះឆ្នាំ ហើយមិនអាចទៅរស់នៅជាមួយគ្រួសារនៅប្រទេសជប៉ុនបាន ខណៈដែលចិញ្ចឹមកូនប្រុសពីរនាក់របស់យើង។

យើងចង់បន្តគាំទ្រការរីករាលដាលនៃអប់រំកាយដែលមានគុណភាពខ្ពស់នៅកម្ពុជា។ លើសពីនេះយើងចង់ភ្ជាប់ និងផ្សព្វផ្សាយបណ្តាញដែលបានបង្កើតតាមរយៈអប់រំកាយមិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏មាននៅក្នុងបណ្តាប្រទេសអាស៊ាន និងពិភពលោកផងដែរ។ «អប់រំកាយ»គ្រាន់តែជាមុខវិជ្ជាមួយនៅក្នុងសាលា ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា ខ្ញុំជឿថាមានលទ្ធភាពគ្មានទីបញ្ចប់នៅក្នុងថ្នាក់រៀន២ម៉ោងក្នុងមួយសប្តាហ៍នេះ។ ដូចមានចែងក្នុងមាត្រា១ នៃ«ធម្មនុញ្ញអន្តរជាតិស្តីពីអប់រំកាយ សកម្មភាពរាងកាយ និងកីឡា» របស់អង្គការយូណេស្កូ ការអនុវត្តអប់រំកាយ សកម្មភាពរាងកាយ និងកីឡា គឺជាសិទ្ធិជាមូលដ្ឋានសម្រាប់មនុស្សគ្រប់រូប (UNESCO, ២០១៥)។ តាមរយៈកីឡា កុមារអាចរៀនពីសមត្ថភាពជាច្រើនដែលពួកគេនឹងត្រូវការនៅពេលចូលរួមក្នុងសង្គម ដូចជាសមភាព ការគោរព ការដឹងគុណ ការវិភាគបញ្ហានិងដោះស្រាយបញ្ហា ជំនាញទំនាក់ទំនង ភាពជាអ្នកដឹកនាំ និងស្មារតីអ្នកកីឡា ហើយតាមរយៈ

ការចែករំលែកស្ថានភាពអប់រំកាយនៅក្នុងប្រទេសនីមួយៗចំណេះដឹងរបស់ប្រទេសនីមួយៗអាច ត្រូវបានអនុវត្តនៅក្នុងប្រទេសផ្សេងទៀតខណៈពេលធ្វើការសម្របខ្លួនវាទៅនឹងស្ថានភាពនៅក្នុង ប្រទេសនោះ។

វាជាការលំបាកខ្លាំងណាស់ក្នុងការសម្រេចបាននូវ«ភាពល្អឥតខ្ចោះ»ក្នុងរឿងអ្វីមួយ ហើយដោយសារតែវាពិបាក ដោយមានបំណងចង់កែលម្អជានិច្ច ខ្ញុំចង់បន្តធ្វើការដើម្បីបង្ហាញពី លទ្ធភាពបន្ថែមទៀតដល់កុមារដែលមានអនាគតភ្លឺស្វាងតាមរយៈអប់រំកាយ។

ជាចុងក្រោយខ្ញុំសូមអរគុណអ្នកអានទាំងអស់ដែលបានយកសៀវភៅនេះមកអាន។

ខែមីនា ឆ្នាំ២០២៤ នីស៊ីយ៉ាម៉ា ណាអូគិ

# ឯកសារយោង

បេះដូងមាស (២០១០), ស៊េរីកូនសៀវភៅ NPO HG (១) ការរីកលូតលាស់រួមគ្នា – វឌ្ឍនភាព១០ឆ្នាំនៃបេះដូងមាស –

បេះដូងមាស (២០២១), ស៊េរីកូនសៀវភៅ NPO HG (២) ការអប់រំមុខវិជ្ជាអប់រំកាយចាប់ផ្តើមនៅប្រទេសកម្ពុជា

Ministry of Education, Youth and Sport (២០០៧), PE Curriculum for Primary School

Ministry of Education, Youth and Sport (២០១៦), PE Curriculum for Lower Secondary School

Ministry of Education, Youth and Sport (២០១៨), PE Curriculum for Upper Secondary School

Ministry of Education, Youth and Sport (២០១៥), Curriculum Framework of General Education and Technical Education

Ministry of Education, Youth and Sport (២០១៨), Physical Education Teachers' Manual for Primary School

Ministry of Education, Youth and Sport (២០១៩), Physical Education Teachers' Manual for Lower Secondary School

Ministry of Education, Youth and Sport (២០២១), Physical Education Teachers' Manual for Upper Secondary School

National Institute of Physical Education and Sport (២០១៩), Framework Bachelor of Arts (Physical Education) National Institute of Physical Education and Sport (NIPES)

Ministry of Education, Youth and Sport (២០២០), Public Education Statistics and Indicators ២០១៩-២០២០

ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា « ខ្លឹមសារលម្អិតនៃគោលបំណងនៃអប់រំកាយ - អ្វីដែលកុមារទាំងអស់គួរទទួលបាន - » (ទទួលបាននៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ https://www.mext.go.jp/b_menu/shingi/chukyo/chukyo0/toushin/attach/1395089.htm)

Kingdom of Cambodia (១៩៩៩), Constitution of the Kingdom of Cambodia
យ៉ាម៉ាហ្គូជិ តាគុ (២០១២), RECTI-PE II- PTTC reform –
UNESCO (២០១៥), Quality Physical Education - Guidelines for Policy Makers
ផ្នែកអន្តរជាតិនៃអគ្គនាយកដ្ឋានកីឡាជប៉ុន(២០១៧)របាយការណ៍សន្និសីទអន្តរជាតិនៃរដ្ឋមន្ត្រីទទួលបន្ទុកកីឡា និងអប់រំកាយ (MINEPS VI) របស់អង្គការយូណេស្កូ (ទទួលបាននៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ https://www.mext.go.jp/sports/b_menu/shingi/014_index-/shiryo/__icsFiles/afieldfile/2017/09/11/1395318_8.pdf?msclkid=31336443d11611ec8a00d7f7b4c377ea)
បេះដូងមាស (២០២០), ពាក្យស្នើសុំសម្រាប់«គម្រោង "អប់រំកាយសម្រាប់ទាំងអស់គ្នា" ដើម្បីសិក្សាប្រកបដោយគុណភាពខ្ពស់ជាប់លាប់ពីបឋមសិក្សាដល់វិទ្យាល័យ»
បេះដូងមាស (២០១៥), ពាក្យស្នើសុំសម្រាប់« គម្រោងជំនួយចងក្រងនិងផ្សព្វផ្សាយសៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិក្នុងព្រះរាជាណាចក្រកម្ពុជា»
National Institute of Physical Education and Sport (២០២២), Pedagogy and Methodology of Teaching Physical Education
Ministry of Education, Youth and Sport (២០០៤), Policy for Curriculum Development ២០០៥-២០០៩
UNESCO (២០១៥), International Charter of Physical Education, Physical Activity and Sport

## បញ្ជីអក្សរកាត់

ACPES ASEAN Council of Physical Education and Sport ( សមាគមអប់រំកាយ និងកីឡាអាស៊ាន)

ASEAN Association of South-East Asian Nations (សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍)

ASEAN Para Games (អាស៊ានប៉ារ៉ាហ្គេម)

AWHM AngkorWatInternationalHalfMarathon(ទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្ត)

DRESS Department of Physical Education and Sport for Students (នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត)

ICT Information and Communications Technology (បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង)

JICA Japan International Cooperation Agency ( ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន)

MINEPS International Conference of Ministers and Senior Officials Responsible for Physical Education and Sport ( សន្និសីទអន្តរជាតិយូណេស្កូរបស់រដ្ឋមន្ត្រី។ល។ទទួលបន្ទុកអប់រំកាយ និងកីឡា)

MoEYS Ministry of Education, Youth and Sport (ក្រសួងអប់រំ យុវជន និងកីឡា)

NGO Non-governmental Organization (អង្គការក្រៅរដ្ឋាភិបាល)

NIPES National Institute of Physical Education and Sport (វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា)

SEA Games Southeast Asian Games (ការប្រកួតកីឡាស៊ីហ្គេម)

SDGs Sustainable Development Goals (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព)

[អ្នកនិពន្ធ]
## នីស៊ីយ៉ាម៉ា ណាអូតិ

កើតនៅឆ្នាំ១៩៨០។ ឆ្នាំ២០០៤ បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យរដ្ឋ San Diego។ ឆ្នាំ២០០៥-១២ JICA (អ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស/ប៉ារ៉ាហ្គាយ, ការិយាល័យយុវជនស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស, ហ្គូបល ផ្លាហ្សា) ។ ពីឆ្នាំ២០១២ ប្រធានការិយាល័យអាស៊ីអាគ្នេយ៍នៃអង្គការអង្គការក្រៅរដ្ឋាភិបាលបេះដូងមាស។ពីឆ្នាំ២០១៩សមាជិកក្រុមប្រឹក្សាភិបាលនៃអង្គការដដែល។ឆ្នាំ២០២២ទទួលបានសញ្ញាបត្រអនុបណ្ឌិត(វិទ្យាសាស្ត្រអប់រំកាយ) ពីសាកលវិទ្យាល័យវិទ្យាសាស្ត្រកីឡា នីបប៉ុន ។ ពីឆ្នាំ២០២២ អគ្គលេខាធិការនៃអង្គការបេះដូងមាស។

ពីឆ្នាំ២០១៣ ដល់ ២០១៥ អ្នកគ្រប់គ្រងគម្រោង សម្រាប់កម្មវិធីភាពជាដៃគូរបស់ JICA ។ ឆ្នាំ២០១៥ - ១៦ អ្នកគ្រប់គ្រងគម្រោង គម្រោងការរួមចំណែកអន្តរជាតិទ្វេភាគីជាយុទ្ធសាស្ត្រ គម្រោងជំនួយចងក្រងសៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិក្នុងព្រះរាជាណាចក្រកម្ពុជា។ឆ្នាំ២០១៧-២០អ្នកគ្រប់គ្រងគម្រោង កម្មវិធីភាពជាដៃគូរបស់ JICA គម្រោងជំនួយចងក្រងនិងផ្សព្វផ្សាយសៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិក្នុងព្រះរាជាណាចក្រកម្ពុជា។ឆ្នាំ២០១៩-២៣ប្រធានគម្រោង គម្រោងជំនួយឥតសំណងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន គម្រោងប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា(NIPES) ព្រះរាជាណាចក្រកម្ពុជា ទៅជាសាកលវិទ្យាល័យ វគ្គសិក្សាអប់រំកាយរយៈពេល៤ឆ្នាំ។ ពីឆ្នាំ២០២១ អ្នកគ្រប់គ្រងគម្រោង កម្មវិធីភាពជាដៃគូរបស់ JICA គម្រោង «អប់រំកាយសម្រាប់ទាំងអស់គ្នា»ដើម្បីសិក្សាប្រកបដោយគុណភាពខ្ពស់ជាប់លាប់ពីបឋមសិក្សាដល់វិទ្យាល័យ។ ពីឆ្នាំ២០២៣ ប្រធានគម្រោង គម្រោងជំនួយឥតសំណងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន គម្រោងគាំទ្រវិទ្យាស្ថានគរុកោសល្យអប់រំកាយរយៈពេល៤ឆ្នាំប្រកបដោយគុណភាពខ្ពស់តាមរយៈ ICT ក្នុងព្រះរាជាណាចក្រកម្ពុជា។

ពីឆ្នាំ២០១៥ ទីប្រឹក្សារបស់អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា (ឯកឧត្តម អ៊ុក សិទ្ធិជាតិ និងឯកឧត្តម ប៉ុន សុខ)។

ISBN 978-9924-511-24-3

ដោយ វិទ្យាស្ថានស្រាវជ្រាវ ចៃកា អូហ្គាតា សាដាកុ
ដើម្បីសន្តិភាព និងការអភិវឌ្ឍន៍